លេខ / N°: D267

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

## ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**Case File No: 003/07-09-2009-ECCC-OCIJ**

**ចំពោះមុខ៖** សហចៅក្រមស៊ើបអង្កេត

**កាលបរិច្ឆេទ៖** ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨

**ភាសា៖** ភាសាអង់គ្លេស [ច្បាប់ដើម]

**ចំណាត់ថ្នាក់៖** សាធារណៈ/Public

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Feb-2019, 10:30
CMS/CFO: Ly Bunloung

---

# ដីកាដំណោះស្រាយ

---

**ជូនចំពោះ៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

LIU Yiqiang
Laure DESFORGES
Isabelle DURAND

Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# មាតិកា

១. ប្រវត្តិនីតិវិធី ........................................ 8

២. បញ្ហាបឋម ........................................ 16

២.១ ការពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ និងផលប៉ះពាល់នៃការពិចារណានេះលើដីកាដំណោះស្រាយ ........................................ 16

២.២ សំណើរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ........................................ 17

២.៣ បទដ្ឋានបង្ហាញភស្តុតាង ........................................ 17

២.៤ សំណើរបស់ ស.ព.អ សុំចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ ប៉ុន្តែមិនបានធ្វើការចោទឡើយ ........................................ 18

៣. ច្បាប់ជាធរមាន ........................................ 18

៣.១ យុត្តាធិការបុគ្គលនៅ អ.វ.ត.ក ........................................ 18

៣.២ ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ........................................ 21

៣.២.១ ឧក្រិដ្ឋកម្មអន្តរជាតិ ........................................ 21

៣ ២.២.ឧក្រិដ្ឋកម្មជាតិ ........................................ 52

៣.៣ ទម្រង់នៃការទទួលខុសត្រូវ ........................................ 54

៣ ១.៣.ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ........................................ 54

៣.៣.២ ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ ........................................ 67

៤. ការពិចារណាអំពីភស្តុតាង ........................................ 68

៤.១ ចម្លើយដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយដែលរៀបចំដោយ ក.ស.ច.ស ........................................ 68

៤.២ ភស្តុតាងពាក្យចចាមអារ៉ាម និងការពឹងផ្អែកលើភស្តុតាងដែលមិនមានការបញ្ជាក់ ........................................ 71

៤.៣ ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ........................................ 73

៤.៤ របាយការណ៍រៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ........................................ 75

៤.៥ ចំនួនជនរងគ្រោះ ........ 76

៤.៥.១ ការគណនាចំនួនជនរងគ្រោះផ្អែកលើភស្តុតាងដែលទទួលបានពីសាក្សីម្នាក់ ........ 76

៤.៥.២ ការគណនាចំនួនជនរងគ្រោះផ្អែកតាមភស្តុតាងពីសាក្សីច្រើននាក់ ........ 77

៤.៥.៣ ការរាប់ចំនួនសមាជិកនៅក្នុងគ្រួសារ ........ 78

៤.៦ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស ........ 79

៤.៧ លិខិតធានា ........ 79

៤.៨ ការព្យាយាមស្វែងរកជំនួយពីប្រទេសវៀតណាម ប្រទេសថៃ និងអង្គការសហប្រជាជាតិ ........ 80

៥. ការវិភាគអង្គហេតុ និងសំអាងហេតុ ........ 83

៥.១ រចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា និងតួនាទី និងការទទួលខុសត្រូវរបស់ មាស មុត ........ 83

៥.១.១ កងទ័ពបដិវត្តកម្ពុជា និងគណៈកម្មាធិការមជ្ឈិម/អចិន្ត្រៃយ៍ ........ 83

៥.១.២ រចនាសម្ព័ន្ធកងពលធំ ១៦៤ ........ 88

៥.១.៣ សិទ្ធិអំណាចរបស់ មាស មុត ក្នុងឋានៈជាមេបញ្ជាការកងពលធំ ........ 92

៥.១.៤ តួនាទីរបស់ មាស មុត ក្នុងឋានៈជាលេខាតំបន់ស្វយ័តកំពង់សោម ........ 95

៥.១.៥ តួនាទីរបស់ មាស មុត ក្នុងសេនាធិការ ........ 97

៥.១.៦ ការចាត់តាំងឲ្យទៅខេត្តក្រចេះ និងភូមិភាគបូព៌ា ........ 98

៥.១.៧ មន្ទីរសន្តិសុខ ស-២១ ........ 98

៥.២ សំអាងហេតុអំពីសហឧក្រិដ្ឋកម្មរួម ........ 106

៥.២.១ គោលនយោបាយរបស់ ប.ក.ក ស្តីពីការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ ........ 107

៥.២.២ ការអប់រំ "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរយោធា ទាំងនៅក្រៅជួរយោធា ........ 116

៥.២.៣ ការដាក់គោលដៅលើក្រុមជាក់លាក់ ជាពិសេសជាតិពិន្ទុ ឬជនជាតិវៀតណាម និងថៃ (ទាំងពិតប្រាកដ ទាំងអ្នកដែលគេយល់ឃើញថាជាជនជាតិវៀតណាម និងថៃ) ព្រមទាំងបុគ្គលិកយោធាបច្ចុប្បន្ន ឬអតីតបុគ្គលយោធា និងជនស៊ីវិល ........ 128

៥.២.៤ ការរៀបការដោយបង្ខំមកលើជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា ............... 136

៥.៣ ជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម និងថៃ ........................................ 154

៥.៣.១ ជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម ................................................ 154

៥.៣.២ ប្រទេសថៃ ........................................................................................ 164

៥.៤ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ......................... 169

៥.៤.១ សេចក្តីផ្តើម ....................................................................................... 169

៥.៤.២ ការចាប់នាវាថៃ និងវៀតណាម ................................................................ 171

៥.៤.៣ ប្រតិបត្តិការរួមរបស់កងពលធំលេខ ១ និងកងពលធំលេខ ១៦៤ ក្នុងខេត្តកោះកុង ...... 180

៥.៤.៤ ការសម្លាប់មនុស្សនៅលើដែនកោះរបស់កម្ពុជាប្រជាធិបតេយ្យ ............................ 184

៥.៤.៥ ចំនួនជនរងគ្រោះ ................................................................................ 199

៥.៥ ទីតាំងសម្លាប់ចម្ការទុរេន ........................................................................ 208

៥.៥.១ កម្មវត្ថុនៃការចោទប្រកាន់ ...................................................................... 208

៥.៥.២ ទីតាំង និងពេលវេលានៃការដំណើរការ ........................................................ 210

៥.៥.៣ រចនាសម្ព័ន និងបុគ្គលិក ....................................................................... 211

៥.៥.៤ ការប្រើប្រាស់ជាទីតាំងសម្លាប់មនុស្ស ........................................................... 212

៥.៥.៥ ការចុះទៅដល់ទីកន្លែងរបស់ មាស មុត ....................................................... 216

៥.៦ ឧក្រិដ្ឋកម្មប្រឆាំងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង១១៧ ............................ 216

៥.៦.១ សេចក្តីផ្តើម ....................................................................................... 216

៥.៦.២ ការបោសសម្អាតកងពលធំ ១៦៤ ............................................................... 217

៥.៦.៣ ការបោសសម្អាតកងពលធំ ៥០២, ៣១០ និង ១១៧ ............................................ 233

៥.៦.៤ ចំនួនជនរងគ្រោះចំពោះការបោសសម្អាតកងពលធំលេខ ១៦៤, ៥០២, ៣១០ និង ១១៧ 275

៥.៧ ការដ្ឋានកងកេង និងបិតត្រាំង (“តំបន់រាម”) ...................................................... 276

៥.៧.១ ទីតាំង និងសមាសភាពនៃការដ្ឋាន និងសហករណ៍ ............................................ 276

01600472



៥.៧.២ រចនាសម្ព័ន្ធ និងបុគ្គលិក ........................................ 281

៥.៧.៣ ពេលវេលានៃការដំណើរការការដ្ឋាន ........................................ 285

៥.៧.៤ កម្លាំងការងារ ........................................ 287

៥.៧.៥ ស្ថានភាពរស់នៅ និងស្ថានភាពការងារ ........................................ 293

៥.៧.៦ ការផ្លាស់ទី ការចាប់ខ្លួន និងការបាត់ខ្លួន ........................................ 304

៥.៧.៧ ការចុះដល់ទីកន្លែងរបស់ មាស មុខ ........................................ 312

៥.៨ ការដ្ឋានស្ទឹងហាវ ........................................ 312

៥.៨.១ ទីតាំង និងថិរវេលាប្រតិបត្តិការ ........................................ 313

៥.៨.២ រចនាសម្ព័ន្ធ និងបុគ្គលិក ........................................ 319

៥.៨.៣ កម្លាំងពលកម្ម ........................................ 322

៥.៨.៤ ស្ថានភាពរស់នៅ និងធ្វើការ ........................................ 328

៥.៨.៥ ការចាប់ខ្លួន ការឃុំខ្លួន និងការសួរចម្លើយ ........................................ 340

៥.៨.៦ ការសម្លាប់ និងការបាត់ខ្លួន ........................................ 345

៥.៨.៧ ការចុះដល់ទីកន្លែងរបស់ មាស មុត ........................................ 347

៥.៩ មន្ទីរសន្តិសុខទឹកសាប ........................................ 348

៥.៩.១ ទីតាំង និងការបង្កើត ........................................ 348

៥.៩.២ រចនាសម្ព័ន្ធ និងបុគ្គលិក ........................................ 352

៥.៩.៣ ការចាប់ខ្លួន និងការឃុំខ្លួន ........................................ 354

៥.៩.៤ ការសម្លាប់ និងការបាត់ខ្លួន ........................................ 360

៥.៩.៥ ការចុះដល់ទីកន្លែងរបស់ មាស មុត ........................................ 365

៥.១០ មន្ទីរសន្តិសុខវត្តឥន្ទញាណ ........................................ 365

៥.១០.១ ទីតាំង និងការបង្កើត ........................................ 365

៥.១០.២ រចនាសម្ព័ន្ធ និងបុគ្គលិក ........................................ 367

៥.១០.៣ ការឃុំខ្លួន និងស្ថានភាពនៃការឃុំខ្លួន ........ 368

៥.១០.៤ ការសួរចម្លើយ ........ 372

៥.១០.៥ ការសម្លាប់ ........ 374

៥.១០.៦ ការចុះដល់ទីកន្លែងរបស់ មាស មុត ........ 377

៥.១១ ការរៀបការដោយបង្ខំនៅកំពង់សោម ........ 377

៦. ការយល់ឃើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គល ........ 385

៦.១ តួនាទីនៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ ........ 386

៦.២ ចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានកំណត់ ........ 387

៦.៣ សេចក្តីសន្និដ្ឋាន ........ 389

៧. សំអាងច្បាប់ស្តីពីឧក្រិដ្ឋកម្ម ........ 390

៧.១ ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ........ 390

៧.២ ធាតុផ្សំតាមបរិបទនៃការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ........ 392

៧.៣ ការរកឃើញផ្នែកអង្គច្បាប់ស្តីពីឧក្រិដ្ឋកម្ម ........ 393

៧.៣.១ ការសម្លាប់ជនជាតិវៀតណាមដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ........ 393

៧.៣.២ ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ........ 398

៧.៣.៣ ទីតាំងសម្លាប់មនុស្សចម្ការទុរេន ........ 401

៧.៣.៤ ការបោសសម្អាតកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ........ 402

៧.៣.៥ ការដ្ឋានកងកេង និងបិតត្រាង (តំបន់រាម) ........ 406

៧.៣.៦ ការដ្ឋាននៅស្ទឹងហាវ ........ 407

៧.៣.៧ មន្ទីរសន្តិសុខទឹកសាប ........ 409

៧.៣.៨ មន្ទីរសន្តិសុខវត្តឥន្ទញាណ ........ 412

៧.៣.៩ អាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម ........ 414

៨. សំអាងច្បាប់ស្តីពីទម្រង់នៃការទទួលខុសត្រូវ ........ 414

៨.១ ឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ ........ 414

៨.១.១ ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE) ........ 414

៨.១.២ ការរៀបចំផែនការ ........ 417

៨.១.៣ ការបញ្ជា ........ 417

៨.១.៤ ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 418

៨.២ ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ ........ 419

៨.២.១ សហចារី ........ 419

៨.២.២ ការរៀបចំផែនការ និងការបញ្ជា ........ 419

៩. សេចក្ដីសម្រេចលើការឃុំខ្លួន មុនការជំនុំជម្រះ ........ 419

១០. ដីកាបញ្ចប់អនុលោមតាមវិធាន ៦៦*ស្ទួន* ........ 420

១១. ដីកាលើកលែងការចោទប្រកាន់ដោយផ្នែក ........ 420

១២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ........ 422

១៣. ការបញ្ចប់ការស៊ើបអង្កេតដែលនៅសេសសល់ ........ 431

ឧបសម្ព័ន្ធ I កាលប្បវត្តិនៃគម្រោងបញ្ចប់ផែនការ

ឧបសម្ព័ន្ធ II ពាក្យសុំ និងសំណើដែលបានដាក់ទៅ សស.ច.

ឧបសម្ព័ន្ធ III អក្សរកាត់

ឧបសម្ព័ន្ធ IV បញ្ជីនៃការប្រកបឈ្មោះរបស់សាក្សីរដ្ឋប្បវេណីបណ្ដឹងដើមខ្លួនជាតាំងពាក្យសុំដាក់អ្នក/ងទៀតផ្សេតាមបែប

# ១. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ បានដាក់*ដីកាបញ្ជូនរឿងឱ្យស៊ើបសួរទី២របស់សហព្រះរាជអាជ្ញា* ("ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ") ដែលបានធ្វើការចោទប្រកាន់មួយចំនួន*ក្នុងនោះរួមមានទាំង* ថា ស៊ូ ម៉េត និង **មាស មុត** បានទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហៅថា កម្ពុជាប្រជាធិបតេយ្យ នៅក្នុងរយៈពេលរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលជារយៈពេលមួយពាក់ព័ន្ធទៅនឹងការចោទប្រកាន់[1]។ ដោយសារមានការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានបញ្ជូនមកសហចៅក្រមស៊ើបអង្កេតដោយ ស.ព.អ ស្តីទី នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩[2]។

2. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស.ច.ស បានចេញនូវសេចក្តីជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរយោងទៅតាមវិធានផ្ទៃក្នុង ៦៦ ដោយជូនដំណឹងថា សហចៅក្រមទាំងពីរបានសម្រេចថា ការស៊ើបសួរត្រូវបានបញ្ចប់សព្វគ្រប់ហើយ[3]។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នូវសំណើចំនួន៣ សុំឱ្យមានការបំពេញកិច្ចស៊ើបសួរ ដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ដោយឈរលើសំអាងហេតុថា សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវតែចាត់ការរួមគ្នាជាមួយនឹងសមភាគីជាតិរបស់គាត់ លើកលែងតែមានការចុះនូវការប្រគល់អំណាច ឬការខ្វែងយោបល់ ("សេចក្តីសម្រេចចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១")[4]។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ជាថ្មីម្តងទៀតនូវសំណើសុំបំពេញកិច្ចស៊ើបសួរ ក្រោយពីបានចុះនូវកំណត់ហេតុនៃការខ្វែងយោបល់ជាមួយនឹងសហព្រះរាជអាជ្ញាជាតិ ហើយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានបដិសេធនូវសំណើបំពេញកិច្ចស៊ើបសួរទាំង៣ នោះ ("សេចក្តីសម្រេចចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ

---

[1] ឯកសារ **D1** *ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងកងទ័ពបដិវត្តន៍កម្ពុជា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[2] ឯកសារ **D1/1** *សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២* ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

[3] ឯកសារ **D13** *សេចក្តីជូនដំណឹងស្តីអំពីការបញ្ចប់ការស៊ើបសួរ* ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

[4] ឯកសារ **D20/3** *សេចក្តីសម្រេចទៅលើសំណើស្តីអំពីការសុំបន្តពេលវេលា និងសំណើបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣* ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ១, ៣-៥, ១២ ...។

២០១១")[5]។ សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ និងចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ប៉ុន្តែអង្គបុរេជំនុំជម្រះមិនបំពេញបាននូវលក្ខខណ្ឌមតិភាគច្រើនដើម្បីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ទាំងនោះ[6]។

3. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ចៅក្រម Blunk បានលាលែងតំណែងនៅមុនពេលដែលសំណុំរឿងបានបញ្ជូនទៅខាងសហព្រះរាជអាជ្ញា យោងទៅតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ហើយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ស.ច.ស បម្រុង Laurent Kasper-Ansermet បានចេញសេចក្តីបង្គាប់ឲ្យបន្តកិច្ចស៊ើបសួរ[7]។

4. នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចៅក្រម Mark Harmon បានចូលកាន់តំណែងជា ស.ច.ស.អ។ បន្ទាប់ពីគាត់បានធ្វើការវាយតម្លៃទៅលើការស៊ើបអង្កេតសំណុំរឿង០០៣ សហចៅក្រម Mark Harmon បានសម្រេចថា ជាការចាំបាច់ត្រូវធ្វើការស៊ើបសួរបន្ថែម មុននឹងសំណុំរឿងអាចបញ្ជូនទៅខាងសហព្រះរាជអាជ្ញា[8]។

5. ករណីខ្វែងយោបល់ទាំងឡាយត្រូវបានចុះដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ និងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣។

6. នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស.ច.ស បានជូនដំណឹងដល់ភាគីថា ស៊ូ ម៉េត បានស្លាប់ហើយ[9] នីតិវិធីទាំងឡាយប្រឆាំងនឹង ស៊ូ ម៉េត ក្រោយមកបានបញ្ចប់ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥[10]។

---

[5] ឯកសារ **D26** *សេចក្តីសម្រេចទៅលើការដាក់ជាថ្មីនូវសំណើបំពេញកិច្ចស៊ើបសួរទាំង៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣* ចុះថ្ងៃទី២៧ កក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៣, ៥-៩។

[6] ឯកសារ **D20/4/4** *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសេចក្តីសម្រេចទៅលើសំណើសុំពន្យារពេលវេលា និងសំណើបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង០០៣* ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។ ឯកសារ **D26/1/3** *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះស្តីអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងសេចក្តីសម្រេចអំពីការដាក់ឡើងវិញនូវសំណើបំពេញកិច្ចទាំង៣* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១។

[7] ឯកសារ **D28** *សេចក្តីបង្គាប់ស្តីអំពីការបន្តកិច្ចស៊ើបសួរ* ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១។

[8] ឯកសារ **D53/2** *សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ទៅក្នុងសំណុំរឿងនូវប្រតិចារឹកសំណុំរឿង០០២* ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ១២។

[9] ឯកសារ **D86** *សេចក្តីជូនដំណឹងអំពីមរណភាពជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង០០៣* ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ៥។

[10] ឯកសារ **D86/3** *សេចក្តីសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹងស៊ូ ម៉េត* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ ទំ.៧។

7. ករណីខ្វែងយោបល់មួយទៀតត្រូវបានចុះកំណត់ហេតុដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤។

8. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នូវដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដោយបានស្នើសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់ថ្មីៗទៀតប្រឆាំងនឹង **មាស មុត** យោងទៅតាមវិធានផ្ទៃក្នុង ៥៥(៣)[11]។

9. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត Mark Harmon បានចោទប្រកាន់ **មាស មុត** *ដោយកំបាំងមុខ* ពីបទរំលោភលើមាត្រា ៥០១ មាត្រា ៥០៦ (មនុស្សឃាត) ហើយនិងមាត្រា៥០០ (ទារុណកម្ម) នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស និងការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ[12]។

10. ចៅក្រម Mark Harmon បានលាលែងពីតំណែង ហើយយើងបានចូលកាន់តំណែងជា ស.ច.ស.អ ដោយមានសុពលភាពចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ តទៅ។

11. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នៅឯការបង្ហាញខ្លួនជាលើកដំបូងនៅខេត្តបាត់ដំបង យើងបានធ្វើមោឃភាពទៅលើការចោទប្រកាន់មួយចំនួនប្រឆាំងនឹង **មាស មុត** ដែលសហចៅក្រមស៊ើបអង្កេតនៅក្នុងតំណែងរបស់យើងពីមុនបានចោទប្រកាន់ ហើយបានចោទប្រកាន់ **មាស មុត** ពីការរំលោភទៅលើអនុសញ្ញាស្ដីអំពីការទប់ស្កាត់ និងការផ្ដន្ទាទោសបទឧក្រិដ្ឋនៃការប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ព្រមទាំងបទចោទបន្ថែមទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ និងការរំលោភទៅលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (ឃាតកម្ម)[13]។ កំណត់ហេតុទាំងស្រុងនៃការចោទប្រកាន់បានកត់ត្រានៅក្នុង *កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូង* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥[14]។

---

[11] ឯកសារ **D120** *ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីអំពីទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងសំណុំរឿង០០៣* ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៦-២៤។

[12] ឯកសារ **D128** *សេចក្ដីសម្រេចស្ដីអំពីការចោទប្រកាន់មាស មុត ដោយកំបាំងមុខ* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D128.1** *ឧបសម្ព័ន្ធ៖ សេចក្ដីជូនដំណឹងស្ដីពីការចោទប្រកាន់ប្រឆាំងនឹងមាស មុត* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។

[13] ឯកសារ **D174** *កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូង* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

[14] ឯកសារ **D174** *កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូង* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ទំ. ៩-១០។

01600478



12. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ យើងបានចេញសេចក្តីសម្រេចកាត់បន្ថយនូវវិសាលភាពនៃការស៊ើបអង្កេតដោយបានដកចេញនូវអង្គហេតុដែលបានចោទប្រកាន់ ខាងក្រោមនេះ យោងវិធានផ្ទៃក្នុង៦៦*ស្ទួន* ("សេចក្តីសម្រេចវិធាន៦៦*ស្ទួន*")៖[15]

ក. ការចោទប្រកាន់ទាំងឡាយពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១[16]

ខ. ការចោទប្រកាន់ទាំងឡាយពាក់ព័ន្ធនឹងទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[17]

គ. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធទៅនឹងទីតាំងសម្លាប់មនុស្សស្ទឹងតូច[18] និង

ឃ. ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធទៅនឹងការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុង "ការបោសសម្អាត" ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា លើកលែងតែ "ការបោសសម្អាត" ដែលបានចោទប្រកាន់ទៅលើសមាជិកនៃអង្គភាពកងទ័ពបដិវត្តន៍កម្ពុជា ដែលមានមូលដ្ឋានឈរជើងនៅតំបន់ទាំងនោះ[19]។

(រួមគ្នាហៅថា "អង្គហេតុដែលបានលើកលែង")។

13. សំអាងហេតុនៃការកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតបានសរសេរនៅក្នុង *សេចក្តីជូនដំណឹងស្តីពីការផ្អាកការស៊ើបអង្កេតជាបណ្តោះអាសន្ន* និង *សេចក្តីជូនដំណឹងយោងវិធាន៦៦ស្ទួន* របស់

[15] ឯកសារ **D226** *សេចក្តីសម្រេចស្តីអំពីការកាត់បន្ថយវិសាលភាពនៃការស៊ើបសួរយោងវិធានផ្ទៃក្នុង៦៦ស្ទួន* ចុះថ្ងៃទី១០ មករា ឆ្នាំ២០១៧។

[16] ឯកសារ **D1** *ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៤៦។

[17] ឯកសារ **D1** *ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៤៧។

[18] ឯកសារ **D1** ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជាចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦៦។

[19] ឯកសារ **D1** ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកងទ័ពបដិវត្តន៍កម្ពុជាចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦៦។

យើង[20]។ ការស៊ើបសួរចំពោះអង្គហេតុដែលបានលើកលែង ត្រូវតែបញ្ចប់ជាផ្លូវការយោងវិធានផ្ទៃក្នុង៦៦*ស្ទួន* (៥) ហើយយើងនឹងចេញនូវសេចក្ដីបង្គាប់ទៅតាមនោះ។

14. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ យើងបានជូនដំណឹងទៅភាគីយោងវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ស្ដីអំពីការបញ្ចប់ការស៊ើបសួរប្រឆាំងនឹង **មាស មុត** ហើយបានជូនដំណឹងភាគីថា ភាគីអាចដាក់សំណើបំពេញកិច្ចស៊ើបសួរបន្ថែមក្នុងរយៈពេល៣០ថ្ងៃ[21]។

15. ស.ច.ស បានចុះករណីខ្វែងយោបល់លើកទីបីនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

16. បន្ទាប់មក ភាគីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួន ហើយកិច្ចស៊ើបសួរបន្ថែមមួយចំនួនត្រូវបានបំពេញ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ក្រោយពីបានចេញសេចក្ដីសម្រេចទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងនេះ យើងបានចេញនូវសេចក្ដីជូនដំណឹងលើកទី២ ស្ដីអំពីការបញ្ចប់ការស៊ើបសួរប្រឆាំងនឹង **មាស មុត** ហើយបានជូនដំណឹងភាគីថា សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតនឹងមិនត្រូវបានពិចារណាឡើយ[22]។

---

[20] ឯកសារ **D184/3** *សេចក្ដីជូនដំណឹងស្ដីអំពីការផ្អាកជាបណ្ដោះអាសន្ននៃការស៊ើបសួរពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទីមួយៗ* ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦។ ឯកសារ **D184/4** *សេចក្ដីជូនដំណឹងយោងវិធាន៦៦ស្ទួន* ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

[21] ឯកសារ **D225** *សេចក្ដីជូនដំណឹងស្ដីអំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹងមាស មុត* ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

[22] ឯកសារ **D252** *សេចក្ដីជូនដំណឹងលើកទី២ ស្ដីអំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹងមាស មុត* ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧។ អង្គបុរេជំនុំជម្រះមិនត្រូវបានស្នើឱ្យសម្រេចជាផ្លូវការចំពោះបញ្ហានេះ ក្នុងពេលបច្ចុប្បន្ន ក៏ប៉ុន្តែកន្លងមកបានលើកឡើងនៅក្នុង*ការអនុវត្ត* នៅក្នុងសេចក្ដីសម្រេចមួយនៅក្នុងសំណុំរឿង០០៤ ថា យោងទៅតាមការបកស្រាយរបស់ខ្លួននៃវិធានផ្ទៃក្នុង ៦៦(១) ការបន្ថែម១៥ថ្ងៃទៀតទៅលើកាលបរិច្ឆេទនៃការជូនដំណឹងជាលើកទី២នៃការបញ្ចប់ការស៊ើបសួរ គួរត្រូវបានសហចៅក្រមស៊ើបអង្កេតអនុញ្ញាតដល់ភាគីទាំងឡាយ ដើម្បីពិនិត្យនូវភស្តុតាងដែលប្រមូលបានថ្មីៗ (*សូមមើល* **សំណុំរឿងលេខ ០០៤-D361/4/1/10** *សេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ [កោសលុប] ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីអំពី [កោសលុប] សំណើសុំឱ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំ* ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ២៣-២៧)។ យើងមិនចាត់ទុកថាមានការចាំបាច់ក្នុងការផ្ដល់ដល់ភាគីក្នុងសំណុំរឿង០០៣ នូវពេលវេលា១៥ថ្ងៃបន្ថែម ដើម្បីដាក់សំណើបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធទៅនឹងការលើកឡើងរបស់អង្គបុរេជំនុំជម្រះនេះឡើយ ដោយសារយើងយល់ឃើញថា មិនទំនងថាមានភាគីណាមួយបានរងនូវការខូចខាតដោយសារតែយើងមិនបានផ្ដល់នូវថេរវេលា១៥ថ្ងៃនោះឡើយ ហើយជាការពិតមិនបានរងនូវការខូចខាតក្នុងកម្រិតមួយដែលបង្កើតបានជាករណីពិសេស ដែលតម្រូវឱ្យមានការពិចារណាឡើងវិញនៃសេចក្ដីសម្រេចរបស់យើង។ ចំណាត់ការនេះបានគាំទ្រដោយអង្គហេតុថា មិនមានភាគីណាមួយក្នុងសំណុំរឿង០០៣ បានប្ដឹងឧទ្ធរណ៍នូវសេចក្ដីជូនដំណឹងជាលើកទី២របស់យើង ឬក៏មិនបានលើកឡើងនូវបញ្ហាបន្ថែមថេរវេលា១៥ថ្ងៃ ថាជាបញ្ហាខ្វះខាតនោះឡើយ ហើយភាគីក៏មិនបានព្យាយាមស្នើនូវការពិចារណាឡើងវិញ នូវការជូនដំណឹងជាលើកទី២ នៃការបញ្ចប់ការស៊ើបសួរ គិតចាប់តាំងពីពេលដែលអង្គបុរេជំនុំជម្រះបាន

17. នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ យោងតាមវិធានផ្ទៃក្នុង៦៦(៤) យើងបានបញ្ជូនសំណុំរឿងទៅខាងសហព្រះរាជអាជ្ញា ដើម្បីឲ្យធ្វើការពិនិត្យរៀបចំនូវសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន[23]។

18. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំកែប្រែកាលវិភាគនៃការដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[24]។ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ យើងបានបង្គាប់សហព្រះរាជអាជ្ញាអន្តរជាតិឲ្យដាក់នូវសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនជាភាសាអង់គ្លេសតែមួយមុខ ក្នុងរយៈពេល៣ខែ គិតចាប់ពីកាលបរិច្ឆេទនៃដីកាបញ្ជូនរឿងទៅពិនិត្យទាំងជាភាសាអង់គ្លេស និងទាំងភាសាខ្មែរ ហើយមេធាវីការពារក្តី **មាស មុត** ("មេធាវីការពារក្តី") ឲ្យដាក់សេចក្តីឆ្លើយតបរបស់ខ្លួនជាភាសាអង់គ្លេសតែមួយមុខនៅក្នុងរយៈពេល ៦ សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃអត្ថបទបកប្រែទាំងស្រុង នៃសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹង ("សេចក្តីសម្រេចស្តីអំពីការកំណត់កាលវិភាគ")[25]។

19. នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ស.ព.អ បានជូនដំណឹងដល់ភាគីថា ពួកគេបានពិចារណាទៅលើដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដោយផ្អែកលើករណីខ្វែងយោបល់រវាងពួកគេ ដែលអាចទទួលយកបាន អនុលោមតាមច្បាប់ជាធរមាននៅ អ.វ.ត.ក និងអំពីផលវិបាកដែល

---

លើកឡើងដូច្នោះមក ទោះបីបានទទួលសំណើជាសាធារណៈនៃសេចក្តីសម្រេចរបស់ អ.ប.ជ ហើយបានដឹងពីទស្សនៈរបស់ អ.ប.ជ ក៏ដោយ។ ប្រការនេះបង្កើតជាការលះបង់រយៈពេល ១៥ ថ្ងៃបន្ថែម អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដែលមានព័ត៌មានគ្រប់គ្រាន់ ដែលមានន័យថា មតិយោបល់របស់ អ.ប.ជ ស្តីពីអង្គហេតុ ត្រូវទុកជាអសារបង់។ មានខ្លឹមសារពាក់ព័ន្ធនៅក្នុងបរិបទនេះថា អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០៤ មិនបានយល់ឃើញថាមានហេតុផលសមរម្យនៅក្នុងការបង្គាប់ជាផ្លូវការឲ្យសហចៅក្រមស៊ើបអង្កេតផ្តល់ថេរវេលា១៥ថ្ងៃ ដូចដែលតាមទ្រឹស្តី អង្គបុរេជំនុំជម្រះអាចនឹងបង្គាប់ទៅបាន ដោយសារថាជារួម បណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនោះនិយាយអំពីពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំ (ទោះជាតាមសំអាងហេតុរបស់ខ្លួនផ្ទាល់ដែលមិនបានផ្សារភ្ជាប់ដោយពិស្តារជាមួយនឹងយោបល់ផ្ទុយដែលមានសំអាងហេតុរបស់ ស.ច.ស អវត្តមាននៃការបន្ថែមរយៈពេល១៥ថ្ងៃ អាចនឹងបំពេញលក្ខខណ្ឌបានថាជាវិការៈធំមួយនៃនីតិវិធី) ហើយអង្គបុរេជំនុំជម្រះដោយខ្លួនឯងផ្ទាល់ក៏មិនបានចាត់ទុកបញ្ហានេះថាជាហេតុផលគ្រប់គ្រាន់ក្នុងការអនុញ្ញាតឲ្យមានការពន្យារពេលវេលាសម្រាប់រៀបចំបន្ថែម ដូចដែលមេធាវីការពារក្តីបានស្នើនៅក្នុងសំណុំរឿង០០៤។

[23] ឯកសារ **D256** *ដីកាបញ្ជូនរឿងទៅពិនិត្យ យោងវិធាន ៦៦(៤)* ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

[24] ឯកសារ **D256/1** *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំព័ត៌មានស្តីអំពីកាលបរិច្ឆេទរំពឹងទុកនៃការជូនដំណឹងអត្ថបទភាសាខ្មែរ នៃដីកាបញ្ជូនរឿងទៅពិនិត្យ និងសំណើសុំកែប្រែកាលវិភាគសម្រាប់ដាក់សេចក្តីសន្និដ្ឋានស្ថាពរ* ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ៨។

[25] ឯកសារ **D256/3** *សេចក្តីសម្រេចស្តីអំពីកាលវិភាគនៃការដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងសេចក្តីឆ្លើយតបរបស់មេធាវីការពារក្តី* ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ៨-៩។

ទំនងជាកើតមាន សម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[26]។

20. នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ មេធាវីការពារក្តី បានស្នើឱ្យយើងពិចារណាឡើងវិញនូវសេចក្តីសម្រេចស្តីអំពីការកំណត់កាលវិភាគ[27] ហើយនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ យើងបានបង្គាប់ឱ្យមេធាវីការពារក្តីដាក់សេចក្តីឆ្លើយតបរបស់ខ្លួនជាភាសាអង់គ្លេសតែមួយមុខ នៅក្នុងរយៈពេល៦០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃអត្ថបទបកប្រែទាំងស្រុងនៃសេចក្តីសន្និដ្ឋានស្ពាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹង[28]។

21. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ (i) ស.ព.ជ បានដាក់នូវសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើលើកលែងការចោទប្រកាន់ប្រឆាំង **មាស មុត** ដោយឈរលើសំអាងហេតុថា **មាស មុត** មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាទេ[29] ហើយ (ii) សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនចំនួនប្រហែល ៩៥០ ទំព័រ ដោយបញ្ជូន **មាស មុត** ទៅជំនុំជម្រះពីបទចោទទាំងឡាយដែលបានសរសេរនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ("ដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព")[30]។

---

[26] ឯកសារ **D262** *ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣* ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧។ ឯកសារ **D262.2** *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់* ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១៣-១៦។ ពុំមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះទេ ហើយក៏ពុំមានសំណើសុំឱ្យពិចារណាសាជាថ្មីដែរ។

[27] ឯកសារ **D256/4** *សំណើរបស់មាស មុត សុំឱ្យមានការពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីអំពីកាលវិភាគនៃការដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងសេចក្តីឆ្លើយតបរបស់មេធាវីការពារក្តី* ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ទំព័រ ៧។

[28] ឯកសារ **D256/5** *សេចក្តីសម្រេចស្តីអំពីសំណើរបស់មាស មុត សុំឱ្យមានការពិចារណាឡើងវិញទៅលើកាលវិភាគនៃការដាក់សេចក្តីឆ្លើយតបរបស់មេធាវីការពារក្តី* ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ១៤។

[29] ឯកសារ **D256/6** *សេចក្តីសន្និដ្ឋានស្ថាពរ ពាក់ព័ន្ធនឹងមាស មុត យោងវិធានផ្ទៃក្នុង៦៦* ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ៣៧។

[30] ឯកសារ **D256/7** *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ១១៣៦។

22. នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅក្នុងការឆ្លើយតបចំពោះសំណើមួយទៀតរបស់មេធាវីការពារក្តី យើងបានអនុញ្ញាតដល់មេធាវីការពារក្តីនូវថេរវេលាចំនួន ២០ ថ្ងៃបន្ថែម ដើម្បីដាក់នូវសេចក្តីឆ្លើយតបរបស់ខ្លួន ជាពិសេសដោយសារទំហំនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ[31]។

23. នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ មេធាវីការពារក្តីបានដាក់សេចក្តីឆ្លើយតបរបស់ខ្លួនចំពោះសេចក្តីសន្និដ្ឋានស្ថាពររបស់ការិយាល័យសហព្រះរាជអាជ្ញា ដោយស្នើឱ្យសហចៅក្រមស៊ើបអង្កេតតម្កល់នីតិវិធីជាអចិន្ត្រៃយ៍បិទផ្លូវតវ៉ា ដោយសារមេធាវីការពារក្តីបានពិចារណាថា មានលទ្ធភាពខ្ពស់បំផុត ដែលនឹងមិនមានថវិកាគ្រប់គ្រាន់នៅក្នុងការដំណើរការប្រឆាំងនឹង **មាស មុត** ឱ្យបានចប់សព្វគ្រប់។ បើមិនដូច្នោះទេ មេធាវីការពារក្តី សូមស្នើសហចៅក្រមស៊ើបអង្កេតឱ្យចេញដីកាលើកលែងការចោទប្រកាន់[32]។

24. នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ និងនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចស្តីអំពីសំណើមោឃភាពចំនួន២ ដែលមេធាវីការពារក្តីបានស្នើពាក់ព័ន្ធទៅនឹងសម្ភារៈ ដែលបានចោទថាពាក់ព័ន្ធទៅនឹងអំពើទារុណកម្ម បដិសេធពាក្យសុំ (មោឃភាពចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលចោទថាមានវិការៈ) ទាំងពីរ ដោយបានសម្រេចថាកំណត់ហេតុស្តាប់ចម្លើយដែលរងការជំទាស់ទាំងនោះមិនមានវិការៈឡើយ[33]។

25. នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ មេធាវីការពារក្តីបានដាក់សំណើសុំដាក់សារណាបន្ថែមទៅលើចម្លើយតបរបស់ខ្លួន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ បន្ទាប់ អ.ប.ជ បានចេញ*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* របស់ខ្លួន ក្នុងសំណុំរឿង ០០៤/១ ("សំណើសុំដាក់បន្ថែមសារណាទៅលើចម្លើយ

---

[31] ឯកសារ **D256/9** *សេចក្តីសម្រេចស្តីអំពីសំណើរបស់មាស មុត សុំពន្យារកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ១៨។

[32] ឯកសារ **D256/11** *ចម្លើយឆ្លើយតបរបស់មាស មុត ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ៧៣៦-៧៤០។

[33] ឯកសារ **D253/1/8** *សេចក្តីសម្រេចស្តីអំពីសំណើរបស់ មាស មុត សុំធ្វើមោឃភាពឯកសារ **D114/164, D114/167, D114/179** និងឯកសារ **D114/171*** ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ កថាខណ្ឌ២៩-៣៤ ទំ.១៥។ ឯកសារ **D257/1/8** *សេចក្តីសម្រេចលើពាក្យសុំរបស់ មាស មុត សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម* ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ កថាខណ្ឌ ២៩-៤១ ទំព័រ ១៦-២២។

តប")[34]។ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើនេះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨[35]។

26. នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ យើងបានប្រកាសថា សំណើសុំដាក់បន្ថែមសារណាទៅលើចម្លើយតបត្រូវទុកជាអសារបង់មួយផ្នែក ហើយហេតុនេះ បានបដិសេធផ្នែកផ្សេងទៀតនៃសំណើនោះ[36]។

27. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ស.ច.ស បានចុះបញ្ជីនូវករណីខ្វែងយោបល់មួយពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។

## ២. បញ្ហាបឋម

### ២.១ ការពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ និងផលប៉ះពាល់នៃការពិចារណានេះលើដីកាដំណោះស្រាយ

28. នៅក្នុងការពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១[37] នោះ អង្គបុរេជំនុំជម្រះ និង/ឬចៅក្រមអន្តរជាតិរបស់ខ្លួនបានផ្តល់សំអាងហេតុមួយចំនួន ដែលតាមទ្រឹស្តីអាចធ្វើឲ្យប៉ះពាល់ដល់ខ្លឹមសារនៃដីកាដំណោះស្រាយ។ និយាយជារួម ការយោងដល់ទឡ្ហីករណ៍របស់ខ្ញុំនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/២ នឹងមានភាពគ្រប់គ្រាន់ ដែលក្នុងនោះខ្ញុំបានបកស្រាយបញ្ជាក់លើបញ្ហាទាំងនេះរួចហើយ[38]។

---

[34] ឯកសារ **D256/12** *សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់សារណាបន្ថែមទៅលើចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨។

[35] ឯកសារ **D256/13** *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការអនុញ្ញាតដើម្បីបន្ថែមចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨។

[36] ឯកសារ **D256/14** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំអនុញ្ញាតដាក់សារណាបន្ថែមទៅលើចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា* ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨។

[37] **សំណុំរឿង លេខ ០០៤/១ ឯកសារ D308/3/1/20** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (អបជ)* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[38] **សំណុំរឿង លេខ ០០៤/២ ឯកសារ D360** [កោសលុប] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៧-៣៨។

## ២.២ សំណើរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍

29. មេធាវីការពារក្តីអះអាងថាមានតែការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ដែលមានភាពលម្អៀងយ៉ាងខ្លាំងប៉ុណ្ណោះទើបអាចធានាដល់សិទ្ធិរបស់ **មាស មុត** ក្នុងទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមស្ថានភាពថវិការបស់ អ.វ.ត.ក[39]។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់រួចហើយពីទស្សនៈរបស់ខ្លួនទាក់ទងនឹងស្ថានភាពថវិកានៅក្នុងដីកាសម្រេច ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ហើយខ្លួននៅតែបន្តទទួលបានព័ត៌មានពីបញ្ហាថវិកានេះជាប្រចាំ[40]។ ជាងនេះទៀត ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ បានបញ្ជាក់សាជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅ និងជាបន្តរបស់ខ្លួនក្នុងការផ្តល់មូលនិធិសមស្របដល់អង្គជំនុំជម្រះ នៅពេលពួកគេបានជួបប្រជុំជាមួយនឹងសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។ បន្ទាប់ពីចេញដីកាដំណោះស្រាយរួចហើយ សហចៅក្រមស៊ើបអង្កេត *លែងមានភារកិច្ចទៀតហើយ* ហើយវាជាកិច្ចការរបស់ចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[41]។

## ២.៣ បទដ្ឋានបង្ហាញភស្តុតាង

30. បើទោះបីជាមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានផ្ទុយក៏ដោយ[42] ក៏វាជាច្បាប់ដែលត្រូវបានរៀបចំឡើងសម្រាប់សំណុំរឿងដែលថា បទដ្ឋានបង្ហាញភស្តុតាងសម្រាប់ដីកាសម្រេចលើការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះគឺផ្អែកលើលក្ខខណ្ឌភវនីយភាព[43]។

---

[39] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ១៤-៦៩។

[40] **ឯកសារ D249/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

[41] **ឯកសារ D249/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ១១ ខែសីហា ឆ្នាំ ២០១៧, កថាខណ្ឌ ១៨។ **សំណុំរឿង លេខ ០០៤/២ ឯកសារ D360/3** [សាធារណៈ] *សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងចាត់វិធានការបណ្តោះអាសន្ន* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៦, ១៣។ **សំណុំរឿង លេខ ០០៤/២ ឯកសារ D360** [កោសលុប] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤-៤៥។

[42] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ៨២-១០៨។ **ឯកសារ D256/12** *សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់សារណាបន្ថែមទៅលើ*

### ២.៤ សំណើរបស់ ស.ព.អ សុំចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ ប៉ុន្តែមិនបានធ្វើការចោទឡើយ

31. ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិស្នើសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់ក៏ដោយ[44] ក៏សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនពុំបានទទួលការអនុញ្ញាតឱ្យចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះទេចំពោះឧក្រិដ្ឋកម្មនានាដែលរងការចោទប្រកាន់ ប៉ុន្តែមិនបានធ្វើការចោទឡើយ[45]។

## ៣. ច្បាប់ជាធរមាន

### ៣.១ យុត្តាធិការបុគ្គលនៅ អ.វ.ត.ក

32. តាមមាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក៖

> "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់ មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩"។

33. មាត្រា ១ នៃច្បាប់ អ.វ.ត.ក ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក[46] ចែងថា៖

---

*ចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៩ (ខ)។

[43] **ឯកសារ D261** *ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២។

[44] **ឯកសារ D256/7** *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ១០៦២-១០៦៤។

[45] **ឯកសារ D261** *ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៤៥។ **សំណុំរឿង លេខ ០០៤/២ ឯកសារ D360** [កោសលុប] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៤៧។

[46] មាត្រា ២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក។

"ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"។

34. មាត្រា ២ នៃច្បាប់ អ.វ.ត.ក រំឭកឡើងវិញថា អ.វ.ត.ក ត្រូវបង្កើតឡើងដើម្បីជំនុំជម្រះ *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩"*។

35. អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានបកស្រាយពាក្យថា *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"* សំដៅលើជនពីរប្រភេទ គឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែក៏ជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ ជនទាំងពីរប្រភេទនេះ ត្រូវតែជាមន្ត្រីខ្មែរក្រហម និងស្ថិតនៅក្នុងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដើម្បីឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការបុគ្គលឱ្យបានត្រឹមត្រូវ ហេតុនេះ លក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នា មិនមែនដាច់ដោយឡែកពីគ្នាទេ[47]។

36. អ.ជ.ត.ក បានប្រកាសដោយខ្លួនឯងស្តីពីលក្ខណៈយុត្តាធិការនៃមាត្រា ១ នៃច្បាប់ អ.វ.ត.ក។ ទាក់ទិននឹងចំណុចនេះ អ.ជ.ត.ក បានសន្និដ្ឋានថា បញ្ហាថាតើជនជាប់ចោទជាកម្មាភិបាលខ្មែរក្រហម ឬអត់នោះ គឺ *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្តល់ឆន្ទានុសិទ្ធិតិចតួច ឬមិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង"* ហេតុនេះជាបញ្ហាដែលអាចវិនិច្ឆ័យបាននៅក្នុង យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[48]។

[47] **សំណុំរឿង ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៥៧។

[48] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦១។

37. ផ្ទុយទៅវិញ ទាក់ទិននឹងពាក្យថា “មេដឹកនាំជាន់ខ្ពស់” និងជនដែល“ទទួលខុសត្រូវខ្ពស់បំផុត” អ.ជ.ត.ក បានសន្និដ្ឋានថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណ:វិនិច្ឆ័យផ្នែកយុត្តាធិការ *តាមន័យចង្អៀត* *(stricto sensu)* ទេ វាគ្រាន់តែបង្ហាញពីគោលការណ៍ចោទប្រកាន់របស់ ក.ស.ព និង គោលការណ៍ស៊ើបអង្កេតដោយឯករាជ្យរបស់ ក.ស.ច.ស ប៉ុណ្ណោះ។ អ.ជ.ត.ក បានសន្និដ្ឋានថា ជាគោលការណ៍ ប្រភេទទាំងពីរនេះមិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារ វាពុំអាចធ្វើការវិនិច្ឆ័យបានទេនៅចំពោះមុខ អ.ជ.ស.ដ ឬ អ.ជ.ត.ក ប្រសិនបើ ពុំមានបង្ហាញអំពីការបំពានឆន្ទានុសិទ្ធិដោយពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ[49]។ ស.ច.ស បានបង្ហាញការយល់ឃើញរួមគ្នាផ្ទាល់ខ្លួនរួចហើយអំពីការបកស្រាយ និងលក្ខណៈនៃលក្ខខណ្ឌនេះនៅក្នុងសំណុំរឿង ០០៤/១ *ដីកាដំណោះស្រាយ (សំអាងហេតុ)*[50]។ ការយល់ឃើញរួមគ្នាដូចគ្នានេះអនុវត្តនៅក្នុងសំណុំរឿងនេះដែរ។

*<u>គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍ “វិមតិសង្ស័យបានប្រយោជន៍ដល់ជនជាប់ចោទ” និងការបកស្រាយក្នុងន័យចង្អៀត</u>*

38. ក្នុងចំណោមកត្តានានាដែលត្រូវយកមកពិចារណាដើម្បីអនុវត្តឆន្ទានុសិទ្ធិ មានគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតអំពីច្បាប់ព្រហ្មទណ្ឌ។ ចំពោះសំអាងហេតុលម្អិតអំពីចំណុចនេះ យើង Michael Bohlander យោងលើ*ដីកាដំណោះស្រាយ (សំអាងហេតុ)* សំណុំរឿង ០០៤/១[51]។

*<u>លក្ខណៈវិនិច្ឆ័យក្នុងការអនុវត្តឆន្ទានុសិទ្ធិ៖ ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ</u>*

39. យើង Michael Bohlander កត់សម្គាល់ឃើញថា ដោយប្រើប្រាស់និយមន័យដែលបានកំណត់នៅក្នុងសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០១ អ.ជ.ត.ក ក៏បានសម្រេចដោយប្រយោលថា ពុំមានមូលដ្ឋានទេចំពោះការអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាអំពីការបង្កើត

---

[49] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៧៩-៨១។

[50] **សំណុំរឿងលេខ ០០៤/១-ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៩-១០។

[51] **សំណុំរឿងលេខ ០០៤/១-ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៦-៣៦។

អ.វ.ត.ក នាំឲ្យមានការយល់ឃើញជារួម និងត្រូវជាប់កាតព្វកិច្ចថា មានតែបុគ្គល(មានឈ្មោះ) មួយចំនួនប៉ុណ្ណោះដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការពោលគឺ ការជ្រើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកាលពីពេលមុន និងឥឡូវនេះគឺជាបញ្ហាឆន្ទានុសិទ្ធិសុទ្ធសាធរបស់ ក.ស.ព និង ក.ស.ច.ស ហើយផ្អែកទាំងស្រុងទៅលើអង្គសេចក្ដីនៃរឿងក្ដីនីមួយៗ។ ចំពោះសេចក្ដីលម្អិតអំពីការអនុវត្តឆន្ទានុសិទ្ធិនេះ យើង Michael Bohlander យោងទៅសំណុំរឿង ០០៤/១ *ដីកាដំណោះស្រាយ (សំអាងហេតុ)*[52]។

## ៣.២ ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក

40. ឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក មានរៀបរាប់នៅក្នុងមាត្រា ៣ ដល់ មាត្រា ៨ នៃច្បាប់ អ.វ.ត.ក។ ផ្នែកនេះនឹងសង្ខេបតែច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាការចោទប្រកាន់ និងបទចោទលើ **មាស មុត** តែប៉ុណ្ណោះ ។

### ៣១.២. ឧក្រិដ្ឋកម្មអន្តរជាតិ

41. អនុសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ គឺជាប្រភពច្បាប់អន្តរជាតិជាធរមាននៅក្នុងអំឡុងពេលពាក់ព័ន្ធ[53]។ ទោះបីជាយុត្តិសាស្ត្រនៃសាលាក្ដី *មិនអចិន្ត្រៃយ៍*ដែលត្រូវបានបង្កើតឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក ពុំចងកាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក៏ដោយ[54] ក៏អង្គជំនុំជម្រះនានានៅ អ.វ.ត.ក បានពឹងផ្អែកយ៉ាងខ្លាំងលើសេចក្ដីសម្រេចរបស់សាលាក្ដីទាំងនោះពាក់ព័ន្ធនឹងធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ដោយ អ.ជ.ត.ក បានកត់សម្គាល់ថា អង្គជំនុំជម្រះនានាមានកាតព្វកិច្ចត្រូវសម្រេចថា សេចក្ដីសម្រេចបែបនោះអាចអនុវត្តបាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយជនត្រូវចោទ អាចដឹងជាមុនថាមានសេច

---

[52] **សំណុំរឿងលេខ ០០៤/១-ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៣៧-៤១។

[53] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧ ដល់ កថាខណ្ឌ ១៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

[54] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧ *ដកស្រង់* មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

ក្តីសម្រេចបែបនោះ និងអាចចូលពិនិត្យមើលសេចក្តីសម្រេចបែបនោះបានចំពោះពេលវេលាពាក់ព័ន្ធនឹងបទចោទ[55]។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

42. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឲ្យ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាត្រានេះកំណត់និយមន័យថាជា“*អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ*” ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

43. លើកលែងតែអំពើរំលោភសេពសន្ថវៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនេះគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[56]។ ចំពោះការរំលោភលើផ្លូវភេទ អ.ជ.ត.ក បានសម្រេចថា វាពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពោលគឺជាអំឡុងពេលដែលមានចែងនៅក្នុងក្របខណ្ឌយុត្តាធិការរបស់ អ.វ.ត.ក[57]។ ទោះបីជាយ៉ាងនេះក្តី អ.វ.ត.ក មានយុត្តាធិការលើការរំលោភលើផ្លូវភេទ ជាអំពើទារុណកម្មនៅពេលដែល

---

[55] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧។

[56] <u>មនុស្សឃាត</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១១។ <u>ការសម្លាប់រង្គាល</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៥។ <u>ការដាក់ឲ្យទៅជាទាសករ</u>៖ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤២។ <u>ការដាក់ពន្ធនាគារ</u>៖ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៧។ <u>ទារុណកម្ម</u>៖ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥៣។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥ ដល់ កថាខណ្ឌ ២០៥។ <u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៦។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២២៥។ <u>អំពើអមនុស្សធម៌ផ្សេងទៀត</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៥។

[57] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៨០ ដល់ កថាខណ្ឌ ១៨៣។

ធាតុផ្សំទាំងអស់ផ្សេងទៀតនៃអំពើទារុណកម្មត្រូវបានបំពេញ[58] និងជាអំពើអមនុស្សធម៌ផ្សេងៗទៀត[59]។

*ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

44. ***អត្ថិភាពនៃការវាយប្រហារ៖*** ការវាយប្រហារគឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើន ដែលមិនមែនគិតត្រឹមតែការប្រើកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះទេ ហើយអាចរួមបញ្ចូលទាំងការធ្វើបាបប្រជាជនស៊ីវិលផងដែរ[60]។ ការវាយប្រហារទៅលើប្រជាជនស៊ីវិល មានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ[61]។

45. ***លក្ខណៈជាទូទៅ ឬជាប្រព័ន្ធនៃការវាយប្រហារ៖*** លក្ខខណ្ឌនៃ"លក្ខណៈជាទូទៅ" គឺសំដៅលើការវាយប្រហារដែលមានលក្ខណៈទ្រង់ទ្រាយធំ និងមានចំនួនជនរងគ្រោះច្រើន ហើយធាតុផ្សំនៃលក្ខណៈ"ជាប្រព័ន្ធ" គឺសំដៅលើអំពើហិង្សាដែលមានការរៀបចំ[62]។ ភ័ស្តុតាងដែលបង្ហាញអំពី"លក្ខណៈជាទូទៅ" ឬ"ជាប្រព័ន្ធ"នៃការវាយប្រហារ គឺគ្រប់គ្រាន់អាចបំពេញតាមលក្ខខណ្ឌធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[63]។

---

[58] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧ ដល់ កថាខណ្ឌ ២០៨ កថាខណ្ឌ ២១៣។

[59] **សំណុំរឿងលេខ ០០២-ឯកសារ D427/2/12** *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ* ដីកា ១១(០២)។ **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៤៣៣។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* ICTR-96-4-T សាលក្រម ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៨៨។

[60] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩៨។

[61] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩៨។

[62] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៩។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០០។

[63] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៩។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០០។

46. ***សំដៅលើប្រជាជនស៊ីវិល៖*** ការវាយប្រហារត្រូវតែមានគោលដៅជាចម្បងសំដៅលើប្រជាជនស៊ីវិល[64]។ មិនចាំបាច់ត្រូវបង្ហាញថា ទាល់តែប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រ ណាមួយបានទទួលរងការវាយប្រហារ ទើបត្រូវចាត់ទុកថា ការវាយប្រហារនោះសំដៅលើជនស៊ីវិលទេ។ គ្រប់គ្រាន់ហើយត្រឹមតែបង្ហាញថា បុគ្គលមួយចំនួននៅក្នុងក្រុមនោះគឺជាគោលដៅនៅក្នុងអំឡុងពេលវាយប្រហារ ឬក៏ជាគោលដៅក្នុងរបៀបមួយដែលបង្ហាញថា ការវាយប្រហារនោះតាមពិតសំដៅលើ"ប្រជាជន"ស៊ីវិល មិនមែនសំដៅលើបុគ្គលក្នុងចំនួនមួយមានកម្រិត និងដោយចៃដន្យទេ[65]។ ប្រជាជនដែលត្រូវទទួលរងការវាយប្រហារ ត្រូវតែមានចំនួន ជនស៊ីវិលច្រើនលើសលុប[66]។ ជាលក្ខណៈប្រពៃណី វត្តមានរបស់បុគ្គលមួយចំនួននៅក្នុងចំណោមប្រជាជនស៊ីវិល ហើយបុគ្គលទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់ជាជនស៊ីវិលទេ មិនប្រាកដជាដកហូត លក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនោះទេ[67]។ ក៏ប៉ុន្តែ ទោះបីមេធាវីការពារក្តីជំទាស់នឹងចំណុចនេះក៏ដោយ[68] ហើយដូចដែលយើង Michael Bohlander បានជូនដំណឹងភាគីទាំងអស់រួចហើយ យើងយល់ឃើញថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន គឺជាការវាយប្រហារមកលើប្រជាជនស៊ីវិល លើកលែងតែករណីដែលកងកម្លាំងប្រដាប់អាវុធដែល

---

[64] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩១-៩២។

[65] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០៣។

[66] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៣៨, ៧៤០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29/1-A) សាលដីកា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៥០-៥១។

[67] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stanislav Galić* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29-A) សាលដីកា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៣៦-១៣៨។

[68] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១៣៤-១៣៦។

រងការវាយប្រហារនោះ មានសម្ព័ន្ធភាព ឬផ្តល់ការគាំទ្រពាក់ព័ន្ធនឹងកងទ័ពទៅឲ្យភាគីប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធ[69]។

47. ***ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា៖*** មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា ការវាយប្រហារដូចបានកំណត់ខាងលើ ត្រូវតែធ្វើឡើង ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ប៉ុន្តែ មិនមែនចាំបាច់ទាល់តែមូលហេតុរើសអើងឡើយ[70]។ នេះគឺជាលក្ខខណ្ឌយុត្តាធិការដែលអនុវត្តចំពោះការវាយប្រហារជាទូទៅ ហើយមិនអនុវត្តចំពោះបទល្មើសជាមូលដ្ឋានទេ[71]។ ដូច្នេះ មិនចាំបាច់បង្ហាញភ័ស្តុតាងអំពីចេតនារើសអើងសម្រាប់គ្រប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ចេតនារើសអើង គឺគ្រាន់តែជាលក្ខខណ្ឌតម្រូវមួយទាក់ទិននឹងបទឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ[72]។

48. ***ទំនាក់ទំនងរវាងអំពើរបស់ជនត្រូវចោទ និងការវាយប្រហារ៖*** អំពើរបស់ចារី ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានលទ្ធផលយ៉ាងណាក៏ដោយ ជាសត្យានុម័តត្រូវតែជាផ្នែកមួយនៃការវាយប្រហារលើប្រជាជនស៊ីវិល[73]។

---

[69] **សំណុំរឿងលេខ ០០៤/២-ឯកសារ D347.1** *ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ* ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៦៩។

[70] **សំណុំរឿងលេខ ០០២-ឯកសារ F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤២, ៧៤៤-៧៤៥។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨។

[71] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤៤-៧៤៥។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨។

[72] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤៤។ **សំណុំរឿង លេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨-១៨៩។ **សំណុំរឿងលេខ ០០១ -ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jean-Paul Akayesu* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (ICTR-96-4-A) សាលដីកា ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៤៦៥-៤៦៦។

[73] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* កថាខណ្ឌ ៧៥៣-៧៥៤។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩០។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា

49. ***ត្រូវដឹង៖*** ចារីត្រូវតែបានដឹងអំពីការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងបានដឹងថា អំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ។ ចារីមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយ ប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារដែលមានលក្ខណៈទូទៅនោះទេ[74]។

50. ***ពុំមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ៖*** យើង Michael Bohlader បានសម្រេចពីមុនថា អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយនឹងជម្លោះប្រដាប់អាវុធលែងជាធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅត្រឹមឆ្នាំ១៩៧៥ទៀតហើយ[75]។ អ.ប.ជ អ.ជ.ស.ដ និង អ.ជ.ត.ក សុទ្ធតែបានធ្វើសេចក្ដីសម្រេចដូចគ្នានេះដែរ[76]។

*__ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក__*

---

ឆ្នាំ២០១០ កថាខណ្ឌ ៣១៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩៩។

[74] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩១។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១០២-១០៣។

[75] **សំណុំរឿងលេខ ០០៣-ឯកសារ D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦។

[76] *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៧ និង**សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧២១, ៧៣២។ នៅឆ្នាំ ២០១១ អ.ប.ជ ពិតជាបានសម្រេចថា ទំនាក់ទំនងនេះគឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427/3/15** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៤៤ និង **សំណុំរឿងលេខ ០០២-ឯកសារ D427/1/30** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀ សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៣១១។ ប៉ុន្តែ ក្រោយពីមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អន្តរជាតិ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ (**សំណុំរឿងលេខ ០០៣-ឯកសារ D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦) ទើប អ.ប.ជ បានពិចារណាឡើងវិញលើជំហរពីមុនរបស់ខ្លួន ហើយបានសម្រេចថា ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធមិនតម្រូវឱ្យមានទេ ហេតុនេះ អ.ប.ជ ស្របតាមអង្គជំនុំជម្រះផ្សេងទៀតនៅ អ.វ.ត.ក *សូមមើល* **សំណុំរឿងលេខ ០០៣-ឯកសារ D87/2/1.7/1/1/7** *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧។

51. ធាតុផ្សំនៃ**ការធ្វើមនុស្សឃាត** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ និងចូលរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យជនរងគ្រោះស្លាប់[77]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចេតនារបស់ចារីក្នុងការសម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស[78]។

52. ធាតុផ្សំនៃ**ការសម្លាប់រង្គាល** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម អំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[79]។ ការកំណត់ទៅលើការសម្លាប់រង្គាលមិនចាំបាច់ត្រូវបង្ហាញចំនួនជនរងគ្រោះក្នុងកម្រិតអប្បបរមាណាមួយនោះទេ[80]។ លក្ខខណ្ឌតម្រូវ "ទ្រង់ទ្រាយធំ"ត្រូវវាយតម្លៃតាមករណីនីមួយៗ ដោយផ្អែកលើកត្តាពេលវេលា និងទីកន្លែង សម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងការសម្លាប់ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែលើជនរងគ្រោះម្នាក់ៗ[81]។

---

[77] **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣១។

[78] **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣៩១, ៤០៩, ៤១០។ **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៣។

[79] **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។ **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៤។

[80] **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៦។

[81] **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២៥, ៥២៧។ **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milan Lukić*

ខ. *ធាតុផ្សំអត្តនោម័ត៖* ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ[82]។ អ.ជ.ត.ក បានសម្រេចថា គោលបំណងនៃការសម្លាប់រង្គាលគឺដើម្បីលុបបំបាត់បុគ្គលដែលជាផ្នែកនៃក្រុមមួយ ដូច្នេះហើយវាពុំស្របជាមួយនឹងសញ្ញាណនៃចេតនាប្រយោល (*dolul eventualis*) ទេ។ ប៉ុន្តែបន្ទាប់មក អ.ជ.ត.ក បានបញ្ជាក់ថា មិនចាំបាច់ត្រូវដឹងថា *អំពើពិរុទ្ធនោះ*នឹងបណ្តាលឱ្យមនុស្សស្លាប់ទេ ប៉ុន្តែអ្វីដែលចាំបាច់នោះគឺ“*ការបង្ហាញថា ការសម្លាប់សមាជិកនៃក្រុមមួយគឺជាចេតនារបស់ចារី ដោយពុំគិតពីបញ្ហាថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតមានឡើងជាក់ស្តែង ដែរឬយ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថាអាចមានការស្លាប់កើតឡើង ពុំគ្រប់គ្រាន់ឡើយ*”[83]។

53. ធាតុផ្សំនៃ**ការធ្វើឱ្យទៅជាទាសករ** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមនុស្ស[84]។ ការធ្វើការងារដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត អាចជា

---

*និង* *Sredoje Lukić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-32/1-A) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៥៣៨។

[82] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០, ៥២២ ដកស្រង់*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Krsti* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY( IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥០៣។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៨។

[83] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។

[84] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤២, ៣៤៦។

ការធ្វើឲ្យទៅជាទាសករ[85]។ ភស្តុតាងបញ្ជាក់អំពីការធ្វើបាប គឺមិនចាំបាច់ត្រូវមានឡើយដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃបទល្មើសនៃការធ្វើឲ្យទៅជាទាសករ[86]។

ខ. *ធាតុផ្សំអត្តនោម័តៈ* ចារីត្រូវតែបានប្រើប្រាស់ដោយចេតនានូវអំណាចមួយ ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលម្នាក់ទៀត[87]។

54. ធាតុផ្សំនៃ**ការដាក់ក្នុងមន្ទីរឃុំឃាំង** គឺៈ

ក. *ធាតុផ្សំសត្យានុម័តៈ* ការរដកហូតសេរីភាពរបស់បុគ្គលតាមទំនើងចិត្តដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ ឬផ្អែកលើបទប្បញ្ញត្តិច្បាប់ជាតិដែលរំលោភលើច្បាប់អន្តរជាតិ[88]។ មិនមែនរាល់ការរំលោភបំពានបន្តិចបន្តួចលើសិទ្ធិសេរីភាព មានន័យថាជាការដាក់ក្នុងមន្ទីរឃុំឃាំងនោះទេ ហើយការដកហូតសិទ្ធិសេរីភាពត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក[89]។

---

[85] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY( IT-97-25T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ៣៥៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-23-T & IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៥៤២-៥៤៣។

[86] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២៣*ដកស្រង់រឿងក្តីសហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកផ្សេងទៀត* សាលក្រម ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧ បោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង* វ៉ុល ៥ (ឆ្នាំ ១៩៩៧) ទំព័រ ៩៥៨ ត្រង់ទំព័រ ៩៧០។

[87] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២២។

[88] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៧-៣៤៨។

[89] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៩ ដកស្រង់រឿងក្តី *រឿងក្តីរដ្ឋអាជ្ញា Ntagerura និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-99-46-T) កថាខណ្ឌ

ខ. *ធាតុផ្សំអត្តនោម័តៈ* ចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬចារីបានប្រព្រឹត្តដោយបានដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឲ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល[90]។

55. ធាតុផ្សំនៃ**ការធ្វើទារុណកម្ម** គឺ៖

ក. *ធាតុផ្សំសត្យានុម័តៈ* អំពើណាមួយដែលបណ្តាលឲ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរផ្នែករាងកាយ ឬស្មារតី ដែលប្រព្រឹត្តឡើង ឬដោយញុះញង់ពីមន្ត្រីសាធារណៈ[91]។

ខ. *ធាតុផ្សំអត្តនោម័តៈ* ចារីត្រូវមានចេតនាបង្កឲ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរទៅលើជនរងគ្រោះ[92]។

គ. អំពើនោះត្រូវតែបានប្រព្រឹត្តឡើងក្នុងគោលបំណង ដូចជា ដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ[93]។

56. អ.ជ.ត.ក បានសម្រេចថា **ការរំលោភលើផ្លូវភេទ** អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលណាដែលធាតុផ្សំផ្សេងៗទៀតនៃអំពើទារុណកម្មត្រូវបានបំពេញ[94]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដែលមានការយល់ស្របពី អ.ជ.ត.ក ផងដែរនោះ[95] បានកំណត់ចរិតលក្ខណៈនៃការរំលោភសេពសន្ថវៈ ដូចខាងក្រោម៖

---

៧០២។ *សូមមើល ផ្ទុយពីនេះ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY( IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១១២។

[90] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(*I*IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១១៥។

[91] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥៥។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[92] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[93] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[94] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧-២០៨, ២១៣។

[95] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៨។

ក. *ធាតុផ្សំសត្យានុម័ត៖* ការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារីនៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ។ ការយល់ព្រមមានន័យថា ត្រូវតែស្ម័គ្រចិត្តចេញពីឆន្ទៈរបស់ជនរងគ្រោះ ដែលត្រូវធ្វើការវាយតម្លៃក្នុងបរិបទកាលៈទេសៈពាក់ព័ន្ធជុំវិញ[96]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានប្រព្រឹត្តដោយមានចេតនាបញ្ចូលអង្គជាត និងដឹងថា ការបញ្ចូលអង្គជាតកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[97]។

57. ធាតុផ្សំនៃ**បទធ្វើទុក្ខបុកម្នេញ** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្ម ដែលរើសអើងជាក់ស្តែង និងដកហូត ឬរំលោភសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ ឬសន្ធិសញ្ញា[98]។ ធាតុផ្សំនៃការរើសអើងនៅក្នុង*អំពើពិរុទ្ធ*ត្រូវបានបង្កើតឡើង នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកនៅក្នុងក្រុមណាមួយដែលចារីបានកំណត់ជាអត្តនោម័ត និងបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[99]។ ជនរងគ្រោះត្រូវតែស្តែងឱ្យបានឃើញច្បាស់លាស់គ្រប់គ្រាន់ថាគាត់ស្ថិតក្នុងក្រុមនយោបាយ

---

[96] **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២៧។

[97] **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៥។

[98] **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៧-៦៦៨។ **សំណុំរឿងលេខ ០០១-ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៦៧, ២៧១-២៧៨។ **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៧-៤២៨។

[99] **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៧, ៦៧៨-៦៧៩, ៦៨៧, ៦៩៥។ **សំណុំរឿងលេខ ០០១-ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧២-២៧៣, ២៧៤, ២៧៦, ២៧៧។ **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៨។

ពូជសាសន៍ ឬសាសនាណាមួយ ដែលផលវិបាកដោយសារការធ្វើទុក្ខបុកម្នេញ ត្រូវតែកើតមានទៅលើក្រុមនោះ[100]។ ទាក់ទិននឹងបញ្ហានេះ អ.ជ.ត.ក បាន សម្រេចថា ពុំមានការរើសអើងទេ នៅពេលដែលនៅក្នុងអង្គហេតុ ចារីមានការ ភាន់ច្រឡំលើជនរងគ្រោះដោយបានមិនដឹងថាតើ ជនរងគ្រោះពិតជាស្ថិតនៅក្នុង ក្រុមគោលដៅ ដែលត្រូវកំណត់ដោយអត្តនោម័ត ដែរឬយ៉ាងណា ឬនៅពេល ដែលចារីកំណត់ គោលដៅជនរងគ្រោះដោយមិនគិតថាតើ ជនរងគ្រោះស្ថិតនៅ ក្នុងលក្ខណៈវិនិច្ឆ័យនៃការរើសអើង ដែរឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅ ពេលដែលចារីកំណត់គោលដៅ"ដោយមិនរើសមុខ"[101]។ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពិចារណាទៅលើការយល់ឃើញរបស់ចារី នៅពេល ធ្វើការកំណត់ក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ដូច្នេះ មិនមានលក្ខខណ្ឌ តម្រូវថា សមាជិកនៃក្រុមដែលគេកំណត់គោលដៅនោះ ត្រូវតែប្រកាន់ទស្សនៈ នយោបាយរួម ឬទស្សនៈនយោបាយណាមួយនោះ ឡើយ[102]។

ខ. ការធ្វើទុក្ខបុកម្នេញអាចប្រព្រឹត្តឡើងតាមរយៈបទល្មើសមួយ ឬច្រើនក្នុងចំណោម បទល្មើសជាមូលដ្ឋានដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែង នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ព្រមទាំងតាមរយៈអំពើដទៃទៀត ដែលមាន ស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរស្មើគ្នា រួមបញ្ចូលទាំងអំពើទាំងឡាយដែលមិនចាំបាច់ ទាល់តែឧក្រិដ្ឋកម្មអន្តរជាតិទេ[103]។

---

[100] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧៤-២៧៧។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៨។

[101] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧៧។ *សូមមើលផងដែរ* កថាខណ្ឌ ២៧២-២៧៦។

[102] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៦៨, ៦៧៧-៦៨០។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧២-២៧៣។

[103] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radoslav Brđanin សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (T-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ២៩៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tihomir Blaškić សាលដីកា* អង្គជំនុំ ជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៣៥។

គ. *ធាតុផ្សំអត្តនោម័ត៖* ការប្រព្រឹត្តអំពើសកម្ម ឬអកម្មដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[104]។ ទោះបីជាក្នុងករណីដែល អំពើទាំងនេះ បង្កើតបានជាបទល្មើសនៅក្រោមច្បាប់អន្តរជាតិក៏ដោយ ក៏មិនចាំបាច់ត្រូវបង្ហាញនូវ *ចេតនាឧក្រិដ្ឋ*ដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទល្មើសទាំងនេះឡើយ៖ គ្រប់គ្រាន់ហើយត្រឹម បង្ហាញថា អំពើនេះត្រូវបានអនុវត្តឡើងដោយមានចេតនារើសអើង ដែលជាលក្ខខណ្ឌតម្រូវ[105]។

58. ធាតុផ្សំនៃ**អំពើអមនុស្សធម៌ផ្សេងៗទៀត** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មរបស់ចារី ដែលបណ្ដាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ[106]។ អំពើសកម្ម ឬអកម្មរបស់ចារីត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀត ដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវធ្វើការវាយតម្លៃទៅតាមករណីជាក់ស្ដែងនីមួយៗ ដោយពិចារណាលើកាលៈទេសៈនីមួយៗនៅក្នុងរឿងក្ដី[107]។ មិនមានលក្ខខណ្ឌតម្រូវថា ការឈឺចាប់នោះត្រូវមានផលប៉ះពាល់រយៈពេលយូរអង្វែងនោះឡើយ ទោះបីជាថានេះអាចជាកត្តាពាក់ព័ន្ធដើម្បីវាយតម្លៃភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[108]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សា

---

[104] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៧។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៥៧។

[105] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-88-A) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៧៣៨។

[106] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨០។

[107] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៦៧, ៥៨៦។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៨។

[108] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៩។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៩។

យ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ ឬបានដឹងថា អំពើសកម្ម ឬអកម្មនោះទំនងជាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហឹង្សាយ៉ាងធ្ងន់ធ្ងរមកលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ[109]។

59. អំពើអមនុស្សធម៌ផ្សេងៗទៀត មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់តាំងពីឆ្នាំ១៩៧៥ មក[110]។ អំពើដែលជាមូលដ្ឋាននៃ"អំពើ ឧក្រិដ្ឋកម្មអមនុស្សធម៌ផ្សេងៗទៀត" មិនចាំបាច់ទាល់តែជាអំពើឧក្រិដ្ឋតាមច្បាប់អន្តរជាតិនៅពេលដែលប្រព្រឹត្តនោះឡើយ[111]។ គ្រប់គ្រាន់ហើយត្រឹមថា អំពើនោះបំពេញតាមធាតុផ្សំអង្គច្បាប់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[112] ដោយពិចារណាលើកាលៈទេសៈនៃសំណុំរឿងនោះ។ ហេតុនេះ មិនចាំបាច់បញ្ជាក់អំពីធាតុផ្សំនៃអំពើដែលបានចោទថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះទេ។

60. ប៉ុន្តែ អាចចាំបាច់ត្រូវកំណត់ប៉ារ៉ាម៉ែត្រនៃអំពើនោះដើម្បីកំណត់ថាតើ ជនត្រូវចោទ អាចប្រមើលមើលដឹង និងអាចដឹងថា ខ្លួនអាចត្រូវស៊ើបអង្កេត និងចោទប្រកាន់ដោយសារអំពើបែបនោះដែរឬអត់[113]។ ត្រូវគោរពតាមគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង ប្រសិនបើអំពើនោះរំលោភលើសិទ្ធិជាមូលដ្ឋានណាមួយរបស់ជនរងគ្រោះ ហើយមានលក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នានឹងបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតម្រូវឱ្យធ្វើការវិភាគលើអំពើនោះតាមករណីនីមួយៗ[114]។

---

[109] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៧។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៨, ៣៧១។

[110] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៧៦។

[111] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

[112] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៩។

[113] **ឯកសារ D301/5** *ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៥១, ៦៣។

[114] **ឯកសារ D301/5** *ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៦៤។

61. ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវសច្ចភាពផ្លូវច្បាប់ ត្រូវធ្វើការប្រៀបធៀបរវាងលក្ខណៈ និងស្ថានទម្ងន់នៃប្រភេទអំពើខាងលើជាមួយនឹងលក្ខណៈ និងស្ថានទម្ងន់នៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានចែង យោងតាម*គោលការណ៍នៃការបញ្ចូលគ្នាតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)*[115]។ ចំពោះលក្ខណៈនៃអំពើដែលអាចបង្កើតបានជាអំពើអមនុស្សធម៌ណាមួយ អាចយោងលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិដែលចែងអំពីជម្លោះប្រដាប់អាវុធ រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ រួមមាន ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឬការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើបទដ្ឋានសិទ្ធិមនុស្សជាសារវន្តដែលត្រូវការពារតាមច្បាប់អន្តរជាតិនៅពេលនោះ[116]។

62. ករណីបាត់ខ្លួនដោយបង្ខំ[117] រំលោភលើផ្លូវភេទ[118] ការបំពារបំពានលើរាងកាយអ្នកទោស[119] ស្ថានភាពអមនុស្សធម៌នៃការឃុំខ្លួន[120] និងការរៀបការដោយបង្ខំ[121] ធ្លាប់ត្រូវបានសម្រេចថាមានលក្ខណៈ និងស្ថានទម្ងន់ដូចគ្នានឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានចែង។ យើង Michael

---

[115] ពាក្យ *ejusdem generis* មាននិយមន័យថាជា"ប្រភេទនៃគោលការណ៍ដែលបកស្រាយថា នៅពេលដែលពាក្យ ឬឃ្លាទូទៅណាមួយមានចែងបន្ទាប់ពីការរៀបរាប់អំពីប្រភេទអ្វីមួយ នោះ ពាក្យ ឬឃ្លាទូទៅនេះនឹងត្រូវបកស្រាយថារួមមានតែអ្វីដែលជាប្រភេទដូចគ្នាដូចបានរៀបរាប់នោះតែប៉ុណ្ណោះ(វចនានុក្រម Black's Law បោះពុម្ពលើកទី ៩)។

[116] **សំណុំរឿងលេខ ០០២-ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៦៤។

[117] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៤៤-៤៤៨។ *រឿង ក្តី រដ្ឋអាជ្ញា តទល់នឹង Zoran Kupreškić និងអ្នកផ្សេងទៀត សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-16-T) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៦៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima និង អ្នក ផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL (SCSL-04-16-A) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ១៨៤។

[118] **សំណុំរឿងលេខ ០០២-ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៥៤។ **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៤៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៨៨។

[119] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvocka សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-30/1-T) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌ ២០៨ និង ២០៩។

[120] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krnojelac សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១៣៣។

[121] **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១៤។

Bohlander មិនជឿជាក់ទៅលើសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារដែលបដិសេធថា អាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានដាក់បញ្ចូលទៅក្នុងអំពើអមនុស្សធម៌ផ្សេងៗទៀតទាល់តែសោះ ដោយហេតុថា មេធាវីការពារក្ដីទទួលស្គាល់ដោយខ្លួនឯងថា លក្ខខណ្ឌនៃការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ត្រូវបានបញ្ចូលទៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ នៅពេលនោះ[122]។

*អំពើប្រល័យពូជសាសន៍*

63. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ដែលផ្ដល់ឲ្យ អ.វ.ត.ក នូវយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺមានមូលដ្ឋានលើមាត្រា ២ និង ៣ នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍[123] ដែល

---

[122] ឯកសារ **D214** *ញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជាអំពើអមនុស្សផ្សេងទៀត* ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៨។ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ជើងទំព័រ ៥១៩៥។

[123] មាត្រា ៤ នៃច្បាប់ អ.វ.ត.ក មិនផ្ដន្ទាទោសចំពោះការជំរុញដោយផ្ទាល់ និងជាសាធារណៈដើម្បីធ្វើការប្រល័យពូជសាសន៍ ឬការរួមគំនិតដើម្បីធ្វើការប្រល័យពូជសាសន៍ ដូចមានចែងនៅកថាខណ្ឌ ខ និង គ នៃអនុសញ្ញាស្ដីអំពីការបង្ការ និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ទេ ("អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍")។ និយមន័យអំពីអំពើប្រល័យពូជសាសន៍នៅក្នុងសំណៅជាភាសាអង់គ្លេសនៃមាត្រា ៤ នៃច្បាប់ អ.វ.ត.ក អាចត្រូវបកស្រាយថាជាការរៀបរាប់មិនចេះអស់អំពីអំពើប្រល័យពូជសាសន៍ (ដោយសារមានពាក្យ "*such as*-ដូចជា") ហើយដកចេញនូវពាក្យ"*as such*-ដោយមានចេតនាបែបនោះ" ពីឃ្លាថាដើម្បីបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ។ ករណីទាំងពីរនេះ គឺផ្ទុយពីអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រដែលបានបង្កើតរួចហើយ។ ផ្ទុយមកវិញ សំណៅជាភាសាបារាំងនៃមាត្រា ៤ ឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ដោយចែងថា៖ "*On entend par crime de génocide, qui est imprescriptible l'un quelconque des actes ci-après, commis dans l'intention de détruire, en tout ou en partie, un groupe national, ethnique, racial ou religieux, comme tel*"។ សំណៅជាភាសាខ្មែរកាន់តែជិតត្រូវគ្នាជាមួយនឹងខ្លឹមសារនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ដោយបានកម្រិតអំពើប្រល័យពូជសាសន៍នៅត្រឹមតែអំពើដែលបានរៀបរាប់នៅក្នុងមាត្រា៤ តែប៉ុណ្ណោះ៖ "អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាលគឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា:" បកប្រែទៅជាភាសាអង់គ្លេស "*The acts of genocide, which have no statute of limitations, mean any of the following acts committed with the intent to destroy, in whole or in part, a national, ethnical, racial or religious group:*"។ ទាំង កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៩ ទាំងច្បាប់ អ.វ.ត.ក មាត្រា ៤ ក៏ចែងថា យុត្តាធិការរបស់អ.វ.ត.ក ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ត្រូវកម្រិតនៅត្រឹមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "*ដូចដែលបានកំណត់*" នៅក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍។ ហេតុនេះ និយមន័យអំពីអំពើប្រល័យពូជសាសន៍ដែលប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយនេះ គឺប្រកាន់យកតាមនិយមន័យនៅក្នុងសំណៅជាភាសាបារាំង និងភាសាខ្មែរនៃមាត្រា ៤ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រដែលបានបង្កើតរួចហើយ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១១។

ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[124]។ ស្របតាមគោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង* *(nullem crimen sine lege)* និង យុត្តិសាស្ត្រដែលបានបង្កើតរួចហើយនោះ និយមន័យអំពីអំពើប្រល័យពូជសាសន៍ ដែលប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយនេះ គឺសំដៅលើការប្រព្រឹត្តិអំពើណាមួយក្នុងចំណោមអំពើដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ប្រព្រឹត្តឡើងដោយមានចេតនាជាក់លាក់ដើម្បីបំផ្លាញទាំងស្រុង ឬមួយផ្នែកទៅលើក្រុមជាតិ ក្រុមជាតិពិន្ទុ ក្រុមពូជសាសន៍ ឬក្រុមសាសនា ដែលជាក្រុមគោលដៅច្បាស់លាស់ដោយមានចេតនាបែបនោះ[125]។

*ធាតុផ្សំទូទៅនៃអំពើប្រល័យពូជសាសន៍*

64. មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលបានចោទនោះត្រូវតែបានកើតឡើងនៅក្នុងបរិបទដែលបង្ហាញឱ្យឃើញច្បាស់អំពីលំនាំអំពើស្រដៀងគ្នាទេ[126]។ ស្រដៀងគ្នានេះដែរ អត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ (ឬគោលនយោបាយ ឬផែនការផ្សេងទៀត)ដើម្បីប្រព្រឹត្តអំពើប្រល័យពូជ

---

[124] សេចក្តីមន្ទិលអំពីអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ *មតិយោបល់ប្រឹក្សា* ICJ Rep15(ឆ្នាំ ១៩៥១)ទំព័រ ២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៣៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៩៥។ **សំណុំរឿងលេខ ០០២-ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១០៨។ ប្រទេសកម្ពុជាបានចូលជាសមាជិកអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ នៅចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០ បន្ទាប់ពីទទួលបានស្វ័យភាពអធិបតេយ្យភាព យោងតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋបារាំងលើកទី ៤។ ការចូលជាសមាជិករបស់កម្ពុជា ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ ហើយមិនមានកំណត់ហេតុអំពីការជំទាស់អង្គច្បាប់អំពីការចូលជាសមាជិកនេះទេ។ បន្ទាប់ពីទទួលបានការចូលជាសមាជិក និងការធ្វើសច្ចាប័នតាមចំនួនដែលត្រូវការរួចមក អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ បានចូលជាធរមាននៅចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១០។

[125] **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៤៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៩៨-៤៩៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៤២។

[126] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២២៣-២២៤។

សាសន៍ គឺមិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ[127] ហើយក៏មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលបានចោទនោះត្រូវតែជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមកលើប្រជាជនស៊ីវិលទេ[128]។ ប៉ុន្តែ កត្តាបែបនេះអាចជួយបញ្ជាក់ពីការរកឃើញ ចេតនាជាក់លាក់នៃការប្រព្រឹត្ត[129]។

*ក្រុមត្រូវការពារ*

65. អ.វ.ត.ក មានយុត្តាធិការលើអំពើប្រល័យពូជសាសន៍ដែលសំដៅលើក្រុមជាតិ ក្រុមជាតិពិន្ទុ ក្រុមពូជសាសន៍ និងក្រុមសាសនា[130]។ មានតែក្រុមទាំងបួនដែលបានបញ្ជាក់យ៉ាងច្បាស់នេះទេដែលជាក្រុមត្រូវការពារ[131]។

---

[127] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-88-A) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៤៣៩, ៤៣៦, ៤៤០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Rutaganda សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៥២៥។

[128] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Jelisić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-10-A) ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ ៤៨។

[129] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Jelisić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-10-A) ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ ៤៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Rutaganda សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៥២៥។

[130] ច្បាប់ អ.វ.ត.ក មាត្រា ៤។ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ មាត្រា ២ និង ៣។

[131] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៥៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨០៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ៩៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Bagilishema សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦០-៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១១។ ទោះបីជាថា *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Akayesu សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥១៦ អង្គជំនុះជម្រះសាសលាដំបូងនៅតុលាការ

66. មិនមាននិយមន័យដែលត្រូវបានទទួលស្គាល់ជាទូទៅអំពីក្រុមត្រូវការពារទាំងបួនប្រភេទនេះទេ[132]។ យុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ បញ្ជាក់អំពីការវិវត្តនៃលក្ខខណ្ឌចម្រុះតាមករណីនីមួយៗ ដើម្បីកំណត់ថាតើ ជនរងគ្រោះ (ឬក្រុមគោលដៅ) ស្ថិតនៅក្នុងចំណោមក្រុមណាមួយក្នុងចំណោមក្រុមត្រូវការពារដែរឬអត់[133]។ ទីមួយ គួរយោងលើលក្ខណៈសត្យានុម័តនៃបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលជាប់ពាក់ព័ន្ធ[134]។ ប៉ុន្តែ ដោយសារថា ក្រុម

---

ICTR បានបញ្ជាក់ថា អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ត្រូវបានរៀបចំឡើងដើម្បីការពារក្រុមដែលមានស្ថិរភាព និងអចិន្ត្រៃយ៍*ណាមួយ* (គូសបញ្ជាក់បន្ថែម) ដោយធ្វើការបញ្ជាក់ឆ្លើយតបទៅនឹងបញ្ហាចោទថាតើអំពើប្រល័យពូជសាសន៍កម្រិត ឬមិនកម្រិតនៅត្រឹមអំពើដែលប្រព្រឹត្តមកលើក្រុមទាំងបួនដែលបានលើកឡើងយ៉ាងច្បាស់។ ត្រង់ចំណុចនេះ សេចក្តីសម្រេចដែលលក្ខណៈទូលំទូលាយជាងនេះគឺកម្រិតនៅត្រឹមថា ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍គឺកំណត់នៅត្រឹមក្រុមដែលមានស្ថិរភាព និង អចិន្ត្រៃយ៍ ហេតុនេះមិនរាប់បញ្ចូល"ក្រុមចល័ត"ទេ ប៉ុន្តែ មិនបានធ្វើសេចក្តីសន្និដ្ឋានថា ហេតុនេះ ក្រុមដែលមានស្ថិរភាព និងអចិន្ត្រៃយ៍ គឺជាក្រុមដែលត្រូវការពារនោះទេ។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦២។

[132] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៥៥-៥៥៦។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៧០ ទោះបីជាថា អង្គជំនុំជម្រះសាលាដំបូងទាំងឡាយនៅតុលាការ ICTR ម្តងម្កាលបានព្យាយាមកំណត់និយមន័យអំពីក្រុមត្រូវការពារទាំងបួន *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥១២-៥១៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ៩៨។

[133] ទោះបីជាថា *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩ កថាខណ្ឌ ៧០ មានការប្រកាន់យកលក្ខខណ្ឌដែលមើលទៅបង្ហាញឲ្យឃើញថាមានលក្ខណៈអត្តនោម័តទាំងស្រុងក៏ដោយ។

[134] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃ

គោលដៅណាមួយអាចមិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ទេ ហើយអាចត្រូវចារីធ្វើការកំណត់ចរិតលក្ខណៈក្នុងរបៀបផ្សេងខុសពីការយល់ឃើញដែលគេទទួលស្គាល់រួមគ្នាជាទូទៅអំពីក្រុមគោលដៅនោះ ឬក៏ខុសពីការយល់ឃើញរបស់មនុស្សទាំងឡាយនៅក្នុងសង្គម[135] ទើបគួរតែពិចារណាផងដែរទៅលើការយល់ឃើញអត្តនោម័តរបស់ជនរងគ្រោះ និងចារី អំពី សមាជិកភាពរបស់ជនរងគ្រោះនៅក្នុងក្រុមគោលដៅនោះ[136]។

67. ក្រុមដែលត្រូវបានចាត់ទុកជាគោលដៅមានអត្តសញ្ញាណវិជ្ជមានជាក់លាក់ ហើយហេតុនេះមិនអាចត្រូវបានកំណត់បែបអវិជ្ជមានបានឡើយ[137]។ ប្រសិនបើមានក្រុមលើសពីមួយត្រូវបានកំណត់ជាគោលដៅដើម្បីបំផ្លិចបំផ្លាញ ត្រូវតែបំពេញទៅតាមធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ពាក់ព័ន្ធនឹងក្រុមនីមួយៗ[138]។

*ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក*

68. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ចែងអំពីអំពើប្រល័យពូជសាសន៍ ដែលធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តត្រូវតែធ្វើការបញ្ជាក់ (បន្ថែមពីលើចេតនាជាក់លាក់ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍[139] ដូចមានបង្ហាញជូនខាងក្រោម)។ អំពើប្រល័យពូជសាសន៍ខាងក្រោមនេះគឺមានភាព

---

តុលាការ ICTR (ICTR-96-3-T) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៦-៥៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៥៧។

[135] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៧០។

[136] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៥៧។

[137] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។

[138] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។

[139] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤កថាខណ្ឌ ២០។

ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤/២៖ (១) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (២) ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម និង (៣) ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលរៀបចំឡើងសម្រាប់បំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក។

69. ធាតុផ្សំនៃ**ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម** គឺស្មើគ្នានឹងធាតុផ្សំនៃការធ្វើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[140]។ ការស្លាប់ជនរងគ្រោះអាចបញ្ជាក់បានតាមរយៈភ័ស្តុតាងតាមកា

---

[140] *សូមមើលខាងលើ* កថាខណ្ឌ ៥១។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨១០, ៧៨៧-៧៨៨។ ក្នុងសាលក្រមនេះ នៅក្នុងការយល់ឃើញរបស់ខ្លួនដែលថា ធាតុផ្សំនៃការសម្លាប់សមាជិកក្រុមគឺស្មើនឹងធាតុផ្សំនៃការធ្វើមនុស្សឃាត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ធាតុផ្សំនៃការធ្វើមនុស្សឃាត ដែលជាការរំលោភលើច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម (តាមត្រាម ៣ នៃលក្ខន្តិកៈ ICTY) និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាធាតុផ្សំដូចគ្នា។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤២។ ពាក្យថា "ការសម្លាប់"ត្រូវបានបកស្រាយថាជាការសម្លាប់ដោយចេតនា (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Kayishema *និង* Ruzindana សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ១០៣) មនុស្សឃាតដែលបានប្រព្រឹត្តឡើងដោយមានចេតនាបណ្តាលឱ្យស្លាប់ (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Seromba សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-2001-66-I) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Musema សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៥៥) និងការធ្វើមនុស្សឃាត (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨១០, ៧៨៧-៧៨៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤២)។ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ នៅផ្នែកកំណត់សម្គាល់ ២៩១៨ អង្គជំនុំជម្រះសាលាដំបូង បានឯកភាពយោងលើ*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៩ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-2001-66-I) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣១៧ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Musema សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៥៥ ដែលបង្ហាញពីធាតុផ្សំស្មើគ្នាទោះបីជារបៀបហៅខុសគ្នាក៏ដោយ។ ចំពោះធាតុផ្សំអត្តនោម័ត សំណៅជាភាសាអង់គ្លេសនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ហាមឃាត់មិនឱ្យមាន"ការសម្លាប់" ដែលពាក្យនេះមានលក្ខណៈអព្យាក្រឹត្យចំពោះចេតនានៃការប្រព្រឹត្តិ ចំណែកឯ សំណៅជាភាសាបារាំងវិញ ហាមឃាត់មិនឱ្យមាន"*ការសម្លាប់ដោយចេតនា-*

លៈទេសៈ ដរាបណាមានតែសេចក្ដីសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចទាញចេញបានពីភ័ស្តុតាងបែបនោះ គឺសេចក្ដីសន្និដ្ឋានដែលថា ជនរងគ្រោះបានស្លាប់ហើយ[141] ហេតុនេះ តម្រូវឱ្យមានភ័ស្តុតាងបញ្ជាក់ពីលទ្ធផល (ទោះបីជាតាមរយៈសេចក្ដីសន្និដ្ឋានក៏ដោយ)[142]។ មិនមាន

---

*meurtre*" ដែលមានន័យថាការធ្វើមនុស្សឃាតដោយចេតនា។ អង្គជំនុំជម្រះនៅតុលាការ ICTR បានប្រកាន់យកការបកស្រាយដែលល្អបំផុតសម្រាប់ជនជាប់ចោទ គឺ *"ការ សម្លាប់ដោយចេតនា-meurtre"* ហេតុនេះត្រូវមានចេតនាសម្លាប់ ឬបណ្ដាលឱ្យស្លាប់ ប៉ុន្តែពុំមានការគិតទុកជាមុនទេ (*សូមមើល រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥០០-៥០១។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំ ជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣កថាខណ្ឌ ៣១៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-95-1-A) ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៥១)។ អង្គជំនុំជម្រះនៅ ICTY បានប្រកាន់យកគោលជំហរស្មើភាពគ្នា ដោយឱ្យ "ការសម្លាប់" ស្មើនឹង"ការធ្វើមនុស្សឃាត" ហើយតាមរយៈការសម្រេចបែបនេះ បានឯកភាពតាមវិធីសាស្ត្ររបស់តុលាការ ICTR (*សូមមើល រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤២ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨១០ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-10-T) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៣ និង*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦៤២)។ ក្នុងករណីណាក៏ដោយ ក៏មានការសេចក្ដីអង្កេតថា នៅក្នុងបរិបទនៃចេតនាប្រល័យពូជសាសន៍ *"ស្ទើរតែគ្មានភាពខុសគ្នា"*រវាងការសម្លាប់ ជាមួយនឹងការសម្លាប់ដោយចេតនាឡើយ (*សូមមើល រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-95-1-A) ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៥១)។

[141] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៧៨៩, ៨១០។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៤៤៦,៥៤២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ២៦០។

[142] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤២។

លក្ខខណ្ឌតម្រូវត្រូវធ្វើការវាយតម្លៃអំពីចំនួនមនុស្សដែលត្រូវបានសម្លាប់ដើម្បីបញ្ជាក់ពី*អំពើពិរុទ្ធ*ទេ[143]។

*ចេតនាអំពើប្រល័យពូជសាសន៍*

70. ក្រៅពីត្រូវមានលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័ត*ទាក់ទិននឹងអំពើពាក់ព័ន្ធដូចបានបង្ហាញខាងលើនេះ ចារីត្រូវមានចេតនាជាក់លាក់ដើម្បីបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារដោយមានចេតនាបែបនោះ[144]។

71. "***ដើម្បីបំផ្លិចបំផ្លាញ***"- អំពើប្រល័យពូជសាសន៍ រួមមានតែអំពើដែលបានប្រព្រឹត្តឡើងដើម្បីបំផ្លិចបំផ្លិចផ្នែកជីវសាស្ត្រ ឬរូបរាងកាយទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ[145]។ ហេតុនេះ អំពើដែលគ្រាន់តែវាយប្រហារលើលក្ខណៈសង្គម ឬវប្បធម៌របស់ក្រុមត្រូវការពារ ដើម្បីកុំឱ្យក្រុមនោះមានអត្តសញ្ញាណផ្ទាល់ខ្លួន (ឧទាហរណ៍ ការបំផ្លាញអគារសាសនា ឬផ្ទះរបស់សមាជិកក្រុមនោះ) គឺមិនស្ថិតនៅក្នុងនិយមន័យអំពីអំពើប្រល័យពូជសាសន៍ទេ។ ប៉ុន្តែ អំពើបែបនេះអាចជាភស្តុតាងដែលអាចទាញសន្និដ្ឋានបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញផ្នែកជីវសាស្ត្រ និងរូបរាងកាយ[146]។

---

[143] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* វិធាន ៩៨ ស្ទួន សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-5/18-AR98bis.1) ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ២៣។

[144] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨០៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២០។

[145] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨២២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥៣។

[146] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨២២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង*

72. "***ទាំងស្រុង ឬមួយផ្នែក***" - ឃ្លានេះសំដៅលើចេតនាបំផ្លិចបំផ្លាញទាំងស្រុង *ឬមួយផ្នែក*មកលើក្រុមត្រូវការពារ៖ ការបំផ្លិចបំផ្លាញក្រុមមួយផ្នែក មិនចាំបាច់ទាល់តែមានចេតនាបំផ្លិចបំផ្លាញក្រុមទាំងស្រុងទេ[147]។ ដោយសារមិនមានសេចក្ដីណែនាំនៅក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ឬនៅក្នុងលក្ខន្តិកៈរបស់ខ្លួននោះ ទើបសាលាក្ដីមិនអចិន្ត្រៃយ៍ បានបង្កើតនិយមន័យថា ចេតនាបំផ្លិចបំផ្លាញក្រុមមួយផ្នែក គឺជាចេតនាបំផ្លិចបំផ្លាញក្រុមយ៉ាងហោចណាស់មួយផ្នែក "ធំ" ល្មមអាចមានផលប៉ះពាល់មកលើក្រុមទាំងមូល ដោយគិតពីបរិបទដែលអំពើដែលបានចោទនោះបានប្រព្រឹត្តឡើង[148]។

*Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥៣។

[147] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៨៣-៥៨៤។

[148] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Bagilishema សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦៤។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៩០។ ការអនុវត្តអនុសញ្ញាស្ដីអំពីការបង្ការ និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (រឿងក្ដី បូស្នៀ និង *Herzegovina តទល់នឹងស៊ែប៊ី និង Montenegro)*តុលាការ ICJ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ១៩៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៨-៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨៣១។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥៥។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៦។ ទោះបីជានៅក្នុង*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ត្រង់កថាខណ្ឌ ៩៧ ភាសាដែលបានប្រើប្រាស់គឺ *"ចំនួនមនុស្សយ៉ាងច្រើន"* ហើយនៅក្នុង*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Bagilishema សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ (ត្រង់កថាខណ្ឌ ៦៤) ដោយដកស្រង់*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ (ហើយត្រូវបានដកស្រង់វិញនៅក្នុង*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Semanza សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៦) យ៉ាងណាក៏ដោយ ក៏អង្គជំនុះជម្រះសាលាដំបូង ប្រើប្រាស់ពាក្យ"មួយផ្នែកធំ" ហេតុនេះច្បាស់លាស់គឺថា អង្គជំនុំជម្រះសាលាដំបូងរឿងក្ដី *Kayishema* មិនមានបំណងអនុវត្តបទដ្ឋានផ្សេងទេ *សូមមើល រឿងក្ដីរដ្ឋអាជ្ញា ត*

73. ក្រុមគោលដៅ អាចរួមមាន បុគ្គលិកយោធា ដរាបណាបុគ្គលិកយោធានោះត្រូវបានចាត់ទុកថាជាគោលដៅដោយសារពួកគេជាសមាជិកនៅក្នុងក្រុមត្រូវការពារ[149]។

74. “***ដោយមានចេតនាបែបនោះ***” - អំពើបទល្មើស ត្រូវតែបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញក្រុមគោលដៅ ដែលជាក្រុមមួយដាច់ដោយឡែក និងខុសគេរបស់បុគ្គលជាជនរងគ្រោះ៖ ជនរងគ្រោះចុងក្រោយបំផុតដោយសារឧក្រិដ្ឋកម្មនេះគឺជាក្រុម[150]។ ជាប់ពាក់ព័ន្ធគ្នានេះវិញដែរ បុគ្គលជាជនរងគ្រោះត្រូវតែជាគោលដៅ *ដោយសារថា* ពួកគេជាសមាជិកនៅក្នុងក្រុម (ប៉ុន្តែ មិនចាំបាច់ទាល់*តែ*ថា ពួកគេជាសមាជិកបែបនេះទេ) ហេតុនេះ ការគ្រាន់តែដឹងអំពីសមាជិកភាពបែបនេះតែមួយមុខនោះ គឺមិនគ្រប់គ្រាន់អាចបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញក្រុមបែបនេះបានទេ[151]។

*ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*

---

*ទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កំណត់សម្គាល់ ១៥ កថាខណ្ឌ ៩។

[149] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-33-A) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ២២៦។

[150] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨២១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦១។

[151] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Krstić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Niyitegeka* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-14-A) ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៥៣។

75. យោងតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក អ.វ.ត.ក មានយុត្តាធិការលើរឿងក្តីទាក់ទងនឹងការ បំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចំនួនបួនឆ្នាំ១៩៤៩ (“អនុសញ្ញាទីក្រុងហ្សឺណែវ ”)។

76. អនុសញ្ញាទីក្រុងហ្សឺណែវ ចែងអំពីលក្ខខណ្ឌដូចជា បទល្មើសដែលមានចែងនៅមាត្រា ៦ ត្រូវតែជាបទឧក្រិដ្ឋ[152]។ ប្រទេសកម្ពុជា បានធ្វើសច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ១៩៥៨ ហេតុនេះគឺជាភាគីមួយនៅក្នុងអនុសញ្ញានេះស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ជាងនេះទៀត ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរវាងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[153]។ ហេតុនេះ **មាស មុត** អាចប្រមើលមើល និងអាចដឹងថា មានការហាមឃាត់ និងការកាត់ទោសចំពោះឧក្រិដ្ឋកម្មដូចមានចែងនៅក្នុងមាត្រា ៦ រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[154]។

[152] អនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន សុទ្ធតែហាមឃាត់ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តិដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងការបំផ្លិចបំផ្លាញ ឬការធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដែលមិនមែនជាមូលហេតុចាំបាច់ផ្នែកយោធា ហើយបានប្រព្រឹត្តឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី (អនុសញ្ញាទីក្រុងហ្សឺណែវ I មាត្រា ៤៩-៥០, អនុសញ្ញាទីក្រុងហ្សឺណែវ II មាត្រា ៥០-៥១, អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ១២៩-១៣០, អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ១៤៦-១៤៧)។ អនុសញ្ញាទីក្រុងហ្សឺណែវ III (មាត្រា ១២៩-១៣០) ហាមឃាត់ការដកហូតដោយចេតនាពីឈ្លើយសឹកនូវសិទ្ធិទទួលបានការជំនុំក្តីជម្រះជាទូទៅ និងដោយយុត្តិធម៌។ អនុសញ្ញាទីក្រុងហ្សឺណែវ IV (មាត្រា ១៤៦-១៤៧) ហាមឃាត់ការដកហូតដោយចេតនាពីជនស៊ីវិលនូវ សិទ្ធិទទួលបានការជំនុំក្តីជម្រះជាទូទៅ និងដោយយុត្តិធម៌ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងការយកជនស៊ីវិលជាចំណាប់ខ្មាំង។

[153] **សំណុំរឿងលេខ ១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤០៥។ **សំណុំរឿងលេខ ២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៥៦-២៥៨។ **សំណុំរឿងលេខ ២-ឯកសារ D427/2/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១១៧-១១៨។ *សូមមើលផងដែរ* **សំណុំរឿងលេខ ១-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣១៦។

[154] **សំណុំរឿងលេខ ២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកា ដំណោះ ស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៥៦-២៥៧។ **សំណុំរឿងលេខ ២-ឯកសារ D427/2/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១១៩-១២១, ១២៣។ **សំណុំរឿងលេខ ១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤០៤-៤០៨។

77. មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា អ.វ.ត.ក មិនមានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឡើយ ពីព្រោះថា អាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មបែបនេះបានផុតរលុតហើយ[155]។ ទាំង អ.ជ.ស.ដ ទាំង អ.ប.ជ ធ្លាប់បានសម្រេចថា មិនមានអាជ្ញាយុកាលអនុវត្តលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឡើយ[156] ហេតុនេះហើយច្បាស់ណាស់គឺថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា ទីក្រុងហ្សឺណែវ យោងតាមមាត្រា ៦ មិនផុតរលុតអាជ្ញាយុកាលឡើយ។

*លក្ខខណ្ឌទូទៅនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*

78. ***អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ-*** មាត្រា ២ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ តម្រូវឲ្យមានអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលកើតមាននៅពេលណាដែលមានករណីត្រូវប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋ និងរដ្ឋ ដោយមិនគិតថា រដ្ឋនោះទទួលស្គាល់ថាមានសង្គ្រាមឬអត់នោះទេ[157]។

---

[155] ឯកសារ **D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១២៤-១២៨។ **ឯកសារ D174/1/1** *បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃ អនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ* ចុះថ្ងៃទី០៦ ខែ មករា ឆ្នាំ២០១៦ កថាខណ្ឌ ៨-៣០។

[156] **សំណុំរឿងលេខ ២-ឯកសារ** **E306/6** *សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩* ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៤ កថាខណ្ឌ ៨-១២។ **សំណុំរឿងលេខ ២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៧៣។

[157] មាត្រា ២ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១១-៤១៤។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៣៧៣។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Tadić* សាលដីកាលើញត្តិរបស់មេធាវីការពារក្តីសុំឲ្យបណ្តឹងសាទុក្ខបន្ទាន់លើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-AR72) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៨៤។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ១៨៣។ សូមមើលផងដែរ ICRC *មតិយោបល់ភ្ជាប់ជាមួយនឹងអនុសញ្ញាទីក្រុងហ្សឺណែវ IV* ទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៨ ទំព័រ ២០-២១ [ភាសាអង់គ្លេស]។

79. អនុសញ្ញាទីក្រុងហ្សឺណែវ អនុវត្តចាប់ពីពេលចាប់ផ្ដើមមានជម្លោះប្រដាប់អាវុធ និងក្រោយពេលបញ្ឈប់ជម្លោះនេះ រហូតទាល់តែមានសន្តិភាពជាទូទៅ ហើយអនុវត្តចំពោះដែនដីទាំងអស់របស់រដ្ឋនានាដែលជាភាគីនៅក្នុងជម្លោះនេះ ដោយមិនគិតថា មានចម្បាំងកើតឡើងនៅទីនោះឬអត់នោះទេ[158]។

80. ***ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទ ជាមួយនឹងជម្លោះប្រដាប់អាវុធ-*** ឧក្រិដ្ឋកម្មដែលបានចោទ ត្រូវតែមានភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងជម្លោះប្រដាប់អាវុធ ជារួម៖ មិនចាំបាច់ត្រូវបញ្ជាក់ថា មានចម្បាំងពិតប្រាកដកើតឡើងនៅក្នុងតំបន់ដែលឧក្រិដ្ឋកម្មត្រូវបានចោទថាបានប្រព្រឹត្តឡើងឡើយ។ ជម្លោះប្រដាប់អាវុធ មិនចាំបាច់ទាល់តែជាដើមហេតុនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទនោះទេ ប៉ុន្តែ ត្រូវដើរតួនាទីមួយយ៉ាងសំខាន់នៅក្នុងសេចក្ដីសម្រេច និងសមត្ថភាពរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ របៀបដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើង ឬគោលបំណងដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើង[159]។

81. **ឋានៈរបស់ជនរងគ្រោះជាជនត្រូវការពារ**-មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ផ្ដល់ជូន អ.វ.ត.ក នូវយុត្តាធិការលើអំពើទាំងឡាយដែលបានប្រព្រឹត្តមកលើជន ឬទ្រព្យសម្បត្តិដែលត្រូវការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ដែលតាមការពាក់ព័ន្ធជាមួយនឹងសំណុំរឿង ០០៣ គឺមានរហូតដល់ឈ្លើយ

---

[158] **សំណុំរឿងលេខ ១-ឯកសារ**-E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៥។ រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៣១៩-៣២១។ រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ១៨៣ *ដោយដកស្រង់ពី* រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Tadić* សាលដីកាលើញត្តិរបស់មេធាវីការពារក្ដីសុំឲ្យបណ្ដឹងសាទុក្ខបន្ទាន់លើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-AR72) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៧០។

[159] **សំណុំរឿងលេខ ១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៦។ រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Tadić* សាលដីកាលើញត្តិរបស់មេធាវីការពារក្ដីសុំឲ្យបណ្ដឹងសាទុក្ខបន្ទាន់លើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-AR72) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៧០។ រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Kunarac និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៥៧-៥៩។ រឿងក្ដី*រដ្ឋអាជ្ញាតទល់នឹង Duško Tadić* មតិយោបល់ និងសាលក្រម អង្គជំនុះជម្រះសាលាដំបូងនៃតុលាការ ICTY (IT-94-1-T) ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ ៥៧២-៥៧៣។

01600516



សឹក (ជាជនត្រូវការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ III) និងជនស៊ីវិល (ជាជនត្រូវការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ IV)[160]។

82. ឈ្លើយសឹក គឺជាជនដែលបាន"*ធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ខ្មាំងសត្រូវ*" ហើយ ជាសមាជិក នៃក្រុមជនមួយចំនួន រួមមានសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីនៅក្នុងជម្លោះ និងសមាជិក នៃកងជីវពល ឬកងទ័ពស្ម័គ្រចិត្តដែលជាផ្នែកមួយ នៃកងកម្លាំងប្រដាប់អាវុធបែបនោះ[161]។ ការការពារដែលឈ្លើយសឹកត្រូវទទួលបាន អនុវត្តចាប់ពីពេលដែលឈ្លើយសឹកបានធ្លាក់ចូលកណ្តាប់ដៃរបស់សត្រូវ រហូតដល់ពេលចុងក្រោយដែលឈ្លើយសឹកត្រូវបានដោះលែង និងធ្វើមាតុភូមិនិវត្ត[162]។

83. ចំពោះជនស៊ីវិល អនុសញ្ញាទីក្រុងហ្សឺណែវ IV ការពារ"*ជនទាំងឡាយណា ក្នុងពេលណាមួយ និងក្នុងរបៀបណាមួយក៏ដោយក្នុងករណីមានជម្លោះ ឬការកាន់កាប់ ដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះ ឬដែលកាន់កាប់អំណាចដែលពួកគេមិនមែនជាប្រជាជាតិដូចគ្នា*"[163]។

84. ***ការដឹងរបស់ជនជាប់ចោទ-*** ជនជាប់ចោទត្រូវតែបានដឹងគ្រប់គ្រាន់អំពីអង្គហេតុដែលបញ្ជាក់ពីលក្ខណៈអន្តរជាតិនៃជម្លោះប្រដាប់អាវុធ ហើយត្រូវតែបានដឹងឲ្យបានគ្រប់គ្រាន់អំពីឋានៈរបស់ជនរងគ្រោះដែលត្រូវការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ[164]។

*ធាតុផ្សំនៃឧក្រិដ្ឋកម្មដែលបង្កើតបានជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*

---

[160] ត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤, ១២៨-១៣០ និង អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៤, ១៤៦-១៤៧។ **សំណុំរឿងលេខ ១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៧។

[161] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤(ក)(១)(ប្រភេទជនផ្សេងទៀតទាំងអស់ដែលត្រូវចាត់ទុកថាជាឈ្លើយសឹក ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤ គឺមិនពាក់ព័ន្ធនឹងបទចោទនៅក្នុងសំណុំរឿង ០០៣ ទេ។ **សំណុំរឿងលេខ ១-ឯកសារ**-E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៨ ។

[162] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៥។

[163] អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៤។ សូមមើលផងដែរ **សំណុំរឿងលេខ ១-ឯកសារ**-E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤១៨ ។

[164] **សំណុំរឿងលេខ ១-ឯកសារ**-E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤២១-៤២២។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Naletilic និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-34-A) ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ ១១៣-១២១។ *សូមមើលផងដែរ* រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៣១១។

85. ខាងក្រោមនេះគឺជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[165]។

86. ធាតុផ្សំនៃ**ការធ្វើមនុស្សឃាតដោយចេតនា** គឺដូចគ្នានឹងធាតុផ្សំនៃការធ្វើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[166]។

87. ធាតុផ្សំនៃ**ការធ្វើទារុណកម្ម** គឺដូចគ្នានឹងធាតុផ្សំនៃការធ្វើទារុណកម្ម ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[167]។

88. ធាតុផ្សំនៃ**ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព** គឺ

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មដែលបង្កឱ្យមានការឈឺចាប់ ឬរងរបួសផ្នែកស្មារតី ឬរាយកាយយ៉ាងធ្ងន់ធ្ងរ លុះត្រាតែមានភ័ស្តុតាងបញ្ជាក់អំពីកម្រិតនៃការឈឺចាប់ ឬការរងរបួស។ ព្យសនកម្មដែលបានបង្កឡើងនេះមិនចាំបាច់ទាល់តែមិនអាចព្យាបាលបាន ឬក៏អចិន្ត្រៃយ៍ឡើយ។ ព្យសនកម្មនេះត្រូវតែជាព្យសនកម្មដែលបណ្តាលឱ្យមានផលវិបាករយៈពេលយូរ និងធ្ងន់ធ្ងរដល់លទ្ធភាពរបស់មនុស្សក្នុងជីវភាពធម្មតា។ អំពើសកម្ម ឬអកម្មដែលបង្កឱ្យមានព្យសនកម្មពាក់ព័ន្ធតែនឹងសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ របស់ជនរងគ្រោះមិនរាប់បញ្ចូលនៅក្នុងឧក្រិដ្ឋកម្មនេះឡើយ[168]។

---

165 ច្បាប់ អ.វ.ត.ក មាត្រា ៦។

166 *សូមមើលខាងលើ* កថាខណ្ឌ ៥១។ **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៣១។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៣៨០។

167 *សូមមើលខាងលើ* កថាខណ្ឌ ៥៥។ **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៣៩។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៤៨២។

168 **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៥១-៤៥៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែ

ខ. *ធាតុផ្សំអត្តនោម័តៈ* ចេតនាបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ឬការធ្វេសប្រហែស ដោយមិនគិតថា ការឈឺចាប់ ឬរបួស នោះនឹងបង្កឱ្យមានឬអត់នោះទេ[169]។

គ. បទល្មើសនេះខុសគ្នាពីការធ្វើទារុណកម្ម ដោយសារថា អំពើសកម្ម ឬអកម្មដែលត្រូវបានចោទ មិនចាំបាច់ទាល់តែបានប្រព្រឹត្តឡើងដើម្បីគោលបំណងជាក់លាក់ណាមួយនោះទេ[170]។

89. ធាតុផ្សំនៃ**ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់** គឺដូចគ្នានឹងធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំង ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ លើកលែងតែលក្ខណៈធាតុផ្សំខុសគ្នាដូចខាងក្រោមនេះ[171]៖

ក. ការឃុំខ្លួនជនស៊ីវិលក្នុងពេលមានជម្លោះប្រដាប់អាវុធ អាចអនុញ្ញាតបានតែក្នុងករណីដែលមានមូលហេតុសមស្របជឿថា ការឃុំខ្លួននេះគឺជាការ"*ចាំបាច់ដាច់ខាត*" ដោយសារសន្តិសុខរបស់រដ្ឋស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។ ការឃុំខ្លួនដោយស្របច្បាប់នៅពេលដំបូងអាចក្លាយទៅជាការឃុំខ្លួនខុសច្បាប់ ប្រសិនបើភាគីដែលមានសិទ្ធិឃុំខ្លួន មិនបានគោរព

---

កុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤២៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥១១។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៤៥។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះ សាលាដំបូងនៃតុលាការ ICTY (IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥១១-៥១៣។

[169] **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៥៥។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Blaškić* សាលក្រម អង្គជំនុះជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-14-T) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១៥២។

[170] **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៥៣។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-21-T) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥០៨, ៥១១។

[171] *សូមមើលខាងលើ* កថាខណ្ឌ ៥៤។ **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៦៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY (IT-95-14/2-T) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៩២, ៣០១។

សិទ្ធិជាមូលដ្ឋានតាមនីតិវិធីរបស់អ្នកជាប់ឃុំ ឬបង្កើតតុលាការ ឬក្រុមប្រឹក្សាគ្រប់គ្រងសមស្រប ដូចមានចែងក្នុងមាត្រា ៤២ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV[172]។

ខ. មិនដូចការដាក់ក្នុងមន្ទីរឃុំឃាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ការឃុំខ្លួនដោយខុសច្បាប់ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក មិនចាំបាច់ទាល់តែមានស្ថានទម្ងន់និងធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឡើយ។

៣.២.២ ឧក្រិដ្ឋកម្មជាតិ

90. មាត្រា ៣ ថ្មីនៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឲ្យ ស.ច.ស លើឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត[173] ជាការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលជាក្រមព្រហ្មទណ្ឌអាចយកមកអនុវត្តបាននៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩[174]។

91. នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ស.ព.អ លើកឡើងថា គាត់មិនស្វែងរកការជំនុំជម្រះ **មាស មុត** ចំពោះឧក្រិដ្ឋកម្មជាតិនោះទេ ដោយផ្អែកលើមូលដ្ឋានថា ការប្រព្រឹត្តិរបស់ **មាស មុត** ត្រូវបានពិពណ៌នាល្អជាងពេលកំណត់ប្រភេទតាមផ្លូវច្បាប់ជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អន្តរជាតិ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថា ការមិនចោទប្រកាន់ឧក្រិដ្ឋកម្មជាតិនឹងបញ្ចៀសការជំទាស់តវ៉ាដែលមិនចាំបាច់ ហេតុនេះ ជាការពន្លឿនកិច្ចដំណើរការនីតិវិធី[175]។ មេធាវីការពារក្តី គាំទ្រឲ្យលើកលែងបទចោទអំពីឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋានថា មេធាវីការពារក្តី ជឿថា ឧក្រិដ្ឋកម្មបែបនេះលែងមានអាជ្ញាយុកាលហើយ ដោយដកស្រង់មតិយោបល់ពីមុនរបស់ចៅក្រមជាតិនៅ

---

[172] អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៥, ៤២-៤៣។ **សំណុំរឿងលេខ ១-ឯកសារ-E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៦៥។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kordić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៦៩-៧៣។ រឿងក្តី *រដ្ឋអាជ្ញា តទល់ នឹង Delalić និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៣២០-៣២២។

[173] មាត្រា ៥០១ មាត្រា ៥០៣ មាត្រា ៥០៤ មាត្រា ៥០៥ មាត្រា ៥០៦ មាត្រា ៥០៧ និងមាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[174] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

[175] ឯកសារ **D256/7** *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ១០៦១។

អង្គជំនុំជម្រះសាលាដំបូង អំពីបញ្ហានេះ[176]។ យើង Michael Bohlander មិនយល់ឃើញថា ចាំបាច់ ឬក៏គួរតែលើកលែងបទចោទអំពីឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋានបែបនោះឡើយ។ ទីមួយ ប្រសិនបើលើកលែងបទចោទបែបនោះមែន នោះពេលវេលាដែលអាចចំណេញបានគឺមាន ចំនួនតិចតួចបំផុត ដោយពិនិត្យឃើញថា អង្គហេតុ និងភ័ស្តុតាងដែលត្រូវការដើម្បីបញ្ជាក់ពីឧក្រិដ្ឋ កម្មអន្តរជាតិ ត្រួតដូចគ្នាយ៉ាងច្រើនបើទោះជាមិនបានទាំងស្រុងក៏ដោយ ជាមួយនឹងអង្គហេតុ និងភ័ ស្តុតាងដែលត្រូវការដើម្បីបញ្ជាក់ពីឧក្រិដ្ឋកម្មជាតិ។ ទីពីរ បញ្ហាអាជ្ញាយុកាល ត្រូវបាន អ.ប.ជ ដោះស្រាយយ៉ាងច្បាស់ និងដោយឯកច្ឆន្ទរួចហើយ ហេតុនេះ ច្បាស់លាស់គឺថា ឧក្រិដ្ឋកម្មជាតិ ដែលជាបទចោទលើ **មាស មុត** មិនបានផុតរលត់អាជ្ញាយុកាលទេ[177]។

*មនុស្សឃាត*

92. ឧក្រិដ្ឋកម្មមនុស្សឃាតក្នុងច្បាប់ជាតិមានពីរទម្រង់ យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មួយ ទម្រង់ គឺ មនុស្សឃាតគិតទុកជាមុន[178] ដែលទាមទារនូវធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវជាអ្នកដែលបណ្តាលឲ្យបុគ្គលម្នាក់ទៀតស្លាប់[179]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានធ្វើសកម្មភាព"*ដោយគិតទុកជាមុន*" និង "*មានចេតនា បណ្តាលឲ្យស្លាប់*"[180]។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថាជា "*ការតាំងចិត្តជា ស្រេចថានឹងប្រព្រឹត្តនូវអំពើណាមួយមុនពេលដែលប្រព្រឹត្តនូវអំពើនោះ គឺថា ពេលសម្រេច*

---

[176] **សំណុំរឿងលេខ ០០៤/២-ឯកសារ D351/6** *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជ អាជ្ញា អន្តរជាតិ អនុលោមតាមវិធាន ៦៦* ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៥១ ដោយដកស្រង់មតិយោបល់របស់ ចៅក្រម Cartwright និងចៅក្រម Lavergne នៅក្នុង**សំណុំរឿងលេខ ១-ឯកសារ E187** *សេចក្តីសម្រេចស្តីពីអញ្ញត្រ កម្មទាក់ទងនឹង ចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៧-៣៥, ៣៩-៥៥។

[177] **សំណុំរឿងលេខ ០០៤-ឯកសារ D258/1** *ដីកាសម្រេចលើពាក្យសុំតាមវិធានផ្ទៃក្នុង ៧៦ របស់ អោ អាន សុំ មោឃភាព បទ ចោទប្រកាន់អំពីមនុស្សឃាតដោយចេតនា និងកិច្ចស៊ើបសួរពាក់ព័ន្ធនានា* ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ១១-១២។

[178] មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤ កថាខណ្ឌ ៧៦។

[179] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤។

[180] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៦។

*ចិត្ត និងពេលដែលប្រព្រឹត្តមានចន្លោះឃ្លាតពីគ្នាល្មមឲ្យចារីរៀបចំដំណើរការនោះបាន*"[181] ។

93. អ.ប.ជ បានសម្រេចថា មនុស្សឃាតគិតទុកជាមុន មិនមានបញ្ចូលនៅក្នុងបទមនុស្សឃាតក្រោមច្បាប់អន្តរជាតិ ពីព្រោះថា មនុស្សឃាតគិតទុកជាមុន ទាមទារធាតុផ្សំនៃការគិតទុកជាមុន និង*ធាតុផ្សំអត្តនោម័ត*ខ្ពស់ជាង ពោលគឺ ចេតនាសម្លាប់ មិនមែនត្រឹមតែមានចេតនាធ្វើឲ្យមានការខូចខាតធ្ងន់ធ្ងរលើរូបរាងកាយទេ[182]។

## ៣.៣ ទម្រង់នៃការទទួលខុសត្រូវ

### ៣.៣.១ ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

94. អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក បុគ្គលម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈទម្រង់នៃការទទួលខុសត្រូវតាមរយៈការប្រព្រឹត្ត (រួមទាំងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ការរៀបចំផែនការ ការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ គឺសុទ្ធតែជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលដែលស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[183]។

95. ***ការប្រព្រឹត្ត៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ រួមមានការប្រព្រឹត្តផ្ទាល់ ឬអំពើអកម្មដែលមានពិរុទ្ធនៃអំពើសកម្មមួយ[184]។ ចារីត្រូវតែបានប្រព្រឹត្តអំពើដោយមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មនឹងកើតមានឡើងដោយសារតែអំពើដែលត្រូវបាន

---

[181] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៨។

[182] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៨៤។

[183] <u>ការប្រព្រឹត្ត៖</u> **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៧៨-៤៧៩។ <u>ការរៀបចំផែនការ៖</u> **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៧។ <u>ការបញ្ជា៖</u> **សំណុំរឿង ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០១។ <u>ការទទួលខុសត្រូវរបស់ថ្នាក់លើ៖</u> **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៤។

[184] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៧៩។

ចោទប្រកាន់នោះ[185]។ ការប្រព្រឹត្តិក៏រួមមានការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម[186] ដែលនឹងត្រូវពិភាក្សាបន្ថែមនៅផ្នែកខាងក្រោម។

96. ***ការរៀបចំផែនការ៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ កើតឡើងនៅពេលដែលមនុស្សម្នាក់ ឬច្រើននាក់រៀបចំអំពើព្រហ្មទណ្ឌ ដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងនៅពេលបន្ទាប់[187]។ ការរៀបចំផែនការចាំបាច់ត្រូវតែកើតឡើងមុន និងចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[188]។ ចារីចាំបាច់ត្រូវតែមានចេតនាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មនឹងត្រូវកើតឡើងនៅពេលបំពេញ ឬអនុវត្តផែនការ[189]។

97. ***ការបញ្ជា៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ នៅក្នុងតួនាទីមាន*សិទ្ធិអំណាចជាក់ស្តែង* ឬ*តាមផ្លូវច្បាប់* បង្គាប់មនុស្សផ្សេងទៀតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[190]។ មិនតម្រូវឲ្យមានទំនាក់ទំនងថ្នាក់លើថ្នាក់ក្រោមផ្លូវការណាមួយឡើយរវាងអ្នកចេញបង្គាប់ និងអ្នកទទួលបង្គាប់[191]។ ការបង្គាប់បញ្ជានេះ ដែលមិនតម្រូវថាត្រូវតែមានក្នុងទម្រង់ណាមួយនោះទេ ចាំបាច់ត្រូវតែរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[192]។ ការទទួលខុសត្រូវលើការ

---

[185] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៨១។

[186] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៧៩។

[187] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Kordić *និង* *Čerkez* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៦។

[188] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។

[189] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥១៩។

[190] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥២៧។

[191] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥២៧។

[192] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

បញ្ជាអាចកើតឡើងផងដែរនៅពេលដែលបុគ្គលម្នាក់បានប្រគល់បញ្ជា ឬផ្ទេរបញ្ជា រួមមានតាមរយៈអន្តរការី[193]។ អ្នកចេញបញ្ជាចាំបាច់ត្រូវតែមានចេតនាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្តដោយសារការធ្វើតាមបញ្ជា ឬអនុវត្តតាមបញ្ជា[194]។

98. ***ការទទួលខុសត្រូវរបស់ថ្នាក់លើ៖*** ការទទួលខុសត្រូវរបស់ថ្នាក់លើ (បញ្ជា) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈអំពើអកម្មដែលមានពិរុទ្ធភាព ហើយតាមរយៈអំពើនេះ ថ្នាក់លើស៊ីវិល ឬយោធា អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមិនបានរារាំង និង/ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មដែលអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត។

99. លក្ខខណ្ឌតម្រូវទីមួយគឺអត្ថិភាពនៃទំនាក់ទំនងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់[195] ដែលអាចជាលក្ខណៈជាក់ស្តែង ឬផ្លូវច្បាប់[196]។ បន្ថែមលើនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្ត ចំពោះថ្នាក់លើទាំងស៊ីវិល ទាំងយោធា[197]។ ថ្នាក់លើទោះបីជាស៊ីវិល ឬយោធា ចាំបាច់ត្រូវតែមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដែលជាសមត្ថភាពជាក់ស្តែងដើម្បីរារាំង និង/ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មរបស់ចារីជាអ្នកនៅក្រោមបង្គាប់[198]។ ចុងក្រោយ ថ្នាក់លើចាំបាច់ត្រូវតែមិនបាន

---

[193] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[194] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៨។

[195] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥៣៨។

[196] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥៤០។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត (“រឿងក្តី Čelebići”)* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១៩១-១៩២ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-88-T) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១០៣៨។

[197] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៤។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៧៦-៤៧៧។

[198] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥៤០ ដល់ ៥៤២។

ចាត់វិធានការដែលចាំបាច់ និងសមហេតុផលដើម្បីរារាំងការប្រព្រឹត្តិឧក្រិដ្ឋកម្មបែបនេះ ឬដាក់ទណ្ឌកម្មចារី[199]។ យោងតាមយុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ គឺមិនចាំបាច់ត្រូវបង្ហាញភ័ស្តុតាងបញ្ជាក់ពីទំនាក់ទំនងហេតុនិងផលរវាងការដែលថ្នាក់លើមិនបានរារាំងឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ ជាមួយនឹងការកើតឡើងនូវឧក្រិដ្ឋកម្មទាំងអស់នេះទេ[200]។

100. បន្ថែមលើនេះ ដើម្បីទទួលខុសត្រូវព្រហ្មទណ្ឌ ថ្នាក់លើចាំបាច់ត្រូវតែបានដឹង ឬមានហេតុផលត្រូវដឹងថា ឧក្រិដ្ឋកម្មមួយរៀបនឹងកើតឡើង ឬបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់ម្នាក់ ឬក៏ច្រើននាក់ ពោលគឺការដឹងតាមរយៈការមានព័ត៌មានដែលសមល្មមនឹងធ្វើឲ្យជ្រួតជ្រាបសម្រាប់ជាយុត្តិកម្មឲ្យសួរដេញដោលបន្ថែមទៀត[201]។ ថ្នាក់លើមិនចាំបាច់ត្រូវដឹងអត្តសញ្ញាណច្បាស់លាស់របស់ចារីជាអ្នកនៅក្រោមបង្គាប់ទេ ប៉ុន្តែ អត្ថិភាពនៃអត្តសញ្ញាណនេះត្រូវតែមានការបញ្ជាក់[202]។

101. ការមិនបានរារាំង និងការមិនបានដាក់ទណ្ឌកម្ម គឺជាទម្រង់នៃការទទួលខុសត្រូវដាច់ពីគ្នាទាំងអង្គហេតុ ទាំងអង្គច្បាប់ ដែលមានកាតព្វកិច្ចផ្លូវច្បាប់ពីរខុសដាច់ពីគ្នា។ ថ្នាក់លើអាចត្រូវទទួលខុសត្រូវចំពោះការមិនបានអនុវត្តចំណុចទាំងពីរ[203]។

102. ថ្នាក់លើអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោមដែលមិនបានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួនជាផ្លូវការទេ ដរាបណា លក្ខខណ្ឌតម្រូវផ្សេងទៀតនៃការទទួលខុសត្រូវថ្នាក់លើត្រូវបានបំពេញ[204]។

---

[199] **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៦។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។

[200] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Hadžihasanović និង Kubura* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-01-47-A) ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ ៤០។

[201] **សំណុំរឿងលេខ ០០២-ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥៤៣ ដល់ ៥៤៤។

[202] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-02-60-A) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ២៨៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Orić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-03-68-A) ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

[203] **សំណុំរឿងលេខ ០០១-ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-01-47-A) ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ ២៥៩-២៦០។

103. មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនអាចយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ទេ[205]។ ប៉ុន្តែ មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងយ៉ាងច្បាស់ថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[206] ហើយវាបានក្លាយជាមូលដ្ឋាននៃការសម្រេចផ្តន្ទាទោសជាច្រើនចំពោះឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍នៅសាលាក្តីមិនអចិន្ត្រៃយ៍[207]។ ធាតុផ្សំអត្តនោម័តដែលតម្រូវឱ្យថ្នាក់លើ ទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ គឺថ្នាក់លើបានដឹង ឬមានហេតុផលត្រូវដឹងថា ថ្នាក់ក្រោមរបស់ខ្លួន (១) ហៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និង (២) មានចេតនាច្បាស់លាស់តាមលក្ខខណ្ឌតម្រូវនេះ[208]។

---

[204] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧២១។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤២ ដកស្រង់*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៧ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត (“រឿងក្តី* Čelebići*”)* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៥២។

[205] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១១៦, ១១៨។ ១២៨។ ឯកសារ **D174/1/1** *បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ* ចុះថ្ងៃទី០៦ ខែ មករា ឆ្នាំ២០១៦ កថាខណ្ឌ ៧៧-៨០។

[206] មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងថា “[...] *ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ[...]*”។

[207] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Blagojević & Jokić *សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦៨២, ៦៨៦។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Brđanin អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៧១៥-៧២១។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Ruzindana *និង* Kayishema *សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៥៥, ៥៥៩, ៥៦៣។

[208] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Blagojević & Jokić *សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦៨២, ៦៨៦។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Brđanin អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36-T) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៧១៥-៧២១។

104. មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថែមទៀតថា ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចយកមកអនុវត្តបានតែក្នុងករណីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ[209]។ យើង Michael Bohlander យល់ឃើញថា នៅ អ.វ.ត.ក វាជាអង្គច្បាប់ដែលបានដោះស្រាយរួចហើយ ដែលថា នៅមុនឆ្នាំ១៩៧៥ ទ្រឹស្តីទទួលខុសត្រូវរបស់ថ្នាក់លើនេះអាចអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធទាំងអន្តរជាតិ ទាំងមិនមែនអន្តរជាតិ ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ[210] ហើយយើង Michael Bohlander ប្រើប្រាស់ជាមូលដ្ឋាន និងយោងលើគោលជំហរជាបន្តបន្ទាប់ដែលអនុវត្តនៅ អ.វ.ត.ក ចំពោះទ្រឹស្តីនេះ គឺថា ការទទួលខុសត្រូវរបស់ថ្នាក់លើមានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិរួចហើយនៅត្រឹមឆ្នាំ១៩៧៥ ដោយមិនគិតពីបរិបទអ្វីឡើយ[211] ។

---

[209] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១១៧-១១៨។ **D145** *ញត្តិរបស់ មាស មុតណាប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលមិនពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ* ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥។

[210] **ឯកសារ D145/3** *ដីកាសម្រេចលើការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្រៅជម្លោះប្រដាប់អាវុធអន្តរជាតិ* ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ៣៣។

[211] នៅក្នុងសំណុំរឿង ០០២ មិនមានការបែងចែកឲ្យខុសគ្នារវាងជម្លោះប្រដាប់អាវុធអន្តរជាតិ ជាមួយនឹងជម្លោះប្រដាប់មិនមែនអន្តរជាតិទេពាក់ព័ន្ធនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងដីកាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះរបស់ ស.ច.ស (**សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣០៧, ១៣១៩, ១៥៥៨-១៥៦២) តាមរយៈសាលដីការបស់ អ.ប.ជ នៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ (**សំណុំរឿងលេខ ០០២-ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៩០-២៣២។ **សំណុំរឿងលេខ ២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤១៣-៤៦០)។ ក៏មិនមានការបែងចែកបែបនេះដែរតាមរយៈសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (**សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧១៤-៧១៩) និងតាមរយៈសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីសំណុំរឿង ០០២/២ (**សំណុំរឿងលេខ ០០២-ឯកសារ E457/6/3/1** *សារណាបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១២១៣, **សំណុំរឿងលេខ ០០២-ឯកសារ E457/6/1/1** *សេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី០២ ខែ តុលា ឆ្នាំ២០១៧ កថាខណ្ឌ ២៤៦-២៥៥, **សំណុំរឿងលេខ ០០២-ឯកសារ E457/6/2/3** *សារណាបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី០២ ខែ តុលា ឆ្នាំ២០១៧, **សំណុំរឿងលេខ ០០២-ឯកសារ E457/6/4/1.2**, *Conclusions Finales Amendées de Khieu Samphan (002/02)* ចុះថ្ងៃទី០២ ខែ តុលា ឆ្នាំ២០១៧ កថាខណ្ឌ ២៤៦៩-២៤៧០)។

105. ***សហឧក្រិដ្ឋកម្មរួម៖*** ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មានន័យស្មើនឹងការប្រព្រឹត្តិ អនុលោមតាម មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[212]។ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃសហចារីដែលមនុស្សជាច្រើន នាក់មានគោលបំណង ឬគោលដៅរួមគ្នាដែលស្មើនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន ឬពាក់ព័ន្ធ នឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន[213]។

106. តុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានាបានកំណត់ទម្រង់ចំនួនបីនៃសហឧក្រិដ្ឋកម្មរួម[214]។ ផ្ទុយពីអ្វីដែលមេធាវីការពារក្តី បានអះអាង[215] ទម្រង់ទីមួយ និងទីពីរនៃសហឧក្រិដ្ឋកម្មរួម មាន អត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយអាចអនុវត្ត បាននៅ អ.វ.ត.ក[216]។ ទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួម ដែលជាគោលការណ៍ មានធាតុផ្សំដូចគ្នា ជាមួយនឹងទម្រង់ទីមួយ មិនបានដាក់ជាបទចោទលើ **មាស មុត** ឡើយ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋ កម្មរួម មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលវេលានោះឡើយ ដូច្នេះ ទម្រង់នេះមិនអាចអនុវត្តបានទេនៅ អ.វ.ត.ក[217]។ ហេតុដូច្នេះ មានតែធាតុផ្សំនៃទម្រង់ទី មួយនៃសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះដែលនឹងត្រូវសង្ខេបនៅក្នុងផ្នែកនេះ។

---

[212] **សំណុំរឿងលេខ ០០២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាន នូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ២២។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩០។

[213] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩២។

[214] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩៦-២០៤។

[215] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១១៩-១២០។

[216] **សំណុំរឿងលេខ ០០២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩១។ **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៩១។

[217] **សំណុំរឿងលេខ ០០២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៣៥, ៣៨។ **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៩១។ **សំណុំរឿងលេខ ០០២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ៧៧, ៨៧ ដល់ ៨៨។

107. *គោលបំណងរួម៖* គោលបំណង ឬគោលដៅរួម អាចជាអំពើឧក្រិដ្ឋតែម្តង (ហេតុនេះ គោលបំណងរួមនេះ*ស្មើនឹង*ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន) ឬអាចជាគោលដៅមិនមែនឧក្រិដ្ឋកម្ម ដែលមនុស្សជាច្រើនមានចេតនាសម្រេចតាមរយៈមធ្យោបាយឧក្រិដ្ឋកម្ម (ហេតុនេះ គោលបំណងរួមនេះ*ពាក់ព័ន្ធនឹង*ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន)[218]។

108. ជាឧទាហរណ៍នៅក្នុងសំណុំរឿង ០០២/០១ អ.ជ.ស.ដ និង អ.ជ.ត.ក បានសម្រេចថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមមួយ ដើម្បីអនុវត្តបដិវត្តសង្គមនិយម នៅក្នុងប្រទេសកម្ពុជា ដែលគោលបំណងរួមនេះមិនមែនជាគោលបំណងឧក្រិដ្ឋឡើយ ប៉ុន្តែពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីធ្វើឱ្យគោលបំណងរួមនោះសម្រេចបានជាផ្លែផ្កា[219]។

109. មិនមានលក្ខខណ្ឌតម្រូវថា អ្នកចូលរួមសហឧក្រិដ្ឋកម្មរួមត្រូវតែមានផែនការដែលបានរៀបចំ ឬបង្កើតឡើងពីមុនរួចហើយទេ។ គោលបំណង ឬគោលដៅរួម អាចលេចចេញជារូបរាងដោយឥត

---

[218] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៤។ **សំណុំរឿងលេខ ០០២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៧។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៨។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL (SCSL-04-16-A) ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ៨០។*សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៩៦។

[219] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧៧៨, ៨០៤ និង ៨៣៤។ **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៦។ ប្រហែលគ្នានេះដែរនៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-04-74-T) វ៉ុលទី ៤ នៃវ៉ុលទី ៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ២៤, ៤១ ដល់ ៤៣, ៦៥ ដល់៦៨ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សមាជិកសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមដើម្បីបង្កើតរដ្ឋឯករាជ្យ ដែលដាច់ចេញពី Bosnia និង Herzegovina។ ទោះបីជាគោលដៅនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ តែសមាជិកសហឧក្រិដ្ឋកម្មរួម មានបំណងសម្រេចគោលដៅនេះតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងប្រជាជនមូស្លីម។

ព្រៀងទុក ហើយអាចទាញចេញសេចក្ដីសន្និដ្ឋានបានពីអង្គហេតុដែលថា មនុស្សជាច្រើននាក់បានធ្វើសកម្មភាពរួមគ្នា ដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួម[220]។

110. *មនុស្សច្រើននាក់៖* សហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានការចូលរួមពីមនុស្សច្រើននាក់ ដើម្បីគោលបំណងឧក្រិដ្ឋកម្មរួម[221]។ មិនចាំបាច់បង្ហាញឈ្មោះអ្នកចូលរួមទាំងអស់នៅក្នុងសហឧក្រិដ្ឋកម្មរួមឡើយហើយអាចគ្រប់គ្រាន់ហើយត្រឹមលើកឡើងឱ្យបានច្បាស់លាស់អំពីប្រភេទមនុស្ស ឬក្រុមមនុស្ស[222]។ មនុស្សច្រើននាក់មិនចាំបាច់ត្រូវរៀបចំជារចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលឡើយ[223]។

---

[220] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៧ (ii)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Mpambara* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-01-65-T) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១៣ "*ខុសពីការសមគំនិត គឺមិនចាំបាច់បង្ហាញពីការព្រមព្រៀងជាក់លាក់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ៖ គោលបំណងរួមអាចកើតឡើងភ្លាមៗ និងមិនផ្លូវការទេ ហើយអ្នកចូលរួមពាក់ព័ន្ធ មិនចាំបាច់ពាក់ព័ន្ធគ្នាតាមរយៈអង្គការចាត់តាំងផ្លូវការឡើយ*"។

[221] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩២។ សាលដីកា *Kvocka* កថាខណ្ឌ ៨១។

[222] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-87/1-T) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៨៦១៖ *មិនចាំបាច់ត្រូវបង្ហាញឈ្មោះអ្នកចូលរួមទាំងអស់ឡើយ។ អាស្រ័យតាមកាលៈទេសៈនៃរឿងក្ដី គឺអាចគ្រប់គ្រាន់ហើយត្រឹមសំដៅលើប្រភេទមនុស្ស ឬក្រុមមនុស្ស។ ទោះជាយ៉ាងនេះក្ដី ប្រភេទ ឬក្រុមមនុស្សបែបនេះ ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណឱ្យបានគ្រប់គ្រាន់ដើម្បីចៀសវាងភាពមិនច្បាស់លាស់ ឬមិនប្រាកដប្រជា*"។ ឧទាហរណ៍អំពីការកំណត់ចរិតលក្ខណៈមិនបានច្បាស់លាស់អំពី សមាជិកសហឧក្រិដ្ឋកម្មរួម *សូមមើល រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៥៦ ដល់ ១៥៧។

[223] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៧(i)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-05-87/1-T) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៨៦១។

111. *ការចូលរួមគោលបំណងរួម៖* ការចូលរួមគោលបំណងរួម មិនចាំបាច់ពាក់ព័ន្ធនឹងការអនុវត្តផ្នែកណាមួយនៃធាតុផ្សំសត្យានុម័តរបស់ឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃគោលបំណងរួមនោះទេ[224]។ គ្រប់គ្រាន់ហើយត្រឹមថា អំពើរបស់អ្នកចូលរួមនោះក្នុងរបៀបណាម្យ៉ាងមានគោលដៅជំរុញគោលបំណងឧក្រិដ្ឋរួម[225]។ អំពើរបស់អ្នកចូលរួមសហឧក្រិដ្ឋកម្មរួម អាចជាអំពើសកម្ម ឬអំពើអកម្មដែលមានពិរុទ្ធភាព[226]។ ការរួមចំណែករបស់អ្នកចូលរួមសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ត្រូវទាល់តែ

[224] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤២៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៧ (iii)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២១៥។

[225] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩១, ២២៧ (iii), ២២៩(iii)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១៨៧។ សាលក្រម *Krajišnik* បានផ្តល់ជាឧទាហរណ៍ល្អមួយអំពីការប្រព្រឹត្តិដែលមិនមានលក្ខណៈឧក្រិដ្ឋទេ ប៉ុន្តែនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ នៅក្នុងកថាខណ្ឌ ១១២០ និង ១១២១ នៃ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-00-39-T) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ អង្គជំនុំជម្រះសម្រេចថា ការរួមចំណែកជារួមរបស់ Krajišnik នៅក្នុងសហឧក្រិដ្ឋកម្មរួម គឺដើម្បីជួយបង្កើត និងរក្សានិរន្តរភាពបក្ស SDS និងរចនាសម្ព័ន្ធរដ្ឋ *"ដែលចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម"*។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានបញ្ជាក់ថា *"ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ អ្វីដែលសំខាន់គឺថា ការចូលរួមនេះគឺដើម្បីជំរុញការអនុវត្តគោលដៅ ឬគោលបំណងរួមដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម" រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២១៥, ២១៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។

[226] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១៨៧, ៤២១ និង ៥៥៦។ ជាគោលការណ៍ទូទៅ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានសម្រេចស្របគ្នាថា ឧក្រិដ្ឋកម្មអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលមានពិរុទ្ធភាព ក្នុងករណីដែលមានភារកិច្ចត្រូវអនុវត្តសកម្មភាព ហើយជនជាប់ចោទអាចត្រូវទទួលខុសត្រូវផ្ទាល់ចំពោះចូលរួមចំណែកដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈអំពើអកម្ម ក្នុងករណីដែលជនជាប់ចោទមានភារកិច្ចអនុវត្តសកម្មភាព *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៦៣ និង *រឿងក្តីរ*

ជាការរួមចំណែកដែលចាំបាច់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទេ ដែលការរួមចំណែកដែលចាំបាច់នេះមានន័យថា ប្រសិនបើគ្មានការចូលរួមបែបនេះទេ នោះឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃគោលបំណងរួម អាចមិនបានប្រព្រឹត្ត ឬមិនត្រូវបានប្រព្រឹត្តឡើយ[227] ប៉ុន្តែ ការរួមចំណែកនោះយ៉ាងហោចណាស់ចាំបាច់ត្រូវតែជាការរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[228]។

112. ស្ទើរតែសកម្មភាពដែលតាមការមើលឃើញ គឺមិនមានភាពពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ ក៏សកម្មភាពទាំងនោះអាចត្រូវយកមកពិចារណាផងដែរនៅពេលសម្រេចថាតើអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមនោះបានចូលរួមចំណែកយ៉ាងសំខាន់ដែរ ឬអត់[229]។ ទោះជាយ៉ាងនេះក្តីសកម្មភាពបែបនេះអាចជំរុញ និងគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម បើទោះបីជាដោយប្រយោលក្តី[230]។ នៅក្នុងការវាយតម្លៃនេះ សកម្មភាពទាំងអស់គួរយកមកពិចារណា ហើយការចូលរួមចំណែកណាមួយមិនគួរត្រូវវាយតម្លៃឲ្យដាច់ដោយឡែកពីគ្នានោះឡើយ[231]។ ភាពសំខាន់នៃការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម គួរត្រូវសម្រេចតាមករណីនីមួយៗ ដោយគិតពីកត្តាផ្សេងៗគ្នា រួមទាំងតួនាទីរបស់ជនត្រូវចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ព្រមទាំងការខិតខំណាមួយដើម្បីរារាំងឧក្រិដ្ឋកម្ម[232]។

113. *ធាតុផ្សំអត្តនោម័ត៖* សមាជិកនៅក្នុងសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកមួយនៃគោលបំណងរួម គឺថា ចេតនានេះចាំបាច់ត្រូវតែមានទាំងគោល

---

*ដីកាអាជ្ញា តទល់នឹង Galić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29-A) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧៥។

[227] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៩៨ និង ១៩៣។

[228] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៨០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២១៥ និង ៦៩៦។

[229] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨៤។

[230] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៨៤។

[231] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៨០។

[232] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៨០។

បំណងរួម ទាំងឧក្រិដ្ឋកម្មដែលមាននៅក្នុងចេតនានោះ[233]។ ចេតនានេះចាំបាច់ត្រូវតែចូលរួម និងជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមទាំងអស់[234]។ នៅក្នុងករណីដែលឧក្រិដ្ឋកម្មនោះពាក់ព័ន្ធជាមួយនឹងការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ សមាជិកសហឧក្រិដ្ឋកម្មរួមចាំបាច់ត្រូវតែចូលរួមចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នោះ[235]។

114. អ.ជ.ត.ក បានបញ្ជាក់បំភ្លឺថា នៅក្នុងករណីដែលគោលបំណងរួម*ពាក់ព័ន្ធជាមួយនឹង*ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើននោះ មិនចាំបាច់ថា អ្នកដែលឯកភាពលើគោលបំណងរួម ពិតជា*ចង់ឱ្យ*

[233] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០៥៣។

[234] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Brđanin សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២០០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Stakić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-97-24-A) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៦៥។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-94-1-A) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩៦៖“ប្រភេទបែបនេះលើកដំបូងមាននៅក្នុងរឿងក្តី ដែលសហជនជាប់ចោទទាំងអស់ធ្វើសកម្មភាពផ្អែកតាមការរៀបចំរួម ដោយមានចេតនាឧក្រិដ្ឋកម្មដូចគ្នាតែមួយ។ ឧទាហរណ៍ ការបង្កើតផែនការក្នុងចំណោមសហចារីដើម្បីសម្លាប់ ក្នុងករណីដែលអនុវត្តការរៀបចំរួម *(និងបើទោះបីជាសហចារីនីមួយៗអនុវត្តតួនាទីផ្សេងៗគ្នានៅក្នុងផែនការនោះក៏ដោយ) ក៏ពួកគេទាំងអស់សុទ្ធតែមានចេតនាសម្លាប់។ លក្ខខណ្ឌតម្រូវសត្យានុម័ត និងអត្តនោម័តសម្រាប់ដាក់បន្ទុកការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើអ្នកចូលរួមដែលមិនមាន ឬមិនអាចមានភស្តុតាងបញ្ជាក់ពីការនាំឱ្យមានការសម្លាប់នោះ គឺមានដូចតទៅ៖ (១) ជនជាប់ចោទត្រូវតែចូលរួមដោយស្ម័គ្រចិត្តនៅក្នុងផ្នែកមួយនៃការរៀបចំរួម (ឧទាហរណ៍ តាមរយៈការជំរុញអំពើហិង្សាមិនដល់ស្លាប់មកលើជនរងគ្រោះ ឬតាមរយៈការផ្តល់ជំនួយជាក់ស្តែង ឬសម្របសម្រួលសកម្មភាពរបស់សហចារី) និង (២) ជនជាប់ចោទបើទោះបីជាមិនបាននាំឱ្យមានការសម្លាប់ក៏ដោយ ប៉ុន្តែមានចេតនាចង់បានលទ្ធផលបែបនេះ”* និង កថាខណ្ឌ ២២៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Ntakirutimana* *និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-10-A និង ICTR-96-17-A) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៤៦៣៖ *“ប្រភេទទីមួយគឺជាទម្រង់“មូលដ្ឋាន”នៃសហឧក្រិដ្ឋកម្មរួម។ ទម្រង់នេះមាននៅក្នុងរឿងក្តីដែលសហចារីទាំងអស់* ធ្វើសកម្មភាពផ្អែកតាមការរៀបចំរួម ដោយមានចេតនាឧក្រិដ្ឋកម្មដូចគ្នាតែមួយ”។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* *Vasiljević* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-32-A) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ១០១។

[235] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Kvočka* *និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-30/1-A) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១០៩-១១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Krnojelac* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-97-25-A) ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ១១១ -១១២។

ប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្ត ដើម្បីសម្រេចគោលបំណងចុងក្រោយនោះ[236]។ អ.ជ.ត.ក បានបន្ថែមថា ករណីនេះអាចរួម បញ្ចូលឧក្រិដ្ឋកម្មដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយដើម្បីសម្រេចគោលបំណងរួមណា មួយ បើទោះបីជាការប្រព្រឹត្តិពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ[237]។ អ.ជ.ត.ក បានពន្យល់ថា ប្រសិនបើគោលដៅនៃគោលបំណងរួមនឹងសម្រេចបានលុះត្រាតែអាចមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយមានការព្រមព្រៀងគ្នាថាត្រូវបន្តសម្រេចគោលដៅនេះដោយពុំគិតថាអាចមានការប្រព្រឹត្តិ ឧក្រិដ្ឋកម្មយ៉ាងណាក៏ដោយ នោះ គោលបំណងរួម មានបញ្ចូលឧក្រិដ្ឋកម្មទាំងនេះ ពីព្រោះថា បើ ទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះត្រូវបានគ្រោងទុកដោយគោលបំណងរួម រួចហើយ[238]។ ដោយផ្អែកផងដែរលើការប្រើប្រាស់ពាក្យ "*ចង់ឱ្យ*" យើង Michael Bohlander សូមបកស្រាយថា សេចក្តីសម្រេចនេះរបស់ អ.ជ.ត.ក គឺការបញ្ជាក់បំភ្លឺថា ការប្រព្រឹត្តិឧក្រិដ្ឋកម្ម មិនចាំបាច់ទាល់តែជាគោលដៅចម្បងរបស់សមាជិកសហឧក្រិដ្ឋកម្មរួមឡើយ។ ទោះជាយ៉ាងនេះក្តី នៅតែចាំបាច់ត្រូវតែបង្ហាញពីចេតនារបស់សមាជិកសហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជាលក្ខខណ្ឌតម្រូវជាមូលដ្ឋានសម្រាប់សហឧក្រិដ្ឋកម្មរួមប្រភេទទីមួយ។

115. *ចារីផ្ទាល់៖* សមាជិកសហឧក្រិដ្ឋកម្មរួមអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយ ចារីផ្ទាល់ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ប្រសិនបើឧក្រិដ្ឋកម្មនោះគឺជាផ្នែកមួយនៃ គោលបំណងរួម ហើយត្រូវបានប្រព្រឹត្តឡើងដើម្បីជំរុញគោលបំណងរួមនោះ[239]។ ដើម្បីឱ្យ សមាជិកសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយអ្នកដែលមិនមែនជា សមាជិកសហឧក្រិដ្ឋកម្មរួមនោះ ចាំបាច់ត្រូវតែបង្ហាញថា ឧក្រិដ្ឋកម្មនោះអាចកើតឡើងដោយសារ សមាជិកសហឧក្រិដ្ឋកម្មរួម យ៉ាងហោចណាស់ក៏ម្នាក់ដែរ ហើយសមាជិកនោះនៅពេលប្រើប្រាស់

---

[236] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៨។

[237] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៨។

[238] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៨។

[239] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១០-៤១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃ តុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២២៥។

ចារីផ្ទាល់ ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម បានធ្វើសកម្មភាពដើម្បីជំរុញគោលបំណងរួម[240]។ អត្ថិភាពនៃទំនាក់ទំនងនេះ គឺជាបញ្ហាដែលត្រូវវាយតម្លៃតាមករណីនីមួយៗ[241]។

ពា ២.៣.ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ

116. ស.ច.ស ក្នុងសំណុំរឿង ០០២ បានសម្រេចថា ការប្រព្រឹត្តិតាមរយៈការចូលរួមសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ អនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ[242]។ អ.ប.ជ មិនបានដោះស្រាយជាក់លាក់អំពីភាពអាចអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ចំពោះឧក្រិដ្ឋកម្មជាតិឡើយ ប៉ុន្តែ បានច្រានចោលទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ។ តាមទស្សនៈរបស់ អ.ប.ជ ការចូលរួមសហឧក្រិដ្ឋកម្មរួម រួមមានស្ថានភាពដែលជនត្រូវចោទអាច“*មានលក្ខណៈដាច់ឆ្ងាយចេញពីការរួមប្រព្រឹត្តជាក់ស្តែងនៃអំពើពិរុទ្ធនៃបទឧក្រិដ្ឋ ជាជាងស្ថានភាពទាំងឡាយដែលត្រូវបានដឹងមុន*

---

[240]**សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៣។

[241]*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-99-36-A) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៣ និង ៤១៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-00-39-A) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ២២៥-២២៦។យោងតាម សាលដីកា *Krajišnik* កថាខណ្ឌ ២២៦៖ “*កត្តាដែលបង្ហាញពីចំណងទាក់ទងបែបនេះ រួមមានភ័ស្តុតាងបង្ហាញថា សមាជិករបស់សហឧក្រិដ្ឋកម្មរួម បានស្នើសុំដោយត្រង់ ឬដោយប្រយោលទៅអ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ឬបានញុះញង់ បញ្ជា ជំរុញ ឬលើកទឹកចិត្ត ឬជួយដល់អ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម*"។ យោងតាម សាលដីកា *Brđanin* កថាខណ្ឌ ៤១០៖ “ក្នុងករណីដែលមេឃ្លោងចារីនៃឧក្រិដ្ឋកម្មណាមួយមួយមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមទេ នោះ លក្ខខណ្ឌតម្រូវដ៏សំខាន់នេះអាចទាញសេចក្តីសន្និដ្ឋានចេញពីកាលៈទេសៈផ្សេងៗ រួមមាន ការពិតដែលថា ជនជាប់ចោទ ឬសមាជិកណាម្នាក់ទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម បានសហការយ៉ាងជិតស្និទ្ធជាមួយមេចារីដើម្បីជំរុញគោលបំណងឧក្រិដ្ឋកម្មរួម"។

[242] **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣០៧។ **សំណុំរឿងលេខ ០០២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៩៦។ **សំណុំរឿងលេខ ០០២-ឯកសារ D97/13** *ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ២២។

*តាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់នៅថ្នាក់ជាតិ'*[243]។ អ.ប.ជ ក៏បានបង្ហាញទស្សនៈផងដែរថា ទម្រង់ថ្នាក់ជាតិនៃសហចារី ដែលមានចែងនៅក្នុងមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺដូចសហឧក្រិដ្ឋកម្មរួមដែរ ជាទម្រង់មួយនៃការប្រព្រឹត្តិដែលស្ថិតនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[244]។

117. ហេតុដូច្នេះ ស្របតាមដីកាដំណោះស្រាយសំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២ ដោយអនុវត្តតាមរូបមន្តរបស់ អ.ប.ជ អំពីទម្រង់នៃការទទួលខុសត្រូវនៅថ្នាក់ជាតិ និងដោយពិចារណាលើវិធីសាស្ត្ររបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០២ នោះ ទម្រង់នៃការទទួលខុសត្រូវតាមរយៈការប្រព្រឹត្តិ (ជាចារី) ការរៀបចំផែនការ និងការបញ្ជា នឹងត្រូវយកមកពិចារណាពាក់ព័ន្ធនឹងការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

## ៤. ការពិចារណាអំពីភស្តុតាង

### ៤.១ ចម្លើយដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយដែលរៀបចំដោយ ក.ស.ច.ស

118. ភាគច្រើនលើសលប់នៃភស្តុតាងដែលត្រូវបានពឹងផ្អែកក្នុងសំណុំរឿង ០៣ គឺរួមមានកំណត់ហេតុស្តាប់ចម្លើយដែល ក.ស.ច.ស បានធ្វើឡើងនៅក្នុងពេលស៊ើបអង្កេត ហើយត្រូវបានរៀបចំឡើងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងត្រូវការពារនីតិវិធីផ្លូវច្បាប់ច្បាស់លាស់ ដូច្នេះហើយត្រូវទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[245]។ យើង Michael Bohlander

---

[243] **សំណុំរឿងលេខ ០០២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១០១។

[244] មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងជាភាសាបារាំងថា៖ *"Toute personne participant volontairement, soit directement, soit indirectement, à la perpétration d'un crime ou d'un délit, est passible des peines applicables à l'auteur principal. La participation directe constitue la coaction, la participation indirecte constitue la complicité."*។ **សំណុំរឿងលេខ ០០២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ១០២។

[245] **សំណុំរឿងលេខ ០០២-ឯកសារ E96/7** *សេចក្តីសម្រេចលើសំណើសុំ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២៦ ដល់ ២៧, ២៩។ **សំណុំរឿងលេខ ០០២-ឯកសារ E162,** *ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះផ្នែកនៃឯកសារ E114, E114/1, E131/1/9. E131/6, E136 និង E158* ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៣។ **សំណុំរឿងលេខ ០០២-ឯកសារ E185** *សេចក្តីសម្រេចលើការជំទាស់ ទៅនឹងឯកសារដែលបានស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥ របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុង*

យល់ឃើញថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមកពីសំណុំរឿងផ្សេងទៀតរបស់ អ.វ.ត.ក ហើយបានដាក់ចូលក្នុងសំណុំរឿង ០០៣ ដោយសារប្រតិចារឹកទាំងនោះពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់នានា ក៏ទទួលបានសច្ចធារណ៍ដូចគ្នានេះផងដែរ។

119. ចម្លើយ ឬភ័ស្តុតាងដទៃទៀតដែលប្រមូលបានដោយមិនមានការត្រួតពិនិត្យតាមផ្លូវតុលាការពីសំណាក់ស្ថាប័នដែលមិនស្ថិតនៅក្នុង អ.វ.ត.ក រួមមាន មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធ្វើឡើងដោយគ្មានការធានា និងបែបបទនីតិវិធីតុលាការ ដែលជាលក្ខខណ្ឌនៃកំណត់ហេតុស្តាប់ចម្លើយទេ ហេតុនេះ មិនទទួលបានសច្ចធារណ៍បែបនេះឡើយ[246]។ ទោះជាយ៉ាងនេះក្តី ករណីនេះមិនរាប់បញ្ចូលឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពដើមពីមជ្ឈមណ្ឌលឯកសារកម្ពុជា ពោលគឺជាឯកសារដែល អ.ជ.ស.ដ បានសម្រេចថាទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធជាបឋម និងភាពអាចជឿជាក់បាន[247]។

120. ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា បើទោះបីជាត្រូវបានរៀបចំឡើងជាពិសេសសម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយទាំងនេះមិនត្រូវបានធ្វើឡើងដោយមានការស្បថ ដែរ ហើយត្រូវបានរៀបចំឡើងដោយភាគីមួយដែលមានផលប្រយោជន៍ជាក់ស្តែងនៅក្នុងលទ្ធផលនៃសំណុំរឿង។ ទោះជាយ៉ាងនេះក្តី ចម្លើយបែបនេះត្រូវបានប្រមូលឡើងក្នុងគោលបំណងសម្រាប់សវនាការព្រហ្មទណ្ឌ ដូច្នេះហើយ ជាគោលការណ៍ ត្រូវទទួលបានតម្លៃជាភ័ស្តុតាងខ្ពស់ជាងភ័ស្តុតាងដែលមិនបាន

---

*កថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១២ កថាខណ្ឌ ២០។

[246] **សំណុំរឿងលេខ ០០២-ឯកសារ** E96/7 *សេចក្តីសម្រេចលើសំណើសុំ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២៩។

[247] **សំណុំរឿងលេខ ០០២-ឯកសារ** E185 *សេចក្តីសម្រេចលើការជំទាស់ ទៅនឹងឯកសារដែលបានស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក ១ ដល់ ក ៥ របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ២៨។ **សំណុំរឿងលេខ ០០២-ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣៧៣។

01600537



រៀបចំឡើងក្នុងគោលបំណងបែបនេះ (រួមទាំងចម្លើយដែលប្រមូលបានដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ផង)[248]។

121. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពុំអាចទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានទេ ហើយទទួលបានតម្លៃជាភ័ស្ដុតាងទាបប៉ុណ្ណោះ ប្រសិនបើមិនដឹងអំពីកាលៈទេសៈដែល បានកត់ត្រាពាក្យសុំនោះទេ[249]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងពាក្យបណ្ដឹងរបស់ជនរងគ្រោះដែលគ្រាន់តែបង្ហាញពីសេចក្ដីសន្និដ្ឋានទូទៅ ហេតុនេះគ្រាន់តែជា"*ការរៀបរាប់ទូទៅ*"ដែលមិនមែនជាបទពិសោធន៍ផ្ទាល់ខ្លួនទេ ត្រូវចាត់ទុកថាមិនមានព័ត៌មានគ្រប់គ្រាន់អាចបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធបានទេ[250]។ ចម្លើយដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់នៅក្រៅនីតិវិធីតុលាការ ត្រូវទទួលបានតម្លៃជាភ័ស្ដុតាងទាប[251] ចំណែកឯសក្ខីកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់តាមនីតិវិធីតុលាការត្រូវបានវាយតម្លៃយ៉ាងប្រយ័ត្នប្រយែង[252]។

122. ជាការសន្និដ្ឋាន និងថ្លឹងថ្លែងលើការពិចារណាទាំងអស់នេះ កំណត់ហេតុស្ដាប់ចម្លើយរបស់ ក.ស.ច.ស និងប្រតិចារឹកសវនាការ ត្រូវទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានខ្ពស់ជាង ហើយត្រូវទទួលបានតម្លៃជាភ័ស្ដុតាងខ្ពស់ជាងការស្ដាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត។ ចំពោះការស្ដាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នផ្សេងទៀត គឺមានការអនុវត្តវិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាងក្នុងការវាយតម្លៃលើឯកសារទាំងនោះ ហើយព័ត៌មានដែលមាននៅក្នុងនោះត្រូវបានពឹងផ្អែកតែក្នុងករណីដែលមានការបញ្ជាក់ពីប្រភពផ្សេងទៀតប៉ុណ្ណោះ។

123. ក៏មានការអនុវត្តវិធីសាស្ត្រប្រុងប្រយ័ត្នផងដែរចំពោះការវាយតម្លៃលើកិច្ចសម្ភាសន៍ និងចម្លើយដែល **មាស មុត** បានផ្ដល់ឲ្យស្ថាប័នផ្សេងក្រៅពី ក.ស.ច.ស ។ ដូចដែល ស.ច.ស បានកត់សម្គាល់នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០៤/១ (សំអាងហេតុ) រួចហើយ នៅក្នុងវិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិដែលចែងអំពីការប្រើប្រាស់ចម្លើយដែលជនសង្ស័យ និងជនត្រូវចោទបានផ្ដល់ជូនទៅស្ថាប័ន ឬអង្គការផ្សេង ទោះបីជាថាបានដឹង ឬមិនបានដឹងថា ខ្លួនឯងជាជនសង្ស័យ ឬជា

---

[248] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៩៦។

[249] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៩៦។

[250] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៥៧។

[251] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥០។

[252] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣១៥។

ជនត្រូវចោទស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ អ.វ.ត.ក នោះទេ ប៉ុន្តែ ចម្លើយបែបនេះត្រូវបាន អតីត ស.ច.ស និង អ.ជ.ស.ដ ប្រើប្រាស់ជាមូលដ្ឋានតាមកម្រិតផ្សេងៗតាមការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងស្របតាមបទដ្ឋានទូទៅនៃការវាយតម្លៃភ័ស្តុតាង[253]។ ស្របតាមវិធីសាស្ត្របែបនោះ និងគោលការណ៍វាយតម្លៃភ័ស្តុតាងដែលបានពន្យល់នៅក្នុងផ្នែកនេះ យើង Michael Bohlander ឱ្យតម្លៃទៅលើកិច្ចសម្ភាសន៍ និងចម្លើយបែបនេះរបស់ **មាស មុត** ទាបជាងការស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស។ ភាពអាចជឿជាក់បាន និងតម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងបែបនេះ ត្រូវបានវាយតម្លៃ ដោយគិតពីភ័ស្តុតាងផ្សេងទៀតទាំងអស់នៅក្នុងសំណុំរឿង។

## ៤.២ ភ័ស្តុតាងពាក្យចចាមអារ៉ាម និងការពឹងផ្អែកលើភ័ស្តុតាងដែលមិនមានការបញ្ជាក់

124. មេធាវីការពារក្តី បញ្ជាក់ថា ភ័ស្តុតាងពាក្យចចាមអារ៉ាម គួរយកជាមូលដ្ឋានតែករណីដែលមានការបញ្ជាក់ពីប្រភពអាចជឿជាក់បានប៉ុណ្ណោះ ហើយភ័ស្តុតាងណាក៏ដោយ ដោយមិនគិតពីប្រភពដើមទេ គួរយកជាមូលដ្ឋានតែករណីដែលមានការបញ្ជាក់ប៉ុណ្ណោះ[254]។ យោងតាមវិធានផ្ទៃក្នុង ៨៧ រាល់ភ័ស្តុតាងទាំងអស់អាចទទួលយកបាននៅក្នុងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក រួមទាំង ពាក្យចចាមអារ៉ាម ផងដែរ។ ទាំង អ.ជ.ស.ដ ទាំង អ.ជ.ត.ក យល់ឃើញថា ភ័ស្តុតាងពាក្យចចាមអារ៉ាម អាចយកជាមូលដ្ឋានបានក្នុងករណីដែលមានភាពពាក់ព័ន្ធ និងតម្លៃជាភ័ស្តុតាងគ្រប់គ្រាន់[255]។ តុលាការអន្តរជាតិផ្សេងទៀតក៏បានទទួលស្គាល់ថា ចៅក្រមអាចពឹងផ្អែកដោយប្រុងប្រយ័ត្នលើពាក្យចចាមអារ៉ាម ដោយកំណត់លើភាពអាចជឿជាក់បាន និងតម្លៃជាភ័ស្តុតាងនៃពាក្យចចាមអារ៉ាមនោះតាមករណីនីមួយៗ[256]។ នេះគឺជាវិធីសាស្ត្រដែលអនុវត្តតាមនៅក្នុងដីកាដំណោះស្រាយនេះ។

---

[253] **ឯកសារ D261** *ដីកាដំណោះស្រាយ (សំអាងហេតុ)សំណុំរឿង ០០៤/១* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ១៣៨-១៣៩។

[254] **ឯកសារ D256/11** *ចម្លើយតបរបស់ មាស មុត ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ កថាខណ្ឌ ១៤៤-១៤៥។

[255] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៣។**សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣០២។

[256] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ndindabahizi* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-01-71-A) ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ ១១៥។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Gacumbitsi* សាលដីកា អង្គជំនុំជម្រះតុលាការ កំពូលនៃតុលាការ ICTR (ICTR-2001-64-A) ចុះថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១១៥។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង*

125. សក្ខីកម្មរបស់សាក្សីណាម្នាក់អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីអង្គហេតុណាមួយ ក្នុងករណីដែលអាចជឿជាក់បាន និងមានតម្លៃជាភស្តុតាងគ្រប់គ្រាន់(ទោះបីជាវិធីសាស្ត្រនេះដូចបានកត់សម្គាល់ខាងលើ បានយកមកអនុវត្តតែក្នុងករណីកំណត់ហេតុស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស និងប្រតិចារឹកសវនាការរបស់ អ.វ.ត.ក ក៏ដោយ)[257]។ ជាគោលការណ៍ ភស្តុតាងពាក្យចចាមអារ៉ាមដែលមិនមានការបញ្ជាក់ ក៏អាចយកជាមូលដ្ឋានបានដែរ[258]។ ប៉ុន្តែ កត្តានានា ដូចជាប្រភពនៃពាក្យចចាមអារ៉ាមនោះ កាលៈទេសៈដែលសាក្សីបានដឹងអំពីពាក្យចចាមអារ៉ាមនោះ ភាពស៊ីសង្វាក់រវាងភស្តុតាងនោះជាមួយនឹងភស្តុតាងពាក់ព័ន្ធផ្សេងទៀតនៅក្នុងសំណុំរឿង និងកាលៈទេសៈពាក់ព័ន្ធទាំងអស់ផ្សេងទៀត ចាំបាច់ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្នក្នុងករណីពាក្យចចាមអារ៉ាមមិនមានការបញ្ជាក់ ជាពិសេសក្នុងករណីភស្តុតាងប្រភេទនេះពាក់ព័ន្ធនឹងធាតុផ្សំជាក់លាក់នៃបទឧក្រិដ្ឋ ឬការប្រព្រឹត្តិរបស់ជនត្រូវចោទ។

126. ដោយខុសពីចម្លើយដែលប្រមូលបានក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យដែលមានប្រភពដើមផ្ទាល់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេល ឬនៅជិតអំឡុងពេលនៃហេតុការណ៍ដែលបានរៀបរាប់នៅក្នុងឯកសារនោះ ហេតុនេះគឺជាភស្តុតាងផ្ទាល់។ ឯកសារប្រភេទនេះមិនប៉ះពាល់ការចងចាំរបស់សាក្សីឡើយចំពោះចម្លើយរបស់សាក្សី ហើយមិនបានធ្វើឡើងដោយភាគីណាមួយដែលមានប្រយោជន៍រួចជាស្រេចពីលទ្ធផលនៃសំណុំរឿងឡើយនៅពេលដែលបង្កើតឯកសារនោះ។ ដូចបានកត់សម្គាល់ខាងលើ ឯកសារប្រភេទនេះក៏ទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បានដែរ។ ហេតុនេះ ខ

---

*Rutaganda* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣៤,២០៧, ៣១១។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង* *Karera* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-01-74-A) ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ៣៩, ១៧៨។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង* *Kordić និង Cerkez* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៨១-២៨៤។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង* *Gatete* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-00-61-A) ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ ៩៩។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង. Đorđević* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-87/1-A) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ៣៩៧។

[257] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៣។

[258] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០២។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង* *Gacumbitsi* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-64-A) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៣៣។

ណៈដែលត្រូវអនុវត្តវិធីសាស្ត្រមួយដ៏ប្រុងប្រយ័ត្ន ភស្តុតាងដែលមិនមានការបញ្ជាក់ប្រភេទនេះត្រូវបានប្រើប្រាស់នាពេលកន្លងមកក្នុងករណីសមស្រប។

## ៤.៣ ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

127. អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម មានការហាមឃាត់ដាច់ខាតមិនឲ្យប្រើប្រាស់ជាភស្តុតាងទេនូវព័ត៌មាននៅក្នុងចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម[259] និងមិនឲ្យប្រើប្រាស់ចម្លើយបែបនេះនៅក្នុងការសួរដេញដោលសាក្សីទេ[260] ក្រៅពីប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទជាអ្នកធ្វើទារុណកម្ម ដើម្បីបញ្ជាក់ថា មានការផ្តល់ចម្លើយដោយសារការធ្វើទារុណកម្ម។

128. ចម្លើយសារភាពរបស់អ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថាធ្វើឡើងដោយទារុណកម្ម។ នេះគឺជាសច្ចធារណ៍[261]។

129. ព័ត៌មាននៅក្នុង"ប្រវត្តិរូបអ្នកទោស" មន្ទីរ ស-២១[262] ក្រៅពីឈ្មោះអ្នកទោស ភេទ ថ្ងៃខែឆ្នាំចាប់ខ្លួន ឬសម្លាប់ គឺស្ថិតនៅក្នុងការហាមឃាត់នេះ[263]។ ប៉ុន្តែ ព័ត៌មាននៅក្នុងចម្លើយសារភាពនៅមន្ទីរ

---

[259] **សំណុំរឿងលេខ ០០២-ឯកសារ D130/9/21** *សេចក្តីសម្រេចលើភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត លើការប្រើប្រាស់ចម្លើយដែលទទួលបាន ឬអាចទទួលបានតាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៣០។ **សំណុំរឿងលេខ ០០១-ឯកសារ E1/27.1** *ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ កាំង ហ្គេកអ៊ាវ ហៅឌុច* ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៨ ដល់ ៩។ **សំណុំរឿងលេខ ០០១-ឯកសារ E176** *សេចក្តីសម្រេចលើសំណើរបស់ភាគីទាទាសុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)* ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៨។ **សំណុំរឿងលេខ ០០២-ឯកសារ E1/129.1** *ប្រតិចារឹកសវនាការលើអង្គសេចក្តីសំណុំរឿង ០០២ [មាស វឿន]* ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ **ERN 00851054** បន្ទាត់ ២១-២៣, **ERN 00851055** បន្ទាត់ ១-៦ ។

[260] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៤៧។ **សំណុំរឿងលេខ ០០២-ឯកសារ E1/129.1** *ប្រតិចារឹកសវនាការលើអង្គសេចក្តីសំណុំរឿង ០០២ [មាស វឿន]* ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ **ERN 00851054** បន្ទាត់ ២១-២៣, **ERN 00851055** បន្ទាត់ ១-៦។

[261] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៥៧ ដល់ ៥៨។

[262] ជាទូទៅ ជាឯកសារមួយទំព័រដែលបង្ហាញពីឈ្មោះអ្នកទោសនៅ ស ២១ ឈ្មោះក្រៅ ថ្ងៃខែឆ្នាំកំណើត ភេទ ជនជាតិ តួនាទី និងមន្ទីរ/ផ្នែកនៅក្នុងជួរ"បដិវត្តន៍" ទីកន្លែងកំណើត ចំនួនកូន ថ្ងៃខែឆ្នាំចាប់ខ្លួន និងទីកន្លែងចាប់ខ្លួន។ សូមមើល **ឯក សារ D251** *សេចក្តីសម្រេចរួមសំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្ខានុពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៣១។

សន្តិសុខ ស-២១ ដែលមានប្រភពដើមពីជនដែលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ឧទាហរណ៍ ចំណាររបស់អ្នកធ្វើទារុណកម្ម គឺមិនស្ថិតនៅក្នុងការហាមឃាត់នេះឡើយ[264]។ មាត្រា ១៥ ក៏មិនបានហាមឃាត់មិនឱ្យប្រើប្រាស់ព័ត៌មាននៅក្នុងចម្លើយដែលធ្វើឡើងដោយទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សី និងអាចឈានទៅស្តាប់ចម្លើយពួកគាត់ដែរ[265]។ ហេតុដូច្នេះ មិនមានការហាមឃាត់មិនឱ្យប្រើប្រាស់ភ័ស្តុតាងពីសាក្សីដែលមានអត្តសញ្ញាណនៅ

[263] **ឯកសារ D251** *សេចក្តីសម្រេចរួមសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្តានុពលនៃភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៣៥។

[264] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៦៦ ដល់ ៦៨។

[265] ហេតុផលមួយក្នុងចំណោមហេតុផលនានានៃគោលការណ៍ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មគឺដើម្បីដកចេញការលើកទឹកចិត្តមិនឱ្យរដ្ឋចូលរួមក្នុងការធ្វើទារុណកម្ម។ ដើម្បីជៀសវាងកុំឱ្យស្មុគស្មាញអំពីហេតុផលគោលការណ៍នេះ ក្នុងការបញ្ជាក់ពីភាពស្របច្បាប់ក្នុងការប្រើប្រាស់ភ័ស្តុតាងដែលបានរកឃើញតាមរយៈព័ត៌មានដែលទទួលដោយសារការធ្វើទារុណកម្ម គឺចាំបាច់ត្រូវបែកចែងឱ្យដាច់ពីគ្នារវាងសេណារីយ៉ូពីរដូចតទៅ។ សេណារីយ៉ូទីមួយ គឺករណីដែលព័ត៌មានទទួលបានដោយសារការធ្វើទារុណកម្ម ត្រូវអាជ្ញាធរដែលធ្វើទារុណកម្ម ប្រើប្រាស់ដើម្បីស្វែងរកសាក្សី ជនសង្ស័យ អ្នករត់គេចខ្លួន ឬដើម្បីជួយការស៊ើបអង្កេតដែលកំពុងបន្ត។ សេណារីយ៉ូទីពីរ គឺករណីដែលស្ថាប័នតុលាការដែលស៊ើបអង្កេតលើអ្នកធ្វើទារុណកម្ម ព្យាយាមប្រើប្រាស់ព័ត៌មានដែលទទួលបានពីអ្នកធ្វើទារុណកម្មនោះ ដើម្បីកំណត់អត្តសញ្ញាណប្រភពភ័ស្តុតាងដែលអាចមានប្រឆាំងអ្នកធ្វើទារុណកម្មនោះ។ ការអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានទទួលបានតាមរយៈការធ្វើទារុណកម្ម ធ្វើជាតម្រុយស៊ើបអង្កេតនៅក្នុងសេណារីយ៉ូទីមួយ អាចជាការលើកទឹកចិត្តឱ្យប្រើប្រាស់ទារុណកម្ម។ ឧទាហរណ៍ ប្រសិនបើអង្គភាពស៊ើបអង្កេតមួយទទួលបានចម្លើយតាមរយៈការធ្វើទារុណកម្ម បន្ទាប់មកប្រើប្រាស់ឈ្មោះដែលមាននៅក្នុងចម្លើយនោះ ដើម្បីស្វែងរកបណ្តុំឯកសារ ឬជនដែលមានព័ត៌មានពាក់ព័ន្ធជាមួយការស៊ើបអង្កេតនោះ ឯកសារ ឬសក្ខីកម្មពីរបស់ជននោះមិនត្រូវទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ ប៉ុន្តែ នៅក្នុងសេណារីយ៉ូទីពីរ ស្ថាប័នតុលាការមិនបានពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងអាជ្ញាធរដែលធ្វើទារុណកម្មទេ ហើយប្រើប្រាស់តម្រុយដែលអាចមានដើម្បីស្វែងរកភ័ស្តុតាងប្រឆាំងអ្នកធ្វើទារុណកម្មនោះ។ តាមទស្សនៈរបស់យើង ភ័ស្តុតាងពីសាក្សីដែលបានរកឃើញ ដោយផ្អែកលើចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្ម អាចប្រើប្រាស់បានតែក្នុងសេណារីយ៉ូទីពីរប៉ុណ្ណោះ។ អ.ប.ជ ក៏បានបញ្ជាក់ផងដែរថា ការប្រើប្រាស់ជាតម្រុយស៊ើបសួរនូវព័ត៌មានពីឯកសារដែលទទួលបានដោយសារការធ្វើទារុណកម្ម មិនមានន័យថាព័ត៌មាននោះត្រូវបានប្រើប្រាស់ជា"ភ័ស្តុតាង"ទេ (**សំណុំរឿងលេខ ០០៣-ឯកសារ** D253/1/8 *សេចក្តីសម្រេចលើសំណើសុំមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171* ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ កថាខណ្ឌ ៣០ និង ៣២)។ **សំណុំរឿងលេខ ០០៤-ឯកសារ D372/1/7** [សំណៅកោសលុប] *សេចក្តីសម្រេចលើពាក្យសុំរបស់ [កោសលុប] ស្នើឱ្យធ្វើមោឃភាពភ័ស្តុតាងនានាដែលទទួលបានដោយការធ្វើទារុណកម្ម* ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ២៣-២៥)។

ក្នុងចម្លើយដែលទទួលបានដោយការធ្វើទារុណកម្មទេ ដូចជា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ហើយក្រោយមកសាក្សីនោះត្រូវបាន ក.ស.ច.ស ស្តាប់ចម្លើយ[266]។

## ៤.៤ របាយការណ៍រៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

130. ជាផ្នែកមួយនៃគម្រោងរៀបចំផែនទីរបស់ខ្លួនដើម្បីកំណត់អត្តសញ្ញាណ និងរៀបចំផែនទីរណ្តៅសាកសពរួមនៅទូទាំងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំរបាយការណ៍មួយដែលមានព័ត៌មានអាចពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរលើការចោទប្រកាន់ទៅលើ **មាស មុត** ("របាយការណ៍រៀបចំផែនទី")។ របាយការណ៍រៀបចំផែនទី គឺពាក់ព័ន្ធនឹងបេសកកម្មចុះទៅក្រុងព្រះសីហនុ និងតំបន់នៅជំវិញនោះកាលពីខែវិច្ឆិកា ឆ្នាំ ១៩៩៥[267]។ របាយការណ៍រៀបចំផែនទី ផ្តល់ព័ត៌មានផ្សេងៗ ដូចជា ចំនួនរណ្តៅសាកសព និងចំនួនជនរងគ្រោះពាក់ព័ន្ធ នឹងទីតាំងដែលត្រូវបានចោទថាស្ថិតនៅក្នុងតំបន់ទទួលខុសត្រូវរបស់ **មាស មុត**។ ដោយសារថា មិនមានការបង្ហាញឲ្យឃើញថា ទីតាំងនៅក្នុងរបាយការណ៍រៀបចំផែនទី ជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាបទចោទលើ **មាស មុត** នោះ ទើបរបាយការណ៍រៀបចំផែនទី មិនត្រូវបានពឹងផ្អែកជាភ័ស្តុតាងឡើយ។

131. ការយល់ឃើញរបស់យើង Michael Bohlander អំពីតម្លៃជាភ័ស្តុតាងនៃរបាយការណ៍រៀបចំផែនទី គឺដូចគ្នានឹងការយល់ឃើញដែល ស.ច.ស ជាតិ បានបង្ហាញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) សំណុំរឿង ០០៤/១[268]។ ជាពិសេស របាយការណ៍រៀបចំផែនទី ដែលពឹងផ្អែកលើការចុះដល់ទីកន្លែង និងការសម្ភាសន៍ជាមួយនឹងប្រភពនានា មិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់អំពីប្រភពដែលសាក្សីបានដឹងអំពីចំនួនជនរងគ្រោះ ដើម្បីអាចវាយតម្លៃឲ្យបានគ្រប់គ្រាន់អំពីភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានលើភ័ស្តុតាងទេ។ កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់ជនរងគ្រោះក៏មិនបានដឹង ឬមានភាពច្បាស់លាស់ដែរ ហេតុនេះមិនអាចកំណត់ថាតើការស្លាប់នោះបានកើតឡើងនៅក្នុងដែនកំណត់យុត្តាធិការពេលវេលាពាក់ព័ន្ធដែរឬអត់។ ហេតុនេះ

---

[266] **សំណុំរឿងលេខ ០០២-ឯកសារ E350/8** *សេចក្តីសម្រេចលើភ័ស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៦៣, ៧០។

[267] **ឯកសារ D4.1.1026** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចំណងជើង កម្មវិធីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ទីតាំងឧក្រិដ្ឋកម្ម-របាយការណ៍ស្តីពីអំពើប្រល័យពូជសាសន៍នៅក្រុងព្រះសីហនុ" រួមមាន របាយការណ៍ស្តីពីទីតាំងកោះខ្យង ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[268] **ឯកសារ D261** *ដីកាដំណោះស្រាយ (សំអាងហេតុ) សំណុំរឿង ០០៤/១* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ១៣១-១៣៥។

យើង Michael Bohlander យល់ឃើញថា ចំនួនជនរងគ្រោះដែលបានរាយការណ៍នៅក្នុងរបាយការណ៍រៀបចំផែនទី មិនអាចជឿជាក់បានទេ ហេតុនេះ យើងមិនបានពឹងផ្អែកលើរបាយការណ៍ទាំងនេះទេ។ ក្នុងការគណនាចំនួនជនរងគ្រោះដែលអាចបង្កឡើងដោយសារ **មាស មុត** យើង Michael Bohlander ពឹងផ្អែកលើសាក្សីដែលបានផ្តល់ភ័ស្តុតាងជូន ក.ស.ច.ស អំពីចំនួនមនុស្សស្លាប់ និងមូលហេតុស្លាប់ ហើយក្នុងករណីសមស្រប ពឹងផ្អែកលើបញ្ជីឈ្មោះរបស់ ក.ស.ច.ស[269] ។

## ៤.៥ ចំនួនជនរងគ្រោះ

132. ផ្នែកនីមួយៗនៃការរកឃើញអង្គហេតុអំពីឧក្រិដ្ឋកម្មនៅក្នុងដីកាដំណោះស្រាយនេះ រួមមានការប៉ាន់ស្មានអំពីចំនួនជនរងគ្រោះពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ឬសេណារីយ៉ូឧក្រិដ្ឋកម្មនីមួយៗ តាមករណីដែលពាក់ព័ន្ធ។ ត្រូវមានការពន្យល់មួយចំនួនអំពីគោលការណ៍ និងវិធីសាស្ត្រដែលយើង Michael Bohlander ប្រើប្រាស់ដើម្បីធ្វើការប៉ាន់ស្មានទាំងនេះ។

133. ចំពោះទីតាំង ឬសេណារីយ៉ូឧក្រិដ្ឋកម្មទាំងអស់ យើង Michael Bohlander ប្រកាន់យកតួលេខអភិរក្សនិយម គឺចំនួនជនរងគ្រោះជាអប្បបរមាដែលអាចធ្វើការប៉ាន់ស្មានបានតាមរយៈភ័ស្តុតាង ដោយអនុវត្តគោលការណ៍ដូចខាងក្រោម។ គោលការណ៍ខ្លះបញ្ជាក់ពីវិធីសាស្ត្រអភិរក្សនិយម ចំពោះការវាយតម្លៃភ័ស្តុតាង ជាងលក្ខខណ្ឌតម្រូវសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ប៉ុន្តែ យើងប្រកាន់យកវិធីសាស្ត្របែបនេះដើម្បីចៀសវាងកុំឱ្យមានហានិភ័យរាប់ចំនួនជនរងគ្រោះស្ទួនគ្នាពីរដង។ ហេតុនេះ ការរាប់ចំនួនជាច្រើនពីសាក្សីដែលរៀបរាប់អំពីជនរងគ្រោះ ត្រូវបានដកចេញពីការគណនាចំនួនសរុប ក្នុងករណីដែលមានហានិភ័យអាចរាប់ចំនួនជនរងគ្រោះស្ទួនគ្នាពីរដង ឬក៏ការស្លាប់ជនរងគ្រោះ ឬភាពរងគ្រោះមិនអាចធ្វើការបញ្ជាក់ឱ្យបានសមហេតុផលទេពាក់ព័ន្ធនឹងវិសាលភាពពេលវេលានៃកិច្ចស៊ើបសួរ។ ការដកចេញការរាប់ចំនួនក្នុងរបៀបអភិរក្សនិយមបែបនេះគឺមានបំណងដើម្បីធានាថា ការប៉ាន់ស្មានចំនួនជនរងគ្រោះនៅតែស្ថិតនៅក្នុងចំនួនអប្បបរមា ប៉ុន្តែ ក៏មានន័យថា ចំនួនជនរងគ្រោះជាក់ស្តែងអាចមានលទ្ធភាពខ្ពស់មានចំនួនច្រើនជាងឆ្ងាយពីចំនួនប៉ាន់ស្មាននៅក្នុងដីកាដំណោះស្រាយនេះ។

៤ការគណនាចំនួនជនរងគ្រោះផ្អែកលើភ័ស្តុតាងដែលទទួលបានពីសាក្សីម្នាក់ ១.៥.

[269] *សូមមើល* កថាខណ្ឌ ១៤៦។

134. ក្នុងករណីដែលសាក្សីម្នាក់ប្រាប់ពីចំនួនជនរងគ្រោះស្ថិតនៅក្នុងរង្វង់ចំនួនណាមួយ (ឧទា. នៅចន្លោះពី ១០០ នាក់ ទៅ ២០០ នាក់) នោះ យើង Michael Bohlander យកចំនួនទាបបំផុតក្នុងរង្វង់ចំនួននោះ (គឺយកចំនួន ១០០ នាក់) ខុសពីការគណនាចំនួនមធ្យមភាគ។

135. ក្នុងករណីខ្លះ សាក្សីរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងដដែលៗ ជាផ្នែកមួយនៃការអនុវត្តជាទៀងទាត់ ឬជាផ្នែកមួយនៃដំណើរការណាមួយ ប៉ុន្តែ មិនបានបញ្ជាក់ពីចំនួនហេតុការណ៍ពិតប្រាកដដែលសាក្សីបានដឹងទេ។ ប្រសិនបើតាមរយៈភ័ស្តុតាង បង្ហាញឱ្យឃើញ ច្បាស់ថា ហេតុការណ៍ទាំងនោះបានកើតឡើងជាទៀងទាត់ និង/ឬក្នុងរយៈពេលយូរអង្វែង ហេតុនេះ ច្បាស់លាស់គឺថា បានកើតឡើងលើសពីពីរដងនោះ យើង Michael Bohlander សន្និតថា ហេតុការណ៍នេះបានកើតឡើងបីដង ប៉ុន្តែ បើខុសពីនេះ ចំនួនដែលបានសន្និតគឺចំនួនពីរដងប៉ុណ្ណោះ។

136. ក្នុងករណីដែលសាក្សីសំដៅលើចំនួន "លើសពាក់កណ្តាល" ក្នុងចំណោមចំនួនមនុស្សនៅក្នុងក្រុមណាមួយ យើង Michael Bohlander ធ្វើការគណនាចំនួននេះត្រឹមចំនួនពាក់កណ្តាលបូកមួយ។

137. ចំពោះចំនួនប្រហាក់ប្រហែល យើងយកចំនួនដែលមើលទៅឃើញជាក់ស្តែង ដរាបណាយើងជឿជាក់លើមូលដ្ឋានដែលសាក្សីដឹងពីចំនួននោះ ពីព្រោះថា មិនមានវិធីសមហេតុផលណាដែលត្រូវកាត់បន្ថយចំនួននេះឱ្យតិចទៀតទេ។ ឧទាហរណ៍ ក្នុងករណីដែលសាក្សីបញ្ជាក់ថា "ប្រហែល ១០ នាក់" ឬ "ប្រមាណ ១០ នាក់" ឬ"ប្រហាក់ប្រហែល ១០ នាក់" នោះចំនួននេះត្រូវគណនាថាមានចំនួន "១០ នាក់"។

138. ចំពោះការលើកឡើងមិនច្បាស់ថា "រាប់រយនាក់" នោះ ត្រូវគណនាថាមានចំនួន ២០០ នាក់ ហើយបើលើកឡើងថាមានចំនួន "រាប់ពាន់នាក់"វិញ នោះ ត្រូវគណនាថាមានចំនួន ២០០០ នាក់។

139. ក្នុងករណីដែលជនរងគ្រោះណាម្នាក់ត្រូវបានគេរៀបរាប់ថា "បានបាត់ខ្លួន"នោះ ជនរងគ្រោះនោះត្រូវបញ្ចូលក្នុងចំនួនមនុស្សស្លាប់ក្នុងករណីដែលមានភ័ស្តុតាងបញ្ជាក់ពីការសន្និដ្ឋានថា ជននោះត្រូវបានគេសម្លាប់ (ឧទា. ក្នុងករណីដែលការបាត់ខ្លួននេះបានកើតឡើងនៅក្នុងបរិបទហេតុការណ៍សម្លាប់រួម និងក្នុងករណីដែលមិនដែលឃើញជននោះម្តងទៀតទេក្រោយរបបកម្ពុជាប្រជាធិបតេយ្យ)។

៤ ២.៥.ការគណនាចំនួនជនរងគ្រោះផ្អែកតាមភ័ស្តុតាងពីសាក្សីច្រើននាក់

140. ចំពោះការគណនាចំនួនជនរងគ្រោះសរុបផ្អែកតាមភស្តុតាងរួមបញ្ចូលគ្នាពីសាក្សីច្រើននាក់ គឺត្រូវបូកចូលគ្នាតែចំនួនអប្បបរមាដែលទទួលបានពីសាក្សីម្នាក់ៗតែប៉ុណ្ណោះ។

141. ក្នុងករណីដែលអាចថា សាក្សីច្រើននាក់រៀបរាប់អំពីហេតុការណ៍ដូចគ្នា នោះ យើង Michael Bohlander មិនបូកចូលគ្នានូវចំនួនដែលទទួលបានពីសាក្សីទាំងនោះឡើយ។ ប៉ុន្តែ ប្រសិនបើមានភស្តុតាងបង្ហាញថា ក្រុមជនរងគ្រោះទាំងនោះគឺជាក្រុមជនរងគ្រោះផ្សេងខុសគ្នាបើតាមសាក្សីម្នាក់ៗ នោះចំនួនជនរងគ្រោះទាំងនោះត្រូវបកបញ្ចូលគ្នា។

142. ក្នុងករណីដែលសាក្សីច្រើននាក់នៅក្នុងហេតុការណ៍ណាមួយ ផ្តល់ព័ត៌មានផ្ទុយគ្នាអំពីចំនួនជនរងគ្រោះ នោះត្រូវយកចំនួនទាបបំផុត ប្រសិនបើតួលេខពីសាក្សីម្នាក់ទៀតមិនអាចជឿជាក់បានជាងទេ ឧទាហរណ៍ ដោយសារតាមរយៈភាពអាចជឿជាក់បាន ការបញ្ជាក់ ឬមូលដ្ឋានដែលបានដឹង។ ឧទាហរណ៍ ប្រសិនបើសាក្សីពីរនាក់បញ្ជាក់ថា ពួកគាត់ឃើញមនុស្ស ២០ នាក់ត្រូវបានគេសម្លាប់នៅក្នុងហេតុការណ៍មួយ ប៉ុន្តែ សាក្សីម្នាក់ទៀតគ្រាន់តែឮថាមនុស្សជិត ១០ នាក់ត្រូវបានគេសម្លាប់នៅក្នុងហេតុការណ៍នោះ(ភស្តុតាងឮគេថា) នោះ ការគណនាចំនួនត្រូវយកចំនួន ២០ នាក់ជាចំនួនដែលទទួលបានពីសាក្សីផ្ទាល់ភ្នែកទាំងពីរនោះ។

143. ប្រសិនបើមានការសន្និដ្ឋានផ្អែកលើការវាយតម្លៃជាក់ស្តែងអំពីភស្តុតាង ដែលបង្ហាញថា ជនរងគ្រោះណាម្នាក់បានស្លាប់នៅក្រៅក្របខណ្ឌពេលវេលានៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣ ជនរងគ្រោះនោះត្រូវដកចេញពីការគណនាចំនួនមនុស្សស្លាប់។

144. ក្នុងករណីដែលសាក្សីណាម្នាក់មិនអាចបញ្ជាក់ឈ្មោះទីតាំងឧក្រិដ្ឋជាក់ស្តែងឲ្យបានច្បាស់លាស់ ដែលជនរងគ្រោះណាម្នាក់បានស្លាប់ទេ ប៉ុន្តែ តាមរយៈភស្តុតាង មានការបង្ហាញឲ្យឃើញច្បាស់ថា ជនរងគ្រោះនោះបានស្លាប់នៅទីតាំងដែលបានដាក់ជាបទចោទ ឬក៏ពុំមាន សម្ពតិកម្មសមហេតុផលណាផ្សេងដែលកាត់ផ្តាច់ភាពពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទចំពោះជនរងគ្រោះនោះទេ ជនរងគ្រោះនោះមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនមនុស្សស្លាប់សរុបសម្រាប់ទីតាំងឧក្រិដ្ឋកម្មណាមួយឡើយ ប៉ុន្តែ ត្រូវរាប់បញ្ចូលក្នុងចំនួនមនុស្សស្លាប់សរុបសម្រាប់តំបន់ ដែលជនរងគ្រោះនោះត្រូវគេអះអាងថា បានជាប់ឃុំឃាំង ឬបានស្លាប់នៅទីនោះ ហេតុនេះ ជនរងគ្រោះនោះត្រូវរាប់បញ្ចូលក្នុងចំនួនមនុស្សសរុបសម្រាប់សំណុំរឿង។

## ៤.៥ ៣.ការរាប់ចំនួនសមាជិកនៅក្នុងគ្រួសារ

145. សាក្សីខ្លះរៀបរាប់អំពីចំនួនជនរងគ្រោះគិតជាចំនួនគ្រួសារ មិនមែនរាប់ចំនួនមនុស្សម្នាក់ៗទេ។ ក្នុងន័យដាច់ខាត ចំនួនមនុស្សអប្បបរមាដែលត្រូវការដើម្បីបង្កើតបានជាគ្រួសារមួយអាចត្រូវគិតថាមានចំនួនពីរនាក់ ហើយស្ទើរតែមិនអាចថាចំនួនសមាជិកមធ្យមនៅក្នុងគ្រួសារមួយមានចំនួនពីរឡើយ ប៉ុន្តែ ក្នុងករណីមិនមានភស្តុតាងដែលអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានផ្សេងពីនេះទេ (ដូចដែលបានធ្វើនៅក្នុងសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹងគ្រួសារចាម)[270] គឺត្រូវយកចំនួនមធ្យមពីរនាក់ជាការប៉ាន់ស្មានចំនួនសមហេតុផលអប្បបរមាទាបបំផុត។

## ៤.៦ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស

146. បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស (“បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស”)[271] ត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៅក្នុងសំណុំរឿងនេះដើម្បីបញ្ជាក់ពីកាលបរិច្ឆេទ ដែលអ្នកទោសចូលមន្ទីរ ស ២១ ហើយក្នុងករណីដែលមានការបញ្ជាក់បែបនេះ ក៏បញ្ជាក់ពីកាលបរិច្ឆេទសម្លាប់អ្នកជាប់ឃុំនៅ ស ២១ និងចំនួនមនុស្សដែលបានបញ្ជូនទៅ ស ២១ និង/ឬត្រូវបានសម្លាប់នៅ ស ២១ បន្ទាប់ពីជាប់ឃុំនៅ ស ២១។ ការប្រើប្រាស់ជាមូលដ្ឋានបែបនេះគឺជាការសមស្រប ដោយសារថា អ្នកវិភាគនៅ ក.ស.ច.ស បានធ្វើការវិភាគគ្រប់ជ្រុងជ្រោយនិងចំណាយពេលច្រើន ហើយបានប្រើប្រាស់វិធីសាស្ត្ររឹងមាំដើម្បីរៀបចំបញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស[272]។

## ៤.៧ លិខិតធានា

147. លិខិតធានាបានប្រគល់ជូនសាក្សីដែលស្នើសុំលិខិតបែបនេះ យោងតាមវិធានផ្ទៃក្នុង ២៨[273]។ បទពិសោធន៍កន្លងមកបានបង្ហាញឱ្យឃើញថា ការផ្តល់ការធានាបែបនេះ មិនប្រាកដថា ធ្វើឱ្យសាក្សី

---

[270] **សំណុំរឿងលេខ ០០៤/២-ឯកសារ D360** *[កោសលុប] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ១៥០-១៥៤។

[271] **ឯកសារ D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ EN ERN 01222328-01222936។

[272] **ឯកសារ D322/8** *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឯកសារ ប.ក.ក ទៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ៤៧។ **ឯកសារ D219/825.1.1** *របាយការណ៍នៃសកម្មភាពស៊ើបអង្កេត* ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ERN 01399603-01399605។

[273] សូមមើល **ឯកសារ D54/99/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក ឡាយ ប៊ុនហាក់* ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤។ **ឯកសារ D54/98/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក ហៀង រ៉េត* ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥។ **ឯក**

មិនស្ទូវស្ទាក់ស្ទើរក្នុងការពិភាក្សាអំពីហេតុការណ៍នានាឡើយ ជាពិសេសក្នុងករណីដែលមានការបង្ហាញឲ្យឃើញថា សាក្សីអាចបានចូលរួមជាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពឧក្រិដ្ឋ។ នេះទំនងជាដោយសារចង់រក្សា "មុខមាត់" ហើយចៀសវាងកុំឲ្យពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកជនជាតិកម្ពុជាខ្លួនឯង។ ហេតុនេះ ភាពអាចជឿជាក់បានលើសាក្សីមួយចំនួនត្រូវបានវាយតម្លៃតាមខ្លឹមសារនៃសក្ខីកម្មរបស់សាក្សីទាំងនោះ និងយោងលើលទ្ធភាពដែលថាសាក្សីនោះអាចបានចូលរួមពាក់ព័ន្ធជាមួយនឹងអំពើឧក្រិដ្ឋដែលបានចោទទោះបីជាបានប្រគល់លិខិតធានាក៏ដោយ។

## ៤.៨ ការព្យាយាមស្វែងរកជំនួយពីប្រទេសវៀតណាម ប្រទេសថៃ និងអង្គការសហប្រជាជាតិ

148. មានការព្យាយាមជាច្រើនលើកច្រើនសា ដើម្បីស្វែងរកជំនួយពីប្រទេសវៀតណាម និងប្រទេសថៃពាក់ព័ន្ធនឹងការទទួលបានឯកសារ និងចូលពិនិត្យមើលបណ្ណសារសម័យកម្ពុជាប្រជាធិបតេយ្យរបស់ប្រទេសទាំងនោះ ដែលអាចមានភ័ស្តុតាងពាក់ព័ន្ធ ជាពិសេសទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[274] តែចុងក្រោយ ការ

---

**សារ** **D54/46/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក អែម សុន* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។ **ឯកសារ** **D54/46/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក អែម សុន* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។ **ឯកសារ** **D54/87/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោកព្រំ សារ៉ាត់* ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤។ **ឯកសារ** **D54/112/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក ឡុង ឈោ* ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០១៤។ **ឯកសារ** **D54/106/1** *លិខិតធានារបស់ ស.ច.ស.អ ផ្ញើជូនលោក សាន កាន* ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤។ **ឯកសារ** **D114/79/1** *លិខិតធានារបស់ ស.ច.ស.អ* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។ **ឯកសារ** **D114/158/1** *លិខិតធានារបស់ ស.ច.ស.អ* ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦។

[274] **<u>ប្រទេសវៀតណាម៖</u>** អនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ D93៖ ឯកសារ **D93/14** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D93/13** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D93/12** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ឯកសារ **D93/11** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ **D93/10** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ឯកសារ **D93/9** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ **D93/8** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D93/7** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D93/6** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D93/5** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D93/4** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី

---

០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D93/3/1** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤, ឯកសារ **D93/3** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ឯកសារ **D93/2** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D93/1** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D93** *ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ (ប្រទេសវៀតណាម)* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣។ អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ D94៖ ឯកសារ **D94/13** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D94/12** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D94/11** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ឯកសារ **D94/10**, *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ **D94/9** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ឯកសារ **D94/8** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ **D94/7** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D94/6** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D94/5** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D94/4** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D94/3** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D94/14/1** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤, ឯកសារ **D94/14** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ឯកសារ **D94/2** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D94/1** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D94** *ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ (ប្រទេសវៀតណាម)* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣។ អនុលោមតាម ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ D95៖ ឯកសារ **D95/13** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D95/12** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D95/11** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ឯកសារ **D95/10** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ **D95/9** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ឯកសារ **D95/8** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ **D95/7** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D95/6** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D95/5** *ចម្លើយរបស់ក្រសួងការបរទេស និងសហ*

*ប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D95/3** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D95/4** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D95/14/1** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤, ឯកសារ **D95/14** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ឯកសារ **D95/2** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជា* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D95/1** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D95** *ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ (ប្រទេសវៀតណាម)* ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣។ **<u>ប្រទេសថៃ៖</u>** <u>អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ D96៖</u> ឯកសារ **D96/12** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D96/11** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D96/10** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ឯកសារ **D96/9** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំកម្ពុជា* ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ **D96/8** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ឯកសារ **D96/7** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ **D96/6** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D96/5** *លិខិតរបស់ ស.ច .ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D96/4** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D96/3/1** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤, ឯកសារ **D96/3** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ឯកសារ **D96/2** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំកម្ពុជា* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D96/1** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D96** *ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ (ប្រទេសថៃ)* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។ <u>អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ D97៖</u> ឯកសារ **D97/13** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D97/12** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៥, ឯកសារ **D97/11** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥, ឯកសារ **D97/10** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំកម្ពុជា* ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ **D97/9** *លិខិតឆ្លើយតបរបស់លោក Miguel de Serpa Soares ក្នុងនាមអគ្គលេខាធិការ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤, ឯកសារ **D97/8** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤, ឯកសារ **D97/7** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D97/6** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤, ឯកសារ **D97/5** *ចម្លើយរបស់ក្រសួងការបរទេស និងសហ*

ព្យាយាមទាំងនេះមិនបានទទួលលទ្ធផលផ្លែផ្កាទេ[275]។ ស្រដៀងគ្នាដែរ អង្គការសហប្រជាជាតិមិនបានផ្តល់ឯកសារសម្ងាត់ពីបណ្ណសាររបស់ខ្លួន ពាក់ព័ន្ធនឹងការចរចាបង្កើត អ.វ.ត.ក ឡើយ[276]។

## ៥. ការវិភាគអង្គហេតុ និងសំអាងហេតុ

### ៥.១ រចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា និងតួនាទី និងការទទួលខុសត្រូវរបស់ មាស មុត

#### ៥.១.១ កងទ័ពបដិវត្តកម្ពុជា និងគណៈកម្មាធិការមជ្ឈិម/អចិន្ត្រៃយ៍

149. កងទ័ពបដិវត្តកម្ពុជារួមចំណែកកសាងប្រទេស និងការពារជាតិ[277] ប្រឆាំងនឹង "ខ្មាំង" ខាងក្នុង និងខាងក្រៅ[278] ដូចមានចែងលម្អិតបន្ថែមនៅខាងក្រោម[279]។

---

*ប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D97/4** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំកម្ពុជា* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D97/3** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤, ឯកសារ **D97/14/1** *ចម្លើយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤, ឯកសារ **D97/14** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ឯកសារ **D97/2** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំកម្ពុជា* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D97/1** *លិខិតរបស់ ស.ច.ស.អ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣, ឯកសារ **D97** *ដីកាចាត់ឱ្យស៊ើបសួរជំនួសអន្តរជាតិ (ប្រទេសថៃ)* ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

[275] ឯកសារ **D210** *របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស* ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

[276] ឯកសារ **D181/1** *សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ* ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦, ឯកសារ **D181/1.1** *លិខិតរបស់អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

[277] ឯកសារ **D1.3.22.2** រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៦ ERN 00089850 មាត្រា ១៩។

[278] ឯកសារ **D4.1.861** ទស្សនាវដ្តីទង់បដិវត្ត លេខ៨ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧៥ ERN 00063340។ ឯកសារ **D1.3.27.10** កំណត់ហេតុនៃកិច្ចប្រជុំលេខា និងអនុលេខាកងពលធំ និងអនុលេខាវរៈសេនាធំ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៦ ERN 00052360 ។ ឯកសារ **D1.3.27.26** កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពលធំ និងវរៈសេនាធំឯករាជ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ ERN 00052307។ ឯកសារ **D1.3.27.19** កំណត់ហេតុនៃកិច្ចប្រជុំការងារបង្កើនផល ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ERN 00088913។ ឯកសារ **D1.3.27.26** កំណត់ហេតុនៃកិច្ចប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំឯករាជ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ ERN 00052310។ ឯកសារ **D1.3.27.4** កំណត់ហេតុនៃអង្គប្រជុំសន្និបាតរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ERN 00053615។ *សូមមើលផងដែរ* ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00053011 កថាខណ្ឌ ៦ ERN 00053035 ជំពូក ៦។

150. កងទ័ពបដិវត្តកម្ពុជាត្រូវស្ថិតក្រោម *"ការដឹកនាំផ្ដាច់មុខ ដាច់ខាត និងគ្រប់ផ្នែក"* របស់ ប.ក.ក[280] ។ គណៈកម្មាធិការមជ្ឈិម ប.ក.ក (ដែលរួមមានសមាជិកបក្សជាន់ខ្ពស់បំផុត ដូចជា ប៉ុល ពត អៀង សារី សុន សេន វ៉ន វេត ខៀវ សំផន និង នួន ជា)[281] មានភារកិច្ចចាត់តាំងកងទ័ពបដិវត្តកម្ពុជា[282] ទោះជាយ៉ាងនេះក្ដីគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក (ដែលរួមមាន ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន) [សមាជិកបម្រុង)[283] ធ្វើការគ្រប់គ្រង *ជាក់ស្ដែង*[284]។ គណៈកម្មាធិការមជ្ឈិមក៏ទទួលបានជំនួយក្នុងចំណោមគណៈកម្មាធិការផ្សេងៗទៀត ពីគណៈកម្មាធិការកងទ័ព ដែលមាន ប៉ុល ពត ជាប្រធាន និងមាន **មាស មុត** និង ស៊ូ ម៉េត ដែលជាជំនួយការពីរនាក់ក្នុងចំណោមជំនួយការទាំងបួននាក់របស់គណៈកម្មាធិការនេះ[285]។ ចំណុចនេះបញ្ជាក់ថា ពួកគេស្ថិត

---

[279] *សូមមើល* សំអាងហេតុស្ដីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧៧-១៨៤។

[280] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00053035 មាត្រា ២៧។

[281] ឯកសារ **D114/158** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202343 ឆ.៣៥។

[282] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00053035 មាត្រា ២៨។

[283] ឯកសារ **D4.1.400** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00239832។ ឯកសារ **D1.3.33.3** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧ ERN 00146482។ ឯកសារ **D1.3.33.15** កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ERN 00156615។

[284] ឯកសារ **D98/1.2.42** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ [David Chandler] ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ERN (អង់គ្លេស) 00156615 បន្ទាត់ ៣-៨។ ឯកសារ **D1.3.33.15** កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ERN 00156750។ ឯកសារ **D1.3.33.11** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ERN 00146558។ ឯកសារ **D234/2.1.52** របាយការណ៍អ្នកជំនាញការដោយ Craig Etcheson ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 00314779 កថាខណ្ឌ ៦។ ឯកសារ **D54/74.1.20** Philip Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឆ្នាំ២០០៤ គ្រឹះស្ថានបោះពុម្ព John Murray ចក្រភពអង់គ្លេស ERN 001152675។

[285] ឯកសារ **D98/3.1.133** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ [នួន ជា] ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ERN 00767110។ ឯកសារ **D114/158** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202341 ឆ.៣៣។ ឯកសារ **D114/159** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202348 ឆ.៣-ឆ.៤។ ឯកសារ **D1.3.33.10** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨ ERN 00195568។

ក្នុងកម្រិត ឬថ្នាក់លើខ្ពស់បំផុតទីបួនរបស់បក្ស[286]។ ក្នុងឋានៈខ្លួនជាជំនួយការ **មាស មុត** បាន ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជាមួយនឹងសមាជិកជាន់ខ្ពស់ផ្សេងៗទៀតរបស់ ប.ក.ក[287]។ ជាងនេះទៀត នៅចុងឆ្នាំ១៩៧៨ គាត់បានក្លាយជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម[288]។

151. រហូតដល់ខែមេសា ឆ្នាំ១៩៧៥ កងពលធំទាំងអស់ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំភូមិភាគ[289] ដែលជាកម្រិតចាត់តាំង នៅក្រោមគណៈកម្មាធិការមជ្ឈិមផ្ទាល់[290]។ នៅខែកក្កដា ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធត្រូវបានរៀបចំឡើងវិញ ហើយកងពលធំមួយចំនួន ក្នុងនោះរួម មានកងពលធំ ១៦៤, ៣១០ និង ៥០២ ត្រូវបានដាក់ឲ្យស្ថិតក្រោមសិទ្ធិអំណាចរបស់សេនាធិការ ដែលទើបបង្កើតថ្មីៗដឹកនាំដោយ សុន សេន (*"បងឌី"*) និងជាថ្នាក់ក្រោមរបស់គណៈកម្មាធិការ មជ្ឈិម និងគណៈកម្មាធិការយោធា[291]។ កងកម្លាំងប្រដាប់អាវុធត្រូវបានរៀបចំសាឡើងវិញម្តង

---

[286] ឯកសារ **D1.3.33.13** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ ERN 00154911។ ឯកសារ **D1.3.33.11** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ERN 00146558-00146559។

[287] ឯកសារ **D114/158** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202341 ឆ.៣២។ ឯកសារ **D114/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202348 ឆ.៤ ERN 01202351 ឆ.១០។

[288] ឯកសារ **D114/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202353 ឆ.១៨។ *សូមមើលផងដែរ* ឯកសារ **D114/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127742 ឆ.៣២។

[289] ឯកសារ **D98/3.1.105** ប្រតិចារឹកនៃដំណើរការនីតិវិធីជំនុំជម្រះក្តីនៃសំណុំរឿង ០០១ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00406932។ ឯកសារ **D114/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01065140 ឆ.៩។

[290] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00053025 មាត្រា ៧។

[291] ឯកសារ **D98/1.2.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ERN 00796353-00796354។ ឯកសារ **D4.1.861** ទស្សនាវដ្តីទង់បដិវត្ត លេខ៨ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៧៥ ERN 00063324។ ឯកសារ **D98/1.2.18** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ERN 00795066។ ឯកសារ **D114/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01065140 ឆ.១០។ ឯកសារ **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រីន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ERN 00194465។ ឯកសារ **D4.1.858** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈៀន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373482។ ឯកសារ **D4.1.947** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ ERN 00320749។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី

ទៀត នៅខែ កញ្ញា-តុលា ឆ្នាំ ១៩៧៥ នៅពេលគណៈកម្មាធិការអចិន្ត្រៃយ៍បានអំពាវនាវឲ្យមានការចាត់តាំងកងទ័ពថ្មី កងទ័ពជើងទឹក និងកងទ័ពអាកាស[292]។

152. ដូច្នេះ បើទោះបីជាអង្គភាពកងទ័ពបដិវត្តកម្ពុជាទាំងអស់ស្ថិតក្រោមការបញ្ជាទាំងស្រុងរបស់សេនាធិការក៏ដោយ[293] ក៏អង្គភាពមួយចំនួនស្ថិតនៅក្រោមសេនាធិការដោយផ្ទាល់ ហើយអង្គភាពផ្សេងៗ

---

២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985322 ឆ.៦៩-ឆ.៧១។ ឯកសារ **D54/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00975783 ឆ.២៣។ ឯកសារ **D114/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ERN 01096735 ឆ.១២។ ឯកសារ **D114/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សាន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ERN 01110578 ឆ.១១។ ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138471 ឆ.១២៩-ឆ.១៣០។ ឯកសារ **D4.1.400** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00239838។ ឯកសារ **D4.1.1106** កំណត់ហេតុនៃការសួរចម្លើយអ្នកត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ERN 00164318។ ឯកសារ **D4.1.403** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242889។ ឯកសារ **D114/277.8** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ERN 01323373 បន្ទាត់ ១៣-១៧។ ឯកសារ **D98/3.1.306** ប្រតិចារឹកនៃសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [អ៊ុង រ៉ែន] ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ ERN 00877884 បន្ទាត់ ៦-៩។ ឯកសារ **D1.3.19.1** សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ERN 00003142។ ឯកសារ **D4.1.764** កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ERN 00398156។

[292] ឯកសារ **D1.3.27.1** កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ERN 00019114-00019120 ERN 00019124។ ឯកសារ **D4.1.805** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នោម សែ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00401315-00401316 ឆ.៣។ ឯកសារ **D114/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ERN 01096735-01096736 ឆ.១៦។

[293] ឯកសារ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ERN 00970618-00970618 ឆ.៤។ ឯកសារ **D54/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00975783 ឆ.២៣។ ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ម៉េន ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138471 ឆ.១៣៥-ឆ.១៣៧, ឆ.១៣៩។ ឯកសារ **D114/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171456 ឆ.៤៧។ ឯកសារ **D114/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127757-01127758 ឆ.១៤៥-ឆ.១៥៦។

ទៀតនៅបន្តស្ថិតក្រោមថ្នាក់ដឹកនាំភូមិភាគ[294]។ សេនាធិការក៏ធ្វើការគ្រប់គ្រងផងដែរលើមន្ទីរសន្តិសុខ ស-២១[295]។

153. នៅក្នុងក្បាលម៉ាស៊ីនយោធា និងស៊ីវិល ប.ក.ក បានធ្វើការបញ្ជាតាមឋានានុក្រម និងវិធីរាយការណ៍យ៉ាងតឹងរ៉ឹង៖ កម្រិតនីមួយៗត្រូវបានអនុញ្ញាតឱ្យធ្វើការប្រាស្រ័យទាក់ទងតែកម្រិតខ្ពស់ជាង និង/ឬកម្រិតក្រោមរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះ[296]។

---

[294] ឯកសារ **D54/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉េត ប៊ាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990387 ឆ.២៧ ERN 00990393 ឆ.៥៨។ ឯកសារ **D114/199** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ERN 01235325 ឆ.១០ ERN 01235327 ឆ.២២-ឆ.២៣។ ឯកសារ **D54/54** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ERN 00970657 ឆ.៤។ ឯកសារ **D114/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01096732-01071594 ឆ.៤-ឆ.៦។ ឯកសារ **D114/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ERN 01096733 ឆ.៩។ ឯកសារ **D114/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សាន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ERN 01110577-01110578 ឆ.១០-ឆ.១១។

[295] *សូមមើលមន្ទីរសន្តិសុខ ស-២១* កថាខណ្ឌ ១៦៤។

[296] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00053024 មាត្រា ៦(៤)-(៥) ERN 00053027 មាត្រា ១០(២)(ខ) ERN 00184042 មាត្រា ១៣(៤) ERN 00053031 មាត្រា ១៦(៤) ERN 00053032 មាត្រា ១៩(៤) ERN 00053035 មាត្រា ២៨។ ឯកសារ **D98/1.2.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ERN 00796339-00796340, ERN 00796342-00796343។ ឯកសារ **D98/1.2.32** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [សៅ សារុន] ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ERN 00814405 បន្ទាត់ ៧-១០ ERN 00814406 បន្ទាត់ ១៤-២០។ ឯកសារ **D98/3.1.248** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [នី កន] ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ERN 00812219 បន្ទាត់ ៨-២៤។ ឯកសារ **D98/1.2.4** ប្រតិចារឹកនៃដំណើរការនីតិវិធីជំនុំនៃសំណុំរឿង ០០១ [Craig Etcheson] ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ERN 00330503។ ឯកសារ **D98/3.1.117** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [ស្អួន កានិល] ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ERN 00871139-00871140, 00871148។ ឯកសារ **D98/3.1.116** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [ផាន់ វ៉ាន] ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ ERN 00870211។ ឯកសារ **D98/3.1.90** ប្រតិចារឹកនៃដំណើរការនីតិវិធីជំនុំនៃសំណុំរឿង ០០១ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ERN 00339554-00339555។ ឯកសារ **D98/1.2.46** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [នង សុផង់] ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ ERN 00844462 បន្ទាត់ ១៥-២២។ ឯកសារ **D98/3.1.316** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [យ៉ុន គីម] ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ERN 00818233-00818234។ ឯកសារ **D98/3.1.178** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [មាស រឿន] ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ERN 00851112-00851113។ ឯកសារ **D98/3.1.306** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [អ៊ុំ រ៉ែន] ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ ERN 00877857 បន្ទាត់ ១៧-១៩។ ឯកសារ **D98/3.1.307** ប្រតិចារឹកសវនាការ

### ៥.១.២ វរសេនាធំសម្ព័ន្ធកងពលធំ ១៦៤

154. កងពលធំ ៣ នៃភូមិភាគនិរតីបានកែប្រែទៅជាកងពលធំ ១៦៤[297]។ នៅខែមេសា ឆ្នាំ១៩៧៥ កងទ័ពនៃកងពលធំ ៣ បានធ្វើដំណើរចូលក្នុងទីក្រុងភ្នំពេញ ហើយក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេត្រូវបានផ្លាស់ទៅកំពង់សោម បន្ទាប់ពីរំដោះភ្នំពេញបានភ្លាមៗ[298]។ កងទ័ពមកពីអង្គភាពផ្សេងៗទៀតក៏ត្រូវបានបញ្ជូនទៅកំពង់សោមដែរ ហើយត្រូវបានដាក់ឱ្យស្ថិតក្រោមបញ្ជារបស់កងពលធំ ៣ ពោលគឺអង្គភាពពីតំបន់ ៣៧ នៃភូមិភាគបស្ចិម[299] ហើយទាហានជាច្រើននាក់មកពីតំបន់ ២២ និងវរៈសេនាធំ ១៥២ នៅភូមិភាគបូព៌ា[300]។ នៅរវាងខែកញ្ញា ឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ កងពលធំ ១៦៤ ថ្មី ត្រូវបានបង្កើតឡើងពីវរសេនាសម្ព័ន្ធគោល

---

លើអង្គសេចក្តីនៃសំណុំរឿង ០០២ [អ៊ុង រ៉េន] ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ERN 00878223 បន្ទាត់ ៣-១២ ERN 00878238, ERN 00878251-00878252។ ឯកសារ **D98/3.1.28** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [ឈួក រីន] ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៣ ERN 00902779-00902780, ERN 00902791-00902792។ ឯកសារ **D4.1.1056** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ERN 00485628 ឆ.១៨។

[297] ឯកសារ **D54/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉េត ប៉ាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990387 ឆ .២៧-ឆ២៨។ ឯកសារ **D114/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ERN 01096733 ឆ.៩។

[298] ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214203 ឆ .១៦-ឆ.១៧។ ឯកសារ **D114/132** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01154110-01154112 ឆ.១៣-ឆ.២២។

[299] ឯកសារ **D54/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹក អ៊ុយ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ERN 00988666 ឆ.៧, ឆ.៩។ ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136616-01136617 ឆ.១៤។ ឯកសារ **D114/194** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៦ ERN 01221865-01221866 ឆ.៥។

[300] ឯកសារ **D54/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន ថន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ERN 0988666 ឆ.៨, ឆ.១០-ឆ.១១ ERN 0988668-0988669 ឆ.២០។ ឯកសារ **D54/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964188 ឆ.២០។ ឯកសារ **D54/96** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តេង សារីម ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៤ ERN 00988679 ឆ.១២ ERN 00988680 ឆ.១៧-ឆ.១៨ ERN 00988681 ឆ.២០-ឆ.២១។ ឯកសារ **D54/97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 00988688-00988689 ឆ.១-ឆ.២ ERN 00988689-00988690 ឆ.៥-ឆ.៨ ERN 00988692 ឆ.១១-ឆ.១២។

នៃកងពលធំ ៣ និងមានអង្គភាពថ្នាក់ក្រោមដែលទើបតែបង្កើតឡើងថ្មីៗរបស់ខ្លួន[301]។ កងពលធំនេះ (ដែលរើសចេញពីកងវរៈសេនាធំ ៦១, ៦២ និង ៦៣) គឺជាកងទ័ពជើងទឹកដែលទើបបង្កើតថ្មី (កងវរៈសេនាធំ ១៤០) និងកងវរៈសេនាតូចឯករាជ្យមួយចំនួនទៀត[302]។ កងវរៈសេនាធំនីមួយៗត្រូវបានបែងចែកទៅជាកងវរៈសេនាតូច អនុសេនាធំ និងកងអនុសេនាតូច[303]។

155. កងពលធំ ១៦៤ គឺជា "កងពលមជ្ឈិម" ដែលរាយការណ៍ដោយផ្ទាល់ជូនសេនាធិការ[304]។ វាគឺជាកងពលធំ ធំជាងគេបំផុតក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យ មានចំនួនប្រហែល ៨.៥០០ នាក់[305]

---

[609] ឯកសារ **D54/71** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ ERN 00979265-00979266 ឆ.៣៨-ឆ.៤៦ ERN 00979267-00979269 ឆ.៥២-ឆ.៦៥។

[610] ឯកសារ **D114/41** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ERN 01065128-01065131 ឆ.៤-ឆ.១២។ ឯកសារ **D114/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី០៦ ខែកុម្ភៈឆ្នាំ ២០១៥ ERN 01065153-01065156 ឆ.១២-

ពេលដែលជនជាតិវៀតណាមមួយចំនួន ដែលបុគ្គលិកមន្ទីរសន្តិសុខ ស-២១ បានចាត់ទុកតាមតែទំនើងចិត្តថាជាចារកិច្ច ត្រូវបានសួរចម្លើយនោះ គ្រួសារនានាដែលត្រូវបានចាត់ទុកថាជា "អ្នកនេសាទ" មិនត្រូវបានសួរចម្លើយឡើយ ប៉ុន្តែត្រូវបានសម្លាប់ភ្លាមៗបន្ទាប់ពីពួកគេបានមកដល់មន្ទីរសន្តិសុខ ស-២១[611]។

224. សាក្សីម្នាក់អះអាងថា ក្នុងឆ្នាំ១៩៧៧ សុន សេន បានផ្តល់ដំបូន្មានដល់កងទ័ពជើងទឹកថា នៅពេលណាដែលទូកវៀតណាមត្រូវបានបញ្ឈប់ ប្រសិនបើអ្នកនៅលើទូកគឺជាជនភៀសខ្លួនដែលធ្វើដំណើរទៅកាន់ប្រទេសថៃ គួរដោះលែងពួកគេ ហើយអនុញ្ញាតឱ្យពួកគេបន្តដំណើរទៅមុខទៀត[612]។ សាក្សីដដែលក៏ជឿដែរថា អ្នកនេសាទវៀតណាមមិនត្រូវបានចាត់ទុកថាជាខ្មាំងឡើយ ពោលគឺជាការអះអាងមួយដែលត្រូវបានបង្ហាញថាមិនពិតដោយភស្តុតាងជាច្រើន[613]។ អតីតមន្ត្រីទំនាក់ទំនងម្នាក់បញ្ជាក់ថាជាការពិតចំពោះការរៀបរាប់ពីព្រឹត្តិការណ៍ដំណើររឿងនេះ ដោយលើកឡើងថាគាត់រំឭកបញ្ជាមួយដែលចេញពី សុន សេន ផ្តល់ទៅឱ្យ **មាស មុត** ថា ជនជាតិវៀតណាមគ្មាន

---

ឆ.២៣។ ឯកសារ **D114/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ERN 01120972 ឆ.៣០-ឆ.៣១, ERN 01120973-01120974 ឆ.៣៥-ឆ.៣៩។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ERN 00985333 ឆ.១២៩ ERN 00985334-00985335 ឆ.១៣៥-ឆ.១៣៧។ ឯកសារ **D4.1.5** អត្ថបទព័ត៌មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា៖ "បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរ ស-២១" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ERN 00339070-00339083។

[611] ឯកសារ **D114/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01065156 ឆ.២១-ឆ.២៣។

[612] ឯកសារ **D54/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉េត ប៉ាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990395 ឆ.៧៥។

[613] ឯកសារ **D54/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រ៉េត ប៉ាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990394 ឆ.៧០។ ឯកសារ **D54/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ កាន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ERN 00993383-00993384 ឆ.៤១-ឆ.៤២។ ឯកសារ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ERN 00955488 ឆ. ៣១-ឆ.៣២។ ឯកសារ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00955548-00955549 ឆ.២៣។ ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982552 ឆ.២៣។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៤ ERN 00985323 ឆ.៧៥ ERN 00985324 ឆ.៨៣, ERN 00985329 ឆ.១០៩-ឆ.១១០, ERN 00985330 ឆ.១១៥។ ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125468 ឆ.៥៨-ឆ.៥៩។ ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01184098-01184099 ERN 01184101-01184102។

អាវុធដែលត្រូវបានចាប់ខ្លួន គួរត្រូវបានដោះលែង[614]។ ទោះជាយ៉ាងណា ប៉ាក សុខ ដែលដំបូងឡើយបានឈរជើងនៅលើកោះពូលូវៃជាមួយកងវរសេនាធំលេខ ៦២ នៃកងពលធំលេខ ១៦៤ ហើយក្រោយមកបានចូលរួមជាមួយកងទ័ពជើងទឹក (កងវរសេនាធំលេខ ១៤០) មិនធ្លាប់បានឮពីការណ៍នេះឡើយ និងថ្លែងថា ការណែនាំដែលគាត់បានឮគឺមានតែការបញ្ជាឱ្យចាប់ជនជាតិវៀតណាមប៉ុណ្ណោះ[615]។ ភស្តុតាងដែលបង្ហាញពីជោគវាសនារបស់ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួន មិនគាំទ្រនោះទេដល់សេចក្តីសន្និដ្ឋានថា ពិតជាមានការចេញបញ្ជានេះ ឬថា បញ្ជារបស់ សុន សេន ត្រូវបានអនុវត្ត បើមានការចេញបញ្ជានេះមែន។

៥ ៣.៤.ប្រតិបត្តិការរួមរបស់កងពលធំលេខ ១ និងកងពលធំលេខ ១៦៤ ក្នុងខេត្តកោះកុង

225. នាវាបរទេសមិនត្រឹមតែត្រូវបានចាប់ឃាត់ទុកនៅក្នុងដែនសមុទ្រកំពង់សោម ដែនកោះ និងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៤ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងដែនសមុទ្រខេត្តកោះកុងទៀតផង[616] ដោយមានកងពលធំលេខ ១៦៤ និងអង្គភាពរបស់កងពលធំលេខ ១ ក្នុងខេត្តកោះកុង[617]។

226. កងពលធំលេខ ១៦៤ មាននាវា PCF ពីរគ្រឿងប្រចាំការណ៍នៅកោះកុង ដើម្បីស្ទាក់ចាប់នាវាបរទេស ដោយស្ថិតក្រោមបញ្ជារបស់ ស៊ីម។ នៅពេលកម្មាភិបាលយោធានៃកងពលធំលេខ ១ រកឃើញនាវាបរទេស ពួកគេនឹងផ្តល់ដំណឹងដល់ ស៊ីម ដែលទាក់ទងទៅ មាស មុត ដើម្បីស្នើសុំការណែនាំ។ កងពលធំលេខ ១ ត្រូវពឹងផ្អែកលើកងពលធំលេខ ១៦៤ ដើម្បីស្ទាក់ចាប់នាវាបរទេស

---

[614] ឯកសារ **D114/211** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុផង់ នង ERN 01247508 ឆ.៣៩។

[615] ឯកសារ **D114/297.1.21** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ] ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០១៦ ERN 01193830-01193834 បន្ទាត់ ២៥-១៦ ERN 01193834-0119385 បន្ទាត់ ១៦-១០។

[616] សូមមើល ឯកសារ **D1.3.34.66** ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ (ទូរលេខ ០១) ផ្ញើដោយ សឿង ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៨ ERN 00020980។ ឯកសារ **D1.3.12.18** របាយការណ៍ផ្ញើពី មាស មុត ជូន សុន សេន ពាក់ព័ន្ធនឹងស្ថានភាពដែនទឹកជាប់នឹងថៃ ចុះថ្ងៃទី២៩ខែឧសភា ឆ្នាំ១៩៧៧ ERN 00162487។

[617] ឯកសារ **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ERN 00970643-00970650 ឆ.១-ឆ.៣២។ ឯកសារ **D45/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964221 ឆ.៥ ERN 00964222 ឆ.១២។ ឯកសារ **D234/2.1.95** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ (មាស វឿន) ថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ ២០០៦ ERN 01394586-01394588។ ឯកសារ **D1.3.34.23** ទូរលេខ ២៨ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ស្តីពីយន្តហោះខ្មាំងប្រតិកម្ម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ERN 00020910។

ព្រោះមានតែកងពលធំលេខ ១៦៤ ទេដែលមាននាវាសម្រាប់ស្ទាក់ចាប់នាវាបរទេស[618]។ បន្ទាប់ពីចាប់ឃាត់ទូកបាន ស៊ីម ជូនដំណឹងដល់កងពលធំលេខ ១៦៤[619]។

227. អ៊ឹង ផុន ដែលជាអ្នកក្រោមបង្គាប់ម្នាក់របស់ ស៊ីម នៅកោះកុង[620] លើកឡើងថា ស៊ីម គ្មានអំណាចសម្រេចចិត្តលើទូកដែលចាប់បានឡើយ និងត្រូវអនុវត្តតាមបញ្ជារបស់កងពលធំលេខ ១៦៤[621]។ ផ្អែកតាមបទបញ្ជាដែលផ្សព្វផ្សាយដោយ ស៊ីម នៅពេលពួកគេចូលទៅជិតទូកនេសាទថៃ ពួកគេបាញ់សំដៅទៅអ្នកនេសាទ ដើម្បីបង្ខំឱ្យអ្នកនេសាទលោតទៅក្នុងទឹក។ ប្រសិនបើពួកគេហ៊ាននៅក្នុងទូក ពួកគេនឹងត្រូវបានបាញ់សម្លាប់។ សាក្សីរូបនេះលើកឡើងថា អង្គភាពរបស់គាត់មិនដែលចាប់បានមនុស្សទាំងរស់ទេ ទោះជាជនជាតិថៃ ឬវៀតណាមក៏ដោយ លើកលែងតែជនភៀសខ្លួនវៀតណាម ២៣ នាក់ដែលត្រូវបានបញ្ជូនទៅកំពង់សោម[622]។ ឯកសារដែលមានអាយុកាលស្រដៀងគ្នាបង្ហាញថា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧ ស៊ីម បានរាយការណ៍ទៅ សុន សេន និង **មាស មុត** ស្តីពីការចាប់បានទូកពីរនៅដែនសមុទ្រកោះកុង។ ស៊ីម បានបញ្ជាក់ថា ចំពោះ មនុស្សគ្មានបានទេ

---

[618] ឯកសារ **D54/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ERN 00970612 ឆ.១៩-ឆ.២០។ ឯកសារ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ERN 00970622-00970624 ឆ.១៧-ឆ.២០។ ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ERN 00970633 ឆ.១៧ ERN 00970637-00970638 ឆ.៣៣-ឆ.៣៥។ ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ផុន ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ERN 00964221 ឆ.៥ ERN 00964222-0096423 ឆ. ១១-ឆ.១៤។ សូមមើលផងដែរ ឯកសារ **D4.1.639** ទូរស័ព្ទសម្ងាត់ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ERN 00143520។

[619] ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ផុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964225 ឆ.២១។ ឯកសារ **D1.3.34.28** សេចក្តីរាយការណ៍តាមទូរស័ព្ទសម្ងាត់ជូនបងកងពល ERN 00161729 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារ **D2/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ ERN 00607097-00607098 ឆ.៤៧-ឆ.៥៤។

[620] ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ផុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964221 ឆ.៥ ERN 00964221 ERN 00964224 ឆ.១៧។

[621] ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ផុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964221 ឆ.៥ ERN 00964225 ឆ.២១-ឆ.២៣។

[622] ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ផុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964221 ឆ.៥ ERN 00964223-00964224 ឆ.១៥-ឆ.១៩ ERN 00964227 ឆ.២៨-ឆ.៣០ ឆ.៣២។ សូមមើលផងដែរ ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00970634-00970635 ឆ.១៨-ឆ.២៥។ ឯកសារ **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៤ ERN 00970646 ឆ.១១-ឆ.១៤។

ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួន *"បងប្អូនកម្ទេចចោលអស់"*[623]។ ក្នុងរយៈពេលប្រហែលមួយឆ្នាំដែលគាត់បម្រើការនៅកោះកុង អ៊ឹង អុន ប៉ាន់ស្មានថា អង្គភាពរបស់គាត់ចាប់បាន *"តិចជាង ១០០ ទូក"*[624]។ មាស វឿន[625] ដែលជាមេបញ្ជាការរងនៃកងពលធំ លេខ ១ បានរំឭកថា ធ្លាប់ចាប់បានទូកនេសាទថៃ ៥០-៦០ គ្រឿង ប៉ុន្តែលើកឡើងថា អ្នកនេសាទ ស្ទើរតែទាំងអស់បានលោតចូលក្នុងទឹក នៅពេលកងទ័ពបដិវត្តន៍កម្ពុជាចូលជិតទូករបស់ពួកគេ[626]។

228. ក្នុងអំឡុងពេលប្រតិបត្តិការរួមគ្នាទាំងនេះ កម្មាភិបាលយោធានៃកងពលធំទាំងពីរ បានរាយការណ៍ទៅមេបញ្ជាការរបស់ខ្លួន ដូចជា **មាស មុត** (កងពលធំលេខ ១៦៤) និង សឿន (កងពលធំលេខ ១)។ ខណៈដែល សឿន និង **មាស មុត** មានឋានន្តរៈសក្តិដូចគ្នាក្នុងនាមជាមេបញ្ជាការកងពលធំ ដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ **មាស មុត** មិនត្រូវបានកំណត់ត្រឹមតំបន់មួយឡើយ ប៉ុន្តែរួមបញ្ចូលដែនសមុទ្រទាំងមូលរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ[627]។ ដូច្នេះ កងទ័ពជើងទឹករបស់ **មាស មុត** មានសិទ្ធិធ្វើប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់កងពលធំលេខ ១[628]។

---

[623] ឯកសារ **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ERN 00970645 ឆ. ៩។ ឯកសារ **D1.3.34.28** សេចក្តីរាយការណ៍តាមទូរស័ព្ទសម្ងាត់ជូនបងកងពល ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧ ERN 00161729 ។

[624] ឯកសារ **D54/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង អុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964221 ឆ.៥ ERN 00964225 ឆ.២០។

[625] ឯកសារ **D98/3.1.178** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ (មាស វឿន) ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ERN 00851110 បន្ទាត់ ១៦-ERN00851111 បន្ទាត់ ១។

[626] ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00970634-00970635 ឆ.១៨-ឆ.២៥។ ឯកសារ **D54/53** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៤ ERN 00970646 ឆ.១១-ឆ.១៤។ ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00970630-00970632 ឆ.២-ឆ.១២។

[627] ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00970630-00970632 ឆ.២-ឆ.១២។

[628] ឯកសារ **D54/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ERN 00970624 ឆ. ២៣។

229. អ្នកទោសដែលត្រូវបានចាប់ខ្លួនក្នុងដែនសមុទ្រកោះកុង ត្រូវបានបញ្ជូនទៅកំពង់សោម កោះតាគាវ ឬរាម[629]។ មាស វឿន បានរំឭកពីព្រឹត្តិការណ៍មួយដែលក្រោយពីបានជូនដំណឹងទៅកងទ័ពជើងទឹក ស្ដីពីការចាប់ខ្លួនអ្នកនេសាទថៃ ១០ នាក់ កម្មាភិបាលយោធានៃកងពលធំលេខ ១ បាននាំអ្នកទោស ទាំងនោះទៅកំពង់សោម ជាទីដែលទាហានកងពលធំលេខ ១ ឃាត់ខ្លួនអ្នកទោស។ នៅពេលចោទ សួរពីមូលហេតុដែលនៅពេលមួយ កម្មាភិបាលយោធានៃកងពលធំលេខ ១ ធ្វើប្រតិបត្តិការក្នុងដែន សមត្ថកិច្ចរបស់កងពលធំលេខ ១៦៤ សាក្សីរូបនេះមិនអាចផ្ដល់ការពន្យល់បានឡើយ[630]។

230. ឯកសារភស្ដុតាងបានបញ្ជាក់បន្ថែមទៀតពីការពាក់ព័ន្ធរបស់ **មាស មុត** និងការទទួលខុសត្រូវ របស់គាត់លើប្រតិបត្តិការរបស់កងទ័ពជើងទឹកក្នុងដែនសមុទ្រកោះកុង៖

- នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ **មាស មុត** បានរាយការណ៍ទៅ សុន សេន ថាទូក នេសាទដែលមានទាហានហែរហម ស្ថិតនៅចម្ងាយ ១៦ គីឡូម៉ែត្រពីឆ្នេរសមុទ្រកោះកុង។ ក្រៅពីនេះ គាត់បានរាយការណ៍ពីការប៉ះទង្គិចជាមួយទូកនេសាទថៃមួយគ្រឿងដែលកើត ឡើងនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦ ហើយចុងបញ្ចប់ ទូកនេសាទនោះត្រូវបានចាប់ទុក ចំណែកអ្នកនេសាទបានលោតចូលក្នុងទឹក[631]។

- នៅចន្លោះថ្ងៃទី១៥ ខែកក្កដា និងថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ កងពលធំលេខ ១៦៤ បាន រាយការណ៍ពីការប៉ះទង្គិចជាមួយទូកនេសាទថៃប្រដាប់អាវុធក្នុងខេត្តកោះកុង[632]។

---

[629] ឯកសារ **D54/34** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964225 ឆ.២១។ ឯកសារ **D54/52** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00970629-00970630 ឆ.១-ឆ.២។ ឯកសារ **D54/53** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ERN 00970643-00970650 ឆ.១-ឆ.៣២។ ។ ឯកសារ **D98/3.1.178** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ (មាស វឿន) ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ERN 00851115 បន្ទាត់ ៥-១៦។

[630] ឯកសារ **D54/53** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ERN 00970647-00970648 ឆ.១៧-ឆ.១៩។

[631] ឯកសារ **D1.3.8.3** កំណត់ហេតុនៃអង្គប្រជុំស្ដីពីការងារយោធានៅកំពង់សោម ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ ERN 00021496។ ឯកសារ **D1.3.34.10** ទូរលេខ ៤៤ ជំរាបជូនបង ៨៩ គោរពជ្រាប ស្ដីពីស្ថានភាពនៅខែសីហា ឆ្នាំ១៩៧៦ ERN 00000860។

[632] ឯកសារ **D1.3.12.7** របាយការណ៍សរុបសភាពការណ៍ចាប់ពីថ្ងៃទី១៥ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ ERN 00021503។

- នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ ក្នុងអំឡុងកិច្ចប្រជុំមួយរបស់កងពលធំលេខ ១៦៤ មានសេចក្ដីរាយការណ៍ថា នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៧៦ ទូកនេសាទថៃ ១០ គ្រឿងបានចូលក្នុងដែនសមុទ្រកោះកុង។ កម្មាភិបាលយោធានៃកងពលធំលេខ ១៦៤ បានចាប់ខ្លួនអ្នកនេសាទ ៨ នាក់ និងរាយការណ៍ថា អ្នកនេសាទ ៧ នាក់ទៀតបានលោតទឹកបាត់[633]។

- នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ក្នុងអំឡុងកិច្ចប្រជុំមួយរបស់លេខា និងប្រធានភស្តុភាររបស់កងពលធំ និងកងវរសេនាធំទាំងអស់របស់កងទ័ពបដិវត្តន៍កម្ពុជា **មាស មុត** បានរាយការណ៍ពីការកើនឡើងនៃចំនួនទូកនេសាទថៃ ដែលឈ្លានពានចូលក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ជាពិសេសក្នុងតំបន់នៅចន្លោះកោះរ៉ុង និងកោះកុង។ ក្បួនទូកនេសាទមានរហូតដល់ ១០០ ឬ ១៥០ គ្រឿង។ ក្រៅពីនេះ គាត់បានរាយការណ៍ពីការចាប់បានទូកមួយគ្រឿង កម្លាំង ៥០ សេះ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦[634]។

- នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ **មាស មុត** បានរាយការណ៍ទៅ សុន សេន និង នួន ជា ស្ដីពីបញ្ហាក្នុងការដោះដូរអ្នកទោសថៃ ដែលត្រូវបានចាប់ខ្លួននៅកោះកុង ដោយអង្គភាពកងទ័ពជើងទឹករបស់កងពលធំលេខ ១[635]។

## ៥ ៤.៤.ការសម្លាប់មនុស្សនៅលើដែនកោះរបស់កម្ពុជាប្រជាធិបតេយ្យ

231. អ្នកទោសបរទេសមិនត្រឹមតែត្រូវបាននាំខ្លួនទៅដីគោកក្រោយការចាប់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងត្រូវបានបញ្ជូនទៅដែនកោះនៅក្នុងដែនសមុទ្រកំពង់សោមទៀតផង។ នៅទីនោះ ពួកគេត្រូវបានសម្លាប់ ឬឃុំខ្លួន មុនពេលត្រូវបានបញ្ជូនទៅកន្លែងផ្សេងទៀត ឬដោះដូរ។ អតីតទាហានកងពលធំលេខ ១៦៤ ម្នាក់បានរំឭកឡើងវិញថា មានការផ្លាស់ប្ដូរនីតិវិធីក្រោយការចាប់បាននាវាបរទេសមួយគ្រឿង។ ដំបូង ជាទូទៅ ជនបរទេសដែលចាប់បាន ត្រូវបានបញ្ជូនត្រឡប់ទៅដីគោក

---

[633] ឯកសារ **D1.3.8.4** កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤៖ របាយការណ៍ស្ដីពីបញ្ហារៀនសូត្រនាវា ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN 00162489។

[634] ឯកសារ **D1.3.27.18** កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN 00052389-00052391។

[635] ឯកសារ **D54/53** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ERN 00970648-00970649 ឆ.២២-ឆ.២៤។ ឯកសារ **D1.3.30.25** របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ របស់កងពលធំលេខ ១៦៤ ផ្នែកនយោបាយ "ទូរស័ព្ទសម្ងាត់ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ ERN 00017026។

ដើម្បីយកទៅសម្លាប់នៅទីតាំងសម្លាប់មនុស្សចម្ការទុរេន និងទីតាំងផ្សេងទៀត[636]។ ប៉ុន្តែការអនុវត្ត នេះបាន ផ្លាស់ប្តូរនៅពេលក្រោយ ពោលគឺកងពលធំបានបញ្ជាឲ្យអង្គភាពកងទ័ពជើងទឹកសន្សំ សំចៃសាំងដោយដកហូតរបស់មានតម្លៃរបស់អ្នកទោស រួចសម្លាប់ពួកគេក្នុងដែនសមុទ្រ ឬនៅលើ កោះ ហើយសាកសពរបស់ពួកគេត្រូវបានប្រើប្រាស់ជាជីសម្រាប់ដើមដូង[637]។

*៥តាងកោះ ១.៤.៤.*

232. ជនជាតិថៃ និងជនជាតិវៀតណាមខ្លះដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ ក្នុងនោះរួមទាំងស្ត្រី និង កុមារ ត្រូវបានបញ្ជូនទៅកោះតាង ហើយពួកគេត្រូវបានសម្លាប់នៅលើកោះនេះដោយទាហាននៃ កងវរសេនាតូច ៦២ នៃកងពលធំ ១៦៤ ដែលមានទីបញ្ជាការនៅលើកោះនេះ[638]។ បន្ទាប់ពីទូក

---

[636] ឯកសារ **D2/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤០-ឆ.៤៣។ ឯកសារ **D2/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN 00623889 ឆ.៧-ឆ.១៣, ERN 00623892 ឆ.៤៦។ ឯកសារ **D54/24.1** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ ERN 00955510-00955511 *ដូចបានបញ្ជាក់នៅក្នុង* ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ (ប៉ាក សុខ) ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01184082 បន្ទាត់ ១១-១៣ ERN 01184082 បន្ទាត់ ១៣-២៥ ERN 01184083 បន្ទាត់ ១-៤ ERN 01184083 បន្ទាត់ ៥-២៥ ERN 01184084 បន្ទាត់ ១។ ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០១៤ ERN 00992752 ឆ.២៩។ ឯកសារ **D114/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ERN 01025096 ឆ.៧, ERN 01025099 ឆ.២០។ *សូមមើលផងដែរ ទីតាំងសម្លាប់មនុស្សចម្ការទុរេន* កថាខណ្ឌ ២៦៥។

[637] ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353859 ឆ.៦៣។ ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992755-00992756 ឆ.៤១-ឆ.៤៤។

[638] ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 01127732-01127734 ឆ.៣២-៤៤។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353857-01353859 ឆ.៥៧-៦៣។ ឯកសារ **D54/78** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ ERN 00982540 ឆ.១០។ ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136622 ឆ.៣៦ ERN 01136622 ឆ.៤៤។ ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គឹម ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138474 ឆ.១៦៤។ ឯកសារ **D54/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន សាន់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ERN 00993380 ឆ.២៥, ឆ.២៦, ERN 00993392-00993394 ឆ.៨០-ឆ.៨៧។ ឯកសារ **D114/57** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ERN 01077735-01077737 ឆ.១១-២២ ERN 01077737-01077738 ឆ.២៦-ឆ.២៨។ ឯកសារ **D114/132** កំណត់ហេតុនៃការស្តា

01600653



ល្បាតល្បឿនលឿនចាប់បាន ទូកនេសាទ ពួកគេត្រូវរាយការណ៍ទៅទីបញ្ជាការកងពល[639]។ បន្ទាប់មក **មាស មុត** រាយការណ៍ជូនអគ្គសេនាធិការអំពីការចាប់បានទូកបរទេស នៅជិតកោះតាង[640]។

233. សាក្សីពីរនាក់បញ្ជាក់ថា ពួកគេមិនបានឃើញអ្នកទោសថៃ និងវៀតណាមនៅកោះតាង[641]។ រយៈពេលដ៏ខ្លីដែលពួកគេបាននៅលើកោះនេះ ឬការពិតដែលថា ពួកគេបានស្នាក់នៅទីតាំងជាក់លាក់ដោយមិនបានឃើញកោះទាំងមូលនោះ គឺជាកត្តាពាក់ព័ន្ធ នៅពេលពិចារណាភស្តុតាង *ពាក់ព័ន្ធ* របស់សាក្សីនានាដែលផ្តល់សក្ខីកម្មខុសពីនេះ។ សាក្សីម្នាក់ទៀតបានលើកឡើងថា គាត់មិនធ្លាប់បានឃើញការចាប់កប៉ាល់ ឬជនបរទេស នៅកោះតាង ប៉ុន្តែបានទទួលព័ត៌មានពីទាហានដែលជាមិត្តភក្តិនៅលើកោះ ពិភាក្សាពីការចាប់ខ្លួនជនបរទេស។ អង្គភាពរបស់គាត់ផ្ទាល់មិនបានពាក់ព័ន្ធនោះទេ[642]។ អតីតអ្នកដាំដំឡូងនៅលើកោះបានបដិសេធថា កងទ័ពនៅលើកោះនេះមិនបានចាប់ខ្លួនជនបរទេស។ ទោះជាយ៉ាងណាក៏ដោយ គាត់បញ្ជាក់ថា ប្រសិនបើមើលឃើញទូកបរទេស ទាហាននៅលើកោះអាចស្នើសុំអន្តរាគមន៍ពីទូកល្បឿនលឿនពីរាមបាន[643]។

---

ប់ចម្លើយសាក្សី ម៉ៅ ភ៉ន់ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ ERN 01154122-01154125 ឆ.៩១-១១០។ សូមមើលផងដែរ ឯកសារ **D1.3.8.3** កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ ERN 00021496។

[639] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136622 ឆ.៣៨-៣៩។

[640] ឯកសារ **D1.3.8.4** កំណត់ហេតុនៃការប្រជុំ ស.ម ១៦៤៖ រាយការណ៍បញ្ហារៀនសូត្រនាវា ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN 00162488។ ឯកសារ **D1.3.8.3** កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ ERN 00021496។ ឯកសារ **D1.3.34.64** ទូរស័ព្ទសម្ងាត់ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ERN 00020982។ ឯកសារ **D1.3.27.18** កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN 00052389-00052391។

[641] ឯកសារ **D114/130** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ERN 01151947 ឆ.៥៧-៥៨, ERN 01151948 ឆ.៧៥។ ឯកសារ **D114/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹន សេង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01111034 ឆ.31-A32។ ឯកសារ **D114/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ផ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01145816 ឆ.២០, ERN 01145823 ឆ.៦៦។

[642] ឯកសារ **D114/122** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផន ណុប ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៥ ERN 01145832 ឆ.២៦, ERN 01145832 ឆ.២៩, ERN 01145833-01145834 ឆ.៣៧-៤៤។

[643] ឯកសារ **D114/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ERN 01134409 ឆ.៨០-៨៨។

234. ម៉េន គីម ដែលជាសមាជិកនៃអង្គភាពបញ្ជាការកងវរសេនាតូចលើកោះតាង បានដឹងថា កងនាវាបាញ់កាំភ្លើងទៅលើទូកនេសាទបរទេសមួយចំនួន បានចាប់ខ្លួន និងបាញ់អ្នកនេសាទថៃដែលបន្ទាប់មកត្រូវបានបញ្ជូនទៅកំពង់សោម[644]។ ទោះជាយ៉ាងនេះក្តី គាត់អះអាងថា គាត់មិនធ្លាប់បានឃើញជនបរទេសណាមួយនៅលើកោះនេះទេ[645]។ នៅក្នុងការវាយតម្លៃពីភាពអាចជឿទុកចិត្តបានរបស់គាត់ តួនាទីរបស់គាត់នៅក្នុងកម្រិតបញ្ជាការកងវរសេនាតូចនេះមានការពាក់ព័ន្ធជាពិសេសពីព្រោះគាត់អាចបានចូលរួម ឬយ៉ាងហោចណាស់មានការដឹងឮដោយផ្ទាល់ពីការសម្លាប់មនុស្សដែលត្រូវបានប្រព្រឹត្តនៅលើកោះ។ បើទោះបីជាសាក្សីរូបនេះត្រូវបានផ្តល់ការធានាថា គាត់នឹងមិនត្រូវបានធ្វើទុកបុកម្នេញក៏ដោយ[646] ក៏គាត់នៅតែមិនចង់ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់គាត់ និងកិត្តិយសរបស់អ្នកដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យដែលគាត់នៅតែមានអារម្មណ៍កោតសរសើរពួកគេយ៉ាងខ្លាំង[647]។

235. នៅពេលពិចារណាលើភស្តុតាងជារួម ព័ត៌មានរបស់សាក្សីដែលមិនបានដឹងពីការចាប់ខ្លួន និងការសម្លាប់នៅកោះតាង មិនអាចជឿជាក់បាន ឬមិនគួរឲ្យទុកចិត្តបានទេ ពីព្រោះព័ត៌មានទាំងនោះមានលក្ខណៈផ្ទុយគ្នាទៅនឹងការសង្កេតផ្ទាល់របស់សាក្សីផ្សេងៗទៀត។ ឧទាហរណ៍ អ៊ុំ សុខន បានចូលរួមដោយផ្ទាល់ក្នុងការចាប់ខ្លួនអ្នកនេសាទថៃ ដែលពួកគេក្រោយមកត្រូវបានបញ្ជូនទៅកោះតាង និងដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ទាហាននៃកងវរសេនាតូច ៤២០[648]។ ឯក នី បានឃើញដោយផ្ទាល់នូវការចាប់ខ្លួនប្រជាជនវៀតណាម និងថៃដែលក្រោយមកត្រូវបានបញ្ជូនទៅ

[644] ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គីម ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138473 ឆ.១៥៥-១៥៦។

[645] ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គីម ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138476 ឆ. ១៨៦។

[646] ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គីម ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138487 ឆ. ២៦១។

[647] ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គីម ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138484 ឆ. ២៤៣។

[648] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136622 ឆ.៣៦, ERN 01136624 ឆ.៤៤។

កោះតាង[649] ហើយបានបញ្ជាក់ថា នៅលើកោះតាង សាកសពប្រមាណជា ២៥០ នាក់ប៉ុណ្ណោះត្រូវបានកប់នៅគល់ដូង[650]។

*៥.៤.៤.២ កោះរ៉ុង (កោះរ៉ុងធំ និងកោះរ៉ុងសន្លឹម)*

236. កោះរ៉ុងគឺជាកោះពីរដែលស្ថិតនៅភាគខាងត្បូងនៃឆ្នេរសមុទ្រកំពង់សោម[651]។ កោះរ៉ុងដែលត្រូវបានហៅថា កោះរ៉ុងធំ និងកោះរ៉ុងក្រៅ[652] គឺជាកោះដ៏ធំផ្សំឡើងដោយកោះចំនួនពីរ[653] និងស្ថិតនៅភាគខាងជើងនៃកោះរ៉ុងសន្លឹម[654] (ត្រូវបានហៅថា កោះរ៉ុងភ្លើងហ្វា និងកោះរ៉ុងក្នុង)[655]។ មានម្តងនោះ សាក្សីម្នាក់បានចាត់ទុកកោះរ៉ុងសន្លឹមថាជាកោះរ៉ុង ដោយបញ្ជាក់ថា សាក្សីផ្សេងៗទៀតអាចហៅដូចនេះ ក្នុងពេលធ្វើការសើបអង្កេត។ បន្ទាប់ពីបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើភស្តុតាងនៅក្នុងផ្នែកនេះ បញ្ហានេះ ទោះជាយ៉ាងនេះក្តី ហាក់បីដូចជាពុំមានភាពធ្ងន់ធ្ងរនោះទេ[656]។ កោះ

[649] ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 01127732-01127734 ឆ.៣២-៤៤។

[650] ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353868 ឆ. ២២។

[651] ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 013533853-013533854 ឆ.៣៩។ ឯកសារ **D54/27.1** ផែនទីប្រជុំកោះ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ERN 00955554។

[652] ឯកសារ **D54/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈា ឡុង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ERN 00998655 ឆ. ៨១។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353849 ឆ. ២១។ ឯកសារ **D54/100** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ERN 00990732 ឆ.៧៨។

[653] ឯកសារ **D114/57** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ERN 01077735 ឆ. ៧។ ឯកសារ **D54/27.1** ផែនទីប្រជុំកោះ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ERN 00955554។

[654] ឯកសារ **D54/27.1** ផែនទីប្រជុំកោះ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ERN 00955554។

[655] ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 013533853-013533854 ឆ.៣៩។ ឯកសារ **D54/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នី ស៊ីម ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964165 ឆ.៣។ សូមមើលផងដែរ ឯកសារ **D114/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រៀង យឹម ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01121883 ឆ.៨៤។ ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ERN 01353050-01353052។

[656] ឯកសារ **D54/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈា ឡុង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ERN 00998655 ឆ .៨០-៨១។

ទាំងពីរស្ថិតក្រោមការបញ្ជារបស់កងពល ១៦៤ ដោយមានទាហានមកពីកងវរសេនាធំដែលមានមូលដ្ឋាននៅកោះរ៉ុង[657] និងទាហានកងវរសេនាតូច ៣៨៦ ដែលមានមូលដ្ឋាននៅកោះ រ៉ុងសន្លឹម។ កងវរសេនាធំ ១៤០ (គឺ កងទ័ពជើងទឹក) បើទោះជាមានទីបញ្ជានៅឆ្នេរអូរឈើទាល មានទូកល្បាតដែលចតនៅកំពង់ផែកោះរ៉ុងសន្លឹម[658]។ កោះទាំងនេះក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានបណ្តុះបណ្តាលសមាជិកនៃកងវរសេនាធំ ១៤០ នេះដែរ[659]។

237. ឈិន មូល អតីតទាហានម្នាក់ដែលបានចំណាយពេលមួយឆ្នាំនៅកោះរ៉ុងសន្លឹម នៅឆ្នាំ១៩៧៦[660] បញ្ជាក់ថា អង្គភាពរបស់គាត់ដែលជាកងវរសេនាតូច ៣៣៦ នៃកងវរសេនាធំ ៣៨៦[661] បានទទួលភារកិច្ចឃ្លាំមើលផ្ទៃទឹកនៅជុំវិញកោះរ៉ុង និងកោះរ៉ុងសន្លឹមដើម្បីមើលទូកខ្មាំងចូលដែនទឹក

---

[657] ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985327 ឆ. ៩៧។ ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955535 ឆ. ៦។ ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន គឹម ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138474 ឆ. ១៦៣។

[658] ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01065117 ឆ .៦៦-ឆ.៦៧។ ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ERN 01353051-01353054។ ឯកសារ **D54/100** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៤ ERN 00990730 ឆ.៦០-ឆ.៦១។ ឯកសារ **D54/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈា ឡុង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ERN 00998651 ឆ.៥៤-ឆ.៥៥។

[659] ឯកសារ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ERN 00955484 ឆ. ១៤។ ឯកសារ **D54/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ERN 00990805 ឆ.៣៣។ ឯកសារ **D54/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈា ឡុង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ERN 00998651 ឆ.៥១។ ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ សាត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214213-01214214 ឆ.៨៨-ឆ.៩៣។

[660] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049859 ឆ .១១០-ឆ.១១១។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01065117 ឆ.៦៥។

[661] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049847 ឆ.១៣, ERN 01049847-01049848 ឆ.២២-ឆ.២៣។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៥ ERN 01065117 ឆ.៦៧។

កម្ពុជាប្រជាធិបតេយ្យ[662]។ គាត់បានប្រទះឃើញជាសំខាន់ទូកនេសាទថៃ។ នៅពេលគាត់ ឬសហការីរបស់គាត់បានឃើញទូក ពួកគេបានរាយការណ៍ជូនទីបញ្ជាការដីគោកដែលបញ្ចេញទូកល្បឿនលឿនទៅចាប់ទូកទាំងនោះ។ ពេលខ្លះ ពួកគេចាប់បានបី ឬបួនទូកក្នុងមួយថ្ងៃ ដែលទូកនីមួយៗមានចំណុះមនុស្សពី ៦ ទៅ ៣០ នាក់ អាស្រ័យលើទំហំទូក។ អ្នកនេសាទនៅលើទូកនេសាទធំអាចមានអាវុធ។ទូកដែលមិនត្រូវបានពន្លិចនៅកន្លែងចាប់ទេត្រូវបាននាំទៅកាន់កោះរ៉ុងសន្លឹម។ បន្ទាប់មក អ្នកនេសាទត្រូវបានបញ្ជូនទៅទីបញ្ជាការកងវរសេនាតូច ៣៨៦ ដែលស្ថិតនៅភាគខាងជើងនៃកោះរ៉ុងសន្លឹម[663] ហើយពួកគេត្រូវបានសម្លាប់ដោយកងពិសេសក្នុងកងវរសេនាតូចនេះ[664]។ សាក្សីផ្ទាល់បានឃើញអ្នកនេសាទ ១០ ទៅ១៥ នាក់ត្រូវបានសម្លាប់ជារៀងរាល់ពីរ ឬបីថ្ងៃម្តង[665]។ ពេលខ្លះទៀត អ្នកនេសាទដែលបានចាប់ខ្លួនត្រូវបានយកទៅសម្លាប់នៅកំពង់សោម[666]។ សាក្សីរូបនេះបានបញ្ជាក់បន្ថែមទៀតថា ក្រៅពីប្រជាជនថៃ ជនភៀសខ្លួនវៀតណាមរាប់រយនាក់ ដែលប៉ុនប៉ងរត់គេចខ្លួនទៅកាន់ប្រទេសថៃត្រូវបានសម្លាប់ជាប្រចាំតាមរយៈការពន្លិចទូករបស់ពួកគេ ឬការសម្លាប់ដោយពួកទាហានដែលមានមូលដ្ឋាននៅកោះរ៉ុងសន្លឹម។ ជនរងគ្រោះដែលមានសំលៀកបំ

---

[662] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049850 ឆ.៣៥-៣៧។

[663] ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ERN 0135053-01353054, ERN 01353067-01353074។

[664] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049847 ឆ.២២, ERN 01049848 ឆ.២៦, ERN 01049849-01049852 ឆ.៣៦-៥២។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01065115-01065116 ឆ.៦៥ ឆ.៦៧ ឆ.៦៨ ERN 01065120-01065121 ឆ.៨៨-ឆ.៩៥។

[665] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049852-01049853 ឆ.៦០-ឆ.៦៥។

[666] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049852 ឆ.៥៦។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01065118 ឆ.៧៦។

ពាក់ជាស៊ីវិលទាំងនោះរួមមាន កុមារ ស្ត្រី និងមនុស្សចាស់[667]។ សាក្សីនេះមិនធ្លាប់បានឃើញមានការដោះលែងអ្នកទោសវៀតណាម ឬថៃម្តងណាឡើយ[668]។

238. ព័ត៌មានរបស់ មូល ឈិន មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងប្រភពផ្សេងៗទៀត។ នៅឆ្នាំ ១៩៧៥ សៀង គុយ ត្រូវបានបញ្ជូនទៅកំពង់សោម ហើយត្រូវបានចាត់តាំងឲ្យធ្វើការងារនៅលើទូកដឹកត្រី និងសម្ភារៈចាំបាច់ផ្សេងៗទៀតទៅឲ្យកងទ័ព[669]។ សាក្សីនេះបានឃើញដោយផ្ទាល់ភ្នែកពីការចាប់ខ្លួនប្រជាជនថៃនៅក្នុងសមុទ្រដែលក្រោយមកត្រូវបានបញ្ជូនទៅកងវរសេនាធំ ១៤០ ហើយបានយកទៅដាក់ឃុំឃាំងនៅកោះរ៉ុងសន្លឹមដែលនោះទីនោះតាមគាត់ដឹង អ្នកទោសទាំងនោះពេលខ្លះត្រូវបានប្រើប្រាស់សម្រាប់ដោះដូរមុខទំនិញ[670]។ សាក្សីរូបនេះបានទទួលព័ត៌មាន ប៉ុន្តែគាត់មិនបានឃើញផ្ទាល់ទេថា អ្នកនេសាទពេលខ្លះត្រូវបានពន្លិចទឹកឲ្យស្លាប់ ឬវាយនឹងដំបងរហូតដល់ស្លាប់ នៅកោះរ៉ុងសន្លឹម ហើយសាកសពរបស់ពួកគេត្រូវបានកប់នៅក្រោមដើមដូង[671]។ នៅពេលទៅលេងកោះរ៉ុងសន្លឹមបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីនេះបានឃើញរណ្តៅសាកសពនៅក្រោមដើមដូង ខ្សែចង និងសំលៀកបំពាក់វាយប៉ាយនៅលើដី និងសាកសពចំនួនពីរដែលកំពុងរលួយដោយមានដៃចងស្លាបសេក និងមានថ្លង់ផ្លាស្ទិកគ្របក្បាល។ តាមរយៈសម្លៀកបំពាក់របស់សាកសព សាក្សីបានសន្និដ្ឋានថា ពួកគេគឺជាអ្នកនេសាទថៃ[672]។ គាត់ក៏បានឃើញរ

[667] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049854 ឆ.៧៣-៧៨, ERN 01049855 ឆ.៨៤-៨៥។

[668] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049850 ឆ. ៣៦។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ERN 01065120 ឆ.៨៦-៨៧។

[669] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125458 ឆ.៩, ERN 01125459-01125460 ឆ.១៣-១៦។

[670] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125469-01125470 ឆ.៦១-៧១។

[671] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125469 ឆ.៦៦, ERN 01125470 ឆ.៧១-៧៣, ERN 01125473 ឆ.៨៨។

[672] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 0112569-01125472 ឆ.៧៣-៧៩, ERN 01125473 ឆ.៨៨។ ឯកសារ **D114/119** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ERN 01168283 ឆ.៦។

ណ្តោកបសាកសពរាប់រយនៅតំបន់ភាគខ្លួសាននៃកោះនេះ[673]។ សាក្សីម្នាក់ទៀតបានរំលឹកថា នៅចុងឆ្នាំ១៩៧៦ ទូកវៀតណាមមួយគ្រឿងត្រូវគេបានចាប់ ហើយបណ្តើរទៅកោះរ៉ុង ឃុំទុកនៅទីនោះមួយយប់ ហើយអូសទៅកំពង់សោម នៅថ្ងៃបន្ទាប់។ សាក្សីរូបនេះក្រោយមកបានសួរនីរសាររបស់មេបញ្ជាការកងវរសេនាតូចអំពីមនុស្សនៅលើទូកនោះ។ នីរសារនោះបានប្រាប់គាត់ថា អ្នកលើទូកទាំងនោះត្រូវបានសម្លាប់នៅលើកោះអស់ហើយ។ គាត់ក៏បាននិយាយបន្ថែមទៀតថា កងពលបានប្រាប់មេបញ្ជាការកងវរសេនាតូចថា *"ឯងធ្វើមេច ធ្វើទៅ កុំទុក"។* សារនេះចេញពី មាស មុត ហើយមានន័យថា អ្នកទោសទាំងនោះមិនត្រូវបញ្ជូនទៅកំពង់សោមទេ ប៉ុន្តែសម្លាប់ចោលនៅកោះតែម្តងទៅ[674]។

239. ភស្តុតាងជាឯកសារបង្ហាញថា មាស មុត បានទទួលរបាយការណ៍ពីការប្រទះឃើញទូកបរទេសនៅជិតកោះរ៉ុង[675] ហើយថា គាត់បានរាយការណ៍ទៅសេនាធិការអំពីសកម្មភាពទៅលើទូកថៃ និងការចាប់ទូកថៃដែលត្រូវបានបញ្ជូនទៅកោះរ៉ុង[676]។ **មាស មុត** ក៏បានធ្វើដំណើរដោយផ្ទាល់ទៅកាន់កោះរ៉ុង ដើម្បីធានាថាមានការអនុវត្តសេចក្តីសម្រេចរបស់ ប.ក.ក[677]។

240. សាក្សីពីរនាក់ដែលបានធ្វើការងារនៅកោះរ៉ុងបាននិយាយថា ពួកគេមិនបានដឹងពីការចាប់បានទូកបរទេស ឬក៏ជនបរទេស ហើយត្រូវបានបញ្ជូនទៅកាន់កោះរ៉ុងនោះទេ[678]។ អង្គភាពរបស់សាក្សីម្នាក់គឺជាអង្គភាពទីមួយដែលបានទៅកោះរ៉ុងនៅឆ្នាំ១៩៧៥ ប៉ុន្តែសាក្សីមិនបានចាំថាតើគាត់បានធ្វើ

---

[673] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125472 ឆ.៨០-ឆ.៨៣។

[674] ឯកសារ **D54/116** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឿន នាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ERN 01007895-01007896 ឆ.៣៧-៤០ ឆ.៤២។ ឯកសារ **D59/2/3.13a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី យឿន នាក់ ERN 00958267។

[675] ឯកសារ **D1.3.34.14** ទូរលេខ ១៥ ជូនបង មុតពីកម្មាភិបាលឌីម ថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៧៦ ERN 00000866។

[676] ឯកសារ **D1.3.12.2** របាយការណ៍ជូនបង ៨៩ ថ្ងៃទី០៦ ខែកុម្ភៈ (មិនមានផ្តល់ឆ្នាំ) ERN 00000866 ។

[677] ឯកសារ **D114/19. 1** របាយការណ៍ជូនបង ៨៩ ថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៧៦ ERN 0002154។

[678] ឯកសារ **D114/104** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127858 ឆ.១១២-ឆ.១១៥។ ឯកសារ **D114/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ERN 01134406 ឆ.៥៣-ឆ.៥៩។

ការនៅទីនោះអស់រយៈពេលប៉ុន្មានទេ មុននឹងគាត់ត្រូវបានបញ្ជូនទៅកាន់កោះមួយផ្សេងទៀត[679]។ គាត់បានកត់សម្គាល់ថា នៅពេលគាត់នៅលើកោះ អង្គភាពរបស់គាត់ពុំមានទូកប្រើប្រាស់ទេ[680]។ គាត់បានទទួលព័ត៌មានអំពីការចាប់បានទូកថៃជាច្រើនគ្រឿង ប៉ុន្តែបញ្ជាក់ថា អ្នកទោសដែលចាប់បានត្រូវបានបញ្ជូនទៅឱ្យទាហានកងពលដែលមានមូលដ្ឋាននៅកោះតាគាវ នៅជិតរាម[681]។ សាក្សីម្នាក់ទៀត ត្រូវបានបញ្ជូនទៅកោះរ៉ុង នៅឆ្នាំ ១៩៧៥ ហើយគាត់បាននៅទីនោះប្រហែលជាបី ឬបួនខែ[682]។ បន្ទាប់មក គាត់ត្រូវបានបញ្ជូនទៅកោះតាង[683]។ គាត់បានដឹងពីការចាប់បានទូកថៃ និងវៀតណាម ប៉ុន្តែបានបញ្ជាក់ថា អ្នកទោសទាំងនោះត្រូវបានបញ្ជូនទៅ "ថ្នាក់លើ" នៅកំពង់សោម[684]។

241. សាក្សីទីបីដែលបានស្ថិតនៅកោះរ៉ុងសន្លឹមចំនួន ៦ ខែ នៅឆ្នាំ១៩៧៦ គាត់មិនបានឃើញអ្នកនេសាទថៃណាម្នាក់នៅលើកោះនេះទេ[685] ប៉ុន្តែគាត់បានដឹងពីការចាប់បានទូកនេសាទ[686] ហើយគាត់ផ្ទាល់បានចូលរួមចាប់ទូកនេសាទថៃ ដែលអ្នកនេសាទនៅលើទូកនោះត្រូវបានបញ្ជូនទៅកោះតាង[687]។

---

[679] ឯកសារ **D114/104** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127850-01127851, ERN 01127856 ឆ.៣៩, ឆ.៩៣-ឆ.៩៤។

[680] ឯកសារ **D114/104** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127858 ឆ.១១៣។

[681] ឯកសារ **D114/104** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127859-01127860 ឆ.១១៨-ឆ.១២១, ឆ.១២៤-ឆ.១៣១។

[682] ឯកសារ **D114/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ERN 01134406 ឆ.៤១-ឆ.៤២។

[683] ឯកសារ **D114/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ERN 01134407 ឆ.៦៦។

[684] ឯកសារ **D114/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ERN 01134406 ឆ.៥៣-ឆ.៥៧។

[685] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136614 ឆ.២, ERN 01136617 ឆ.១៥, ERN 01136625 ឆ.៥៤។

[686] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136619, ERN 01136623 ឆ.១៧-ឆ.១៨, ឆ.៣៦។

[687] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136622-01136623, ERN 01136624 ឆ.២៦-ឆ.៣៧, ឆ.៤៤។

គាត់ក៏បានដឹងផងដែរអំពីការសម្លាប់អ្នកនេសាទនៅក្នុងសមុទ្ទ[688] ការចាប់បានទូកបរទេស[689] និងវិធីក្នុងការធ្វើឱ្យសម្រេចភារកិច្ចរបស់គាត់[690]។ គាត់បានបំពេញការងារនៅលើកោះ ហើយសមាជិកនៃអង្គភាពរបស់គាត់បានជួយកងនាវាដើម្បីចាប់ទូកបរទេស[691]។ គាត់ត្រូវបានដាក់ឱ្យបំពេញការងារនៅតំបន់ខាងត្បូងនៃកោះ[692] ហើយវាទំនងណាស់ដែលថា ទីតាំងដែលប្រើសម្រាប់សម្លាប់មនុស្សគឺស្ថិតនៅកន្លែងផ្សេង ពោលគឺនៅតំបន់ខាងជើងនៃកោះ ជិតទីបញ្ជាការកងវរសេនាតូច ៣៨៦ និងកំពង់ផែដែលជាកន្លែងសម្រាប់ចតទូកបន្ទាប់ពីចាប់បាន[693]។ នៅពេលពិចារណាលើភស្តុតាងជារួម និងជាពិសេសភស្តុតាងរបស់ ឈិន មូល ដែលព័ត៌មានលម្អិតអំពីការសម្លាប់មនុស្សត្រូវបានសួរដេញដោល[694] ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចទៅកាន់កោះនេះ មានហេតុផលរឹងមាំដែលអាចជឿបានថា ប្រជាជនស៊ីវិលថៃ និងវៀតណាមរាប់រយនាក់ត្រូវបានសម្លាប់នៅកោះរ៉ុងសន្លឹម និងនៅក្នុងទឹកនៅជិតៗកោះនេះ[695]។

---

[688] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136624-01136625 ឆ.៤៦-ឆ.៤៨, ឆ.៥៥។

[689] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136622-01136624 ឆ.៣៦ ឆ.៣៩ ឆ.៤៤ ឆ.៤៨។

[690] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136618-01136625 ឆ.១៧, ឆ.២៦-ឆ.២៨, ឆ.៣៤, ឆ.៣៨-ឆ.៣៩, ឆ.៤៩-ឆ.៥១។

[691] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136618-01136622 ឆ.១៧-៣៦។

[692] ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136621 ឆ.៣៣។

[693] ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ERN 0135053-01353054, ERN 01353067-01353074។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01065116 ឆ.៦៧-ឆ.៦៨, ERN 01065117 ឆ.៧៦, ERN 01065120 ឆ.៨៤។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049849-01049851 ឆ.៣៦-ឆ.៤៩។

[694] ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ERN 0135053-01353054, ERN 01353067-01353074។

[695] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049849-01049855 ឆ.៣៦-ឆ.៨៥។

*៥.៤.៤.៣ កោះពូឡូវ៉ៃ*

242. កងវរសេនាធំ ៦២ នៃកងពល ១៦៤ បានបោះទីតាំងនៅតាមកោះនានានៃកោះពូឡូវ៉ៃចាស់ និងកោះពូឡូវ៉ៃថ្មី តទៅទៀតហៅថាកោះពូឡូវ៉ៃ ពីព្រោះសាក្សីទាំងអស់ជាទូទៅមិនបានបញ្ជាក់ឱ្យបានច្បាស់ថាតើកោះមួយណាក្នុងចំណោមកោះទាំងពីរនេះទេ នៅពេលពួកគេនិយាយសំដៅដល់ កោះនេះក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ពួកគ[696]។ អតីតទាហានកងវរសេនាធំ ៦២ ដែលបានឈរជើងនៅពូឡូវ៉ៃអស់រយៈពេលពីរខែ នៅឆ្នាំ ១៩៧៥ បញ្ជាក់ថា ពួកគេបានជីកត្រង់សេ និងបានយាមកោះនេះ ពីព្រោះក្នុងអំឡុងពេលនោះវៀតណាមធ្លាប់តែ *"លួច"* ចូលទៅកោះនៃប្រទេសកម្ពុជា។ គាត់បញ្ជាក់ថា បើវៀតណាមចូលមកដោយមានបំពាក់អាវុធ យើងទទួលបញ្ជាឱ្យបាញ់សម្លាប់ពួកគេ។ ប្រសិនបើពួកគេគ្មានអាវុធ យើងត្រូវចាប់ខ្លួនពួកគេ។ ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេលពីរខែនៅទីនោះ គាត់មិនបានឃើញមានបរទេសណាម្នាក់នោះទេ[697]។

243. កងវរសេនាធំ ៦២ មានតែទូកឈើតូចៗសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ។ កងវរសេនាធំ ១៤០ មាននាវា PCF ដែលចតនៅទីតាំងជិតៗកោះ ហើយត្រៀមរៀបចំជាស្រេចដើម្បីទៅចាប់ទូកបរទេសប្រសិនបើមានបញ្ហាពីកងពល។ កងវរសេនាធំ ៦២ សម្របសម្រួលក្នុងការគ្រប់គ្រង និងបញ្ជូនអ្នកទោស ដោយសហការជាមួយនឹងកងវរសេនាធំ ១៤០ បន្ទាប់ពីចាប់ទូកបាន[698]។ កោះពូឡូវ៉ៃជាផ្លូវដែលប្រើដោយជនភៀសខ្លួនវៀតណាម[699]។ អ្នកនេសាទថៃ និងអ្នកភៀសខ្លួន វៀតណាម ក្នុងនោះ

---

[696] ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ERN 00985327 ឆ.៩៧។ ឯកសារ **D54/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ERN 00997238-00997239 ឆ.១៤។

[697] ឯកសារ **D114/113** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េន គីម ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138459 ឆ.២០, ERN 01138461 ឆ.៣៥-ឆ.៣៨, ERN 01138462 ឆ.៤៦-ឆ.៥១។

[698] ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982545-00982547 ឆ.៣, ERN 00982548 ឆ.៨។

[699] ឯកសារ **D114/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាល ឈឿន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ERN 01034022 ឆ.១៩។ ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982549 ឆ.១១។ សូមមើលផងដែរ ឯកសារ **D114/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សុខន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ERN 01136621 ឆ.៣១។

រួមមានស្ត្រី និងកុមារ ដែលបានចាប់នៅឯនាយនៃកោះពូឡូវៃ ត្រូវបានបញ្ជូនទៅកំពង់សោម[700] ឬត្រូវបានសម្លាប់ដោយទាហាននៃកងវរសេនាធំ ៦២[701]។ បន្ទាប់ពីចាប់ខ្លួនបាន ជនភៀសខ្លួនវៀតណាមត្រូវបានគេប្លន់យកមាស និងវត្ថុមានតម្លៃ[702]។

244. អ៊ូ គឹម ដែលជាសមាជិកកងវរសេនាតូចនៃកងវរសេនាធំ ៦២ ដែលមានមូលដ្ឋាននៅកោះពូឡូវៃ[703] បានមើលឃើញការចាប់ទូកនេសាទត្រីថៃ និងទូកជនភៀសខ្លួនវៀតណាមជាច្រើន។ សាក្សីបានប៉ាន់ស្មានថា ទូកនេសាទថៃជាធម្មតាមានអ្នកនេសាទយ៉ាងតិច ២០ នាក់ ចំណែកទូកជនភៀសខ្លួនវៀតណាមដឹកមនុស្សប្រមាណជា ៣០ នាក់ បើទោះបីតាមការលើកឡើងរបស់សាក្សីដែលថា ទូកមួយចំនួនអាចមានអ្នកជិះច្រើនជាងនេះរហូតដល់ ៥០ ទៅ ៧០ នាក់ក៏ដោយ[704]។ ជនភៀសខ្លួនវៀតណាមភាគច្រើនបំផុតគឺជាស្ត្រី និងកុមារ ដោយមានបុរសជាអ្នកបើកទូក និងបុគ្គលិកទូកប៉ុណ្ណោះ។ គាត់បានរំលឹកថា គាត់មិនបានរកឃើញអាវុធនៅលើទូកជនភៀសខ្លួននោះទេ ប៉ុន្តែ

---

[700] ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982545-00982547 **ឆ.៣-ឆ.៤, ឆ.៧**។

[701] ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150954 **ឆ.៧-ឆ.៩**, ERN 01150960-01150961 **ឆ.៣១-ឆ.៣៩**, ERN 01150962-01150963 **ឆ.៤៣-ឆ.៤៥**។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150968 **ឆ.៤**, ERN 01150970 **ឆ.១៣**។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049862-01049863 **ឆ.១៣៦-ឆ.១៤៦**។ ឯកសារ **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ERN 00936681-00936682 **ឆ.៤១-៤៩**។ ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955536-00955537 **ឆ.៧ ឆ.១២** ERN 00955539 **ឆ.២០**។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985332-00985333 **ឆ.១២១-ឆ.១៣០**។ ឯកសារ **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ERN 00936681-00936682 **ឆ.៤១-ឆ.៥០**។

[702] ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982549 **ឆ.១២-ឆ.១៣**។

[703] ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150954 **ឆ.៧-ឆ.៩**។

[704] ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150956 **ឆ.១៧**, ERN 01150959 **ឆ.២៨**, ERN 01150960-01150962 **ឆ.៣១-ឆ.៤២**។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150968 **ឆ.៣**។

បញ្ជាក់ថា គាត់បានឃើញ ទូកថៃខ្លះមានកាំភ្លើងកាលីខូ ដែលមានកាណុងមួយ[705]។ អ្នកទោសទាំងនោះត្រូវបានផែកឆេរ នៅឯសមុទ្ទ ហើយបន្ទាប់មកនាំទៅកាន់កោះ[706]។ ដៃរបស់អ្នកទោសប្រុសត្រូវបានចង ហើយចំណែកឯដៃអ្នកទោសស្ត្រី និងកុមារមិនត្រូវបានចងទេនោះទេ[707]។ សាក្សីបានទទួលព័ត៌មានពីអ្នកធ្វើការជាមួយគាត់ថា អ្នកទោសទាំងនោះត្រូវបានយកទៅដាក់នៅក្នុងផ្ទះមួយជិតឆ្នេរសមុទ្ទ និងឃុំខ្លួននៅទីនោះចំនួនពីពីរទៅបីថ្ងៃ មុនពេលពួកគេត្រូវបានវាយដំរហូតដល់ស្លាប់។ ស្ត្រីវៀតណាមជាញឹកញាប់យកមាសតាមខ្លួន ដែលមាសត្រូវបានដកហូតមុននឹងពួកគេត្រូវបានសម្លាប់។ សាក្សីបានអះអាងថា ការសម្លាប់ទាំងនេះត្រូវបានដឹងជាទូទៅក្នុងចំណោមទាហាននៅលើកោះ[708]។ គាត់ប៉ាន់ស្មានដោយប្រយ័ត្នប្រយែងថា មនុស្សប្រមាណពី ៣០០-៤០០ នាក់ត្រូវបានសម្លាប់ និងកប់នៅកោះពូឡូវ៉ៃ។ ទោះជាយ៉ាងនេះក្តី គាត់បានផ្តល់ករណីមួយចំនួន នៅពេលប្រជាជនខ្លះបានទទួលទូក និងទទួលបានការអនុញ្ញាតិឲ្យចាកចេញពីកោះ ប៉ុន្តែគាត់មិនបានបញ្ជាក់ពីសញ្ជាតិរបស់ពួកគេក៏ដោយ[709]។

245. សាក្សីម្នាក់ទៀតដែលបានធ្វើដំណើរជាញឹកញាប់ទៅកាន់កោះពូឡូវ៉ៃ ដើម្បីផ្គត់ផ្គង់សម្ភារៈ ហើយម្តងម្កាលបានស្នាក់នៅនៅទីនោះមួយយប់ នៅពេលរលកធំៗ បានផ្តល់សក្ខីកម្មថា គាត់បានឃើញការចាប់បានទូកដែលមានដឹកប្រជាជនស៊ីវិលថៃ និងវៀតណាមជារៀងរាល់ថ្ងៃ នៅពេលគាត់ស្ថិតនៅលើកោះនោះ។ កងនាវាជើងទឹកបានដឹកអ្នកទោសទាំងនោះទៅកាន់ "សេនាធិការកងពល" នៅលើកោះ ហើយអ្នកទោសទាំងអស់ត្រូវបានសម្លាប់។ ទូកតូចៗត្រូវបានពន្លិចទៅក្នុងទឹក ចំណែក

---

[705] ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150968 ឆ.៤-ឆ.៦។

[706] ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150974 ឆ.២៦។

[707] ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150969 ឆ.៧។

[708] ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150969-01150970 ឆ.១១, ERN 01150973-01150977 ឆ.២៥-ឆ.៤១។ ឯកសារ **D220/1.2.1** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី គឹម អ៊ួ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ERN 01102496-01102497។

[709] ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150962-01150963 ឆ.៤៣-៤៦។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150976 ឆ.៣៤, ERN 01150977-01150978 ឆ.៤១-៤៣។ ឯកសារ **D220/1.2.1** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី គឹម អ៊ួ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ERN 01102498-01102499។

ទូកធំៗត្រូវបានរក្សាទុកដើម្បីឲ្យកងទ័ពបដិវត្តន៍កម្ពុជាប្រើប្រាស់។ ជនរងគ្រោះគឺជាប្រជាជនស៊ីវិល និងមានស្ត្រី កុមារ និងមនុស្សចាស់។ ជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ និងកប់នៅលើកោះ។ គ្មាននរណារួចផុតការសម្លាប់ឡើយ[710]។ ភស្តុតាងរបស់សាក្សីផ្សេងៗទៀតស៊ីសង្វាក់គ្នាជាមួយនឹងព័ត៌មាននេះ[711]។

246. អតីតសមាជិកម្នាក់ទៀតនៃកងវរសេនាធំ ៦២ ដែលមានមូលដ្ឋាននៅលើកោះពូឡូវៃចាស់ រំលឹកថា កប៉ាល់ដែលចាប់បាននៅតាមឆ្នេរនៃកោះនេះត្រូវបានអូសដោយផ្ទាល់ទៅកាន់ កំពង់សោម មិនមែនទៅកោះនោះទេ។ ទោះជាយ៉ាងនេះក្តី គាត់អះអាងថា ការដឹងឮរបស់គាត់មិនទូលំទូលាយនោះទេ ទាក់ទងនឹងអ្វីៗដែលបានកើតឡើងនៅតាមទីតាំងផ្សេងៗទៀតក្នុងកោះ នៅពេលគាត់ស្ថិតនៅទីនោះ ហើយថា មានតែអ្នកដែលស្ថិតនៅលើកោះ និងមានតួនាទីខ្ពស់ប៉ុណ្ណោះ អាចមើលឃើញនូវអ្វីៗដែលបានកើតឡើងនៅតាមទីតាំងផ្សេងៗនៅលើកោះ[712]។ អតីតសមាជិកម្នាក់ទៀតនៃកងវរសេនាតូច ៤១០ ក្នុងកងវរសេនាធំ ៦២ ដែលមានមូលដ្ឋានលើកោះពូឡូវៃពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨[713] បញ្ជាក់ថា នៅពេលគេប្រទះឃើញទូកបរទេស ពួកគេបាន រាយការណ៍ទៅកងពលដែលនឹងបញ្ចេញទូកទៅចាប់ទូកទាំងនោះ។ ទោះជាយ៉ាងនេះក្តី សាក្សីបញ្ជាក់ថា អ្នកទោសមិនត្រូវបានបញ្ជូនទៅកោះទេ ប៉ុន្តែ "*ទៅក្រោយ*" ដែលត្រូវបានយល់ថាសំដៅដល់ រាម ពីព្រោះគាត់និយាយថា ពុំមានកន្លែងចតទូកនៅលើកោះនោះទេ[714]។ អាស្រ័យហេតុនេះ មាន ភស្តុតាង បើទោះបីជាពាក្យ

---

[710] ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049861-01049862 ឆ.១៣២-ឆ.១៣៣, ERN 01049862-01049864 ឆ.១៣៨-ឆ.១៥៨។

[711] ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ] ឯកសារ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01412600-01412601។ ឯកសារ **D114/297.1.21** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ]ប៉ាក សុខ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01412806, ERN 01412835-01412836។ ឯកសារ **D54/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាល់ ណុប ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ERN 00982545-00982547 ឆ.៣។

[712] ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ សាត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214203-01214204 ឆ.២០-ឆ.២៦, ERN 01214205 ឆ.២៧, ERN 01214212-01214214 ឆ.៨០-ឆ.៨៣។

[713] ឯកសារ **D54/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ERN 00997237-00997238 ឆ.៩-១១, ERN 00997238-00997239 ឆ.១៤។

[714] ឯកសារ **D54/109** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០១៤ ERN 00997244-00997246 ឆ.១១-ឆ.១៦។

ចចាមអារ៉ាម ដែលថា កោះពូឡូវ៉ៃ[715] មានកំពង់ផែថ្មមួយ ហើយ ភស្តុតាងផ្ទាល់ពីសាក្សីម្នាក់ ដែលបញ្ជាក់ថាមានកំពង់ផែឈើមួយដែលត្រូវបានប្រើសម្រាប់បញ្ចេញអ្នកទោសពីទូក។ ទោះជាយ៉ាងនេះក្តី គេមិនច្បាស់ថាតើសាក្សីរូបនេះលើកឡើងសំដៅដល់កោះពូឡូវ៉ៃណាមួយនោះទេ[716]។

247. ដូច្នេះ សាក្សីមានការយល់ស្របគ្នាទាំងអស់អំពីការចាប់បានទូកបរទេស និងប្រជាជនស៊ីវិល នៅលើដែនទឹកជុំវិញកោះពូឡូវ៉ៃ។ ភស្តុតាងមានភាពខុសគ្នា ទាក់ទងតែជាមួយនឹងថាតើទូក និងអ្នកទោសទាំងនោះត្រូវបានយកទៅទីណា បន្ទាប់ពីចាប់បានហើយ។

៥គ្រោះរងជនចំនួន ៥.៤.

248. យើងមានការលំបាកក្នុងការធ្វើការប៉ាន់ស្មានគួរឲ្យទុកចិត្តបានអំពីចំនួនជនបរទេស ដែលបានក្លាយជាជនរងគ្រោះនៃកងកម្លាំងរបស់កងពលធំ ១៦៤ នៅរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ការប៉ាន់ស្មានដែលបានផ្តល់ដោយអតីតសមាជិកកងពលធំ ១៦៤ ត្រឹមបានកម្រិតដោយពេលវេលា និងទីតាំងខ្លះៗនៃកន្លែងបំពេញការងារខ្លួន។ ការព្យាយាមស្វែងរកកិច្ចសហការពីប្រទេសវៀតណាម និងប្រទេសថៃក្នុងការចូលពិនិត្យមើលបណ្ណសាររបស់ពួកគេ ទទួលបរាជ័យ[717]។

249. ក៏ប៉ុន្តែ ភស្តុតាងបង្ហាញថា ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ កងកម្លាំងនៅកងពលធំ ១៦៤ រួមទាំងកងវរសេនាធំ ៦២ និង កងវរសេនាធំផ្នែកជើងទឹក ១៤០ ចាប់បានទូកអ្នកនេសាទថៃ និងជនភៀសខ្លួនវៀតណាមយ៉ាងច្រើនជាបន្តបន្ទាប់ ដែលបានចូល ឬឆ្លងកាត់ដែនទឹកកម្ពុជាប្រជាធិបតេយ្យ។

250. ភស្តុតាងជាឯកសារបង្ហាញបន្ថែមថា អ្នកទោសទាំងនេះយ៉ាងច្រើនត្រូវបានចាប់ខ្លួន ហើយត្រូវបានសម្លាប់ក្នុងរយៈពេលដ៏ខ្លី។ ឧទាហរណ៍ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ **មាស មុត** បានរាយការណ៍ថា ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ កងកម្លាំងរបស់គាត់បានចាប់ និង

---

[715] ឯកសារ **D4.1.754** ការចាត់ចែងតំបន់ ៣៧ និងកម្លាំងកងពលធំ ៣/១៦៤ នៅលើកោះតាង បន្ទាប់ពីការចាប់នាវាម៉ាយាហ្គេសរួចមក ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ ERN 00791383-00791384។

[716] ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150969 ឆ. ១០។

[717] *សូមមើល ការព្យាយាមស្វែងរកជំនួយពីប្រទេសវៀតណាម ប្រទេសថៃ និងអង្គការសហប្រជាជាតិ* កថាខណ្ឌ ១៤៨។

បាញ់សម្លាប់ជនជាតិវៀតណាមចំនួន ១២០ នាក់[718]។ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ អ្នកនេសាទថៃចំនួន ៤២ នាក់ និងប្រជាជនវៀតណាមចំនួន ១៧ នាក់ ដែលត្រូវបានចាប់ខ្លួននៅកំពង់សោមត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារនៅមន្ទីរសន្តិសុខ ស-២១ ហើយបន្ទាប់មកត្រូវសម្លាប់នៅពេលបន្ទាប់[719]។ ការចាប់ខ្លួន និងការសម្លាប់បានកើតឡើងជាទៀងទាត់។

251. ដោយលើកឡើងថាការចាប់ខ្លួនដែលមានចំនួនមនុស្ស និងការសម្លាប់ច្រើនបំផុតត្រូវបានធ្វើឡើងនៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ប៉ាក សុខ ដែលជាអតីតទាហាននៅកងពលធំ ១៦៤ បានប៉ាន់ស្មានថា គាត់បានឃើញមនុស្សដែលត្រូវបានបញ្ជូនទៅឆ្នេរអូរឈើទាល បួន ឬប្រាំ ដងក្នុងមួយខែៗ[720]។ គាត់ក៏បានប៉ាន់ស្មានថា នៅក្នុងឆ្នាំ១៩៧៨ អ្នកទោស ប្រមានជា ១០ ទៅ ៥០ នាក់ត្រូវបានបញ្ជូន

---

[718] ឯកសារ **D1.3.30.25** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ពីកងពល ១៦៤ ផ្នែក នយោបាយ ទូរស័ព្ទសម្ងាត់ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨" ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ ERN 00017026។

[719] <u>ជនជាតិថៃ៖</u> ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោសរបស់ កសចស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) ERN (ភាសាអង់គ្លេស) 01222356 លេខរៀង ៦០០, ៦០៤, ERN (ភាសាអង់គ្លេស) 01222357 លេខរៀង ៦០៩, ៦១៣-៦១៦, ៦២០, ៦២៨, ERN (ភាសាអង់គ្លេស) 01222358 លេខរៀង ៦២៩, ៦៤៥-៦៤៦, ៦៤៩-៦៥០, ERN (ភាសាអង់គ្លេស) 01222360 លេខរៀង ៦៧៩-៦៨០, ERN (ភាសាអង់គ្លេស) 01222860 លេខរៀង ១២៩៨១, ១២៩៨៣-១២៩៨៥, ERN (ភាសាអង់គ្លេស) 01222861 លេខរៀង ១២៩៨៧-១២៩៨៩, ១២៩៩៩, ១៣០០១-១៣០០២, ERN (ភាសាអង់គ្លេស) 01222862 លេខរៀង ១៣០០៥-១៣០០៦, ១៣០២៣, ERN (ភាសាអង់គ្លេស) 01222863 លេខរៀង ១៣០៣១, ១៣០៥២-១៣០៥៣, ១៣០៥៥, ERN (ភាសាអង់គ្លេស) 01222890 លេខរៀង ១៣៦៤៥, ១៣៦៥៣, ERN (ភាសាអង់គ្លេស) 01222924 លេខរៀង ១៤០៩៦-១៤០៧៣។ ទោះបីបញ្ជីនេះមិនបានផ្តល់កាលបរិច្ឆេទចូលមន្ទីរសន្តិសុខ ស-២១ សម្រាប់ការចូលចំនួន ៨ លើកចុងក្រោយក៏ដោយ តែយើងជឿជាក់ថា ជនជាតិថៃចំនួន ៨ នាក់ក៏បានចូលក្នុងមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ដែរ ដោយសារពួកគេជាអ្នកដំណើរដែលស្ថិតលើទូកជាមួយដឹកមនុស្សដូចគ្នា (ដែលបានលើកឡើងនៅក្នុងការចូលខាងដើម) ដែលបានចូលនៅឯកាលបរិច្ឆេទនោះ។ <u>ជនជាតិវៀតណាម៖</u> ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោសរបស់ កសចស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) ERN (ភាសាអង់គ្លេស) 01222356 លេខរៀង ៥៩២-៥៩៤, ៥៩៦-៥៩៧, ៦០២, ៦០៦-៦០៧, ERN (ភាសាអង់គ្លេស) 01222357 លេខរៀង ៦១២, ៦២៥, ERN (ភាសាអង់គ្លេស) 01222358-01222359 លេខរៀង ៦៥១-៦៥៣, ៦៦៣, ERN (ភាសាអង់គ្លេស) 01222360 លេខរៀង ៦៧៦, ៦៧៨, ERN (ភាសាអង់គ្លេស) 01222890 លេខរៀង ១៣៦៤៣។

[720] ឯកសារ **D114/297.1.21** ប្រតិចារិកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ] ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01412817-01412818, ERN 01412820។

ទៅកំពង់ផែអូរឈើទាលជារៀងរាល់ខែ[721]។ ទោះជាយ៉ាងនេះក៏ដោយ ការប៉ាន់ស្មាននេះមិនបានរាប់បញ្ចូលអ្នកដែលត្រូវបានសម្លាប់នៅឯសមុទ្ទ និងនៅលើកោះនោះទេ។ សាក្សីជាច្រើននាក់បានរាយការណ៍ថា៖

i. នៅក្នុងកោះតាងតែមួយ មានសាកសពប្រមាណជា ២៥០ នាក់ត្រូវបានកប់នៅក្រោមដើមដូង[722]

ii. នៅរវាងពីឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ អ្នកនេសាទថៃពី ១០ ទៅ ១៥ នាក់ត្រូវបានសម្លាប់ជារៀងរាល់ពីរ ទៅបីថ្ងៃម្តង នៅកោះរ៉ុងសន្លឹម បន្ថែមទៅនឹងប្រជាជនវៀតណាមរាប់រយនាក់ផ្សេងទៀត[723]

iii. ប្រជាជនថៃ និងវៀតណាមប្រមាណជា ១០០០ នាក់ត្រូវបានចាប់ខ្លួននៅឯសមុទ្រ ដែលមានការប៉ាន់ស្មានយ៉ាងប្រុងប្រយ័ត្នអំពីចំនួនពី ៣០០ ទៅ ៤០០ នាក់ត្រូវបានសម្លាប់ និងកប់នៅកោះពូឡូវៃ[724]

iv. រណ្តៅសាកសពចំនួនរាប់រយត្រូវបានឃើញនៅភាគឦសានកោះរ៉ុង[725]។

---

[721] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955535 ឆ.៦។ សូមមើលផងដែរ ឯកសារ **D114/297. 1.21** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01412820។

[722] ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353868 ឆ. ២២។

[723] <u>ចន្លោះឆ្នាំ១៩៧៦ រហូតដល់ដើមឆ្នាំ១៩៧៧៖</u> ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049862 ឆ.១១០-ឆ.១១១។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទីចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ERN 01065115 ឆ.៦៥។ ជនជាតិថៃចំនួនពី ១០ ទៅ ១៥ នាក់ និងជនជាតិវៀតណាមរាប់រយនាក់៖ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049852-01049853 ឆ.៦០-៦៥, ERN 01049849 ឆ.៧៣-៧៨, ERN 01049849 ឆ.៨៤-៨៥។

[724] ឯកសារ **D220/1.2.1** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី គឹម អ៊ូ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ERN 01102498-01102499 *ដូចបានបញ្ជាក់នៅក្នុង* ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150962-01150963 ឆ.៤៣-៤៦។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150976 ឆ.៣៤, ERN 01150977-01150978 ឆ.៤១-៤៣។

252. ប៉ាក សុខ បានប៉ាន់ស្មានថា ចំនួនមនុស្សសរុបនៃអ្នកនេសាទថៃ និងជនភៀសខ្លួនវៀតណាមដែលបានចាប់ខ្លួនដោយកងទ័ពជើងទឹកនៅឯសមុទ្រ និងសម្លាប់ពីរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ មាន "*រាប់ពាន់នាក់*"[726]។ បន្ទាប់ពីពិចារណាថា គាត់បានធ្វើការងារនៅលើកោះ និងក្នុងកងនាវានៅរវាងពីឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ នោះ ភស្តុតាងរបស់គាត់មានភាពជឿជាក់បាន ជាពិសេស ដោយសារតែតួនាទីរបស់គាត់នៅក្នុងជួរដឹកនាំ និងភស្តុតាងនេះ គឺស្ថិតក្នុងវិសាលភាពនៃបទចោទនានាក្នុងសំណុំរឿងនេះ[727]។

253. ដោយបានប្រចាំការនៅលើកោះទាំងនេះពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ចុងឆ្នាំ១៩៧៦[728] ឯក នី បានប៉ាន់ស្មានថា មានជនរងគ្រោះ "*ជាង ១.០០០ ...* [មិន] *ក្រោម ១.២០០ ឬ ១.៣០០ នាក់ទេ*"[729]។ ក្នុងចំណោមទូកចាប់បានដែលគាត់បានឃើញ មានតែបួនគត់ជាទូកថៃ

---

[725] ឯកសារ **D114/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ERN 01125472 ទ.៨០-ទ.៨៣។

[726] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955537 ទ. ១១។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353857 ទ. ៥៨។ *សូមមើលផងដែរ* ឯកសារ **D54/24.1** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ ERN 00955507។ ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ួ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150962 ទ.៤៣, ERN 01150963 ទ.៤៦ បង្ហាញថាមនុស្សដែលចាប់បានពី ៣០០ ទៅ ៤០០ នាក់ដែលត្រូវបានសម្លាប់នៅលើកោះជា *"ចំនួនតិចបំផុត"* បន្ទាប់មក គាត់លើកឡើងថា *"តួលេខ ១០០០នេះ ជាចំនួនសរុបទាំងជនជាតិទាំងពីរ ថៃ និងវៀតណាម"*។

[727] ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955537-00955538 ទ.១២-ទ.១៥។ ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01412591។

[728] <u>ចាប់ពីខែមេសា ឆ្នាំ១៩៧៥៖</u> ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353864 ទ.២។ *សូមមើលផងដែរ* ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353849 ទ.២២, ERN 01353853 ទ.៣៨, ERN 01353855-01353856 ទ.៤៨-ទ.៥០។ <u>រហូតដល់ចុងឆ្នាំ១៩៧៦/ដើមឆ្នាំ១៩៧៧៖</u> ឯកសារ **D54/105** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ERN 00992814-00992815 ទ.៧-ទ.៨។ ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353864 ទ.២។

[729] ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353858 ទ.៦០-ទ.៦១។

ហើយ "*ទូកផ្សេងទៀតជាទូកវៀតណាម*"[730]។ ក្នុងរយៈពេល ២០ ខែនោះ ឯក នី បានឃើញការចាប់ទូកវៀតណាមដែលដឹកជនភៀសខ្លួន ជួនកាល បី ទៅបួនគ្រឿងក្នុងមួយថ្ងៃ ឬក្នុងមួយខែ[731]។ ទូកនីមួយៗដែលចាប់បាន មានដឹកមនុស្សពី ៣០ ទៅ ៦០ នាក់[732]។ ភស្តុតាងរបស់ ឯក នី អាចជឿជាក់បាន ដោយពិចារណាទៅលើតួនាទីដឹកនាំរបស់គាត់ និងការដឹងដោយផ្ទាល់របស់គាត់អំពីការចាប់ទូកទាំងនោះ[733]។ វាមានការលំបាកក្នុងកំណត់ឲ្យបានជាក់លាក់ទៅតាមគណិតវិទ្យា នូវសមាមាត្រនៃការចាប់ទូកក្នុងមួយថ្ងៃ ធៀបទៅនឹងក្នុងមួយខែ។ ការគណនាប្រៀបធៀបដោយផ្អែកលើភស្តុតាងត្រូវតែរួមជាមួយការវាយតម្លៃជាក់ស្តែង និងធម្មតានៃលំដាប់តួលេខដែលខុសៗគ្នាដោយគិតទៅដល់គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ*។

i. មូលដ្ឋានទូទៅសម្រាប់ការគណនាទៅតាមគោលការណ៍ *មតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺ ២០ ខែ នៅពេលមានទូកចំនួនបីគ្រឿង ដែលក្នុងមួយគ្រឿងៗមានមនុស្ស ៣០ នាក់ត្រូវបានចាប់ក្នុងមួយខែ។

ii. សាក្សីក៏បានផ្តល់កាត់រយៈពេល ២០ ខែដែរ នៅពេលមានការចាប់ទូកចំនួនបីគ្រឿងយ៉ាងហោចណាស់ក្នុងមួយថ្ងៃ ដែលក្នុងមួយគ្រឿងៗមានមនុស្ស ៣០ នាក់។ ក៏ប៉ុន្តែ គាត់មិនបញ្ជាក់ពីចំនួនថ្ងៃ និងមិនបានរៀបរាប់ពីករណីលើកលែងជារួមទេ។ ទោះបីមានការសន្មតថា ក្នុងមួយថ្ងៃមានការចាប់ទូកបីគ្រឿងដែលជាស្ថិតិបានកើតឡើងជារៀងរាល់ខែក៏ដោយ តែគេមិនបានដកចេញថា តើថ្ងៃទាំងនោះនឹងតំណាងឲ្យការចាប់ទាំងមូលក្នុងខែនោះ ឬ

[730] ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353864 ឆ.៣។

[731] ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353864 ឆ.៣។

[732] ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353858 ឆ.៦១។ ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353865 ឆ.៧, ឆ.៩។ *សូមមើលផងដែរ* ការបញ្ជាក់ និងការបង្ហាញថា ម្តងម្កាលទូកមានដាក់មនុស្សដល់ទៅ ៧០ នាក់៖ ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150960 ឆ.៣៤, ERN 01150961 ឆ.៣៨, ERN 01150962 ឆ.៤៣។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ី ចុះថ្ងៃទីចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៥ ERN 01150968 ឆ.៣។

[733] ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 01127732-01127734 ឆ.៣២-៤៤។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353857-01353859 ឆ.៥៧-៦៣។

យ៉ាងណាទេ ដោយសារភស្តុតាងមិនអនុញ្ញាតឲ្យធ្វើការប៉ាន់ស្មានជាអប្បបរមានូវថ្ងៃដែលចាប់បានបីគ្រឿងក្នុងមួយខែនោះ។

iii. ចំនួនសរុបអប្បបរមានៃការចាប់ជនជាតិថៃ និងជនជាតិវៀតណាមនៅឯសមុទ្រ ត្រូវបានសង្កេតដោយសាក្សីតែម្នាក់គត់ក្នុងរយៈពេល ២០ ខែ ហេតុនេះ មានចំនួន ១.៨០០ នាក់ (២០ខែ គុណនឹង ទូក ៣ គ្រឿង គុណនឹង ៣០ នាក់)។

iv. តាមរយៈចំនួនសរុបនេះ ទូក ៤ គ្រឿង គុណនឹងអ្នកនេសាទថៃ ៦០ នាក់ដែលបានលើកឡើងដោយសាក្សីត្រូវបានកាត់បន្ថយ (២៤០ នាក់) ពាក់ព័ន្ធនឹងការរាប់ពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម។ នៅទីនេះចំនួន ៦០ នាក់ត្រូវតែមាន ដោយសារថាពាក់ព័ន្ធនឹងបទចោទពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម វានឹងផ្តល់ផលប្រយោជន៍កាន់តែច្រើនដល់ **មាស មុត** ប្រសិនបើប្រកាន់យកការគណនាខ្ពស់បំផុតនៃចំនួនជនជាតិថៃ។

v. ហេតុនេះ ការគណនាអប្បបរមាបំផុតនៃជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រក្នុងអំឡុងពេលដែលសាក្សីបានសង្កេតតែម្នាក់ឯងគឺមានចំនួន ១.៥៦០ នាក់ ដែលស្របទៅនឹងការប៉ាន់ស្មានរបស់គាត់ផ្ទាល់តែថាមិនតិចជាង ១.២០០ ឬ ១.៣០០ នាក់នោះ។

vi. ក៏ប៉ុន្តែ ដោយពិចារណាទៅលើភស្តុតាងពាក់ព័ន្ធផ្សេងទៀត ពុំមានហេតុផលដែលជឿបានថា ការអនុវត្តន៍ការចាប់ខ្លួនជនជាតិវៀតណាម និងជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យខុសគ្នា ពីអំឡុងពេលផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ហេតុនេះ គេអាចដកស្រង់ចេញពីការប៉ាន់ស្មានយ៉ាងប្រយ័ត្នប្រយែងក្នុងរយៈពេល ២០ ខែដោយផ្អែកលើសក្ខីកម្មរបស់ ឯក នី ចំពោះថិរវេលាទាំងមូលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបាន។ អង្គហេតុដែលថា ចំនួនអប្បបរមាបំផុត (បន្ទាប់ពីកែតម្រូវចំនួនអតិបរមាសម្រាប់ជនរងគ្រោះថៃ ទៅនឹងជនរងគ្រោះវៀតណាមសរុប) ត្រូវបានយកមកប្រើសម្រាប់ការគណនានេះ សម្របសម្រួល និងកែតម្រូវសម្រាប់ការប្រយ័ត្នចេញពីសក្ខីកម្មដែលថា នៅក្នុងចំនួន ២០ ខែនោះ ចំនួននៃការចាប់ខ្លួនស្ថិតក្នុងចំណោមចំនួនខ្ពស់បំផុតនៃសាក្សីបានសង្កេត។ ដោយសារ មានការចាប់ទូកតាំងពីចុងខែមិថុនា ឆ្នាំ១៩៧៥ រហូត

មក[734] ហើយដោយផ្អែកលើភស្តុតាងដែលថា ការចាប់ទូកបានបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ចំណុចនេះនាំឲ្យដកស្រង់បាននូវចំនួនអប្បបរមាដែលប្រុងប្រយ័ត្ន គឺមានជនជាតិវៀតណាមចំនួន ៣.២៧៦ នាក់ (៤២ ខែ គុណនឹង ជនជាតិវៀតណាមចំនួន ៧៨ នាក់ដែលបានចាប់ខ្លួនក្នុងមួយខែ ចំនួន ៧៨ នាក់ក្នុងមួយខែចេញមកពីការបែងចែកពីជនរងគ្រោះចំនួន ១.៥៦០ នាក់ដែលបានគណនាខាងលើ ក្រោយពីដកជនជាតិថៃចំនួន ២៤០ នាក់ ចែកនឹង ២០ ខែ)។

254. បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនពីរបានលើកឡើងថា ជនជាតិវៀតណាមមួយចំនួនត្រូវបានដោះលែងជាពិសេស[735]។ ការសន្និតទាំងនេះមិនអាចជឿជាក់បានទេ។ ផ្ទុយទៅវិញ ភស្តុតាងច្រើនលើសលប់ផ្សេងទៀតបង្ហាញថា ជនជាតិវៀតណាមទាំងអស់ដែលកងទ័ពជើងទឹកបានចាប់ខ្លួន ត្រូវបានយកទៅសម្លាប់ ហើយថា ទាំងនោះគឺជាបញ្ហា[736]។ ក្នុងកាលៈទេសៈណាក៏

---

[734] ឯកសារ **D114/24** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាវ អ៊ូ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ ERN 01043296-01043297 ឆ.៨៩-ឆ.៩១។

[735] ឯកសារ **D59/1/1.12** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៧ ERN 00926627។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី គឹម អ៊ូ ចុះថ្ងៃ០៣ ខែមីនា ឆ្នាំ២០១៥ ERN 01102498។

[736] ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353867 ឆ. ១៨។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353859 ឆ. ៦៣។ ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992755 ឆ. ៤១។ ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/២ [ប៉ាក សុខ] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៥ ERN 01184074 បន្ទាត់ ២១-២២, ERN 01184088 បន្ទាត់ ៩-២៥, ERN 01184089 បន្ទាត់ ១-២៥, ERN 01184098 បន្ទាត់ ៨-២៥, ERN 01184099 បន្ទាត់ ៤-១២ *សូមមើលផងដែរ* ERN 01184103 បន្ទាត់ ១៩-២២។ ឯកសារ **D114/297.1.21** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ] ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01193802 បន្ទាត់ ២២-២៥, ERN 01193803 បន្ទាត់ ១-៤, ERN 01193823 បន្ទាត់ ៨-៩។ ឯកសារ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ERN 00955486 ឆ.២៥, ERN 00955487 ឆ.២៩, ERN 00955488 ឆ.៣១-ឆ.៣៤។ ឯកសារ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៣ ឆ.២៣-ឆ.២៤។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មូល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049849 ឆ.៣៦, ERN 01049851 ឆ.៤៦-ឆ.៤៩, ERN 01049853- ERN 01049855 ឆ.៦៨-ឆ.៨៤។ ឯកសារ **D114/285** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន សារ៉ាត់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01354326 ឆ.១៩៣-ឆ.១៩៥។ ឯកសារ **D4.1.754** ទូរលេខអាមេរិកពាក់ព័ន្ធនឹងឧបទ្ទវហេតុនៃការចាប់នាវាម៉ាយ៉ាហ្គេស និងការសង្កេតនៅលើកោះតាងនៅខែធ្នូ ឆ្នាំ១៩៧៥ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ (កាលបរិច្ឆេទដាក់ឯកសារ) ERN 00791383-00791384។

ដោយ ដូចបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ រួចហើយ[737] អង្គហេតុដែលថា អាចមានករណីលើកលែងម្តងម្កាល មិនអាចបង្វែរចេញពីអត្ថិភាព និងការអនុវត្តន៍បញ្ជាដើម្បីកម្ចាត់ជនជាតិវៀតណាមទាំងអស់។

255. ក៏ប៉ុន្តែ ភស្តុតាងមិនច្បាស់លាស់ពាក់ព័ន្ធនឹងសមាមាត្រពីទីកន្លែងដែលជនរងគ្រោះត្រូវបានយកទៅសម្លាប់ ទោះជានៅឯសមុទ្រ នៅតាមកោះ ឬនៅលើដីគោក (រួមទាំងនៅចម្ការទុរេន និងនៅមន្ទីរសន្តិសុខ ស-២១)[738]។ ហេតុនេះ ជាក់ស្តែងអាចមានការត្រួតគ្នា និងរាប់ពីរដង។ វាមានន័យគ្រប់គ្រាន់សម្រាប់គោលបំណងរបស់ដីកាដំណោះស្រាយ ហើយពិសេសជាងនេះទៀត សម្រាប់ការបង្ហាញនូវធាតុផ្សំដែលពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល គឺ ស្ថានទម្ងន់នៃអំពើប្រព្រឹត្តិរបស់ជនត្រូវចោទដើម្បីរាប់ឡើងវិញទៅលើចំនួនសរុបនៃការស្លាប់។ ការធ្វើបែបនេះ ពុំចាំបាច់ព្យាយាមគូសបញ្ជាក់ពីទីតាំងសម្លាប់មនុស្ស ឬពិចារណាទៅលើភស្តុតាងបែបនិទានរបស់សាក្សីនានាពីទីតាំងសម្លាប់នីមួយៗ ដែលភស្តុតាងខ្លះត្រឹមតែបង្ហាញតួលេខម្តង ឬពីរដងប៉ុណ្ណោះ[739]។ ហេតុនេះដីកាដំណោះស្រាយនេះនឹងផ្អែកលើចំនួនអប្បបរមាយ៉ាងប្រុងប្រយ័ត្នបំផុតនៃជនជាតិវៀតណាមចំនួន **៣.២៧៦** នាក់ត្រូវបានសម្លាប់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើប្រតិបត្តិការចាប់មនុស្សដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ។

---

[737] សំណុំរឿងលេខ ០០៤/២-ឯកសារ **D360** [សំណៅកោសលុប] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៦២០-៦២១។

[738] ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752 ឆ.២៩, ERN 00992755-00992756 ឆ.៤១, ឆ.៤៣-ឆ.៤៤។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353857 ឆ.៥៧, ERN 01353859 ឆ.៦៣។

[739] ឯកសារ **D1.3.30.25** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ពីកងពល ១៦៤ ផ្នែក នយោបាយ ទូរស័ព្ទសម្ងាត់ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨" ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ ERN 00017026។ ឯកសារ **D1.3.34.64** ទូរស័ព្ទសម្ងាត់ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ERN 00020982។ ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/២ [ប៉ាក សុខ] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01184081-01184082, ERN 01184089-01184090។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985332-00985333 ឆ.១២១-ឆ.១២៧, ERN 00985334-00985335 ឆ.១៣៥-ឆ.១៣៦។ ឯកសារ **D54/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន សាន់ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ERN 00993392-00993394 ឆ.៨០-ឆ.៨៧។ ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោសរបស់ កសចស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ (កាលបរិច្ឆេទដាក់ឯកសារ) ERN (ភាសាអង់គ្លេស) 01222328-01222936៖ *សូមមើលឧទាហរណ៍* កថាខណ្ឌ ២៥០ ដែលរៀបរាប់ចំនួនជនជាតិថៃ និងជនជាតិវៀតណាមដែលបានបញ្ជូនចេញពីកំពង់សោម ទៅមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ តែមួយថ្ងៃ។

256. ដោយហេតុថា ជនជាតិថៃដែលចាប់ខ្លួនត្រូវបានដោះលែងម្តងម្កាល[740] មានតែភស្តុតាងរបស់ មួល ឈិន អំពីការសម្លាប់ប៉ុណ្ណោះដែលអាចយកមកពិចារណាសម្រាប់ធ្វើជាការគណនា[741]។ អតីតទាហាននៅកងវរសេនាតូច ៣៨៦ រូបនេះ ដែលបានចំណាយពេលមួយឆ្នាំនៅកោះរ៉ុងសន្លឹមនៅឆ្នាំ ១៩៧៦[742] បានឃើញអ្នកទោសាទថៃពី ១០ ទៅ ១៥ នាក់ត្រូវបានសម្លាប់រវាងពីរ ឬបីថ្ងៃម្តង[743]។ ចំនួនសរុបនៃការគណនាទាបបំផុតគឺ ១០នាក់ គុណនឹង ១០ ថ្ងៃ គុណនឹង ១២ ខែ ជាលទ្ធផលគឺមានជនជាតិថៃប្រហែល **១.២០០** នាក់ត្រូវបានកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យសម្លាប់។

257. ដោយពិចារណាថា៖

i. ការប៉ាន់ស្មានទាំងនេះកើតឡើងពីរបាយការណ៍យោធាតែមួយគត់ និង ការលើកឡើងរបស់អតីតទាហាននៅកងពលធំ ១៦៤ ពីរនាក់[744]។

ii. តួលេខទាបបំផុតត្រូវបានយកមកពិចារណាចាត់ទុកជាមូលដ្ឋានសម្រាប់ការគណនា។

iii. សាក្សីប្រាំពីរនាក់ផ្សេងទៀតបានធ្វើសក្ខីកម្មអំពីការសម្លាប់ជនជាតិវៀតណាម និងជនជាតិថៃដែលបានចាប់ខ្លួន ដោយមិនបានផ្តល់នូវចំនួនជនជាតិទាំងនោះ[745]។

---

740 *សូមមើល* កថាខណ្ឌ ២១៨។

741 ជាលទ្ធផល ទូកថៃចំនួនបួនគ្រឿងដែលត្រូវបានចាប់ មានយោងនៅក្នុងសក្ខីកម្មរបស់ ឯក នី (*សូមមើល* ឯកសារ **D114/283** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353864 ឆ.៣) មិនត្រូវបានបញ្ចូលនៅក្នុងការគណនានេះទេ។

742 ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មួល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049849 ឆ.៣៩, ឆ.៣៦, ERN 01049858 ឆ.១១០-ឆ.១១១។ ឯកសារ **D114/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មួល ចុះថ្ងៃទីចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ERN 01065115 ឆ.៦៥។

743 ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មួល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN ERN 01049852-01049853 ឆ.៦០-ឆ.៦៥។

744 ឯកសារ **D1.3.30.25** របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ពីកងពល ១៦៤ ផ្នែកនយោបាយ ទូរស័ព្ទសម្ងាត់ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨" ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ ERN 00017026។ ឯកសារ **D114/282** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01353859 ឆ.៦៣។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មួល ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049852 ឆ.៦០-ឆ.៦១។

745 ឯកសារ **D114/126** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម អ៊ូ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150954 ឆ.៧-ឆ.៩, ERN 01150960-01150963 ឆ.៣១-ឆ.៤៥។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិន មួល ចុះ

iv. ពុំយកមកពិចារណានូវភស្តុតាងទាំងអស់ដែលការរាប់ពីរដងមិនអាចត្រូវបានដកចេញ។ និងថា

v. ដូចបានពន្យល់ខាងលើ ការព្យាយាមស្វែងរកកិច្ចសហប្រតិបត្តិការពីប្រទេសថៃ និងវៀតណាមក្នុងការវាយតម្លៃលើ ឯកសារនេះដើម្បីស្វែងរកភស្តុតាងបន្ថែម មិនបានទទួលជោគជ័យឡើយ។

ចំនួនជនរងគ្រោះសរុប **៤.៤៧៦** នាក់ (ជនជាតិថៃចំនួន **១.២០០** នាក់ និងជនជាតិវៀតណាមចំនួន **៣.២៧៦** នាក់) ត្រូវបានភ្ជាប់ទៅនឹងគោលនយោបាយនៃការចាប់ខ្លួនរបស់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាការប៉ាន់ស្មានយ៉ាងប្រុងប្រយ័ត្ន។ ចំនួនជនរងគ្រោះ ហាក់ដូចជាមានច្រើនជាងនេះ។

## ៥.៥ ទីតាំងសម្លាប់ចម្ការទុរេន

### ៥ ១.៥.កម្មវត្ថុនៃការចោទប្រកាន់

---

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049854 ឆ.៧៤, ឆ.៧៦, ឆ.៧៨, ERN 01049855 ឆ.៨១-ឆ.៨៥, ERN 01049861-01049862 ឆ.១៣២-ឆ.១៣៣, ERN 01049862-01049863 ឆ.១៣៦-ឆ.១៤២, ឆ.១៥២។ ឯកសារ **D54/25** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៣ ERN 00955536-00955537 ឆ.៧, ឆ.១២។, ERN 00955539 ឆ.២០។ ឯកសារ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ERN 00955486 ឆ.២៥ ឯកសារ **D114/297.1.20** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/២ [ប៉ាក សុខ] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ERN 01184082 បន្ទាត់ ២២-២៥, ERN 01184083 បន្ទាត់ ១, បន្ទាត់ ១២-១៧, ERN 01184089-01184090។ ឯកសារ **D114/297.1.21** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ប៉ាក សុខ] ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ERN 01193809-01193810, ERN 01193832-01193833។ ឯកសារ **D2/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤០-ឆ.៤៣។ ឯកសារ **D2/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុន សារឿន ចុះថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN 00623889 ឆ.៧-ឆ.១៣។ ឯកសារ **D59/2/3.13a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី យឿន នាក់ ERN 00958267 *ដូចត្រូវបានបញ្ជាក់នៅក្នុង* ឯកសារ **D54/116** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឿន នាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ERN 01007894-01007896 ឆ.៣៦ ឆ.៣៩ ឆ.៤២។ *សូមមើលផងដែរ* ឯកសារ **D54/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ERN 00936681-00936682 ឆ.៤១-ឆ.៥០។ ឯកសារ **D114/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ERN 01025096 ឆ.៧, ERN 01025099 ឆ.២០។ ឯកសារ **D114/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីម អ៊ូ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ERN 01150968 ឆ.៤, ERN 01150970-01150971 ឆ.១៣-ឆ.១៤។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985332-00985333 ឆ.១២១-ឆ.១៣០។

258. ជាជំហានដំបូង ភស្តុតាងបានគាំទ្រនូវអត្ថិភាពនៃចម្ការទុរេនជាច្រើននៅក្នុងបរវេណដ៏ធំទូលាយនៃសហករណ៍វាម។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សំដៅទៅលើចម្ការទុរេនចំនួន ២ ដែលបានប្រើជាទីតាំងសម្លាប់មនុស្សនៅក្នុងសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន ពោលគឺចម្ការមួយនៅជិតមាត់សមុទ្រ និងនៅជើងនៃជួរភ្នំទិសខាងលិច*ទៅទីតាំង*ដែលសម័យនោះហៅថាព្រលានយន្តហោះកងកេង ដែលសហព្រះរាជអាជ្ញាហៅថា "*ចម្ការទុរេន I*" ហើយចម្ការទុរេនមួយទៀតនៅម្ខាងទៀតទិសពាយ័ព្យនៃជួរភ្នំដដែល និងនៅក្បែរបិទត្រាង ដែលសហព្រះរាជអាជ្ញាហៅថា "*ចម្ការទុរេន II*"។

259. នៅក្នុងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១២[746] និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២[747] ស្តីអំពីបញ្ហាថា តើសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងឱ្យធ្វើការស៊ើបសួរទៅលើទីតាំងសម្លាប់ចម្ការទុរេន "នោះ" ឬយ៉ាងណា មានការយោងជាពិសេសទៅលើបណ្តាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលនិយាយអំពីចម្ការទុរេន I។ អត្ថបទរបស់ដីកាបញ្ជូនរឿងទៅពិនិត្យ[748] និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[749] មានលក្ខណៈច្បាស់លាស់ថា មានតែចម្ការតែមួយគត់ដែលជាកម្មវត្ថុនៃការស៊ើបសួរពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយកម្មវត្ថុនោះគឺចម្ការទុរេន I។ ដូចគ្នាដែរចំពោះការចោទប្រកាន់ដែលបានប្រកាសនៅក្នុងការបង្ហាញខ្លួនជាលើកដំបូងរបស់ **មាស មុត** នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅបាត់ដំបង នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៥[750]។

---

[746] ឯកសារ **D47** *ដីកាបញ្ជូនរឿងទៅពិនិត្យ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។

[747] ឯកសារ **D47/1** *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១២* ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២។

[748] ឯកសារ **D47** *ដីកាបញ្ជូនរឿងទៅពិនិត្យ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ៦។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598397។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623887។

[749] ឯកសារ **D47/1** *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១២* ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ៦។

[750] ឯកសារ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ERN 01180562 ERN 01180567-01180568។

260. ដូច្នេះ ចម្ការទុរេន II មិនមែនជាកម្មវត្ថុនៃការស៊ើបសួរជាផ្លូវការឡើយ ហើយភស្តុតាងពាក់ព័ន្ធនឹងចម្ការនេះកើតមានឡើងដោយចៃដន្យប៉ុណ្ណោះ នៅក្នុងអំឡុងពេលសាកសួរសាក្សី ទាក់ទងទៅនឹងចម្ការទុរេន I។ មិនមានដីកាបញ្ជូនរឿងទៅពិនិត្យផ្សេងទៀត ត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងចម្ការទុរេន II ទេ។ តាមទ្រឹស្តី ទោះជាត្រូវពង្រីកវិសាលភាពក៏ដោយ ការពិចារណាទៅលើចម្ការទុរេន II អាចធ្វើទៅបាននៅក្នុងបរិបទនៃការចោទប្រកាន់ទាំងឡាយពាក់ព័ន្ធទៅនឹងការដ្ឋានបិទត្រាង ដោយសារមានទីតាំងនៅជិតគ្នា ប៉ុន្តែមិនមានការចោទប្រកាន់ពីការសម្លាប់មនុស្សបានលើកឡើងទេពាក់ព័ន្ធនឹងបិទត្រាង។ ដូច្នេះ ការបញ្ចូលចម្ការទុរេន II ថាជាទីតាំងសម្លាប់មនុស្សនៅក្នុងការចោទប្រកាន់ពាក់ព័ន្ធទៅនឹងបិទត្រាងមិនអាចធ្វើទៅបានឡើយ។ ហេតុនេះ មិនមានការប្តឹងជាផ្លូវការឲ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរទៅលើចម្ការទុរេន II, ការចោទប្រកាន់មិនដែលបានធ្វើឡើងពាក់ព័ន្ធទៅនឹងទីតាំងនេះ, ទីតាំងនេះមិនមែនជា*កម្មវត្ថុ*នៃការស៊ើបសួរ ដូច្នេះហើយវាមិនអាចបង្កើតបានជាផ្នែកមួយនៃដីកាដំណោះស្រាយនេះបានឡើយ។ ហេតុនេះ តទៅនេះរាល់ការលើកឡើងអំពីចម្ការទុរេនណាមួយ គឺនិយាយតែអំពីអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិហៅថាចម្ការទុរេន I ប៉ុណ្ណោះ។

### ៥ ២.៥.ទីតាំង និងពេលវេលានៃការដំណើរការ

261. ចម្ការទុរេនមានទីតាំងស្ថិតនៅជើងនៃជួរភ្នំ ដែលស្ថិតនៅជាប់ភាគខាងលិចនៃព្រលានយន្តហោះកងកេង ហើយមានចម្ងាយប្រហែល១គីឡូម៉ែត្រពីឆ្នេរសមុទ្រប៉ែកខាងនិរតី។ ទីតាំងនេះស្ថិតនៅជិតចម្ការដូង និងក្រូច ហើយទីតាំងទាំងនេះសរុបចូលគ្នា ជួនកាលហៅថាចម្ការ*ចេងហេង*[751]។

---

[751] ឯកសារ **D114/58** កំណត់ហេតុស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ERN 01077753-01077754 ឆ.៤៧-ឆ.៤៩។ ឯកសារ **D114/77** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101701 ឆ.១, ERN 01101703-01101704 ឆ.១០-ឆ.១២ និង ឯកសារ **D114/77.3** ឧបសម្ព័ន្ធ ៣៖ គំនូសតាងនៃទីតាំង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101698។ ឯកសារ **D114/175** កំណត់ហេតុស្តាប់អ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01211343-01211344 ឆ.២២-ឆ.២៥ និងឯកសារ **D114/175.1** ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខេត្តព្រះសីហនុ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ERN 01211334។ ឯកសារ **D114/194** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01221873 ឆ.៤៧។ ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752-00992753 ឆ.២៩-ឆ.៣០។ ឯកសារ **D54/18** កំណត់ហេតុស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ERN 00947207 ឆ.៣៣។ ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00955546-

262. ចម្ការនេះបានប្រតិបត្តិការជាទីតាំងសម្លាប់មនុស្សមួយចាប់តាំងពីដើមឆ្នាំ១៩៧៥ ភ្លាមៗបន្ទាប់ពីការជួលរលំទីក្រុងភ្នំពេញ ហើយបន្តដំណើរការរហូតដល់យ៉ាងហោចណាស់ឆ្នាំ១៩៧៧[752]។

៥ ៣.៥.រចនាសម្ព័ន និងបុគ្គលិក

263. ចម្ការនេះស្ថិតនៅក្នុងការគ្រប់គ្រងរបស់កងទ័ពនៃកងពលធំ ១៦៤។ សាក្សីម្នាក់ ដែលជាយោធាកម្ពុជាប្រជាធិបតេយ្យបានបំភ្លឺថា គាត់បានមកឈរជើងរួចទៅហើយនៅជិតៗនោះនៅក្នុងឆ្នាំ ១៩៧៥ មុនពេលរចនាសម្ព័ន្ធថ្នាក់ក្រោម*យោធា*នៃកងពលធំ ១៦៤ បាន*ប្តូរ*ឈ្មោះ ដោយលើកឡើងថា គាត់បានបម្រើការជាសមាជិកនៃ "*វរៈសេនាតូច* ៣៨៦ នៃតំបន់៣៧" ចំណែកឯអង្គភាពនានាដែលនៅក្រោមបង្គាប់កងពលធំ ១៦៤ ដែលបោះទីតាំងនៅក្នុងតំបន់រាម ក្រោយមកហៅថាវរៈសេនាធំ ៦២ និង ៦៣[753]។ កម្មាភិបាលទាំងនេះត្រូវបានសាក្សីហៅថា ជាអនុបញ្ញាការប្រចាំ*ទីតាំងឈរជើង៖* តាញ៉ាញ់ និងតាជន[754] តាមិញ[755]។

---

00955547 ឆ.១១, ឆ.១៣, ERN 00955547 ឆ.១៤ និង ឯកសារ **D54/26.1** ផែនទីរដ្ឋបាលនៃស្រុកស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ERN 00955542។ ឯកសារ **D54/45** កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ERN 00967528 ឆ.២៦ និង ឯកសារ **D54/45.2** ប្រព័ន្ធផ្លូវថ្នល់ និងភូមិសាស្ត្រក្រុងព្រះសីហនុ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ERN 00967555។ ឯកសារ **D54/90** កំណត់ហេតុស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ERN 00987104 ឆ.១ និង ឯកសារ **D54/89.1** ផែនទីរដ្ឋបាលនៃស្រុកព្រៃនប់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៤ ERN 00987086។ ឯកសារ **D54/109** កំណត់ហេតុស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៤ ERN 00997246 ឆ.១៧។ ឯកសារ **D54/120** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ កែម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៤ ERN 01023175 ឆ.៨-ឆ.៩ និង ឯកសារ **D54/120.1** គំនូសតាងទីតាំង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ERN 01023168។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623889 ឆ.៦។

[752] ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992753-00992754 ឆ.៣២ ឆ.៣៩។ ឯកសារ **D54/18** កំណត់ហេតុស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ERN 00947208 ឆ.៤២, ERN 00977284 ឆ.៥៤។ ឯកសារ **D54/90** កំណត់ហេតុស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ERN 00987104 ឆ.១។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤៨។

[753] ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096742-01096743 ឆ.១២។ ឯកសារ **D114/77** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101701 ឆ.២។ ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992753 ឆ.៣១ (ស្តីអំពី "*វរៈសេនាតូច* ៣៨៦")។ ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១

### ៥ ៤.៥.ការប្រើប្រាស់ជាទីតាំងសម្លាប់មនុស្ស

264. មានភស្តុតាងលើសលុបបង្ហាញពីការសម្លាប់ទ្រង់ទ្រាយធំថាបានកើតឡើងនៅចម្ការនេះ ប៉ុន្តែមិនមានការបំភ្លឺដោយសាក្សីដែលបានឃើញផ្ទាល់ភ្នែកចំពោះព្រឹត្តិការណ៍ជាក់ស្តែងនៃការសម្លាប់ទេ។ ភស្តុតាងទាំងអស់ពាក់ព័ន្ធនឹងការសម្លាប់ គឺជាការនិយាយតគ្នាមួយ ឬនិយាយតគ្នាពីរតក៏មាន តែទោះជាយ៉ាងណាក៏ដោយ មានសាក្សីបំភ្លឺពាក់ព័ន្ធទៅនឹងមនុស្សត្រូវបានបណ្តើរកាត់ចម្ការ ដោយយោធានៃវរៈសេនាធំលេខ ៦២ ឬ ៦៣ នៃកងពលធំ ១៦៤។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងបង្កើតបានជាលំនាំដដែលៗ ដែលអាចទាញការសន្និដ្ឋានបានយ៉ាងរឹងមាំ និងស៊ីសង្វាក់គ្រប់គ្រាន់គាំទ្រដល់ការចោទប្រកាន់ថាចម្ការនោះត្រូវបានប្រើប្រាស់ ហើយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាទីតាំងសម្លាប់មួយ។ សាក្សីបានបំភ្លឺថា នៅក្នុង ឬនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មានឆ្អឹងមនុស្សបានរកឃើញនៅចម្ការនោះ។ នៅលាយឡំជាមួយនឹងឆ្អឹងមនុស្ស ឃើញមានខោអាវ និងខ្សែ។ ពាក់ព័ន្ធនឹងខ្សែ ការសន្និដ្ឋានមួយអាចធ្វើទៅបានដោយមានហេតុផលសមរម្យថា ខ្សែនោះត្រូវបានប្រើសម្រាប់ចងជនរងគ្រោះ យ៉ាងហោចណាស់ក៏ដោយសារមានសាក្សីបំភ្លឺខ្លះៗបញ្ជាក់ថា មានជនរងគ្រោះត្រូវបានចង*និង*បណ្តើរបិទមុខឆ្លងកាត់ចម្ការនោះ[756]។

---

ខែ តុលា ឆ្នាំ ២០១៣ ERN 00955547 ឆ.១៣។ ឯកសារ **D54/90** កំណត់ហេតុស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ERN 00987106 ឆ.៧។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤៣-ឆ.៤៤។

[754] ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01235039 ឆ.១២ (វរៈសេនាធំ៦៣)។

[755] ឯកសារ **D114/77** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101701 ឆ.២ (វរៈសេនាធំ៦២)។

[756] ឯកសារ **D114/5** កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ផាន រីន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ERN 01029083 ឆ.៤០, ERN 01029083 ឆ.៤២។ ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096742-01096743 ឆ.១១-ឆ.១២។ ឯកសារ **D114/89** កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01111043 ឆ.១៣២-ឆ.១៣៦។ ឯកសារ **D114/156** កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ERN 01197067 ឆ.២០២, ERN 01197067 ឆ.២០៣-ឆ.២០៨។ ឯកសារ **D114/175** កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01211343-01211344 ឆ.២២-ឆ.២៨។ ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752-00992753 ឆ.២៩-ឆ.៣២ ERN 00992755 ឆ.៤១-ឆ.៤២។ ឯកសារ **D54/18** កំណត់ហេតុស្តាប់ចម្លើយសាក្សី នួ សារឿន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ERN 00947207 ឆ.៣៣-៣៦, ERN

01600680



265. ជនរងគ្រោះទាំងឡាយដែលបានសម្លាប់នៅចម្ការនេះ ទំនងភាគច្រើនជាអ្នកនេសាទជនជាតិថៃ និង វៀតណាម ដែលកងនាវាកម្ពុជាប្រជាធិបតេយ្យចាប់បាននៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ដែលសាក្សីសម្គាល់បានជាពិសេសដោយសារ អ្នកនេសាទទាំងនោះស្លៀកពាក់ខោអាវចម្រុះពណ៌ដែលមើលទៅខុសប្លែកយ៉ាងខ្លាំងពីឯកសណ្ឋានខ្មៅនៃយោធាកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក៏ដោយ មានភស្តុតាងបញ្ជាក់ថា ជនស៊ីវិលនៅមូលដ្ឋាននេះក៏ត្រូវបានសម្លាប់ផងដែរនៅទីតាំងនេះ[757]។

---

00947207-00947208 ឆ.៣៧-ឆ.៤៤, ERN 00947208-00947209 ឆ.៤៥-៥១, ERN 00947209-00947210 ឆ.៥២-ឆ.៥៥។ ឯកសារ **D54/23** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៣ ERN 00955549 ឆ.២៥, ERN 00955551-00955552 ឆ.៣៥។ ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៣ ERN 00955547 ឆ.១៣, ERN 00955547 ឆ.១៥-ឆ.១៦។ ឯកសារ **D54/90** កំណត់ហេតុស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ERN 00987104 ឆ.១-ឆ.២ ERN 00987105 ឆ.៣-ឆ.៦។ ឯកសារ **D54/118** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ កែម ERN 01023171 ឆ.១ (ស្តីអំពីសេចក្តីសង្ខេបរបស់អ្នកស៊ើបអង្កេតពីមុន)។ ឯកសារ **D54/120** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ កែម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៤ ERN 01023174 ឆ.៤។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤០-ឆ.៤២-ឆ.៤៤, ERN 00598407 ឆ.៤៥-ឆ.៤៦។ ឯកសារ **D2/16** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623910 ឆ.៣២-ឆ.៣៣។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១០ ERN 00623889-00623890 ឆ.៦-ឆ.១៤ ERN 00623890-00623891 ឆ.១៥-ឆ.២៦ ERN 00623891-00623892 ឆ.២៧-ឆ.៣៩, ERN 00623892 ឆ.៤០-ឆ.៤៣។

[757] ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752-00992753 ឆ.២៩, ឆ.៣២។ ឯកសារ **D54/18** កំណត់ហេតុស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ERN 00947207 ឆ.៣៣-ឆ.៣៦, ERN 00947207-00947208 ឆ.៣៧-ឆ.៤៤, ERN 00947208-00947209 ឆ.៤៥-ឆ.៥១, ERN 00947209-00947210 ឆ.៥២-ឆ.៥៥។ ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00955547 ឆ.១៣, ERN 00955547 ឆ.១៥-ឆ.១៦។ ឯកសារ **D54/118** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ កែម ERN 01023171 ឆ.១ (ស្តីអំពីសេចក្តីសង្ខេបរបស់អ្នកស៊ើបអង្កេតពីមុន) និង ឯកសារ **D54/120** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ កែម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ERN 01023174 ឆ.៤។ ឯកសារ **D2/6** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤០-ឆ.៤២-ឆ.៤៤ ERN 00598407 ឆ.៤៥-ឆ.៤៦។ ឯកសារ **D2/16** កំណត់ហេតុស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623910 ឆ.៣២-ឆ.៣៣។ ឯកសារ **D2/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623889-00623890 ឆ.៦-ឆ.១៤, ERN 00623890 ឆ.១៥-ឆ.២៦, ERN 00623891-00623892 ឆ.២៧-ឆ.៣៩, ERN 00623892 ឆ.៤០-ឆ.៤៣។ ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ដេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥

266. ភស្តុតាងមួយជាក់លាក់ដដែលៗ ហើយគួរឲ្យតក់ស្លុតនោះ គឺការប្រើប្រាស់សពជនរងគ្រោះធ្វើជាជីរសម្រាប់ដាំដើមទុរេននៅចម្ការនោះ។ សពត្រូវបានកប់នៅក្នុងរណ្ដៅក្រោមដើមទុរេននីមួយៗ។ ការបំភ្លឺរបស់សាក្សីពាក់ព័ន្ធទៅនឹងចំនួនសពនៅក្រោមដើមឈើនីមួយៗ មិនមានបញ្ជាក់ច្បាស់លាស់ទេសម្រាប់ចម្ការនេះ ប៉ុន្តែនៅឯចម្ការផ្សេងៗទៀតនៅតំបន់រាម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំ ១៦៤ ចំនួនសពមានយ៉ាងហោចណាស់ពី ២ ទៅ ៤នាក់។ តាមពិតចំនួនសពដែលបានស្លាប់នៅតាមដើមឈើនោះជាការច្បាស់ណាស់គឺមានចំនួនច្រើន រហូតដល់ថ្នាក់នៅកន្លែងខ្លះដើមឈើបានចាប់ផ្ដើមងាប់ ដោយសារតែមានជីរច្រើនពេក[758]។ មានហេតុផលសមរម្យដែលថា ការអនុវត្តបែបនេះ អាចមិនខុសគ្នាច្រើនទេពីចម្ការមួយទៅចម្ការមួយ នៅក្រោមការគ្រប់គ្រងរបស់កងពលធំ ១៦៤ ហើយអាស្រ័យហេតុនេះ ភស្តុតាងយកមកពីចម្ការផ្សេងៗមានសារៈប្រយោជន៍នៅក្នុងការឆ្លុះបញ្ចាំងពីការអនុវត្តនៅចម្ការទុរេន I។

267. ទោះជាសន្និដ្ឋានយកតួលេខតិចតួចនៃសាកសពពីរនាក់ក្នុងដើមទុរេនមួយដើម ហើយនិងទំហំដីចម្ការជាមធ្យមដែលមានដើមទុរេនយ៉ាងហោចណាស់រាប់សិបឡូត៍[759] សរុបជាមួយនឹងតួលេខជន

---

ERN 01096742 ឆ.១១។ សូមមើលផងដែរ ឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ២៣១។

[758] ឯកសារ **D114/2** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី០៩ ខែ កញ្ញា ឆ្នាំ ២០១៤ ERN 01025093 ឆ.១ ERN 01025094 ឆ.៣ ERN 01025095 ឆ.៤ ឆ.៦ ERN 01025096 ឆ.៨។ ឯកសារ **D54/123** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ERN 01025097 ឆ.១០-ឆ.១២, ERN 01025098 ឆ.១៣-ឆ.១៦។ ឯកសារ **D54/90** កំណត់ហេតុស្ដាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ERN 00987108 ឆ.២០, ERN 00987109-00987110 ឆ.២១-ឆ.២៧, ERN 00987110-00987111 ឆ.២៨-ឆ.៣៤។ ឯកសារ **D54/102** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752 ឆ.២៩ ERN 00992753 ឆ.៣២។ ឯកសារ **D54/26** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00955547 ឆ.១៣, ERN 00955547 ឆ.១៥-ឆ.១៦។ ឯកសារ **D54/118** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រំ កែម ERN 01023171 ឆ.១ (ស្ដីអំពីសេចក្ដីសង្ខេបរបស់អ្នកស៊ើបអង្កេតពីមុន)។ ឯកសារ **D54/120** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រំ កែម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ERN 01023174 ឆ.៤។ ឯកសារ **D2/26** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ERN 00598407 ឆ.៤០-ឆ.៤២ ឆ.៤៤, ERN 00598407 ឆ.៤៥-ឆ.៤៦។

[759] ដោយសារមានការផ្លាស់ប្ដូរសណ្ឋានដីភូមិសាស្ត្រ និងដោយសារមានជាពិសេសការហូរច្រោះដីជាច្រើននៅក្នុងតំបន់នោះក្នុងរយៈពេលយូរ ការរាប់ចំនួនដើមឈើឲ្យបានត្រឹមត្រូវ ជាការពិតណាស់មិនអាចរាប់បានទៀតទេ ហើយសាក្សីទាំងឡាយចាំមិនបាននូវតួលេខច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែដើមទុរេនរាប់ឡូត៍ ក៏ទំនងជាតួលេខដែលគិតទាបបំផុត។ មានការប្រែប្រួលដូចគ្នានេះដែរ ដោយសារមានការកាយរណ្ដៅជុំវិញដើមទុរេនទាំងនោះ។

រងគ្រោះថៃ និងវៀតណាមដែលបានចាប់នៅសមុទ្រ ចំនួនមនុស្សដែលបានសម្លាប់នៅទីនោះ ក្នុង រយៈពេលទាំងមូលត្រូវតែមានចំនួនរាប់រយនាក់។ អាស្រ័យហេតុនេះមានហេតុផលសមរម្យបញ្ជាក់ថា តួលេខតិចបំផុត គឺមានសាកសពចំនួន ២០០នាក់ នៅក្នុងរយៈពេលនៃប្រតិបត្តិការទីតាំងសម្លាប់នោះ។ ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ អាចនឹងមានចំនួនសាកសពច្រើនជាងនេះ[760]។

268. ដូចដែលភស្តុតាងបានបញ្ជាក់ចេញមកពីឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលបានប្រព្រឹត្តដោយកងនាវាកម្ពុជាប្រជាធិបតេយ្យនៅលើបណ្តាកោះ បញ្ជារបស់ **មាស មុត** ក្នុងនាមជាមេបញ្ជាការកងពលធំ ១៦៤ មានន័យថា *រាល់* ជនជាតិវៀតណាមដែលបានចាប់មកពីសមុទ្រត្រូវតែសម្លាប់ចោល ដោយសារវៀតណាមជាតស្រូវធំជាប្រវត្តិសាស្ត្ររបស់ខ្មែរ ចំណែកឯវាសនារបស់ជនជាតិថៃដែលបានចាប់ដូចគ្នា ត្រូវបានលើកលែងខ្លះៗតាមរយៈការដោះដូរទំនិញ ដោះដូរយោធាកម្ពុជាប្រជាធិប តេយ្យ។ល។ ទោះជាយ៉ាងណាក៏ដោយ រយៈកាលកន្លងមកទៀត អង្គភាពយោធាកម្ពុជាប្រជាធិបតេយ្យនៅតំបន់នោះកាន់តែទទួលបានបទបញ្ជាឲ្យសម្លាប់ជនរងគ្រោះដែលចាប់បាននៅនឹងកន្លែងផ្ទាល់នៅសមុទ្រ ឬនៅទីតាំងឈរជើងរបស់ពួកគេនៅតាមកោះ ដើម្បីកុំឲ្យខាតបង់ធនធាន ដោយបញ្ជូនជនរងគ្រោះមកវាមហើយសម្លាប់នៅចម្ការនោះ[761]។ ជាមួយគ្នានេះ វាទំនងដែលថា ការបញ្ជាឲ្យយកសពជនរងគ្រោះមកធ្វើជាជីរ ត្រូវបានបញ្ជាដោយផ្ទាល់ពី **មាស មុត**[762] ដែលជាថ្មីម្តងទៀតត្រូវបានបញ្ជាក់បន្ថែមតាមរយៈការអនុវត្តដូចៗគ្នា ក្នុងការយកជនរងគ្រោះធ្វើជាជីរ *នៅ*ទីតាំងសម្លាប់មនុស្សផ្សេងៗទៀត នៅក្រោមការគ្រប់គ្រងរបស់កងពលធំ ១៦៤ ទោះបីជានៅតាមបណ្តាកោះក៏មានដែរ។ វាមិនទំនងទាល់តែសោះដែលថា លំនាំដែលបានកើតឡើងដដែលៗបែបនេះ

---

[760] ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ERN 00977835 ឆ.១៣, ERN 00977836 ឆ.១៥-ឆ.១៦ បានបំភ្លឺថា គ្រាន់តែ "ជនជាតិវៀតណាមមានចំនួនរាប់រយនាក់"។

[761] សូមមើលឧទាហរណ៍ដូចជា ឯកសារ **D54/23** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ERN 00977534 ឆ.២៥, ERN 00977536 ឆ.៣៥ ដែលបានបំភ្លឺថា ក្រុមមនុស្សដល់ទៅ២០នាក់ត្រូវបានសម្លាប់ភ្លាមៗនៅនឹងកន្លែង ចំណែកឯក្រុមមនុស្សច្រើនជាងនេះទៀតត្រូវបានបញ្ជូនទៅដីគោក។ សូមមើលផងដែរផ្នែកនៃដីកាដំណោះស្រាយនេះ ដែលលើកឡើងអំពីឧក្រិដ្ឋកម្មទាំងឡាយប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ កថាខណ្ឌ ២៣១។

[762] ឯកសារ **D54/102** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ERN 00992752 ឆ.២៩_ ប៉ុន្តែសាក្សីម្នាក់បានបំភ្លឺថា គាត់មិនដែលបានឮមាស មុត និយាយអំពីចម្ការនោះឡើយ៖ ឯកសារ **D54/26** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00977837 ឆ.២០។

បានកើតឡើង ដោយផ្អែកតែទៅលើការសម្រេចជាលក្ខណៈបុគ្គលរបស់មេបញ្ជាការថ្នាក់មូលដ្ឋាន នោះ។

៥របស់ មាស មុតទីកន្លែងការចុះទៅដល់ ៥.៥.

269. មិនមានភស្តុតាងបញ្ជាក់ថា **មាស មុត** បានមកទស្សនកិច្ចមន្ទីរនោះឡើយ។

## ៥.៦ ឧក្រិដ្ឋកម្មប្រឆាំងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង១១៧

៥ផ្តើមសេចក្តី ១.៦.

270. នៅត្រឹមដំណាច់ឆ្នាំ ១៩៧៥ កងពលធំ ១៦៤, ៥០២ និង៣១០ គឺជា "កងពលធំមជ្ឈិម" ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គសេនាធិការ ដូចគ្នានឹងកងពលធំ ១១៧ ដែរ បន្ទាប់ពីការរើទីតាំងទៅក្រចេះនៅចុងឆ្នាំ១៩៧៧[763]។ កងទ័ព និងកម្មាភិបាលមកពីកងពលធំទាំងអស់នេះ ត្រូវបានបោសសម្អាតចាប់ពីឆ្នាំ១៩៧៦ មក។

---

[763] ឯកសារ **D114/29.1.13** កំណត់ហេតុស្តួរចម្លើយជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ERN 00398158។ កងពលធំ១៦៤៖ សូមមើលរចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា និងតួនាទីនិងការទទួលខុសត្រូវរបស់ មាស មុត កថាខណ្ឌ ១៥៥។ <u>កងពលធំ៥០២៖</u> ឯកសារ **D2/18** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ERN 00629455 ឆ.៣១។ ឯកសារ **D4.1.553** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ERN 00270178។ ឯកសារ **D114/198** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន សំអូន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ERN 01235286 ឆ.៤៦ ឆ.៤៨។ ឯកសារ **D1.3.32.27** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ គង់ គីម ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ ERN 00054840 *ដូចដែលត្រូវបានបញ្ជាក់អះអាងនៅក្នុង* ឯកសារ **D114/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171454 ឆ.៤៧។ ឯកសារ **D4.1.845** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404634 ឆ.២៤-ឆ.២៥។ ឯកសារ **D4.1.854** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ERN 00357536 ERN 00357538។ ឯកសារ **D234/2.1.107** *ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២* [ញ៉ែម អេន] ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ERN 01247057 បន្ទាត់ ៤-១០។ <u>កងពលធំ ៣១០៖</u> ឯកសារ **D114/198** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន សំអូន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ERN 01235286 ឆ.៤៧។ ឯកសារ **D4.1.845** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404634 ឆ.២៤។ ឯកសារ **D234.2.1.50** របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ អំពីស្ថានភាពទូទៅនៅក្នុងកងពលធំ៣១០ និងកងពលធំ៤៥០ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៦ ERN 00876995។ សូមមើលផងដែរ ឯកសារ **D114/168** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រិន្ទ ង៉ិក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01218476 ឆ.៥៨។ ឯកសារ **D114/297.1.31** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២

## ៥១៦៤ ធំពលការបោសសម្អាតកង ២.៦.

### *៥.៦.២.១ ការចាប់ខ្លួន និងការឃុំខ្លួន*

271. ការបោសសម្អាតនៅក្នុងកងពលធំ១៦៤ គឺមានចាប់ពីការបោសសម្អាតទ្រង់ទ្រាយធំ ទៅលើកងទាំងមូល រហូតដល់ការបោសសម្អាត ទៅលើកងទ័ពម្នាក់ៗ (ទាំងនៅក្នុងកងកម្លាំងឋានន្តរសក្តិខ្ពស់ និងនៅក្នុងកងកម្លាំងទូទៅ)។ ការបោសសម្អាតត្រូវបានធ្វើឡើង ដោយកងកម្លាំងកងពលធំ ១៦៤ ហើយភាគច្រើនត្រូវបានដាក់ទៅក្នុងកងនិងទីតាំង ដែលគ្រប់គ្រងដោយកងពលធំ ១៦៤។ កងទ័ពដែលត្រូវបានបោសសម្អាត ត្រូវបានបញ្ជូនទៅ "រៀនសូត្រ" ឬបាត់ខ្លួន ហើយការពន្យល់ដែលសមហេតុផលតែមួយគត់ គឺពួកគេត្រូវបានសម្លាប់។

272. យ៉ាងហោចណាស់មានការបោសសម្អាតទ្រង់ទ្រាយធំចំនួនបី ទៅលើកងទ័ពនៅក្នុងកងពលធំ១៦៤៖

i. កងទ័ពភូមិភាគបូព៌ា

ii. កងវរសេនាតូច៣១០

iii. កងវរសេនាតូច៣៨៥ និង៣៨៦

*កងទ័ពភូមិភាគបូព៌ា*

---

[សែម អំ] ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ERN 01370089-01370090។ ឯកសារ **D114/225** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហាន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ERN 01301610 ឆ.៧១។ <u>កងពលធំ១១៧៖</u> ឯកសារ **D54/63** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00982738 ឆ.១៥។ ឯកសារ **D54/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ERN 00975779 ឆ.៤។ ឯកសារ **D114/297.1.23** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ [ម៉ឹង វេត] ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ERN 01329808 បន្ទាត់ ១-២ ERN 01329810 បន្ទាត់ ២-៥។ ឯកសារ **D114/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071594 ឆ.១, ឆ.៤-ឆ.៦។ ឯកសារ **D114/84** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ERN 01110619 ឆ.២៦។

273. កងទ័ពភូមិភាគបូព៌ាត្រូវបានបោសសម្អាត ជាទ្រង់ទ្រាយធំ ចាប់ពីប៉ែកខាងកើតប្រទេស[764]។ ជាដំបូងមានការចោទប្រកាន់ថា សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា[765] បានជួយដល់វៀតណាម[766]។ បន្ទាប់ពីនោះមក កងទ័ពភូមិភាគបូព៌ាទាំងអស់ ត្រូវបានចាត់ទុកថាជាជនក្បត់[767]។ មានការគូសវាសផែនការមួយ ដើម្បីបោសសម្អាតភូមិភាគបូព៌ា ហើយ **មាស មុត**, តា ម៉ុក និង ស៊ូ ម៉េត បានចូលរួមក្នុងប្រតិបត្តិការនេះ[768]។

274. មានកងទ័ពជា៥០០នាក់ មកពីភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅកំពង់សោម នៅក្នុងឆ្នាំ១៩៧៥ ដើម្បីជួយដល់ការបង្កើតកងពលធំ ១៦៤ ថ្មី (តាមសក្ខីកម្មមានការបញ្ជូនកងទ័ព ចាប់ពី៥០០ រហូតដល់ ១៥០០នាក់)[769]។ កងទ័ពទាំងអស់នេះដឹកនាំដោយ ឌឹម ដែលបានក្លាយជាអនុប្រធាន

---

[764] ឯកសារ **D32/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ វិចិត្រ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២ ERN 00800976 ឆ.២៣។ ឯកសារ **D114/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ERN 01118166-01118167 ឆ.៦។

[765] ឯកសារ **D32/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆែម ហឿង ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ ERN 00787917 ឆ.១២។ ឯកសារ **D32/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង សាត ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ ERN 00808427 ឆ.៣។ ឯកសារ **D54/96** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គេង សារឹម ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ERN 00988677 ឆ.៥-ឆ.៦។

[766] ឯកសារ **D32/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ សារ៉ន ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ERN 00804103 ឆ.១០។

[767] ឯកសារ **D54/96** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គេង សារឹម ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ERN 00988677 ឆ.៦។

[768] ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ERN 00985323 ឆ.៧៥។ ឯកសារ **D114/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ERN 01118167-01118168 ឆ.៨-ឆ.១២ ERN 01118169 ឆ.៣៦។ ឯកសារ **D114/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01202357 ឆ.២៨។ ឯកសារ **D114/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01171454 ឆ.៣៦ ERN 01171455 ឆ.៥០-ឆ.៥២ ERN 01171457 ឆ.៧១-ឆ.៧៦។ ឯកសារ **D98/3.1.27**, ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ [ឈួក រិន] ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ERN 00901254, បន្ទាត់ ១២ -២៤។ ឯកសារ **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ERN 00194468។ *សូមមើល កថាខណ្ឌបន្តបន្ទាប់ និងការបោសសម្អាតកងពលធំ ៥០២ កងពលធំ ៣១០ និងកងពលធំ ១១៧*កថាខណ្ឌ ៣០០-៣០២។

[769] ឯកសារ **D54/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964188 ឆ.២០ (៧០០)។ ឯកសារ **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ERN 00967514 ឆ

ម្នាក់ក្នុងចំណោមអនុប្រធាននានារបស់ **មាស មុត**[770]។ កងទ័ពទាំងអស់នេះត្រូវបានធ្វើសមាហរណកម្ម ទៅក្នុងកងទ័ពជើងទឹក និងកងផ្សេងៗទៀតរបស់កងពលធំ ១៦៤[771]។

275. បន្ទាប់ពីចាប់ខ្លួន ឌឹម នៅដើមឆ្នាំ១៩៧៧[772] កងទ័ពទាំងអស់នេះត្រូវបានដកហូតអាវុធ[773] ហើយត្រូវបានដកចេញពីទីតាំងនានា រួមទាំងពីបណ្តាកោះ[774] នាវាកងទ័ពជើងទឹក[775] ហើយថែមទាំងត្រូវ

---

.៥ ERN 00967517 ឆ.១៩ (១៥០០)។ ឯកសារ **D114/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01121880 ឆ.៥២ (៥០០-៦០០)។ ឯកសារ **D114/220** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ERN 01301538 ឆ.២៣ (ប្រហែល១០០០)។

[770] ឯកសារ **D114/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ ERN 01096734 ឆ.១២។ ឯកសារ **D114/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ERN 01110627 ឆ.១០ ERN 01110631 ឆ.២៩។ ឯកសារ **D114/219** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ERN 01301515 ឆ.១២-ឆ.១៣ ERN 01301518 ឆ.១៧។ ឯកសារ **D114/220** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ERN 01301538 ឆ.២៣ ឆ.២៧ ERN 01301541 ឆ. ៤៧។

[771] ឯកសារ **D2/9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ ERN 00607081 ឆ.៣៨។ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049847 ឆ.២២។ ឯកសារ **D114/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ERN 01110627 ឆ.១០។ ឯកសារ **D114/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01111032-01111033 ឆ.១៦-ឆ.១៧។

[772] សូមមើល *វចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា និងតួនាទីនិងការទទួលខុសត្រូវរបស់ មាស មុត* កថាខណ្ឌ ១៥៧។

[773] ឯកសារ **D54/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ERN 00936731 ឆ.១៥។ ឯកសារ **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ERN 00967515 ឆ.៦។ សូមមើលផងដែរ ឯកសារ **D114/220** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ERN 01301539 ឆ.៣១-ឆ.៣៣, ERN 01301543 ឆ.៥៣-ឆ.៥៤។

[774] ឯកសារ **D114/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01111035-01111036 ឆ.៤១ ឆ.៤៥-ឆ.៤៧ ឆ.៥១-ឆ.៥៥។ ឯកសារ **D114/219** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ERN 01301518-01301519 ឆ.១៧ ឆ.២៣-ឆ.២៤។ សូមមើលផងដែរ ឯកសារ **D54/97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 00988689-00988690 ឆ. ៥ ឆ.១០, ERN 00988695 ឆ.២៦-ឆ.២៧, ERN 00988696 ឆ.២៩។

[775] ឯកសារ **D54/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964188 ឆ.20។ ឯកសារ **D54/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ឈា ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ERN 00998661-00998664 ឆ.១២៨-ឆ.១៤៩។

បានកោះហៅឲ្យវិលត្រឡប់ ពីកម្មវិធីបណ្តុះបណ្តាលនៅប្រទេសចិនទៀតផង[776] ដោយដំបូងគឺមេដឹកនាំ ហើយបន្ទាប់មកគឺកងទ័ពដែលមានបណ្តាស័ក្តិ[777]។ នៅក្នុងការប្រជុំមួយដែលធ្វើឡើងនៅទីបញ្ជាការកងពលធំ ១៦៤ ដែលស្ថិតនៅកំពង់ស្ពឺនោះ **មាស មុត** បានប្រកាសថា កងទ័ពទាំងអស់ដែលមកពីភូមិភាគបូព៌ា ត្រូវបានចាត់ទុកថាជា "សមាសភាពអាក្រក់" ហើយតម្រូវឲ្យដកពួកគេទាំងស្រុង ចេញពីកងពលធំ[778]។ កងទ័ពភូមិភាគបូព៌ាត្រូវបានចាត់ទុកថាជា "ខ្មាំង"[779] ដែលមាន "និន្នាការមិនល្អ"[780] ឬជា "សមាសភាពមិនល្អ"[781]។ ភាគច្រើនកងទ័ពត្រូវបានគេបញ្ជូនទៅកងចល័ត ឬកងផលិតរបស់កងពលធំ ១៦៤ ហើយត្រូវបញ្ជូនទៅធ្វើការ នៅតាមទីកន្លែងផ្សេងៗគ្នា

---

[776] ឯកសារ **D54/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ERN 00982516 ឆ. ១៦។ ឯកសារ **D54/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ERN 01055538 ឆ.៣២។ សូមមើលផងដែរ ឯកសារ **D54/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ កាន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ ERN 00993379-00993380 ឆ.១៩-ឆ.២៣។

[777] ឯកសារ **D2/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00623909 ឆ. ២០។ ឯកសារ **D54/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ERN 00955551 ឆ .៣៣-ឆ.៣៥។ ឯកសារ **D54/97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 00988690 ឆ.១០ ERN 00988696 ឆ. ៣១ ERN 00988698 ឆ. ៤១។ សូមមើលផងដែរ ឯកសារ **D54/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ERN 00936731 ឆ.15.

[778] ឯកសារ **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ERN 00967517 ឆ. ១៩ ERN 00967518-00967519 ឆ.២២-ឆ.២៧។

[779] ឯកសារ **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ERN 00967519 ឆ.២៦។ ឯកសារ **D114/220** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ERN 01301539 ឆ. ៣០។

[780] ឯកសារ **D54/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ERN 00982516 ឆ. ១៦។

[781] ឯកសារ **D54/97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 00988690 ឆ. ១០។ ឯកសារ **D114/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096744-01096745 ឆ.១៩ ឆ.២២។ ឯកសារ **D114/219** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ERN 01301526 ឆ.៦១ ឆ.៦៥។

ដូចជា ស្ទឹងហាវ និងការដ្ឋានតំបន់រាម។ នៅទីនោះ កងទ័ពភូមិភាគបូព៌ា ត្រូវបានចាត់តាំងឱ្យទៅធ្វើស្រែ ធ្វើទំនប់ ជីកប្រឡាយ សាងសង់កំពង់ផែ និងធ្វើការនៅការដ្ឋានវាយថ្ម[782]។

*កងវរសេនាតូច៣១០*

276. កងទ័ពមកពីកងពលធំ១៦៤ រួមទាំងកងទ័ពមកពីកងវរសេនាតូច៣១០ ត្រូវបានបញ្ជូនទៅកោះពូលូវ៉ៃ និងកោះ Tho Chu[783]។ នៅចុងខែឧសភា និងដើមខែមិថុនា ឆ្នាំ១៩៧៥ កោះ Tho Chu និងបន្ទាប់មកគឺកោះពូលូវ៉ៃ ត្រូវបានវៀតណាមវាយប្រហារ[784]។ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យត្រូវបានលុកលុយ ហើយកងទ័ពជាងពីររយនាក់ ដែលភាគច្រើនមកពីកងវរសេនាតូច៣១០ ត្រូវបាន

---

[782] សូមមើល *ការដ្ឋានកងកេង និងបិតត្រាំង (តំបន់រាម)* កថាខណ្ឌ ៣៣៩, ៣៤៤ *ការដ្ឋានស្ទឹងហាវ* កថាខណ្ឌ ៣៦៤, ៣៧៧, ៣៨០។ ឯកសារ **D54/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ERN 00936731 ឆ.១៥ ឆ.១៩។ ឯកសារ **D54/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា Prak Sokha ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964267-00964272 ឆ.២ ឆ.១១-ឆ.១២ ឆ.១៧ ឆ.២៤-ឆ.២៥។ ឯកសារ **D54/44** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ERN 00967515 ERN 00967517 ឆ.៦ ឆ.១៥-ឆ.១៦។ សូមមើលផងដែរ ឯកសារ **D114/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ERN 01049856 ឆ.៨៩។

[783] ឯកសារ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ ERN 00967507 ឆ.១៥។ ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង ស៊ុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104517 ឆ.២៩ ERN 01104524-01104525 ឆ.១១៥ ឆ.១២១។ ឯកសារ **D114/194** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01221879 ឆ.៧៣។ ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214217 ឆ.១១០-ឆ.១១១។ ឯកសារ **D114/287** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01357556 ឆ.១៧។

[784] សូមមើល *ជម្លោះប្រដាប់អាវុធជាមួយ ប្រទេសវៀតណាម និងថៃ* កថាខណ្ឌ ២០៧។ ឯកសារ **D54/6.1.12** ប្រតិចារឹកសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០១ [ណាយ៉ាន់ ចាន់ដា] ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ERN 00334322។ ឯកសារ **D32/12.1** Pham Van Tra *ជីវិតរបស់ទាហានម្នាក់៖ ប្រវត្តិ (a Soldier's Life: A Memoir)* ឆ្នាំ២០០៩ People's Army Publishing House, Hanoi, ERN (ភាសាអង់គ្លេស) 00432793-00432794, ERN 00432797-00432799។ ឯកសារ **D234/2.1.1** ឯកសារការទូត "ទំនាក់ទំនងវៀតណាមកម្ពុជា" (Diplomatic Document, "Vietnamese-Cambodia Relations") ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ ERN (ភាសាអង់គ្លេស) 00305305។ ឯកសារ **D4.1.987** ភស្តុតាងស្តីពីការឈ្លានពានរបស់វៀតណាម មកលើកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៨ ERN 00791351។

ចាប់ខ្លួន។ ពួកគេត្រូវបាននាំយកទៅកោះត្រល់ ដែលនៅទីនោះពួកគេត្រូវបានឃុំខ្លួន ប្រហែលជាបីខែ[785]។

277. សម្តេច នរោត្តម សីហនុ បានធ្វើសន្និសីទពិសេសមួយ លើកកម្ពស់ចំណងមិត្តភាព និងសាមគ្គីភាពរវាងកម្ពុជា និងវៀតណាម ហើយអាចទទួលបានការដោះលែង កងទ័ពទាំងអស់នោះមកវិញ[786]។ នៅពេលដែលកងទ័ពទាំងនោះត្រឡប់មកដល់កំពង់សោមវិញ ពួកគេលែងទទួលបានការទុកចិត្តទៀតហើយ[787]។ គេជឿជាក់ថា កងទ័ពទាំងនោះ ត្រូវបានវៀតណាមបញ្ចូលមនោគមន៍វិជ្ជា ហើយបានក្លាយជា "ភ្នាក់ងារកាហ្សេបេ ឬយួន"[788]។ ពួកគេត្រូវបានដកចេញពីកងរបស់ពួកគេ ហើយដូចគ្នានឹងកងទ័ពភូមិភាគបូព៌ាដែរ ពួកគេត្រូវបានបញ្ជូនទៅធ្វើការ នៅក្នុងកងចល័ត ឬកងផលិតដូចជានៅការដ្ឋានស្ទឹងហាវ និងការដ្ឋានតំបន់រាម[789]។

---

[785] ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104525 ឆ.១២១ ERN 01104526 ឆ.១៣៣ ERN 01104527-01104528 ឆ.១៤៩-ឆ.១៥១ ឆ.១៥៧ ERN 01104531 ឆ.១៩២-ឆ.១៩៤ ERN 01104535 ឆ.២២៩។ ឯកសារ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ ERN 00967507 ឆ.១៥។ ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214217 ឆ.១១០-ឆ.១១១។ ឯកសារ **D114/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន សារ៉ាត់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01354316-01354317 ឆ.១៤៤-ឆ.១៤៥។ សូមមើលផងដែរ ឯកសារ **D114/287** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01357562 ឆ.៤១-ឆ.៤២។

[786] ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104528 ឆ.១៥៨ ERN 01104532 ឆ.១៩៧ ERN 01104535-01104536 ឆ.២២៩។ ឯកសារ **D114/79.1**, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កង សុំ ខែមីនា ឆ្នាំ២០១៥ ERN 01123283។ សូមមើលផងដែរ ឯកសារ **D114/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ERN 01110624 ឆ.៣។

[787] ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104529 ឆ.១៦៤-ឆ.១៦៥ ឆ.១៦៩ ERN 01104532 ឆ.២០០ ERN 01104532 ឆ.២០២ ERN 01104535-01104536 ឆ.២២៩។ ឯកសារ **D114/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ERN 01110625-01110626 ឆ.៥។ ឯកសារ **D114/194** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01221879 ឆ.៧៣។

[788] ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104529 ឆ.១៦៥ ឆ.១៦៩ ERN 01104535-01104536 ឆ.២២៩។

[789] *សូមមើល* ការដ្ឋានកងកេង និងបិតត្រាំង (តំបន់រាម) កថាខណ្ឌ ៣៣៩-៣៤០ *ការដ្ឋានស្ទឹងហាវ* កថាខណ្ឌ ៣៦៤។ ឯកសារ **D54/36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00964267 ឆ.២ ERN

01600690



*កងវរសេនាតូច ៣៨៥ និង៣៨៦*

278. តំបន់៣៧ ស្ថិតនៅក្នុងតំបន់កោះកុង ដែលស្ថិតក្នុងភូមិភាគបស្ចិម[790]។ កងវរសេនាតូច ៣៨៥ និង ៣៨៦ មកពីតំបន់នោះ ត្រូវបានបញ្ចូលទៅក្នុងកងពលធំ១៦៤[791]។ នង ឆាន ដែលជាគណៈតំបន់ ត្រូវបានតែងតាំងជាមេបញ្ជាការរងមួយរូប ក្នុងចំណោមមេបញ្ជាការរងទាំងពីរនៃកងពលធំ១៦៤[792]។ បន្ទាប់ពីគាត់ និងសហការីជាច្រើនត្រូវបានចាប់ខ្លួន ដោយត្រូវបានគេចាត់ទុកថា បានចូលដៃជើងជាមួយវៀតណាមនោះ[793] ការបោសសម្អាតកងទ័ពមកពីកងវរសេនាតូច ៣៨៥ និង៣៨៦ បានចាប់ផ្តើមឡើង[794]។

---

00964269 ឆ.១១។ ឯកសារ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ ERN 00967508 ឆ.១៧។ ឯកសារ **D114/186** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ERN 01214217-01214218 ឆ.១១០-ឆ.១១៣។ សូមមើលផងដែរ ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01104535-01104536 ឆ.២២៩-ឆ.២៣៣។ ឯកសារ **D114/194** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ERN 01221879 ឆ.៧៣។

[790] ឯកសារ **D54/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ ERN 00978512-00978513 ឆ.៩ ឆ.១៤។ ឯកសារ **D114/140** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ផុន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01173067-01173068 ឆ.៨ ឆ.១២។ សូមមើលផងដែរ ឯកសារ **D54/76** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ERN 00982514 ឆ.៧។

ដោយមានភស្តុតាងបញ្ជាក់ថា គោលនយោបាយស្តីពីការរៀបការត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅកំពង់សោម[1349]។ ឧទាហរណ៍ ប្រធានផ្នែកប្រឆាំងនាវាមុជទឹកបញ្ជាក់ថា គាត់មានបំណងរៀបការឱ្យសមាជិកកងរបស់គាត់ទាំងអស់ និងរៀបការឱ្យពួកគេបាន "*ច្រើនគូ*" ដោយជោគជ័យ[1350] ហើយ នារីជាច្រើនមកពីកងវរសេនាតូច ១៦៧ ដែលជាកងវរសេនាតូចនារីនៃកងពលធំ ១៦៤ បានរៀបការនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[1351]។

445. ក្នុងករណីខ្លះ គេបានសួរមតិយោបល់ទាហានទាក់ទងនឹងប្រពន្ធ ហើយនារីត្រូវបានបញ្ជូនឱ្យទៅទាហានជ្រើសរើស[1352]។ ភស្តុតាងជាពាក្យចចាមអារ៉ាមបញ្ជាក់បន្ថែមទៀតថា មានការបញ្ជូននារី

---

.១៨៣-១៨៥។ <u>ពាក់ព័ន្ធនឹងការរៀបការជាក្រុម៖</u> ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ឆ.២-ឆ.៥។ ឯកសារ **D114/113** កំណត់ហេតុស្តាប់ចម្លើយសាក្សី គីម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138481-01138482 ឆ.២២៨ ឆ.២៣០-ឆ.២៣២។ ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096747-01096748 ឆ.២៩។ ឯកសារ **D234/2.1.141** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [ម៉ាក ឈឿន] ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ERN 01377538-01377539 បន្ទាត់ ១៣-២៣។

[1349] *សូមមើល* ភស្តុតាងដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ ៤៤៦-៤៥២។ *សូមមើលផងដែរ* ឯកសារ **D114/78** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01101722-01101723 ឆ.២២-ឆ.២៦ ERN 01101724 ឆ.៣០ ឆ.៣២ ឆ.៣៤ ដែលលើកឡើងថា គោលនយោបាយស្តីពីការរៀបការត្រូវបាន "*អនុវត្តជាទូទៅ*"។ *សូមមើលផងដែរ* ឯកសារ **D114/95** កំណត់ហេតុស្តាប់ចម្លើយសាក្សី យឹម ស្រឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៥ ERN 01121889 ឆ.១៤៨ ERN 01121892-01121893 ឆ.១៨៣ ERN 01121897-01121898 ឆ.២៣១-ឆ.២៤១ ERN 01121895 ឆ.២៤៥-ឆ.២៥១ ដែលរាយការណ៍ថា ការរៀបការទាហានកងពលធំ ១៦៤ រហូតដល់ប្រាំពីរគូ កើតមានរៀងរាល់មួយទៅបីខែម្តង។ ទោះជាយ៉ាងនេះក្តី ការដែលថាសាក្សីស្ទើរតែមិនបានចំណាយពេលនៅលើដីគោកនោះ ធ្វើឱ្យសក្ខីកម្មរបស់គាត់មិនអាចជឿជាក់បានលើចំណុចនេះ។

[1350] ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127746 ឆ.៦០-ឆ.៦៧ ERN 01127766 ឆ.២១១។

[1351] ឯកសារ **D114/83** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ ERN 01110597-01110598 ឆ.១៤ ឆ.១៧ ERN 01110605-01110606 ឆ.៤៥-ឆ.៤៩។

[1352] ឯកសារ **D114/113** កំណត់ហេតុស្តាប់ចម្លើយសាក្សី គីម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138481-01138482 ឆ.២២៨ ឆ.២៣០-ឆ.២៣១ ឆ.២៣៤ ERN 01138483 ឆ.២៣៦-ឆ.២៣៧។ *សូមមើលផងដែរ* ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ឆ.២-ឆ.៣ ERN 01051794 ឆ.១៧ ERN 01051795-01051796 ឆ.២៩។

ដើម្បីរៀបការ ទោះបីពុំមានការបង្ហាញថា នៅក្នុងករណីនេះ ការរៀបការបានប្រព្រឹត្តទៅក៏ដោយ[1353] ។ សំណើរបស់ទាហានសុំរៀបការមិនមែនតែងតែត្រូវបានទទួលយកនោះទេ[1354]។

446. សាក្សីផ្ទាល់ភ្នែកជាច្រើននាក់បញ្ជាក់ថាមានការរៀបការដោយគ្មានការព្រមព្រៀង និងក្នុងកាលៈទេសៈបង្ខិតបង្ខំ ដែលផ្ទុះបញ្ចាំងពីការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1355] នៅតំបន់កំពង់សោមទាំងមូល ពីយ៉ាងហោចណាស់ចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ រហូតដល់យ៉ាងហោចណាស់ចុងឆ្នាំ១៩៧៨៖ នៅក្រុងកំពង់សោម កងកេង ស្ទឹងហាវ និងអូរឧកញ៉ាហេង[1356]។ ចំនួនប្តីប្រពន្ធរៀបការនៅក្នុងពិធីទាំងនោះ មានចាប់ពីមួយគូទៅ ៧១ គូ[1357]។

---

[1353] ឯកសារ **D114/36.1.64** កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អុល ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ERN 00408322-00408323 **ឆ.២ ឆ.៦** ERN 000408324 **ឆ.២០** ERN 00408325-00408326 **ឆ.២២-ឆ.២៩**។ ឯកសារ **D114/91** កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អុល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ERN 01117011-01117012 **ឆ.១៣៧-ឆ.១៣៨** ERN 01117015-01117016 **ឆ.១៧៣-ឆ.១៧៨** ERN 01117017 **ឆ.១៩៣-ឆ.១៩៥** ERN 01117018-01117019 **ឆ.២០១ ឆ.២០៦-ឆ.២១១** ERN 01117020 **ឆ.២២០**។

[1354] ឯកសារ **D114/146** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៥ ERN 01181239-01181240 **ឆ.៣៨-ឆ.៤១**។

[1355] *សូមមើល អាពាហ៍ពិពាហ៍ដោយបង្ខំចំពោះជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា* កថាខណ្ឌ ២០២-២០៤។

[1356] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071643-01071644 **ឆ.២៦៦-ឆ.២៦៨** ERN 01071645-01071646 **ឆ.២៨៣-ឆ.២៨៦** ERN 01071647 **ឆ.២៩៣-ឆ.២៩៥ ឆ.២៩៨** ERN 01071648 **ឆ.២៩៩**។ ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792-01051793 **ឆ.២-ឆ.១០ ឆ.១៣-ឆ.១៤** ERN 01051794-01051795 **ឆ.២០-ឆ.២២ ឆ.២៥** ERN 01051795-01051796 **ឆ.២៨-ឆ.២៩ ឆ.៣២**។ ឯកសារ **D54/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ERN 01022398 **ឆ.២៩-ឆ.៣៣**។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138942 **ឆ.២៤៨-ឆ.២៥៧** ERN 01138944 **ឆ.២៦២-ឆ.២៦៥** ERN 01138944 **ឆ.២៧៣-ឆ.២៧៤** ERN 01138951-01138952 **ឆ.៣៥១-ឆ.៣៦៤**។ ឯកសារ **D114/78** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01101722-01101723 **ឆ.២២-ឆ.២៦** ERN 01101724 **ឆ.៣០ ឆ.៣២**។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156581 **ឆ.៦៧-ឆ.៦៩** ERN 01156582 **ឆ.៨៤-ឆ.៨៧** ERN 01156583 **ឆ.៩១-ឆ.៩៤** ERN 01156584 **ឆ.១០៥-ឆ.១០៧** ERN 01156586 **ឆ.១២៨**។ ឯកសារ **D114/304** កំណត់ហេតុស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ERN 01404242 **ឆ.៦៦-ឆ.៦៧** ERN 01404243 **ឆ.៨១-ឆ.៨២ ឆ.៨៦-ឆ.៨៨** ERN 01404244 **ឆ.៩៥-ឆ.៩៧ ឆ.១០០-ឆ.១០១**។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN

447. ការរៀបការទាំងអស់នេះមានការចូលរួមពីមន្ត្រី ប.ក.ក ជាយោធា ឬស៊ីវិល ដែលធ្វើការផ្គូផ្គងគូស្រករ ណែនាំឱ្យប្តីប្រពន្ធរៀបការ ឬចូលរួម "ប្រជុំ" និង/ឬដឹកនាំ ឬចូលរួមពិធីរៀបការ[1358]។

---

01127746 ទ.៦០-ទ.៦៣ ERN 01127759 ទ.១៦០-ទ.១៦១ ទ.១៦៥ ERN 01127760 ទ.១៧១-ទ.១៧២ ERN 01127761 ទ.១៧៧ ERN 01127762 ទ.១៨៥ ERN 01127763 ទ.១៨៨។

[1357] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071643-01071644 ទ.២៦៦-ទ.២៦៨។ ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ទ.២-ទ.៥។ ឯកសារ **D54/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ERN 01022398 ទ.២៩-ទ.៣៣។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138944 ទ.២៧១ ទ.២៧៥-ទ.២៧៧។ ឯកសារ **D114/78** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01101724 ទ.៣០។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156582 ទ.៨៤-ទ.៨៧ ERN 01156584 ទ.១០៥។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127759 ទ.១៦៣។

[1358] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071643-01071644 ទ.២៦៦-ទ.២៦៩ ERN 01071645-01071646 ទ.២៨៣-ទ.២៨៦ ERN 01071647 ទ.២៩៣-ទ.២៩៥ ទ.២៩៨ ERN 01071648 ទ.២៩៩-ទ.៣០៤។ ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ទ.២-ទ.៣ ERN 01051793 ទ.៦-ទ.៨។ ឯកសារ **D54/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ERN 01022398 ទ.២៩-ទ.៣០។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138942-01138943 ទ.២៤៨-ទ.២៦០ ទ.២៦២-ទ.២៦៤ ERN 01138944 ទ.២៧៣ ទ.២៧៨ ERN 01138946 ទ.២៨៧-ទ.២៩១។ ឯកសារ **D114/78** កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01101722-01101723 ទ.២២ ទ.២៤-ទ.២៦ ERN 01101724 ទ.២៩-ទ.៣០ ទ.៣២។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156581-01156582 ទ.៧០-ទ.៧៦ ERN 01156585-01156586 ទ.១១៤-ទ.១២៩ ទ.១៣៤។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127759 ទ.១៦២ ទ.១៦៤-ទ.១៦៥ ERN 01127760 ទ.១៧០ ទ.១៧២ ERN 01127760-01127761 ទ.១៧៤-ទ.១៧៦។ ឯកសារ **D114/304** កំណត់ហេតុស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ERN 01404245 ទ.១០៧។ *សូមមើលផងដែរ* ចម្លើយរបស់ប្តីប្រពន្ធមួយគូដែលមិនសូវមានភាពជឿជាក់អំពីថាតើ ការរៀបការរបស់ពួកគេប្រព្រឹត្តនៅផ្ទះរបស់ **មាស មុត** ឬយ៉ាងណា៖ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127761 ទ.១៧៧ ទ.១៨០-ទ.១៨១។ ឯកសារ **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៣ ERN 00955650-00955651 ទ.៣។ឯកសារ **D114/304** កំណត់ហេតុស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ERN 01404244 ទ.១០០។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងចម្លើយទាំងអស់នេះ ពុំមានភស្តុតាងពីវត្តមានរបស់ **មាស មុត** ទេ។

448. នារីមួយចំនួនត្រូវគេបង្ខំឲ្យរៀការជាមួយទាហាន ឬទាហានជើងទឹកនៃកងពលធំ ១៦៤ ដែល សកម្ម ឬពិការ ឬរំសាយ[1359]។

449. ជាការឆ្លុះបញ្ចាំងពីស្ថានការណ៍នៅកម្ពុជាប្រជាធិបតេយ្យ[1360] នៅកំពង់សោម បរិយាកាសទូទៅនៃ ការភ័យខ្លាចបានរីករាលដាល ពាក់ព័ន្ធនឹងផលវិបាកនៃការបដិសេធមិនព្រមរៀបការ៖ ទោះបីជា អ្នកខ្លះរៀបការដោយមានការព្រមព្រៀង ឬបដិសេធមិនព្រមរៀបការដោយគ្មានផលវិបាកអ្វីក៏ ដោយ មនុស្សភាគច្រើនមិនហ៊ានបដិសេធទេ អ្នកខ្លះដែលបដិសេធ ត្រូវគេគំរាម កំហែង ហើយ អ្នកផ្សេងទៀតត្រូវគេដាក់ទណ្ឌកម្ម[1361]។ ការជំទាស់មិនរារាំងដល់ការប្រកាសពីការរៀបការនោះ ទេ[1362]។

---

[1359] ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ឆ.២-ឆ.៥ ERN 01051793 ឆ.១៦-ឆ.១៧ ឆ.២០ ERN 01051796 ឆ.៣២។ ឯកសារ **D54/117** កំណត់ហេតុ ស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ERN 01022398 ឆ.៣២។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138942 ឆ.២៤៨-ឆ.២៥៧ ERN 01138943-01138944 ឆ.២៦២-ឆ.២៦៤ ឆ.២៦៧-ឆ.២៦៩ ឆ.២៧៣។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156584 ឆ.១១០-ឆ.១១១ ERN 01156585 ឆ.១២២-ឆ.១២៣។ ឯកសារ **D114/304** កំណត់ហេតុស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ERN 01404246 ឆ.១២៦។

[1360] *សូមមើល អាពាហ៍ពិពាហ៍ដោយបង្ខំចំពោះជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា* កថាខណ្ឌ ២០៤។

[1361] ភ័យខ្លាចក្នុងការបដិសេធ មិនអាចបដិសេធ ត្រូវគេគំរាមកំហែង ឬត្រូវគេដាក់ទណ្ឌកម្ម៖ ឯកសារ **D114/53** កំណត់ហេតុ ស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071647 ឆ.២៩៣-ឆ.២៩៥ ERN 01071648 ឆ.២៩៩។ ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051792 ឆ.២ ERN 01051796 ឆ.៣២។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០១៥ ERN 01138942-01138943 ឆ.២៤៨-ឆ.២៥៧ ឆ.២៦២-ឆ.២៦៤។ ឯកសារ **D114/78** កំណត់ហេតុស្តាប់ ចម្លើយសាក្សី ស្វាយ សាម៉េត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ERN 01101722 01101723 ឆ.២២ ឆ.២៤ ERN 01101724 ឆ.៣២។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156581 ឆ.៦៨-ឆ.៧០ ERN 01156582 ឆ.៧៤-ឆ.៧៥ ឆ.៨៤-ឆ.៨៧ ERN 01156583 ឆ.៩០-ឆ.៩៤ ERN 01156584 ឆ.១០៥-ឆ.១០៧ ERN 01156586 ឆ.១២៨។ ឯកសារ **D114/83** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០១៥ ERN 01110597-01110598 ឆ.១៤ ឆ.១៧ ERN 01110605-01110606 ឆ.៤៥-ឆ.៤៦។ ឯកសារ **D114/33** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម អាង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01053436 ឆ.១៧ ERN 01053447 ឆ.១២៤-ឆ.១២៥ ERN 01053448 ឆ.១៣០ ERN 01053451 ឆ.១៥៥ ឆ.១៦១-ឆ.១៦២។ ឯកសារ **D54/38.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00967308-00967309 ERN 00967320-00967321។ ឯកសារ **D54/38** កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣

450. ទោះបីជាសក្ខីកម្មរបស់សាក្សីផ្ទាល់អំពីការរៀបការដោយបង្ខំនៅកំពង់សោម ពុំមានច្រើនជាពិសេស ដែលពិចារណាទៅលើ (i) ផលវិបាក និងកាលៈទេសៈបង្ខិតបង្ខំ ដែលមាន នៅក្នុងការអនុវត្តគោលនយោបាយស្តីពីការរៀបការ ទាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ទាំងនៅកំពង់សោម (ii) ការអនុវត្តគោលនយោបាយស្តីពីការរៀបការយ៉ាងទូលំទូលាយនៅកំពង់សោម និង (iii) ថាយ៉ាងហោចណាស់ ការរៀបការមួយចំនួនដែលកើតមាននៅកំពង់សោម ជាការរៀបការដោយបង្ខំ ក៏ដោយ មានការរៀបការដោយបង្ខំនៅកំពង់សោមច្រើនជាងការរៀបការដែល

---

ERN 00967296-00967297 ឆ.១-ឆ.៨។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127767 ឆ.២១៩។ ឯកសារ **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៣ ERN 00955650-00955652 ឆ.៣-ឆ.៦។ <u>ការបដិសេធដោយគ្មានផលវិបាក៖</u> ឯកសារ **D114/83** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ ERN 01110605 ឆ.៤៥។ ឯកសារ **D54/38.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00967320-00967321។ ឯកសារ **D54/38** កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ ERN 00967296-00967297 ឆ.១-ឆ.៨។ *សូមមើលផងដែរ* ឯកសារ **D114/38** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ រឹម ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01059338 ឆ.៨៩-ឆ.៩៣ ERN 01059340 ឆ.១០៦-ឆ.១០៧ ERN 01059341-01059342 ឆ.១១៤-ឆ.១១៥ ERN 01059342-01059343 ឆ.១១៧-ឆ.១២២ ឆ.១២៤-ឆ.១២៦ ERN 01059344 ឆ.១៣០ ឆ.១៣៥។ ឯកសារ **D114/113** កំណត់ហេតុស្តាប់ចម្លើយសាក្សី គឹម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138481-01138483 ឆ.២២៨ ឆ.២៣៦-ឆ.២៣៩ ឆ.២៤១។ <u>ការរៀបការដោយមានការព្រមព្រៀង៖</u> ឯកសារ **D114/33** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម អាង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01053451 ឆ.១៦១។ ឯកសារ **D114/139** កំណត់ហេតុស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01172082 ឆ.២០-ឆ.២១ ERN 01172094-01172095 ឆ.១៣៥-ឆ.១៣៧។ ឯកសារ **D59/1/1.7a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ERN 00926328-00926330។ ឯកសារ **D114/17** កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ ERN 01033994-01033995 ឆ.១-ឆ.៦។ ឯកសារ **D234/2.1.141** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ [ម៉ាក ឈឿន] ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ERN 01377538-01377539 បន្ទាត់ ១៣-២៣។ <u>សំណើសុំរៀបការ៖</u> ឯកសារ **D114/139** កំណត់ហេតុស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01172094-01172095 ឆ.១៣៥-ឆ.១៣៧។ ឯកសារ **D114/83** កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ ERN 01110605-01110606 ឆ.៤៦។ ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096747-01096748 ឆ.២៩។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127765 ឆ.២០៦ ERN 01127767 ឆ.២១៥ ឆ.២១៨។ ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051795-01051796 ឆ.២៩។

[1362] ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127759 ឆ.១៦១-ឆ.១៦៥ ERN 01127760 ឆ.១៦៨-ឆ.១៧២ ERN 01127762-01127763 ឆ.១៨៥-ឆ.១៨៦ ឆ.១៨៨។

សាក្សីផ្ទាល់ភ្នែកបានផ្តល់សក្ខីកម្មទៀត។ ទោះជាយ៉ាងនេះក្តី ផ្អែកលើភស្តុតាងដែលមាន យើងមិនអាចផ្តល់នូវការការប៉ាន់ប្រមាណក្នុងចំនួនតិចអំពីចំនួននៃការរៀបការដោយបង្ខំដែលកើតមានឡើងនៅកំពង់សោមបានឡើយ។

451. ម្តងទៀត ជាការឆ្លុះបញ្ចាំងពីស្ថានការណ៍នៅកម្ពុជាប្រជាធិបតេយ្យ[1363] ប្តីប្រពន្ធទើបរៀបការរួចនៅកំពង់សោម ជាទូទៅ ត្រូវបានឲ្យនៅជាមួយគ្នារយៈពេលជាច្រើនថ្ងៃ ដោយរំពឹង ឬបញ្ជាឲ្យពួកគេរួមដំណេកជា មួយគ្នា[1364]។ ក្នុងអំឡុងពេលនេះ ការឃ្លាំមើលប្តីប្រពន្ធដោយបុគ្គលិក ប.ក.ក មានលក្ខណៈជាទូទៅ ដែលសាក្សីជាច្រើនចាត់ទុកថាវាជាការធានាថា ប្តីប្រពន្ធរួមដំណេកជាមួយគ្នា ឬ *"នៅជាមួយគ្នា"*[1365]។ សាក្សីជាច្រើននាក់ដែលរៀបការផ្ទុយពីបំណងរបស់ខ្លួន បញ្ជាក់ថាដំបូង ខ្លួនបានបដិសេធ ឬភ័យខ្លាចក្នុងការរួមដំណេក មុននឹងធ្វើចិត្តបាន ឬយល់ព្រមនាពេលក្រោយ ឬរួមដំណេកផ្ទុយពីបំណងរបស់ខ្លួន[1366]។

---

[1363] *សូមមើល អាពាហ៍ពិពាហ៍ដោយបង្ខំចំពោះជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា* កថាខណ្ឌ ២០៣។

[1364] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071613 ឆ.២៧ ERN 01071643-01071644 ឆ.២៦៦-ឆ.២៦៨ ERN 01071646 ឆ.២៨៧-ឆ.២៨៨ ERN 01071647 ឆ.២៩៣-ឆ.២៩៥ ERN 01071648-01071649 ឆ.២៩៩ ឆ.៣០៦-ឆ.៣១២។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138943 ឆ.២៦៥ ERN 01138944 ឆ.២៧២ ERN 01138947 ឆ.៣០៤-ឆ.៣០៨។ ឯកសារ **D114/33** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម អាង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01053436 ឆ.១៧ ERN 01053447 ឆ.១២៤-ឆ.១២៥ ERN 01053448 ឆ.១៣០ ERN 01053451 ឆ.១៦១-ឆ.១៦៣ ERN 01053455 ឆ.១៩៤-ឆ.១៩៧។

[1365] ឯកសារ **D114/33** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម អាង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01053436 ឆ.១៧ ERN 01053447 ឆ.១២៤-ឆ.១២៥ ERN 01053448 ឆ.១៣០ ERN 01053451 ឆ.១៦១-ឆ.១៦៣ ERN 01053455 ឆ .១៩៤-ឆ.១៩៧។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156587 ឆ.១៤១ ឆ.១៤៤ ERN 01156588 ឆ.១៥១។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127763-01127764 ឆ.១៩២-ឆ.២០១។

[1366] ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051797 ឆ.៤១-ឆ.៤៣ ERN 01051798 ឆ.៤៦ ឆ.៤៨ ឆ.៤៩-ឆ.៥៧។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156587 ឆ.១៣៦ ឆ.១៤១ ឆ.១៤៤ ឆ.១៤៦-ឆ.១៤៧ ERN 01156588 ឆ.១៥១ ឆ.១៥៣។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127763-01127764 ឆ.១៩២-ឆ.២០១។

452. ក្រោយមក ដោយប្តីប្រពន្ធត្រូវរស់នៅដាច់ដោយឡែកពីគ្នា (នៅសហករណ៍ពូធឿង ប្រពន្ធរបស់ទាហានរស់នៅជាមួយគ្នា)[1367] ប្តីទៅលេងប្រពន្ធរបស់ខ្លួនក្នុងរង្វង់រយៈពេលពីរបីថ្ងៃម្តង ឬមួយសប្តាហ៍ម្តង ឬរៀងរាល់ ១០ ថ្ងៃម្តង[1368]។ ទោះបីជាគោលនយោបាយស្តីពីការរៀបការមានគោលដៅបង្កើនចំនួនប្រជាជនក្តី[1369] មានតែសាក្សីតែម្នាក់គត់ដែលឆ្លើយថា *ជាការកំណត់* ប្តីត្រូវទៅលេងប្រពន្ធជាប្រចាំក្រោយរៀបការរួច[1370]។

453. ទោះបីជាមានភស្តុតាងពីការរំលោភផ្លូវភេទដោយផ្ទាល់ អាចឲ្យធ្វើការសន្និដ្ឋានអំពីការឈឺចាប់ទាំងផ្លូវកាយទាំផ្លូវចិត្តក៏ដោយ មានសក្ខីកម្មតិចតួចអំពីកម្រិតនៃការឈឺចាប់ដែលបណ្តាលមកពីការអនុវត្តគោលនយោបាយស្តីពីការរៀបការនៅកំពង់សោម។ សាក្សីឆ្លើយថាមានអារម្មណ៍ឈឺចាប់ ឬបាក់ទឹកចិត្តដោយត្រូវរៀបការ ដោយមិនបានប្រាប់គ្រួសាររបស់ពួកគេ ខូចចិត្តចំពោះការរៀបការមិនសប្បាយចិត្តដោយត្រូវបំបែកចេញពីគ្នាក្រោយរៀបការរួច និងមានកំហឹងដោយគេមិនបានប្រាប់ខ្លួនមុន[1371]។

---

[1367] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071624 ឆ.១០៨ ឆ.១១០ ERN 01071628 ឆ.១៤៥។

[1368] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071643-01071644 ឆ.២៦៦-ឆ.២៦៨ ERN 01071646 ឆ.២៨៧-ឆ.២៨៨ ERN 01071647 ឆ.២៩៣-ឆ.២៩៥ ERN 01071648 ឆ.២៩៩ ERN 01071649 ឆ.៣១២ ERN 01071650-01071651 ឆ.៣២២-ឆ.៣២៦។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156588 ឆ.១៥៤។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127768 ឆ.២២៣។ *សូមមើលផងដែរ* ឯកសារ **D114/66** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ERN 01096747-01096748 ឆ.២៩។

[1369] *សូមមើល អាពាហ៍ពិពាហ៍ដោយបង្ខំចំពោះជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា* កថាខណ្ឌ ២០០។

[1370] ឯកសារ **D114/53** កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01071650-01071651 ឆ.៣២២-ឆ.៣២៣។

[1371] ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051805 ឆ.១១៧។ ឯកសារ **D114/117** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138939 ឆ.២១៩-ឆ.២២៦ ERN 01138942-01138946 ឆ.២៤៨-ឆ.២៩៧ ERN 01138947 ឆ.៣០១ ERN 01138948 ឆ.៣១៦ ERN 01138951-01138952 ឆ.៣៥១-ឆ.៣៦៤។ ឯកសារ **D114/134** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន សាំង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01156584 ឆ.១០៦-ឆ.១០៧។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127760 ឆ.១៧១។

454. ប្តីប្រពន្ធជាច្រើនគូដែលរៀបការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានបែកគ្នានាពេលក្រោយមក[1372]។ ការសិក្សាបង្ហាញថា ជនរងគ្រោះមួយចំនួននៃការរៀបការដោយបង្ខំ មានអារម្មណ៍ ថាជាប់អន្ទាក់ក្នុងទំនាក់ទំនងគ្មានសុភមង្គល រស់នៅជាមួយនឹងភាពសោកស្តាយ និងទុក្ខព្រួយដោយមិនអាចជ្រើសរើសគូស្រកររបស់ខ្លួន ឬរៀបការតាមប្រពៃណីបាន ខណៈដែលជនរងគ្រោះខ្លះនៃអំពើហិង្សាផ្លូវភេទនៅតែមានការឈឺចាប់ពីរបួសផ្លូវកាយ និងការឈឺចាប់ ក៏ដូចជាបញ្ហាផ្លូវចិត្ត រួមមាន កំហឹង ទុក្ខព្រួយ ការភ័យខ្លាច សុបិនអាក្រក់ ការធ្លាក់ទឹកចិត្ត និងគំនិតចង់ធ្វើអត្តឃាត[1373]។

455. ទោះបីជា **មាស មុត** បានចូលរួមដោយផ្ទាល់នៅក្នុងការផ្សព្វផ្សាយគោលនយោបាយស្តីពីការរៀបការនៅកំពង់សោមក្តី ពុំមានភ័ស្តុតាងបញ្ជាក់ថា គាត់បានដឹកនាំការរៀបការ ឬចូលរួមក្នុងពិធីរៀបការទេ។

## ៦. ការយល់ឃើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គល

456. អ.វ.ត.ក មានយុត្តាធិការបុគ្គលទៅលើ **មាស មុត** ដែលជាបុគ្គលម្នាក់ ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

457. គាត់ជាអតីតកម្មាភិបាលខ្មែរក្រហមមួយរូប នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់តុលាការនេះ និងនៅក្នុងអំឡុងពេលដែលបណ្តាបទល្មើសទាំងនោះកើតឡើង ត្រូវបានយកមក ចោទប្រកាន់ចំពោះរូបគាត់។

---

[1372] ឯកសារ **D114/32** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ERN 01051803 ឆ.៩៦។ ឯកសារ **D54/29** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៣ ERN 00955652 ឆ.៩។ ឯកសារ **D114/103** កំណត់ហេតុស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ERN 01127770 ឆ.២៤១។ ឯកសារ **D114/304** កំណត់ហេតុស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ERN 01404248 ឆ.១៤៧-ឆ.១៤៨។ *សូមមើលផងដែរ* ឯកសារ **D114/113** កំណត់ហេតុស្តាប់ចម្លើយសាក្សី កឹម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ERN 01138481 ឆ.២២៦។

[1373] ឯកសារ **D114/297.1.16** អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម ចុះខែមីនា ឆ្នាំ២០១៤ ERN EN 0099246-00992249។ ឯកសារ **D114/297.1.29** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [កាស៊ូមិ ណាកាហ្កាវ៉ា] ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ERN 01364798-01364802។

458. ដូចមានចែងក្នុង*ច្បាប់ជាធរមាន*[1374] ស.ច.ស ពុំយល់ឃើញទៅលើចំនួនជនសង្ស័យតាមបែបព្យាករ "ចរចា" និងជនសង្ស័យជាក់លាក់ថា ជាការបកស្រាយមួយសមស្របសម្រាប់ប្រវត្តិចរចាទៅលើបណ្តាច្បាប់នានារបស់ អ.វ.ត.ក នោះទេ។

459. ទោះបីជា **មាស មុត** មិនមែនជាមេដឹកនាំជាន់ខ្ពស់ក្តី តែគាត់មានភាពស្និទ្ធស្នាលបំផុតជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ចំពោះ៖

*i.* តួនាទីរបស់គាត់ជាមេបញ្ជាការកងពលធំ ១៦៤ (ដែលជាកងពលកងទ័ពបដិវត្តកម្ពុជាដ៏ធំបំផុត) ដែលបានក្លាយជាមេបញ្ជាការកងទ័ពជើងទឹក និងជាផ្នែកមួយនៃផ្នែកទាំងបីរបស់កងកម្លាំងប្រដាប់អាវុធនៃកម្ពុជាប្រជាធិបតេយ្យ។

*ii.* ការទទួលខុសត្រូវរបស់គាត់ចំពោះដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ។

*iii.* តួនាទីរបស់គាត់ជាសមាជិកបម្រុងនៃគណៈកម្មាធិការអគ្គសេនាធិការ និងជាអនុប្រធានមួយរូប ក្នុងចំណោមអនុប្រធានរបស់ សុន សេន និង

*iv.* តួនាទីរបស់គាត់ ចាប់ពីចុងឆ្នាំ១៩៧៨ ជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម។

460. **មាស មុត** ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវជាន់ខ្ពស់បំផុត ដោយសារតែការរួមបញ្ចូលគ្នានៃឋានៈ និងវិសាលភាពនៃអំណាចរបស់គាត់នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ និងដោយយោងទៅលើចរិតលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្មរបស់គាត់។ ការយល់ឃើញនេះបានមកពីការប្រៀបធៀបជាមួយជនត្រូវចោទ ឬទណ្ឌិតដទៃទៀត។ តួនាទីរបស់គាត់ រួមជាមួយនឹងចរិតលក្ខណៈ និងផលប៉ះពាល់ពីអំពើរបស់គាត់ គឺពិតជាលើសពីអំពើរបស់ អោ អាន, អ៊ឹម ចែម និង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច យ៉ាងច្បាស់ក្រឡែតមែនហើយ[1375]។

## ៦.១ តួនាទីនៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ

461. **មាស មុត** បានកាន់កាប់តួនាទីដែលកាន់តែឡើងឋានៈខ្ពស់ទៅៗ នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ ដោយបំពេញកិច្ចការក្នុងកម្រិតខ្ពស់ នៅក្នុងរចនាសម្ព័ន្ធបញ្ជាការកងទ័ពកម្ពុជា

---

[1374] *សូមមើល* ច្បាប់ជាធរមាន កថាខណ្ឌ ៣៩។

[1375] ទាក់ទងនឹង ឌុច *សូមមើល* **សំណុំរឿងលេខ ០០៤/២-ឯកសារ D360** *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* [កោសលុប] ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៦៩។

ប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នកនយោបាយថ្នាក់ជាតិ។ គាត់ទទួលខុសត្រូវបំពេញភារកិច្ច និងកាតព្វកិច្ច ក្នុងកម្រិតមួយខ្ពស់លេចធ្លោជាង អោ អាន យ៉ាងខ្លាំង ដែលត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូបផងដែរ[1376]។ គាត់ត្រូវអំពាវនាវឲ្យអនុវត្តការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា លើសពីតំបន់ប្រតិបត្តិការចម្បងរបស់គាត់ នៅកំពង់សោម និងភារកិច្ចរបស់គាត់ជាមេបញ្ជាការកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ។

## ៦.២ ចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានកំណត់

462. បន្ថែមលើតួនាទីដែលកាន់តែឡើងឋានៈខ្ពស់ទៅៗរបស់ **មាស មុត** ភាពខ្លាំងក្លានៃអំពើរបស់គាត់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ពីអំពើ ដូចបានរៀបរាប់លម្អិតខាងលើ នាំឲ្យឈានដល់ការសន្និដ្ឋានថា គាត់ជាបុគ្គលម្នាក់ ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។

463. បទចោទសំខាន់ៗដែលត្រូវបានកម្រិតចំពោះ **មាស មុត** ហើយបទចោទដែលដាក់ឲ្យគាត់ស្ថិតនៃយុត្តាធិការបុគ្គលយ៉ាងរឹងមាំនោះ គឺបទចោទស្តីពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ក៏ដូចជាការសម្លាប់រង្គាលទៅលើជនជាតិថៃ ដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់ខ្លួនបាននៅក្នុងដែនទឹក និងតាមបណ្តាកោះមួយចំនួន នៅក្នុងដែនសមុទ្រកម្ពុជាប្រជាធិបតេយ្យ។

464. **មាស មុត** បានប្រែក្លាយដែនទឹកទាំងនេះទៅជាអន្ទាក់យក្ស សម្រាប់អ្នកណាដែលបានចូលមកក្នុងដែនទឹកទាំងនេះ។ ដោយសារតែចំនួនជនរងគ្រោះ ដែលបានរកឃើញក្នុងកម្រិតអប្បបរមាមានចំនួនរហូតដល់រាប់សិបពាន់នាក់ តាមការគណនាតាមវិធីបុរាណបំផុត ដែលបញ្ជាក់ថា ចំនួនអប្បបរមានៃជនជាតិថៃ ១.២០០ នាក់ និងជនជាតិវៀតណាម ៣.២៧៦ នាក់ ត្រូវបានសម្លាប់នៅក្នុងអំឡុងប្រតិបត្តិការចាប់ខ្លួនពីសំណាក់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតក្រោមការត្រួតត្រារបស់ **មាស មុត** នោះ បើតាមតថភាពជាក់ស្តែង ទំនងជាលើសពីនេះឆ្ងាយណាស់។ ចំនួនអ្នកស្លាប់ និងរងរបួស ជាពិសេសជនជាតិវៀតណាម គឺអាស្រ័យថាតើជនជាតិថៃ និងជនជាតិវៀតណាមប៉ុន្មាននាក់ ដែលបានចូលមកក្នុងក្នុងដែនទឹកទាំងនោះ ត្រូវបានចាប់ខ្លួន ឬអាចនិយាយម្យ៉ាងទៀតថា បើចាប់ខ្លួនបានច្រើនកាលណា ក៏អាចសម្លាប់ចោលច្រើនកាលនោះដែរ។

---

[1376] **សំណុំរឿងលេខ ០០៤/២-ឯកសារ D360** *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* [កោសលុប] ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៦៩៩។

**មាស មុត** មិនបានជំរុញឱ្យមានការទប់ស្កាត់តាមរយៈអ្នកនៅក្រោមបង្គាប់របស់គាត់ទេ ប៉ុន្តែផ្ទុយទៅវិញ បទបញ្ជារបស់គាត់ឱ្យសម្លាប់មនុស្ស គឺពុំមានដែនកំណត់នោះទេ ហើយវាជាការចៃដន្យតែប៉ុណ្ណោះ ដែលជនជាតិថៃដែលគេចាប់ខ្លួន បានរួចផុតពីសេចក្តីស្លាប់ ដោយសារតែការដោះដូរជាមួយរបស់របរប្រើប្រាស់ផ្សេងៗ។

465. ចរិតលក្ខណៈដ៏គួរឱ្យខ្លាចក្នុងការបោះចោលសាកសពអ្នកទាំងនោះ និងការមាក់ងាយទាំងស្រុងមកលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិចំពោះសាកសពជនរងគ្រោះ ដោយការប្រើប្រាស់សាកសពជនរងគ្រោះទាំងនោះធ្វើជាជីសម្រាប់ដំណាំទុរេនដែល **មាស មុត** បានបញ្ជា គឺជារឿងរ៉ាវពីមុនមកក្នុងការអនុវត្តដែលគេដឹងឮជាទូទៅ និងមានលក្ខណៈជាឧស្សាហកម្មកាប់សម្លាប់ ដែលគេបានចាត់ចែងឡើងជាប្រវត្តិសាស្ត្រ នៅក្នុងជំរំប្រមូលផ្តុំរបស់ពួកណាហ្ស៊ីស ដែលសាកសពរបស់ជនរងគ្រោះត្រូវបានគេប្រើប្រាស់ជាសាប៊ូ សក់របស់ពួកគេត្រូវបានប្រមូលយកយកទៅធ្វើជាសក់ក្លែងក្លាយ ហើយសំណាធ្មេញរបស់ជនរងគ្រោះ ត្រូវបានគេប្រមូល និងរំលាយធ្វើជាបន្ទះលោហធាតុមានតម្លៃ។ ឥរិយាបថបែបនេះវាហួសពីកម្រិតខ្ពស់ "ធម្មតា" របស់របបកម្ពុជាប្រជាធិបតេយ្យ ដូចដែលសហចៅក្រមស៊ើបអង្កេតទាំងពីរបានលើកឡើងនៅក្នុង *ដីកាដំណោះស្រាយ (សំអាងហេតុ)* លើសំណុំរឿង ០០៤/០១[1377]។

466. ទោះជាយ៉ាងណាក្តី **មាស មុត** ក៏ទទួលខុសត្រូវផងដែរ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មជាតិនៃអំពើមនុស្សឃាតដោយចេតនាគិតទុកជាមុន ក្រៅពីការកំណត់គោលដៅទៅលើជនជាតិថៃ និងជនជាតិវៀតណាម ដែលបានបញ្ជាក់លម្អិតនៅក្នុងផ្នែកបន្តបន្ទាប់ ជាពិសេស តួនាទីចម្បងរបស់គាត់នៅក្នុងការបោសសម្អាតកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ របស់កម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការគ្រប់គ្រងរួម និងការរៀបចំចាត់ចែងការដ្ឋាននានានៅកំពង់សោម។

467. ចំនួនជាអប្បបរមានៃជនរងគ្រោះដែលត្រូវបានសម្លាប់ នៅក្នុងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា ដែលអាចត្រូវបានដាក់បន្ទុកចំពោះ **មាស មុត** ត្រូវបានប៉ាន់ប្រមាណដូចតទៅ ដោយសំអាងទៅលើការបញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ និងការសម្លាប់*នៅនឹងកន្លែង*៖

---

[1377] **សំណុំរឿងលេខ ០០៤/១-ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* [កោសលុប] ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ៣២៤។

| | |
|---|---|
| កងពលធំ ១៦៤ | ៧១៩ នាក់ |
| កងពលធំ ៥០២ | ៤៧៨ នាក់ |
| កងពលធំ ៣១០ | ៩២៨ នាក់ |
| កងពលធំ ១១៧ | ២៧ នាក់ |
| **សរុប** | **២.១៥២** នាក់ |

468. ដោយសារតែចំនួនជនរងគ្រោះ ដែលគេបានសម្លាប់ នៅតាមបណ្តាទីតាំងឧក្រិដ្ឋកម្មនៅឯកំពង់សោម មិនអាចញែកឲ្យដាច់ស្រឡះពីគ្នាបាន នោះចំនួនសរុបជាអប្បបរមា គឺមាន ៨៤៥ នាក់ (៤០០ សម្លាប់នាក់នៅមន្ទីរសន្តិសុខវត្តអង្គតាញាណ ១៥ នាក់សម្លាប់នៅស្ទឹងហាវ និង ៤៣០ នាក់សម្លាប់នៅតាមទីតាំងនានាក្នុងតំបន់រាម)។ ចំណែកឯចំនួនជាអប្បរមានៃជនរងគ្រោះធ្វើពលកម្មដោយបង្ខំមានចំនួន ២.០០០ នាក់នៅតាមបណ្តាទីតាំងឧក្រិដ្ឋកម្មនៅរាម និង ១០០ នាក់សម្លាប់ក្នុងពេលណាមួយនៅស្ទឹងហាវ។ **មាស មុត** ខ្លួនឯងបានរាយការណ៍ថា កម្លាំងពលកម្មសរុបរបស់គាត់នៅកំពង់សោមមាន ១៧.០០០ នាក់។ នៅក្នុងបរិបទនៃយុត្តាធិការបុគ្គល គេអនុញ្ញាតឲ្យប្រើប្រាស់ចំនួននេះទាំងស្រុងថាជាសូចនាករនៃចំនួនសរុបទូទៅ និងតួនាទីរបស់ **មាស មុត**។ ដោយហេតុថា ភ័ស្តុតាងគាំទ្រលើសេចក្តីសន្និដ្ឋានថា ចំនួនជនរងគ្រោះ ១៧.០០០ នាក់ដែលគ្រាន់តែជាចំនួនមួយភាគតូច អាចជាកងទ័ពសកម្មរបស់កងពលធំ ១៦៤ បន្ថែមលើយោធាពិការ និងកុមារចំនួន ១៧៦ នាក់ ដូចបានលើកឡើងខាងលើ តែអនុញ្ញាតឲ្យប្រើប្រាស់ដើម្បីដកចេញដោយប្រុងប្រយ័ត្ននូវចំនួនកងទ័ព ២.០០០ នាក់ចេញពីចំនួនសរុបខាងលើ នោះចំនួនជាអប្បរមា ១៥.០០០ នាក់ នៅតែជាចំនួនដែលនឹងត្រូវបានយកមកធ្វើជាកម្មវត្ថុស្តីពីពលកម្មដោយបង្ខំ និងចំពោះការឃុំឃាំងខ្លួន ។ល។ នៅក្រោមស្ថានភាពលំបាកលំបិនបែបនេះ អាស្រ័យទៅលើសំអាងយកចេញពីចំនួនសរុបនៃភ័ស្តុតាងស្តីពីទីតាំងឧក្រិដ្ឋកម្ម។

## ៦.៣ សេចក្តីសន្និដ្ឋាន

469. សរុបសេចក្តីមក ទាំងតួនាទី និងអំពើរបស់ **មាស មុត** កំណត់ថា គាត់ជាអ្នកដើរតួចម្បងនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកចូលរួមប្រកបដោយឆន្ទៈស្រួចស្រាល់ ចំពោះការអនុវត្តយ៉ាងឃោរឃៅ នូវគោលនយោបាយឧក្រិដ្ឋ និងអមនុស្សធម៌របស់កម្ពុជាប្រជាធិបតេយ្យ។

## ៧. សំអាងច្បាប់ស្តីពីឧក្រិដ្ឋកម្ម

### ៧.១ ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

470. នៅចន្លោះអំឡុងចុងខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ប.ក.ក បានធ្វើការវាយប្រហារលើប្រជាពលរដ្ឋស៊ីវិលនៅតំបន់កំពង់សោម និងក្នុងដែនទឹក និងដែនកោះក្នុងដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ និងតាមភូមិភាគនានាដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់កងទ័ពបដិវត្តន៍ កម្ពុជា ដែលទាហានត្រូវបានចាត់ទុកជាប្រជាពលរដ្ឋស៊ីវិល សម្រាប់គោលបំណងនៃដីកាចោទប្រកាន់នេះ។ ការវាយប្រហារនេះរួមមានបណ្តាញប្រតិបត្តិការសំខាន់ៗ ដូចមានរៀបរាប់ខាងក្រោម។

471. ទីមួយ ប.ក.ក បានអនុវត្តគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋានទូទាំងប្រទេសកម្ពុជា និងជម្លៀសប្រជាជនភាគច្រើនដោយបង្ខំ ដើម្បីធ្វើការងារនៅតាមសហករណ៍ និងការដ្ឋានទាំងនោះ។ គោលបំណងចុងក្រោយ គឺការប្រែក្លាយកម្ពុជាទៅជារដ្ឋសង្គមខ្លួនទីពឹងខ្លួនដែលផ្អែកលើសេដ្ឋកិច្ចកសិកម្ម។ ប.ក.ក បានបង្ខំឲ្យប្រជាពលរដ្ឋស៊ីវិលធ្វើការដោយគ្មានប្រាក់កម្រៃ និងស្ថិតក្រោមលក្ខខណ្ឌរស់នៅ និងធ្វើការដ៏គ្រោះថ្នាក់ ដែលធ្វើឲ្យកម្មករប្រឈមនឹងការរងទុក្ខវេទនាឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តដ៏ធំធេង។ ប្រជាពលរដ្ឋស៊ីវិលជាច្រើនបានស្លាប់ដោយសារការហត់នឿយ ការអត់អាហារ និងជំងឺ។ អ្នកផ្សេងទៀតត្រូវបានសម្លាប់ដោយសារការបំពានតូចតាច ឬមូលហេតុតាមទំនើងចិត្តផ្សេងទៀត។

472. ទីពីរ ក្នុងករណីដែនទឹក និងដែនកោះ ប.ក.ក បានអនុវត្តគោលនយោបាយចាប់ខ្លួនទូកនេសាទថៃ និងវៀតណាម និងនាវិក/អ្នកដំណើរក្នុងគោលបំណងសម្លាប់នាវិក និងអ្នកដំណើរទាំងនោះដោយគ្មានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឡើយ។ ផ្ទុយស្រឡះ មានការដាក់បញ្ជាដោយបើកចំហរឲ្យធ្វើការសម្លាប់ ហើយការណ៍នេះបានធ្វើឲ្យជនរងគ្រោះជាច្រើនប្រឈមនឹងផលវិបាកនេះ។ ក្នុងករណីជនជាតិវៀតណាម គ្មានការលើកលែងសោះឡើយ ព្រោះជនជាតិវៀតណាមត្រូវបានចាត់ទុកជាសត្រូវប្រវត្តិសាស្ត្រដ៏ធំរបស់ជនជាតិខ្មែរ និងត្រូវកម្ទេចចោលដោយសារពួកគេជាជនជាតិវៀតណាម។

សកម្មភាពនេះរួមមានការសម្លាប់ស្ត្រី កុមារ និងមនុស្សចាស់។ ពេលខ្លះជនជាតិថៃបានគេចខ្លួនពីការយកទៅសម្លាប់ នៅពេលពួកគេត្រូវបានបញ្ជូនទៅកាន់ប្រទេសថៃជាថ្នូរនឹងទំនិញនានា។ យ៉ាងនេះក្តី ជនជាតិថៃយ៉ាងច្រើនត្រូវបានសម្លាប់ដោយផ្អែកលើគោលនយោបាយដែលបានលើកឡើងពីខាងដើមនេះ។

473. ចំណុចទីបីនៃការវាយប្រហាររបស់ ប.ក.ក លើប្រជាពលរដ្ឋស៊ីវិលនៅកំពង់សោម ជាប់ពាក់ព័ន្ធនឹងការអប់រំ "សមាសភាពមិនល្អ" ឡើងវិញ និងការសម្លាប់ "ខ្មាំង" ទាំងក្នុង និងក្រៅជួរ ប.ក.ក។ ប.ក.ក បានបង្កើតទីតាំងនានាដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណ ពិនិត្យតាមដាន និងអប់រំឡើងវិញ ឬសម្លាប់ខ្មាំងតាមការសន្និតរបស់កម្ពុជាប្រជាធិបតេយ្យ។ អ្នកដែលត្រូវបានសង្ស័យសូម្បីតែដោយសារកំហុសតូចតាច ឬការមិនស្មោះត្រង់ ក៏អាចក្លាយជាចំណុចផ្តោតដែរ។

474. ទីបួន ប.ក.ក បានកំណត់អត្តសញ្ញាណ ផ្តោតលើ និងបោសសម្អាតជាប្រព័ន្ធនូវប្រភេទមនុស្សមួយចំនួនដែលត្រូវបានសន្និតថាអាចបង្កការគំរាមកំហែងដល់របបកម្ពុជាប្រជាធិបតេយ្យ ឬមានទស្សនៈផ្ទុយពីគោលការណ៍របស់ ប.ក.ក។ មនុស្សទាំងនោះរួមមាន កងទ័ពបដិវត្តន៍កម្ពុជា (ក្នុងករណីនេះ ជាពិសេសកងទ័ពមកពីកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧) ប្រជាជនដែលត្រូវបានជម្លៀសចេញដោយបង្ខំពីទីប្រជុំជន អតីតទាហាន និងមន្ត្រីផ្សេងទៀតនៃរបបខ្មែរសាធារណរដ្ឋ និងអ្នកផ្សេងទៀតដែលត្រូវបានសន្និតថាបង្កការគំរាមកំហែងដល់គោលដៅរបស់ ប.ក.ក ក្នុងការផ្លាស់ប្តូរសង្គម កម្ពុជា។

475. ចំណុចទី ៥ នៃការវាយប្រហាររបស់ ប.ក.ក លើប្រជាជននៅកំពង់សោមក្នុងផ្នែកនៃគោលនយោបាយទូទាំងប្រទេស គឺការដាក់កំហិតឲ្យរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន និងកសាងគ្រួសារស្អាតស្អំខាងមនោគមន៍វិជ្ជា។ ប.ក.ក បានបង្ខំឲ្យប្រជាជនរៀបការជាមួយប្តី/ប្រពន្ធដែលជ្រើសរើសដោយអង្គការ និងក្នុងករណីជាច្រើន បង្ខំឲ្យគូស្វាមីភរិយារួមដំណេកជាមួយគ្នា។

476. លក្ខណៈជាប្រព័ន្ធនៃការវាយប្រហារនេះស្តែងចេញពីការរៀបចំផែនការ ការរៀបចំ និងការអនុវត្តពីថ្នាក់មជ្ឈិមដែលជាប់ពាក់ព័ន្ធនឹងកម្រិតទាំងអស់នៃកងទ័ពបដិវត្តន៍កម្ពុជា និងផ្នែកនានានៃការគ្រប់គ្រងប្រជាពលរដ្ឋស៊ីវិល។ លើសពីនេះ លក្ខណៈទូទៅនៃការវាយប្រហារនេះត្រូវបានឆ្លុះបញ្ចាំងក្នុងវិសាលភាពពេលវេលា និងភូមិសាស្ត្រយ៉ាងទូលំទូលាយ ការគ្របដណ្តប់លើភូមិភាគផ្សេងៗ និងចំនួនជនរងគ្រោះយ៉ាងច្រើនអនេកដែលត្រូវបានសម្លាប់ និងបង្ខំឲ្យធ្វើការ។ ការវាយ

ប្រហារនេះត្រូវបានអនុវត្តដោយសារមូលហេតុនយោបាយ ក្នុងទម្រង់ជាការអនុវត្តរបៀបវារៈគោលនយោបាយទូលំទូលាយរបស់ ប.ក.ក។

477. ផ្អែកតាមមុខតំណែងរបស់គាត់ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកដ៏ធំមួយនៃផ្នែកទាំង ៣ ក្នុងកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ និងក្នុងនាមជាសមាជិកបម្រុងរបស់អគ្គសេនាធិការ និងជាអនុប្រធានរបស់ សុន សេន ព្រមទាំងការគ្រប់គ្រងជារួមរបស់គាត់លើការគ្រប់គ្រងប្រជាពលរដ្ឋស៊ីវិលនៅតំបន់ស្វយ័តកំពង់សោម **មាស មុត** គឺជាអ្នកចូលរួមដ៏សំខាន់ម្នាក់ក្នុងការវាយប្រហារទូលំទូលាយ និងជាប្រព័ន្ធលើប្រជាពលរដ្ឋស៊ីវិល ដែលគាំទ្រដោយការពិតដែលថាគាត់មានភារៈកិច្ច និងសហប្រតិបត្តិការក្នុងប្រតិបត្តិការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា សូម្បីតែនៅក្រៅកងពលធំ ១៦៤ របស់គាត់។ តាមរយៈការចូលរួមកិច្ចប្រជុំជាប្រចាំ ការចុះតាមទីតាំង និងប្រព័ន្ធរាយការណ៍យ៉ាងតឹងរ៉ឹង **មាស មុត** ពិតជាបានដឹងច្បាស់ពីការវាយប្រហារនោះ ហើយអំពើរបស់គាត់ក៏ជាផ្នែកមួយនៃការវាយប្រហារនោះផងដែរ។

## ៧.២ ធាតុផ្សំតាមបរិបទនៃការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ

478. ចាប់ពីយ៉ាងហោចណាស់ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មានអរិភាពប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម និងចាប់ពីខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ មានអរិភាពប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសថៃ ហើយអរិភាពនីមួយៗមានទម្រង់ជាជម្លោះប្រដាប់អាវុធអន្តរជាតិ។ ការពិតដែលថាមានភាពស្ងប់ស្ងាត់ដោយអន្លើរៗក្នុងការប្រយុទ្ធនានា និងការប៉ុនប៉ងដោយអសារបង់ក្នុងការឈានដល់ការបញ្ចប់អរិភាព មិនអាចធ្វើឲ្យប៉ះពាល់ដល់អង្គហេតុដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិថៃ និងវៀតណាម ដូចការពិចារណាក្នុងដីកាដំណោះស្រាយនេះឡើយ និងពិតជាមានជម្លោះប្រដាប់អាវុធអន្តរជាតិកើតឡើងប្រាកដមែន ហើយឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តក្នុងផ្នែកនៃអរិភាពនីមួយៗ។ ក្នុងនាមជាមេបញ្ជាការយោធាដែលមានឋានៈខ្ពស់បំផុត **មាស មុត** បានដឹងពីជម្លោះទាំងនេះ និងទំនាក់ទំនងរវាងឧក្រិដ្ឋកម្មនីមួយៗ។

479. រាល់ការចោទប្រកាន់ពីបទរំលោភបំពានធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងជនបរទេស ក្រៅពីជនជាតិវៀតណាម និងថៃ ត្រូវបានទុកជាមោឃៈក្នុងការបង្ហាញខ្លួនលើកដំបូងរបស់ **មាស មុត** កាលពី ថ្ងៃទី

១៤ ខែធ្នូ ឆ្នាំ២០១៥ និងបច្ចុប្បន្ន ស្ថិតក្រោមដីកាបញ្ចប់សំណុំរឿងដែលនៅសេសសល់ខាងក្រោម[1378]។

## ៧.៣ ការរកឃើញផ្នែកអង្គច្បាប់ស្តីពីឧក្រិដ្ឋកម្ម

480. កំណត់សម្គាល់បឋមមួយគឺពិតជាសមស្របនៅចំណុចនេះ៖ ត្រង់ចំណុចពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិថៃ និងវៀតណាម មានសក្តានុពលដ៏ធំនៃភាពត្រួតគ្នាពាក់ព័ន្ធនឹងចំនួនជនរងគ្រោះនៅទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនីមួយៗ។ ចំនួនទាំងអស់នេះត្រូវបានដាក់បញ្ចូលក្នុងចំនួនជនរងគ្រោះក្នុងផ្នែក ៧.៣.១ និង ៧.៣.២ ខាងក្រោម។

### ៧ ១.៣.ការសម្លាប់ជនជាតិវៀតណាមដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ

481. ឧក្រិដ្ឋកម្មភាគច្រើនដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម បានកើតឡើងនៅក្នុងដែនទឹក និងលើកោះនានា ដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម តែប៉ុន្តែក៏មានឧក្រិដ្ឋកម្មមួយចំនួនបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដែរ ដូចដែលនឹងរៀបរាប់ដូចខាងក្រោម។

*អំពើប្រល័យពូជសាសន៍*

482. មានការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ដែលត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងដែនទឹក និងដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ តាមរយៈការសម្លាប់សមាជិកក្រុមជាតិពន្ធុ និងក្រុមជនជាតិវៀតណាមដែលត្រូវបានការពារដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។

483. កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ បានសម្លាប់ជនជាតិវៀតណាមយ៉ាងតិច **៣.២៧៦ នាក់**។

484. អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើង ក្នុងគោលបំណងកម្ទេចជនជាតិវៀតណាមទាំងអស់ដែលត្រូវបានចាប់ខ្លួនក្នុងដែនទឹក និងដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ។ ការរក

---

[1378] ឯកសារ **D174** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ទំព័រ ១០ លេខ ៦។

ឃើញពីចេតនាពិសេសនេះ ផ្អែកលើភស្តុតាងទូលំទូលាយនៃគោលនយោបាយលុបបំបាត់របស់ ប.ក.ក និងគំរូដែលលេចឡើង និងទំហំនៃការសម្លាប់ជនជាតិវៀតណាម។

485. ជនជាតិវៀតណាមត្រូវបានផ្តោតជាពិសេសដោយសារអត្តសញ្ញាណជាតិ និងជាតិពន្ធុរបស់ពួកគេ។ ការរកឃើញនេះត្រូវបានគាំទ្រដោយភស្តុតាងស្តីពីកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញការទទួលស្គាល់ថា មានគោលនយោបាយរើសអើងជាក់លាក់ចំពោះជនជាតិវៀតណាម ដែលពាក់ព័ន្ធនឹងគោលដៅលុបបំបាត់រូបរាងកាយរបស់ពួកគេ។

486. លក្ខណៈជារួមនៃភស្តុតាងនេះ វិសាលភាពយ៉ាងធំធេងនៃការវាយប្រហារ លក្ខណៈជាប្រព័ន្ធនៃការចាប់ខ្លួន និងសម្លាប់ និងការផ្តោតលើដោយមិនរើសមុខ និងទូលំទូលាយលើជនជាតិវៀតណាមទាំងអស់ ចេញពីបរិបទនៃរចនាសម្ព័ន្ធរដ្ឋបាលរបស់ ប.ក.ក និងគោលដៅគោលនយោបាយទូលំទូលាយរបស់ ប.ក.ក បង្ហាញយ៉ាងច្បាស់ថា ក្នុងអំឡុងពេលប្រតិបត្តិការរបស់កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ជនជាតិវៀតណាមត្រូវបានកំណត់ជាចំណុចផ្តោតក្រោមគោលបំណងជាក់លាក់នៃការកម្ទេចរូបរាងកាយរបស់ពួកគេ។

487. ការពិតដែលថា គ្មានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ ហើយជនរងគ្រោះចុងក្រោយជាច្រើនត្រូវបានទុកឱ្យប្រឈមនឹងផលវិបាកនេះ និងភស្តុតាងដែលគូសបញ្ជាក់ពីគោលនយោបាយនៃការមិនលើកលែងឱ្យ ដោយសារតែជនជាតិវៀតណាមត្រូវបានចាត់ទុកជាសត្រូវប្រវត្តិសាស្ត្រដ៏ធំរបស់ជនជាតិខ្មែរ និងត្រូវកម្ទេចចោលដោយសារតែពួកគេជាជនជាតិវៀតណាម (រួមមានការសម្លាប់ស្ត្រី កុមារ និងមនុស្សចាស់) បំពេញលក្ខខណ្ឌនៃចេតនាកម្ទេចផ្នែកដ៏ធំនៃក្រុមគោលដៅនេះ។ គេអាចនិយាយបានថា ប្រសិនបើជនជាតិវៀតណាម ១ លាននាក់ត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ពួកគេនឹងត្រូវបានសម្លាប់ចោលទាំងអស់។ វាមិនចាំបាច់នោះទេក្នុងបរិបទនេះក្រៅពីការពិចារណាពីការសន្និដ្ឋានផ្អែកតាមភស្តុតាងដែលថា ចំនួនជាក់ស្តែងរបស់ជនរងគ្រោះដែលត្រូវបានសម្លាប់គឺមានច្រើនអនេកៈ លក្ខណវិនិច្ឆ័យ "ផ្នែកដ៏ធំ" គឺជាផ្នែកមួយនៃចេតនាឧក្រិដ្ឋ។ អំពើប្រល័យពូជសាសន៍ចាប់ផ្តើមពីជនរងគ្រោះទីមួយ ឱ្យតែអាចបង្ហាញពីចេតនាសម្លាប់ដែលជាផ្នែកដ៏សំខាន់របស់ក្រុមនេះ។ ដូច្នេះ គេមិនចាំបាច់ឡើយក្នុងការកំណត់ថាតើចំនួនជនរងគ្រោះ ៣.២៧៦ នាក់ នឹងបង្កើតជាក្រុមមួយដ៏ធំ និងគួរធៀបនឹងប្រជាជនគោលដៅ ឬយ៉ាងណាឡើយ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

488. អំពើដូចគ្នានេះបញ្ជាក់ពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល ព្រោះការសម្លាប់បានកើតឡើង និងមានចេតនាឲ្យកើតឡើងក្នុងទ្រង់ទ្រាយធំ ដូចការគូសបញ្ជាក់ដោយគោលនយោបាយចាប់ខ្លួន និងសម្លាប់ដោយបើកចំហរ និងចំនួនជនជាតិវៀតណាមយ៉ាងតិច **៣.២៧៦ នាក់** ដែលត្រូវបានសម្លាប់។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

489. ដូចគ្នាដែរ អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល បង្ហាញពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយចេតនា។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

490. ចំពោះវិសាលភាពដែលជនជាតិវៀតណាមត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ធាតុផ្សំនៃអំពើមនុស្សឃាតដោយចេតនាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញ។ នៅពេលដែលជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ការស្លាប់របស់ពួកគេត្រូវបានកំណត់ទុក *ជាក់ស្តែង* ព្រោះគ្មាននរណាម្នាក់ត្រូវបានដោះលែងពីមន្ទីរសន្តិសុខ ស-២១ ឡើយ។ ការសន្និដ្ឋានតែមួយគត់ដោយផ្អែកលើភស្តុតាងគឺថា ការសម្លាប់ដែលបានប្រព្រឹត្តទៅនៅទីនោះ ជាអំពើចេតនា។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

491. អ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានឃុំខ្លួននៅទីនោះផ្ទុយពីឆន្ទៈរបស់ពួកគេក្នុងអំឡុងពេលផ្សេងៗ។ ហេតុនេះ ចំពោះវិសាលភាពដែលជនជាតិវៀតណាមត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាទម្រង់នៃការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

492. នៅពេលស្ថិតក្នុងមន្ទីរសន្តិសុខ ស-២១ អ្នកជាប់ឃុំត្រូវបានដាក់ឲ្យប្រឈមនឹងការធ្វើទុកបុកម្នេញផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដោយចេតនា និងដើម្បីស្រង់យកចម្លើយសារភាពដែលចោទប្រកាន់ពួកគេ និងអ្នកផ្សេងទៀត ដែលក្រោយមកត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់។ ដូច្នេះ ពិតជាមានការបង្កការឈឺចាប់ដើម្បីទទួលបានព័ត៌មាន។ ហេតុនេះ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម ត្រូវបានបំពេញ ទាក់ទិននឹងជនជាតិវៀតណាមដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

493. ការសម្លាប់ជនជាតិវៀតណាម និងការបោះចោលសាកសពរបស់ពួកគេដោយចេតនាដោយមិនគោរពសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ក្នុងលក្ខណៈដែលបិទបាំងដោគវាសនារបស់ពួកគេពីក្រុមគ្រួសារ ឬមិត្តភក្តិ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

494. ស្ថានភាពឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ បានបង្កអារម្មណ៍ភ័យរន្ធត់ និងការលំបាកបំផុតក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលរំលោភបំពានលើតម្រូវការមូលដ្ឋាននៃការប្រព្រឹត្តបែបមនុស្សធម៌ចំពោះអ្នកទោស និងដកហូតសេចក្តីថ្លៃថ្នូរជាមនុស្សចុងក្រោយរបស់អ្នកទោស។ ការសន្និដ្ឋានសមហេតុផលតែមួយគត់ចេញពីភស្តុតាងនេះគឺ អំពើនេះត្រូវបានធ្វើឡើងដោយចេតនា។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ផ្អែកទៅលើការធ្វើបានយ៉ាងអមនុស្សធម៌ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំងត្រូវបានបំពេញ ទាក់ទិននឹងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ ចំពោះវិសាលភាពដែលជនជាតិវៀតណាមត្រូវបានបញ្ជូនទៅ

មន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាទម្រង់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត និង ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ និង ជាតិសាសន៍តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

495. តាមរយៈការប្រព្រឹត្តបទល្មើសនៃការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ ផ្សេងៗទៀតលើជនជាតិវៀតណាមដោយសារតែជាតិពន្ធុរបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុជាតិសាសន៍ ត្រូវបានប្រព្រឹត្តឡើង។

496. យ៉ាងនេះក្តី គ្មានការបញ្ជាក់ក្នុងភស្តុតាងស្តីពីទិដ្ឋភាពបន្ថែមមួយនៃការធ្វើទុក្ខបុកម្នេញជនជាតិវៀត ណាមដែលផ្អែកលើមូលហេតុនយោបាយឡើយ។ ទិដ្ឋភាពនយោបាយតែមួយគត់អាចជាការពិត ដែលថាកម្ពុជាប្រជាធិបតេយ្យ កំពុងធ្វើសង្គ្រាមជាមួយវៀតណាម ប៉ុន្តែចំណុចនេះមិនគ្រប់គ្រាន់ ឡើយ។ ដូច្នេះ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ៖ ការឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការ សម្លាប់ដោយចេតនា ចេតនាបង្កឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់ រូបរាងកាយ ឬដល់សុខភាព និងការធ្វើទារុណកម្ម*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់ សោម</u>

497. ការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាមដោយចេតនា និងមានផែនការទុកជាមុនក្នុងដែនទឹក និង ដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ និងការបញ្ជូនជនជាតិវៀតណាមមួយចំនួនទៅ កាន់ដីគោក ឬកោះដើម្បីសម្លាប់ ដែលជាអំឡុងពេលដែលជនរងគ្រោះស្ថិតក្រោមអារម្មណ៍ភ័យខ្លាច សេចក្តីស្លាប់បំផុត បំពេញធាតុផ្សំនៃឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការសម្លាប់ដោយ ចេតនា និងចេតនាបង្កឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

498. កថាខណ្ឌខាងលើអនុវត្តស្មើគ្នាចំពោះអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ ក្រៅពីនេះ អនុលោមតាមសំអាងហេតុដូចគ្នាដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៤៩២ ធាតុផ្សំនៃការធ្វើទារុណកម្មជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានបំពេញ។

*មនុស្សឃាតគិតទុកជាមុន*

499. ការសម្លាប់ជនជាតិវៀតណាម បង្កើតបានជាមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ២.៣.ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ

500. ពាក់ព័ន្ធនឹងជនជាតិវៀតណាម ទោះបីឧក្រិដ្ឋកម្មភាគច្រើនបានប្រព្រឹត្តទៅលើជនជាតិថៃនៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅក្នុងតំបន់កំពង់សោម ក៏ដោយ តែឧក្រិដ្ឋកម្មមួយចំនួនក៏ត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដែរ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

501. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល ត្រូវបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ លើជនជាតិថៃដែលត្រូវបានចាប់ខ្លួនក្នុងដែនសមុទ្រ។

502. ដូចគ្នានឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាមដែរ កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យបានធ្វើប្រតិបត្តិការក្រោមគោលនយោបាយចាប់ខ្លួនទូកនេសាទថៃទាំងអស់ និងនាវិក/អ្នកដំណើរ ហើយខណៈដែលការលើកលែងមិនសម្លាប់ត្រូវបានធ្វើឡើងម្តងម្កាល ជនជាតិថៃយ៉ាងច្រើន (ឧទាហរណ៍ យ៉ាងហោចណាស់ ១.២០០ នាក់) ត្រូវបានសម្លាប់។ គោលជំហរកំណត់យកស្រាប់ (ដូចការប្រព្រឹត្តចំពោះជនជាតិវៀតណាមដែរ) គឺការចាប់ខ្លួន និងសម្លាប់។

503. ដូច្នេះ ការសម្លាប់បានកើតឡើង និងមានចេតនាឲ្យកើតឡើងក្នុងទ្រង់ទ្រាយធំ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

504. សកម្មភាពដូចគ្នា បំពេញធាតុផ្សំនៃការធ្វើមនុស្សឃាតដោយចេតនាក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

505. អនុលោមតាមសំអាងហេតុដូចគ្នាពាក់ព័ន្ធនឹងជនជាតិវៀតណាម វិសាលភាពដែលជនជាតិថៃត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាតដោយចេតនា ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

506. អនុលោមតាមសំអាងហេតុដូចគ្នាពាក់ព័ន្ធនឹងជនជាតិវៀតណាម វិសាលភាពដែលជនជាតិថៃត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

507. អនុលោមតាមសំអាងហេតុដូចគ្នាពាក់ព័ន្ធនឹងជនជាតិវៀតណាម វិសាលភាពដែលជនជាតិថៃត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

508. ការសម្លាប់ជនជាតិថៃ និងការបោះចោលសាកសពរបស់ពួកគេដោយចេតនា ដោយមិនគោរព សេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ ក្នុងលក្ខណៈដែលបិទបាំងជោគវាសនារបស់ពួកគេពីក្រុមគ្រួសារ ឬមិត្តភក្ដិ ដែលគួរដឹងពីអ្វីដែលបានកើតឡើងចំពោះពួកគេ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

509. សម្រាប់សំអាងហេតុដូចគ្នាពាក់ព័ន្ធនឹងជនជាតិវៀតណាម ចំពោះវិសាលភាពដែលជនជាតិថៃត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតផ្អែកលើការធ្វើបាបយ៉ាងអមនុស្សធម៌ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ និងជាតិសាសន៍តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

510. តាមរយៈការប្រព្រឹត្តបទល្មើសនៃការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀតលើជនជាតិថៃដោយសារតែជាតិពន្ធុរបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុជាតិសាសន៍ ត្រូវបានប្រព្រឹត្តឡើង។

511. យ៉ាងនេះក្ដី គ្មានការគូសបញ្ជាក់ក្នុងភស្តុតាងស្ដីពីទិដ្ឋភាពបន្ថែមមួយនៃការធ្វើទុក្ខបុកម្នេញជនជាតិថៃដោយផ្អែកលើមូលហេតុនយោបាយឡើយ។ ទិដ្ឋភាពនយោបាយតែមួយគត់អាចជាការពិតដែលថា កម្ពុជាប្រជាធិបតេយ្យកំពុងធ្វើសង្គ្រាមជាមួយប្រទេសថៃ ប៉ុន្តែចំណុចនេះមិនគ្រប់គ្រាន់ឡើយ។ ដូច្នេះ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ៖ ឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការសម្លាប់ដោយចេតនា ចេតនាបង្កឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់សុខភាព និងការធ្វើទារុណកម្ម*

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

512. ការចាប់ខ្លួន និងសម្លាប់ជនជាតិថៃដោយចេតនា និងមានផែនការទុកជាមុនក្នុងដែនទឹក និងដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ និងការបញ្ជូនជនជាតិថៃមួយចំនួនទៅកាន់ដីគោក ឬកោះដើម្បីសម្លាប់ ដែលជាអំឡុងពេលដែលជនរងគ្រោះស្ថិតក្រោមអារម្មណ៍ភ័យខ្លាចសេចក្តីស្លាប់បំផុត បំពេញធាតុផ្សំនៃការឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការសម្លាប់ដោយចេតនា និងចេតនាបង្កឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

513. កថាខណ្ឌខាងលើអនុវត្តស្មើគ្នាទៅនឹងមនុស្សដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ ក្រៅពីនេះ អនុលោមទៅតាមសំអាងហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៤៩២ និង ៥០៧ ធាតុផ្សំនៃការធ្វើទារុណកម្មជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានបំពេញ។

*មនុស្សឃាតគិតទុកជាមុន*

514. ការសម្លាប់ជនជាតិថៃ បង្កើតបានជាមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ៣.៣.ទីតាំងសម្លាប់មនុស្សចម្ការទុរេន

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

515. ភស្តុតាងដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនេះ គាំទ្រការសន្និដ្ឋានថា ការសម្លាប់បានកើតឡើងនៅទីនោះក្នុងទ្រង់ទ្រាយធំ ព្រោះទីតាំងនោះត្រូវបានប្រើប្រាស់ជាប្រចាំសម្រាប់ការសម្លាប់ ជាពិសេសជនជាតិថៃ និងវៀតណាម រួមទាំងប្រជាជនមូលដ្ឋានផងដែរ។ ការសម្លាប់ទាំងនេះធ្វើឡើងដោយចេតនា។ ដូច្នេះ វាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

516. អង្គហេតុដូចគ្នា បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)*

517. អង្គហេតុដូចគ្នា ជាពិសេសការសម្លាប់ជនរងគ្រោះ និងការបោះចោលសាកសពរបស់ពួកគេដោយមិនគោរពសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ និងក្នុងលក្ខណៈដែលបិទបាំងដោតវាសនារបស់ពួកគេពីក្រុមគ្រួសារ ឬមិត្តភក្តិ បំពេញធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដោយផ្អែកលើការបាត់ខ្លួនដោយបង្ខំ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ និងជាតិសាសន៍តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

518. អង្គហេតុដូចគ្នា បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងជាតិសាសន៍តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត ឲ្យតែពាក់ព័ន្ធនឹងជនជាតិថៃ និងវៀតណាម។

519. យ៉ាងនេះក្តី គ្មានការបញ្ជាក់គ្រប់គ្រាន់ថា ការរើសអើងផ្នែកនយោបាយក៏ជាមូលហេតុនៃការសម្លាប់នោះទេ៖ លក្ខណវិនិច្ឆ័យនេះមិនអនុវត្តចំពោះជនជាតិថៃ និងវៀតណាមឡើយ ហើយវាមិនច្បាស់ថាហេតុអ្វីប្រជាជនមូលដ្ឋានត្រូវបានសម្លាប់នៅទីនោះ ហើយក៏គ្មានភស្តុតាងបង្ហាញថាមានជនបរទេសផ្សេងៗទៀតត្រូវបានសម្លាប់នៅចម្ការទុរេនឡើយ។ ដូច្នេះ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*មនុស្សឃាតគិតទុកជាមុន*

520. ការសម្លាប់មនុស្សនៅចម្ការទុរេន បង្កើតបានជាមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ៤.៣.ការបោសសម្អាតកងពលធំ ១៦៤១១៧ និង ៣១០ ,៥០២ ,

521. ទាក់ទងនឹងកងពលធំ ១៦៤ ភស្តុតាងគាំទ្រយ៉ាងច្បាស់ដល់ការសន្និដ្ឋានថា សមាជិករបស់កងពលធំនោះ ត្រូវបានបោសសម្អាតក្នុងតំបន់ស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់ **មាស មុត** ហើយដូច្នេះការប្រព្រឹត្តរបស់ពួកគេក្នុងបរិបទនេះត្រួតស៊ីគ្នាទាំងស្រុងក្នុងអង្គសេចក្តីនៃការចោទប្រកាន់នានានៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ ហើយដូច្នេះមិនត្រូវបានលើកឡើងនៅក្នុងផ្នែកនេះ

ឡើយ។ ទោះជាយ៉ាងណា ក៏មានភស្តុតាងផងដែរទាក់ទងនឹងប្រតិបត្តិការបោសសម្អាតសមាជិក កងពល ១៦៤ នៅឯទីតាំងផ្សេងៗនៅកំពង់សោម។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

<u>នៅទីតាំងផ្សេងទៀតក្រៅពីមន្ទីរសន្តិសុខ ស-២១</u>

522. ដូចដែលបានលើកឡើងខាងលើ ប្រតិបត្តិការបោសសម្អាតធ្វើឡើងជាយុទ្ធនាការធំមួយ ដើម្បីបោសសម្អាត *ជាអាទិ៍* មានកងពលដែលត្រូវបានកំណត់ឈ្មោះ មកពីសមាសធាតុមិនល្អគ្រប់ឋានៈទាំងអស់ ហើយនៅក្នុងភាគរយច្រើនបំផុតនៃករណីនានា ការណ៍នេះមានន័យថាជាការសម្លាប់ពួកគេ។ ការសម្លាប់នៅទីតាំងនានាក្រៅពីមន្ទីរ ស-២១ និងទីតាំងដែលត្រូវបានចោទប្រកាន់ផ្សេងៗទៀតទៅលើមនុស្សចំនួន ៦៦១ នាក់មកពីកងពលធំ ១៦៤ និងចំនួន ១៣៥ នាក់មកពីកងពល ៥០២ និងចំនួន២៣ នាក់មកពីកងពល ១១៧ ដែលត្រូវបានយកចេញទៅរួមគ្នា បង្កើតបានជាការសម្លាប់ទ្រង់ទ្រាយធំមួយ។ ការសន្និដ្ឋានតែមួយគត់ដោយឈរលើមូលដ្ឋានភស្តុតាងគឺថា ការសម្លាប់ទាំងនេះត្រូវបានអនុវត្តក្នុងទ្រង់ទ្រាយធំដោយចេតនា។ ដូច្នេះ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាលត្រូវបានបំពេញ។

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

523. នៅពេលដែលជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ការស្លាប់របស់ពួកគេត្រូវបានកំណត់ទុក *ជាក់ស្តែង* ព្រោះគ្មាននរណាម្នាក់ត្រូវបានដោះលែងពីមន្ទីរសន្តិសុខ ស-២១ ឡើយ។ ការសន្និដ្ឋានតែមួយគត់ដោយផ្អែកលើភស្តុតាងគឺថា ការសម្លាប់ដែលបានប្រព្រឹត្តទៅនៅទីនោះ ជាអំពើចេតនា។ ការសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ បានកើតឡើងជាប្រព័ន្ធយ៉ាងរលូន និងក្នុងទ្រង់ទ្រាយធំ (ផ្អែកតាមចំនួនកម្មាភិបាលកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានសម្លាប់នៅទីនោះ)។ ការសន្និដ្ឋានសមហេតុផលតែមួយគត់ស្តីពីភស្តុតាងនេះគឺ ការសម្លាប់ត្រូវបានធ្វើឡើងដោយចេតនាក្នុងទ្រង់ទ្រាយធំ។ អង្គហេតុទាំងនេះគាំទ្រដីកាចោទប្រកាន់ពីបទការសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អង្គហេតុទាំងនេះគាំទ្រដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះការសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

524. អង្គហេតុដូចគ្នាពាក់ព័ន្ធនឹងការសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ និងទីកន្លែងផ្សេងទៀត គាំទ្រដល់ការរកឃើញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយចេតនា។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

525. អ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានឃុំខ្លួននៅទីនោះផ្ទុយពីឆន្ទៈរបស់ពួកគេក្នុងអំឡុងពេលផ្សេងៗ។ ហេតុនេះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានបំពេញ ទាក់ទិននឹងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

នៅ<u>មន្ទីរសន្តិសុខ ស-២១</u>

526. នៅពេលស្ថិតក្នុងមន្ទីរ ស-២១ អ្នកជាប់ឃុំត្រូវបានដាក់ឲ្យប្រឈមនឹងការធ្វើទុកបុកម្នេញផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដោយចេតនា និងដើម្បីស្រង់យកចម្លើយសារភាពដែលចោទប្រកាន់ពួកគេ និងអ្នកផ្សេងទៀត ដែលក្រោយមកត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់។ ដូច្នេះ ពិតជាមានការបង្កការឈឺចាប់ដើម្បីទទួលបានព័ត៌មាន។ ហេតុនេះ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម ត្រូវបានបំពេញ ទាក់ទិននឹងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

នៅ<u>មន្ទីរសន្តិសុខ ស-២១</u>

527. ស្ថានភាពឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ បានបង្កអារម្មណ៍ភ័យរន្ធត់ និងការលំបាកបំផុតក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលរំលោភបំពានលើតម្រូវការមូលដ្ឋាននៃការប្រព្រឹត្តបែបមនុស្សធម៌

ចំពោះអ្នកទោស និងដកហូតសេចក្ដីថ្លៃថ្នូរជាមនុស្សចុងក្រោយរបស់អ្នកទោស។ ការសន្និដ្ឋានសមហេតុផលតែមួយគត់ចេញពីភស្តុតាងនេះគឺ អំពើនេះត្រូវបានធ្វើឡើងដោយចេតនា។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ផ្អែកទៅលើការធ្វើបានយ៉ាងអមនុស្សធម៌ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំងត្រូវបានបំពេញ ទាក់ទិននឹងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយតាម រយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និង ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបន្ថែមនៅមន្ទីរសន្តិសុខ ស-២១។*

<u>នៅទីតាំងផ្សេងទៀតក្រៅពីមន្ទីរសន្តិសុខ ស-២១</u>

528. មនុស្សត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំស្របទៅតាមការបោសសម្អាត ភាគច្រើនពីព្រោះពួកគេត្រូវបានចាត់ទុកថាមិនអាចទុកចិត្តបានផ្នែកនយោបាយដោយសារទស្សនៈ និងឥរិយាបថប្រឆាំងដែលត្រូវបានចោទប្រកាន់ ដូចជា ការមានសមានចិត្តជាមួយរបបចាស់ ឬអំណាចបរទេស ឬការមិនស្មោះត្រង់ចំពោះ ប.ក.ក សម្រាប់ហេតុផលផ្សេងទៀត។ ហេតុដូចនេះ ពួកគេគឺជាកម្មវត្ថុចំពោះការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ ដោយផ្អែកលើការរើសអើងផ្នែកនយោបាយ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយតាមរយៈការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត ត្រូវបានបំពេញពាក់ព័ន្ធនឹងអ្នកដែលត្រូវបានសម្លាប់នៅកន្លែងផ្សេងទៀតក្រៅពីមន្ទីរសន្តិសុខ ស-២១។

នៅ<u>មន្ទីរសន្តិសុខ ស-២១</u>

529. មនុស្សជាច្រើនលើសលប់ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ រួចត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ទទួលរងទារុណកម្ម សម្លាប់ និងប្រឈមនឹងលក្ខខណ្ឌភ័យរន្ធត់នៃការឃុំខ្លួន ពីព្រោះពួកគេត្រូវបានចាត់ទុកថាមិនអាចទុកចិត្តបានផ្នែកនយោបាយដោយសារទស្សនៈ និងឥរិយាបថប្រឆាំងដែលត្រូវបានចោទប្រកាន់ ដូចជា ការមានសមានចិត្តជាមួយរបបចាស់ ឬអំណាចបរទេស ឬការមិនស្មោះត្រង់ចំពោះ ប.ក.ក សម្រាប់ហេតុផលផ្សេងទៀត។ ហេតុដូចនេះ ពួកគេគឺជាកម្មវត្ថុចំពោះការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ ដោយផ្អែកលើការរើសអើងផ្នែកនយោបាយ។ ធាតុ

01600873



ផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយតាមរយៈការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត ត្រូវបានបំពេញ ទាក់ទិននឹងសមាជិកកងពលធំ ១៦៤, ៥០២, ៣១០ និង ១១៧ ដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

*មនុស្សឃាតគិតទុកជាមុន*

530. ការសម្លាប់ជនរងគ្រោះដែលត្រូវបានបោសសម្អាត បង្កើតបានជាមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ៥.៣.ការដ្ឋានកងកេង និងបិតត្រាង(ភាគតំបន់)

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឲ្យទៅជាទាសករ*

531. ខណៈដែលទាក់ទងនឹងសេរីភាពក្នុងការផ្លាស់ទីរបស់កម្មករ របបតឹងរ៉ឹងនេះអាចមានការលើកលែងក្នុងកម្រិតមួយចំនួននៅការដ្ឋានទាំងនេះ ការពិតនៅតែថា ភាគច្រើនបំផុតនៃមនុស្សដែលធ្វើការនៅការដ្ឋានទាំងនេះ មិនស្ថិតក្នុងស្ថានភាពមួយឲ្យជ្រើសរើសថាតើត្រូវចាកចេញឬអត់នោះទេ ហើយគ្មានសិទ្ធិគ្រប់គ្រងលើកាលវិភាគប្រចាំថ្ងៃរបស់ពួកគេ និងគ្មានជម្រើសការងារណាមួយដែលពួកគេនឹងចូលរួមធ្វើឡើយ។ អាហារ និងការថែទាំវេជ្ជសាស្ត្រមានការខ្វះខាតយ៉ាងខ្លាំងសម្រាប់ប្រភេទកម្មករដែលត្រូវធ្វើការងារធ្ងន់ ហើយកម្មករមួយចំនួនបានស្លាប់ដោយសារការអត់អាហារ និង/ឬជំងឺ។ ការប្រព្រឹត្តរបស់ពួកគេចំពោះផ្នែកតូចមួយនៃផលិតកម្មទាំងមូលនៅតាមអនុការដ្ឋានផ្សេងៗ គាំទ្រដល់ការសន្និដ្ឋានថា ពួកគេបានទទួលរងការប្រព្រឹត្តប្រៀបដូចជាចលនវត្ថុ ពោលគឺជាទ្រព្យសម្បត្តិរបស់ ប.ក.ក ហើយដូច្នេះវាជាការប្រព្រឹត្តដោយចេតនា ហើយហេតុដូចនេះគឺថា ពួកគេគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឲ្យទៅជាទាសករ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

532. អង្គហេតុដែលពិពណ៌នាស្ថិតក្រោមចំណងជើងខាងដើម រួមផ្សំជាមួយនឹងភស្តុតាងពាក់ព័ន្ធនឹងរយៈពេលនៃការធ្វើការងារនៅការដ្ឋានទាំងពីរ ព្រមទាំងសក្ខីកម្មរបស់សាក្សីមួយចំនួនអំពីឥទ្ធិពលដែលថា ពួកគេមានអារម្មណ៍ដូចជាពួកគេកំពុងត្រូវបានឃុំឃាំងនោះ គាំទ្រដល់ការសន្និដ្ឋានថា ជនរងគ្រោះត្រូវបានដកហូតសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់ពួកគេដោយចេតនា និងអនុញ្ញាតឲ្យមានការរកឃើញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួន និងពលកម្មដោយបង្ខំ)*

533. អង្គហេតុដូចគ្នាទាំងនេះ និងភស្តុតាងដែលថា កម្មករបានបាត់ខ្លួន (ជាប្រចាំ) ពីការដ្ឋានបន្ទាប់ពីត្រូវបានចាប់ខ្លួនដោយកម្មាភិបាលខ្មែរក្រហម មិនដែលបានវិលត្រឡប់មកវិញ ឬមិនធ្លាប់បានឮដំណឹងជាថ្មីនោះ គាំទ្រដល់ការរកឃើញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយមានមូលដ្ឋានលើការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួន និងពលកម្មដោយបង្ខំ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងពូជសាសន៍ តាមរយៈការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

534. ភស្តុតាង គាំទ្រដល់ការរកឃើញនៃការឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពីព្រោះភាគច្រើននៃអ្នកដែលធ្វើការនៅការដ្ឋាន ក្រៅពីសមាជិកសកម្មរបស់កងពល ១៦៤ ត្រូវបានចាត់ទុកថាមិនអាចទុកចិត្តបានខាងផ្នែកនយោបាយ និងមិនស្មោះត្រង់ចំពោះ ប.ក.ក ហើយដូច្នេះត្រូវបានផ្ទេរទៅកាន់ការដ្ឋានទាំងនោះ។ ហើយក៏មិនមានមន្ទិលសង្ស័យផងដែរថា ការណ៍នេះត្រូវបានធ្វើឡើងដោយចេតនា។

535. ទោះជាយ៉ាងណា មិនមានភស្តុតាងបង្ហាញថា ការកំណត់ទិសដៅណាមួយបានកើតមានឡើងដោយសារមូលហេតុនយោបាយទេ ឬថា មានជនបរទេសណាមួយ មានការពាក់ព័ន្ធឡើយ។

៧ ៦.៣.ការដ្ឋាននៅស្ទឹងហាវ

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

536. បើទោះជាយោងតាមភស្តុតាងដែលអាចរកបាន ចំនួនអ្នករងរបួសមានចំនួនទាបក៏ដោយ ក៏ការសម្លាប់ពិតជាបានកើតមានឡើង និងបានផ្អែកលើគោលនយោបាយទូទៅរបស់ ប.ក.ក ក្នុងការកម្ទេចអ្នកប្រឆាំង និងអ្នកមិនគោរពតាម។ ការសម្លាប់ទាំងនេះតែងតែធ្វើឡើងដោយចេតនា។ ទោះជាយ៉ាងណា មិនមានភស្តុតាងច្បាស់នោះទេទាក់ទងនឹងការស្លាប់ដែលកើតមានឡើងពីការធ្វើការ

បាក់កម្លាំង និងការអស់កម្លាំង។ អង្គហេតុទាំងនេះគាំទ្រដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឲ្យទៅជាទាសករ*

537. ឧត្តមានុភាពនៃភស្តុតាង អនុញ្ញាតឲ្យមានការសន្និដ្ឋានថា កម្មករនៅស្ទឹងហាវមិនត្រូវបានផ្តល់ប្រាក់ឈ្នួលសម្រាប់ការងាររបស់ពួកគេទេ ពួកគេមិនត្រូវបានផ្តល់សិទ្ធិសេរីភាពក្នុងការដើរហើរ មិនមានសិទ្ធិគ្រប់គ្រងលើកាលវិភាគប្រចាំថ្ងៃរបស់ពួកគេ និងមិនមានជម្រើសការងារណាមួយដែលពួកគេនឹងចូលរួមធ្វើឡើយ។ អាហារត្រូវបានបែងចែក ហើយបើទោះជាអាហារអាចមានភាពប្រសើរនៅផ្នែកខ្លះនៃទីតាំងនេះសម្រាប់មនុស្សមួយចំនួនក្តី ក៏វានៅតែមានការខ្វះខាតយ៉ាងខ្លាំងសម្រាប់ប្រភេទកម្មករដែលត្រូវធ្វើការងារធ្ងន់។ ការប្រព្រឹត្តរបស់ពួកគេចំពោះផ្នែកតូចមួយនៃផលិតកម្មទាំងមូលនៅតាមអនុការដ្ឋានផ្សេងៗនៅស្ទឹងហាវ គាំទ្រដល់ការសន្និដ្ឋានថា ពួកគេបានទទួលរងការប្រព្រឹត្តប្រៀបដូចជាចលនវត្ថុ ពោលគឺជាទ្រព្យសម្បត្តិរបស់ ប.ក.ក ហើយដូច្នេះវាជាការប្រព្រឹត្តដោយចេតនា ហើយហេតុដូចនេះគឺថា ពួកគេគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឲ្យទៅជាទាសករ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

538. អង្គហេតុដែលពិពណ៌នាស្ថិតក្រោមចំណងជើងខាងដើម រួមផ្សំជាមួយនឹងភស្តុតាងពាក់ព័ន្ធនឹងរយៈពេលនៃការឃុំខ្លួននៅស្ទឹងហាវ (ចាប់ពីសប្តាហ៍រហូតដល់ខែ) និងទាក់ទងនឹងការឃុំខ្លួនជនរងគ្រោះនៅគុកស្ទឹងហាវ ក៏គាំទ្រផងដែរដល់ការសន្និដ្ឋានថា ជនរងគ្រោះត្រូវបានដកហូតសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់ពួកគេដោយចេតនា និងអនុញ្ញាតឲ្យមានការរកឃើញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងពលកម្មដោយបង្ខំ)*

539. អង្គហេតុមួយចំនួន បន្ថែមលើភស្តុតាងទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន និងការចាប់ខ្លួន និងការសួរចម្លើយដោយហិង្សានៅគុកស្ទឹងហាវ និងនៅ *"កន្លែងឃោធា"* ដែលមានចម្ងាយ ១០០ ម៉ែត្រពីផ្លូវ អនុញ្ញាតឲ្យមានការសន្និដ្ឋានថា ឧក្រិដ្ឋកម្មដោយចេតនាប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជា

អំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការធ្វើបាបដោយអមនុស្សធម៌ និងពលកម្មដោយបង្ខំត្រូវបានប្រព្រឹត្តឡើង។

540. មិនមានការពាក់ព័ន្ធក្នុងបរិបទនេះទេថា *"កន្លែងឃោធា"* ជាទីដែលការសួរចម្លើយមួយចំនួនបានកើតមានឡើងនោះ ជាផ្លូវការអាចស្ថិតនៅក្រៅស្រុកស្ទឹងហាវ ពីព្រោះទំនាក់ទំនងរបស់កន្លែងឃោធានេះ និងភាពនៅជិតស្ទឹងហាវជាកត្តាកំណត់ មិនមែនលក្ខណៈបែងចែកតំបន់របស់កន្លែងនេះឡើយ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

541. អង្គហេតុដែលបានពិពណ៌នាស្ថិតក្រោមទីតាំងឧក្រិដ្ឋកម្មនេះខាងលើ ក៏ឆ្លើយតបផងដែរទៅនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយតាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត ពីព្រោះអ្នកទោសត្រូវបានឃុំខ្លួននៅស្ទឹងហាវ ដោយសារពួកគេត្រូវបានចាត់ទុកថាមិនអាចទុកចិត្តបានផ្នែកនយោបាយ និងមិនស្មោះត្រង់ចំពោះ ប.ក.ក។ ហើយក៏មិនមានមន្ទិលសង្ស័យផងដែរថា ការណ៍នេះត្រូវបានធ្វើឡើងដោយចេតនា។

*មនុស្សឃាតគិតទុកជាមុន*

542. ការសម្លាប់មនុស្សនៅស្ទឹងហាវ បង្កើតបានជាអំពើមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ៧.៣.មន្ទីរសន្តិសុខទឹកសាប

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

543. ភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនេះ គាំទ្រដល់ការសន្និដ្ឋានថា ការសម្លាប់ដោយចេតនាបានកើតមានឡើងនៅទីនោះជាប្រចាំ និងក្នុងទ្រង់ទ្រាយធំដោយចេតនា ដែលគាំទ្រដល់ការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើង។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

544. ភស្តុតាងដូចគ្នារួមជាមួយភស្តុតាងនៅជុំវិញមនុស្សដែលបានស្លាប់ពីការអត់អាហារ គាំទ្រដល់ការរកឃើញនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយចេតនា។ សភាពការណ៍ដ៏រន្ធត់នៅទីតាំងនេះ ដែលកើតពីការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ទាំងស្រុង គួបផ្សំនឹងកម្មករដែលតម្រូវឱ្យធ្វើការងារធ្ងន់ ត្រូវបានដឹងឮដោយកម្មាភិបាលនៅទីតាំងនោះ ហើយចំពោះពួកគេ វាច្បាស់ណាស់ថា ស្ថានភាពនេះនឹងបណ្តាលឱ្យមានអ្នករងរបួសដោយចៀសមិនផុត។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ*

545. ភស្តុតាងជុំវិញបន្ទុកការងារ និងលក្ខខណ្ឌនានា អនុញ្ញាតឱ្យមានការសន្និដ្ឋាថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ ត្រូវបានប្រព្រឹត្តឡើង។ មនុស្សដែលស្ថិតនៅការដ្ឋាន មិនស្ថិតក្នុងស្ថានភាពមួយដែលអាចជ្រើសរើសបានថាតើត្រូវចាកចេញឬអត់នោះទេ ហើយមិនមានសិទ្ធិគ្រប់គ្រងលើកាលវិភាគប្រចាំថ្ងៃរបស់ពួកគេ និងមិនមានជម្រើសការងារណាមួយដែលពួកគេនឹងចូលរួមធ្វើឡើយ។ អាហារ និងការថែទាំវេជ្ជសាស្ត្រមានការខ្វះខាតយ៉ាងខ្លាំងសម្រាប់ប្រភេទកម្មករដែលត្រូវធ្វើការងារធ្ងន់។ ការប្រព្រឹត្តរបស់ពួកគេចំពោះផ្នែកតូចមួយនៃផលិតកម្មទាំងមូលនៅតាមអនុការដ្ឋានផ្សេងៗ គាំទ្រដល់ការសន្និដ្ឋានថា ពួកគេបានទទួលរងការប្រព្រឹត្តប្រៀបដូចទៅនឹងចលនវត្ថុ ពោលគឺជាទ្រព្យសម្បត្តិរបស់ ប.ក.ក ហើយដូច្នេះវាជាការប្រព្រឹត្តិដោយចេតនា។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

546. អង្គហេតុដូចគ្នា គាំទ្រដល់ការរកឃើញថា កម្មករត្រូវបានគេដកហូតសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់ពួកគេដោយចេតនា និងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានប្រព្រឹត្តឡើង។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួន និងពលកម្មដោយបង្ខំ)*

547. ភស្តុតាងដែលត្រូវបានរួមបញ្ចូលគ្នាពាក់ព័ន្ធនឹងការចោទប្រកាន់ដែលបានលើកឡើងខាងលើ និងការរកឃើញបន្ថែមទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន គាំទ្រដល់ការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួន និងពលកម្មដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើង។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងពូជសាសន៍ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

548. ភស្តុតាង គាំទ្រដល់ការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត ពីព្រោះភាគច្រើននៃអ្នកដែលធ្វើការនៅការដ្ឋាន ក្រៅពីសមាជិកសកម្មនៃកងពលធំ ១៦៤ ត្រូវបានគេចាត់ទុកថាមិនអាចទុកចិត្តបានផ្នែកនយោបាយ និងមិនស្មោះត្រង់ចំពោះ ប.ក.ក។ មិនមានមន្ទិលសង្ស័យនោះទេថា ការណ៍នេះត្រូវបានធ្វើឡើងដោយចេតនា។

549. ទោះជាយ៉ាងណា មិនមានភស្តុតាងដែលអាចទុកចិត្តបានគ្រប់គ្រាន់នោះទេថា ជនជាតិថៃ ឬជនជាតិវៀតណាម ឬជនជាតិណាមួយផ្សេងទៀត ត្រូវបានឃុំខ្លួន ឬសម្លាប់នៅទឹកសាបដោយសារមូលហេតុពូជសាសន៍ឡើយ។ ការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ត្រូវតែច្រានចោល។

*ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ - ឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការសម្លាប់ដោយចេតនា ចេតនាបង្កឱ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឱ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់សុខភាព និងការធ្វើទារុណកម្ម*

550. មិនមានភស្តុតាងដែលអាចទុកចិត្តបានគ្រប់គ្រាន់ទេថា ជនជាតិថៃ ឬជនជាតិវៀតណាម ត្រូវបានឃុំខ្លួន ឬសម្លាប់នៅទឹកសាប។ ការចោទប្រកាន់នេះ ត្រូវតែច្រានចោល។

*មនុស្សឃាតគិតទុកជាមុន*

551. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខទឹកសាប បង្កើតបានជាមនុស្សឃាតគិតទុកជាមុន ក្រោម មាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧.៣.៨ មន្ទីរសន្តិសុខវត្តឥន្ទញាណ

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*

552. ដោយផ្អែកលើចំនួនប៉ាន់ស្មានអប្បបរមាដែលមានមនុស្សស្លាប់ចំនួន ៤០០ នាក់ ការសន្និដ្ឋានដ៏សម ហេតុផលមួយគឺថា ការសម្លាប់នៅទីនោះបានកើតឡើងក្នុងចំនួនយ៉ាងច្រើន និងដោយមានចេតនា។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់បំផុតពូជត្រូវបានបង្កើត។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត*

553. អង្គហេតុដូចគ្នាគាំទ្រដល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើមនុស្សឃាត។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ*

554. ភស្តុតាងទាក់ទងនឹងការចោទប្រកាន់នេះ មានលក្ខណៈធូរស្រាលពេកមិនអាចគាំទ្រដល់ដីកាចោទ ប្រកាន់ដែលមានភាពច្បាស់លាស់ជាចាំបាច់ឡើយ។ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

555. ភស្តុតាងទាក់ទងនឹងការចោទប្រកាន់នេះ ទោះបីជាមានលក្ខណៈប្រយោលក៏ដោយ ក៏អនុញ្ញាតឱ្យ មានការសន្និដ្ឋានថា មនុស្សដែលគេមិនអាចដឹងចំនួនច្បាស់លាស់ត្រូវបានឃុំខ្លួននៅវត្តឥន្ទញាណ ក្នុងរយៈពេលប្រហែលយ៉ាងហោចណាស់បីថ្ងៃ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

556. ភស្តុតាងទាក់ទងនឹងការចោទប្រកាន់នេះ មានលក្ខណៈធូរស្រាលពេកមិនអាចគាំទ្រដល់ដីកាចោទ ប្រកាន់ដែលមានភាពច្បាស់លាស់ជាចាំបាច់ឡើយ។ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួន)*

557. ភស្តុតាងនេះក៏អនុញ្ញាតឲ្យមានការសន្និដ្ឋានថា អ្នកដែលត្រូវបានឃុំខ្លួននៅវត្តឥន្ទញាណ ត្រូវបានឃុំឃាំងនៅក្នុងលក្ខខណ្ឌកខ្វក់ ដែលធ្វើឲ្យពួកគេបាត់បង់នូវសេចក្ដីថ្លៃថ្នូររបស់មនុស្ស។ លក្ខខណ្ឌដូចគ្នានេះដែរ ត្រូវបានអនុវត្តចំពោះការចោលសាកសពរបស់ពួកគេ តាមរបៀបដែលមានគោលបំណងដើម្បីធានាថា គ្មាននរណាម្នាក់នៅក្នុងរង្វង់គ្រួសាររបស់ពួកគេ ឬសូម្បីតែមិត្តភក្តិរបស់ពួកគេ គួរតែបានដឹងពីអ្វីដែលបានកើតឡើងចំពោះពួកគេ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សដោយសារលក្ខខណ្ឌនៃការឃុំខ្លួនត្រូវបានបំពេញ។

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយតាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត*

558. ភស្តុតាងនេះមិនអនុញ្ញាតឲ្យមានការសន្និដ្ឋានណាមួយចំពោះប្រភេទអ្នកជាប់ឃុំនៅវត្តឥន្ទញាណទេ ដូច្នេះ គេមិនអាចញែកឲ្យដាច់ពីគ្នានូវចេតនាណាមួយចំពោះការធ្វើទុក្ខបុកម្នេញដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ឡើយ។ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ-ការឃុំឃាំងប្រជាពលរដ្ឋស៊ីវិលដោយខុសច្បាប់ ការសម្លាប់ដោយចេតនា ចេតនាបង្កឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់សុខភាព និងការធ្វើទារុណកម្ម*

559. គ្មានភស្តុតាងដែលអាចទុកចិត្តបានគ្រប់គ្រាន់ដែលថា ទាំងជនជាតិថៃ ឬវៀតណាម ត្រូវបានឃុំឃាំង ឬសម្លាប់នៅវត្តឥន្ទញាណទេ។ ការចោទប្រកាន់នេះត្រូវតែច្រានចោល។

*ការធ្វើមនុស្សឃាតគិតទុកជាមុន*

560. ការសម្លាប់មនុស្សនៅវត្តឥន្ទញាណ គឺជាការធ្វើមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

៧ ៩.៣.អាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ)*

561. នៅទូទាំងកំពង់សោម ប្តីប្រពន្ធត្រូវបានបង្ខំឲ្យរៀបការដោយចេតនា ហើយក្នុងករណីជាច្រើន ពួកគេក្រោយមកត្រូវបានតម្រូវឲ្យរួមដំណេកដោយផ្ទុយនឹងឆន្ទៈរបស់ពួកគេ ពោលគឺ មនុស្សជាច្រើនត្រូវបានរំលោភសេពសន្ថវៈ។ ការធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សបាន បណ្តាលឲ្យមានរបួសរាងកាយ និងការរងទុក្ខវេទនាផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់លើភស្តុតាងនេះគឺថា អំពើនេះគឺជាចេតនា។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ត្រូវបានបង្កើតឡើង។

## ៨. សំអាងច្បាប់ស្តីពីទម្រង់នៃការទទួលខុសត្រូវ

### ៨.១ ឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ

៨) ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ១.១.JCE)

*សហឧក្រិដ្ឋរួម - គោលបំណងរួម និងសមាជិក*

562. ភស្តុតាងបញ្ជាក់ថា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ **មាស មុត**, សុន សេន, ស៊ូ ម៉េត, តា ម៉ុក និងកម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជាជាន់ខ្ពស់ដទៃទៀត មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ដូចខាងក្រោម ៖

ក. ការបង្កើតសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ

ខ. ការអប់រំ "សមាសភាពមិនល្អ" និង "ការសម្លាប់ខ្មាំង" ទាំងក្នុង និងក្រៅជួរយោធា

គ. ការកំណត់មុខសញ្ញាក្រុមជាក់លាក់ ជាពិសេស អ្នកទាំងឡាយណាដែលជាជនជាតិភាគតិច ឬជនជាតិវៀតណាម និងថៃ (ទាំងពិតប្រាកដ និងតាមការសន្មត) ព្រមទាំងអតីតបុគ្គលិកយោធា និងប្រជាជនស៊ីវិល

ឃ. ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំលើប្រជាជនស៊ីវិល និងយោធានៃកងទ័ពបដិវត្តន៍កម្ពុជា

563. គោលនយោបាយទាំងនេះត្រូវបានអនុវត្តដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិទាំងអស់ ដូចបានរៀបរាប់ក្នុងផ្នែកខាងលើ ដោយ **មាស មុត** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ដោយមានមនុស្សដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម ត្រូវបានប្រើប្រាស់ជាឧបករណ៍។

*ការចូលរួមរបស់ មាស មុត ក្នុងការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម និងចេតនារបស់គាត់ក្នុងការសម្រេចនូវគោលបំណងរួម*

564. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ **មាស មុត** គឺជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមនេះ ត្រង់ចំណុចដែលគាត់គឺជាមេបញ្ជាការកងពលធំលេខ ៣ ហើយក្រោយមកកងពលនេះបានក្លាយជាកងពល ១៦៤។

565. ក្នុងឋានៈជាមេបញ្ជាការនៃកងពលធំ ១៦៤ ដែលបញ្ចូលទៅក្នុងកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ (កងវរសេនាធំ ១៤០) ជាសមាជិកបម្រុងនៃគណៈកម្មាធិការអគ្គសេនាធិការ និងជាអនុប្រធានរបស់ សុន សេន, **មាស មុត** បានដឹងពីសកម្មភាពទាំងអស់របស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ។ ការដឹងឮនេះកើតឡើងតាមរយៈកិច្ចប្រជុំ និងប្រព័ន្ធនៃការធ្វើទំនាក់ទំនង និងការរាយការណ៍ដែលគាត់បានធ្វើឡើងជាមួយថ្នាក់លើ និងអ្នកក្រោមបង្គាប់របស់គាត់។ **មាស មុត** គឺជាបុគ្គលដ៏សំខាន់ដែលទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់មានអំណាច ហេតុដូច្នេះហើយគាត់បានដឹងយ៉ាងច្បាស់ថា ការអនុវត្តគោលនយោបាយរបស់ ប.ក.ក គឺត្រូវសម្រេចឲ្យបានតាម រយៈឧក្រិដ្ឋកម្មខាងលើ។ តាមរយៈការដឹងឮនោះ គាត់បានបន្តប្រើប្រាស់អំណាចរបស់គាត់ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគ្រប់ទិដ្ឋភាពនៃគោលនយោបាយទាំងនេះ។

566. **តាស មុត** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីការដ្ឋាន និងសហករណ៍ *ជាអាទិ៍* តាមរយៈការរៀបចំកិច្ចប្រជុំជាមួយអ្នកក្រោមបង្គាប់ និងណែនាំពួកគេអំពីរបៀបអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក ដឹកនាំ និងត្រួតពិនិត្យការដ្ឋាន ត្រួតពិនិត្យ និងពិនិត្យតាមដានសំណង់ និងផលិតកម្ម និងគ្រប់គ្រង និងកៀងគរកម្លាំងពលកម្ម និងធនធានសម្រាប់ប្រតិបត្តិការនៅតាមការដ្ឋាន និងសហករណ៍។

567. **តាស មុត** ក៏បានចូលរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់ ប.ក.ក ស្តីពី "សមាសភាពមិនល្អ" និង "ខ្មាំង" *ជាអាទិ៍* តាមរយៈការជាប់ពាក់ព័ន្ធផ្ទាល់ក្នុងការចាប់ខ្លួន និងការបញ្ជូនសមាជិកកងពលធំ ១៦៤ និង១១៧ ទៅមន្ទីរ ស-២១ និងធ្វើសេចក្តីប្រកាសជាបន្តបន្ទាប់ទាក់ទងនឹងការបោសសម្អាតកម្មាភិបាល តាមរយៈការចូលរួមគាំទ្រជាទៀងទាត់ដល់ការបោសសម្អាតកងពលធំ ៥០២ និង ៣១០ និងតាមរយៈការពិនិត្យតាមដានការអនុវត្តនៃការបោសសម្អាត។

568. **តាស មុត** ក៏បានចូលរួមចំណែកយ៉ាងសំខាន់ផងដែរក្នុងគោលនយោបាយរបស់ ប.ក.ក ដោយផ្តោតលើក្រុមជាក់លាក់ ដែលត្រូវបានចាត់ទុកថាជាការគំរាមកំហែងសក្តានុពល ឬមិនស្មោះត្រង់ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសកម្មាភិបាល ប.ក.ក ដែលត្រូវបានចោទប្រកាន់ពី " សកម្មភាពក្បត់" "ប្រជាជន ១៧ មេសា" ទាហានមកពីភូមិភាគបូព៌ា និងជនជាតិវៀតណាម និងថៃ *ជាអាទិ៍* តាមរយៈការប្រកាសក្រុមទាំងនេះថាជាជនក្បត់ និង/ឬជាខ្មាំង បញ្ជាឱ្យកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងសម្លាប់ពួកគេ និងតាមរយៈការគាំទ្រដល់ការបោសសម្អាតក្រុមជាក់លាក់ទាំងនេះនៅក្នុងតំបន់ដែលគាត់មានអំណាច និងជាពិសេសនៅពេលដែលមានការណែនាំឱ្យធ្វើដូច្នេះនៅខាងក្រៅតំបន់នោះ។

569. **តាស មុត** មានចេតនារើសអើងជាពិសេសក្នុងការកម្ទេចជនជាតិវៀតណាមតាមរយៈអំពើកាប់សម្លាប់សមាជិកក្រុមនេះ។ គាត់បានបញ្ជាអ្នកក្រោមបង្គាប់របស់គាត់នៅក្នុងកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ឱ្យចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាមទាំងអស់នៅក្នុងដែនទឹក និងដែនកោះនៅឆ្ងាយពីឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ ដោយគ្មានការលើកលែង ពីព្រោះពួកគេជាសត្រូវស្បថពូជរបស់ខ្មែរ ហើយដូច្នេះត្រូវតែកម្ទេចចោល។ **តាស មុត** ក៏បានចែករំលែកនូវចេតនារើសអើងទាក់ទិននឹងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិថៃផងដែរ។

570. ជាចុងក្រោយ **តាស មុត** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយបានធ្វើការផ្សព្វផ្សាយគោលនយោបាយស្តីពីអាពាហ៍

ពិពាហ៍ និងតម្រូវការបង្កើនចំនួនប្រជាជន តាមរយៈសុន្ទរកថារបស់គាត់នៅក្នុងកិច្ចប្រជុំ។ ការសន្និដ្ឋានសមហេតុផលតែមួយគត់ ដែលផ្អែកលើភស្តុតាងទាំងអស់ គឺថាគាត់ក៏បានប្រកាសអំពីបទបញ្ញត្តិ ដែលប្ដីប្រពន្ធ ត្រូវបានតម្រូវឲ្យរួមដំណេក ទោះបីពួកគេមិនព្រមព្រៀងគ្នាក៏ដោយ។

៨ ២.១.ការរៀបចំផែនការ

571. ឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិទាំងអស់ ដូចមានចែងនៅក្នុង *អង្គហេតុផ្លូវច្បាប់ស្ដីពីឧក្រិដ្ឋកម្ម* ដែលបានកើតឡើងនៅក្នុងតំបន់កំពង់សោម និងនៅក្នុងដែនទឹក និងដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រព្រឹត្តក្នុងការលើកតម្កើងគោលនយោបាយរបស់ ប.ក.ក ក្រោមការទទួលខុសត្រូវ និងអំណាចផ្ទាល់របស់ **មាស មុត** ក្នុងឋានៈជាមេបញ្ជាការកងពល ១៦៤ និងជាលេខាតំបន់ស្វយ័តកំពង់សោម។ ការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់ពីភស្តុតាងនេះគឺថា គាត់បានចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងរៀបចំវិធីនៃការអនុវត្តរបស់ពួកគេ ក្នុងឋានៈជាមេបញ្ជាការកំពូលនៅក្នុងតំបន់ប្រតិបត្តិការពិសេសនោះ។ ការពិតដែលថា **មាស មុត** មិនមានវត្តមានដោយផ្ទាល់នៅមន្ទីរ ស-២១ មិនបានធ្វើឲ្យគាត់រួចផុតពីការទទួលខុសត្រូវនេះទេ ពីព្រោះគាត់បានរៀបចំផែនការឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរ ស-២១ ពីកំពង់សោម។ ដោយសារតែភាពចាំបាច់នៃការចូលរួមដោយផ្ទាល់របស់គាត់ ភ័ស្តុភារនៃការដឹកជញ្ជូនមនុស្សទៅមន្ទីរ ស-២១ និងវត្តមានផ្ទាល់ខ្លួនរបស់គាត់នៅក្រចេះ គាត់ក៏ជាប់ពាក់ព័ន្ធផងដែរក្នុងការរៀបចំផែនការបោសសម្អាតកងពល ១១៧។

572. ទោះជាយ៉ាងនេះក្ដី គ្មានភស្តុតាងបញ្ជាក់ពីការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការបោសសម្អាត កងពលធំ ៥០២ និង ៣១០ ក្រៅតែពីការចូលរួមរបស់គាត់នៅក្នុងការបោសសម្អាតនៃសហឧក្រិដ្ឋកម្មរួមទេ។ ដូច្នេះ **មាស មុត** មិនទទួលខុសត្រូវចំពោះការរៀបចំផែនការឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលឧក្រិដ្ឋកម្មទាំងបីចុងក្រោយបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១) ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពាក់ព័ន្ធនឹងការបោសសម្អាតកងពល ៥០២ និង ៣១០ ឡើយ។

៨ ៣.១.ការបញ្ជា

573. យោងតាមហេតុផលដូចដែលបានរៀបរាប់ខាងលើនៅក្នុងផ្នែក ៨.១.២ **មាស មុត** ទទួលខុសត្រូវចំពោះការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិទាំងអស់ ដែលបានប្រព្រឹត្តក្រោមអំណាចរបស់គាត់ ក្នុងឋានៈជាមេបញ្ជាការកងពលធំ ១៦៤ និងជាលេខាតំបន់ស្វយ័តកំពង់សោមនៅក្នុងតំបន់កំពង់សោម និងនៅក្នុងដែនទឹក និងដែនកោះ ដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ។ ដោយសារគាត់ក៏មានអំណាចដែលត្រូវបានប្រគល់ឲ្យជាពិសេស ដើម្បីធ្វើការបោសសម្អាតកងពលធំ ១១៧ ដែលមានមូលដ្ឋាននៅខេត្តក្រចេះ សកម្មភាពរបស់គាត់នៅទីនោះ ក៏ត្រូវបានកំណត់ថាជាការបញ្ជាផងដែរ។ ក៏ប៉ុន្តែ **មាស មុត** មិនទទួលខុសត្រូវក្នុងការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខ ស-២១ ពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំ ៥០២ និង ៣១០ ទេ។

៨ ៤.១.ការទទួលខុសត្រូវរបស់ថ្នាក់លើ

574. ម្យ៉ាងវិញទៀត ជាជម្រើសចុងក្រោយ **មាស មុត** ទទួលខុសត្រូវ ក្នុងឋានៈជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិទាំងអស់ ដែលបានប្រព្រឹត្តក្រោមអំណាចរបស់គាត់ក្នុងនាមជាមេបញ្ជាការកងពល ១៦៤ និងជាលេខាធិការតំបន់ស្វយ័តកំពង់សោមនៅក្នុងតំបន់កំពង់សោម និងនៅក្នុងដែនទឹក និងដែនកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ។ ដោយផ្អែកលើខ្សែសង្វាក់រាយការណ៍យ៉ាងតឹងរ៉ឹងនៅពេលនោះ គេមិនអាចគិតថា **មាស មុត** មិនបានដឹងពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់ដែលគាត់ទទួលខុសត្រូវនោះទេ។ ដោយសារគាត់បានរៀបចំផែនការ និងបញ្ជាពួកគេ **មាស មុត** ប្រាកដជាគ្មានចេតនាទប់ស្កាត់មិនឲ្យមានការប្រព្រឹត្តរាល់ឧក្រិដ្ឋកម្ម ដែលបានលើកឡើងខាងលើនោះឡើយ។ ក្នុងករណីណាក៏ដោយ គ្មានភស្តុតាងបង្ហាញថាគាត់បានធ្វើការទប់ស្កាត់ឡើយ។

575. ទោះជាយ៉ាងនេះក្តី គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីសន្មតថាមានកាលៈទេសៈដែលគាំទ្រដល់ការទទួលខុសត្រូវរបស់គាត់ ក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះការបោសសម្អាតកងពលធំ ១១៧ ទេ។ ទោះបីជាគាត់ត្រូវបានណែនាំឲ្យធ្វើប្រតិបត្តិការបោសសម្អាត ដែលក្នុងខណៈពេលនោះគាត់បានជំនួសមេដឹកនាំកងពល ១១៧ ក៏ដោយ ក៏ភស្តុតាងនេះមិនអនុញ្ញាតឲ្យមានការសន្និដ្ឋានថា **មាស មុត** ខ្លួនគាត់ផ្ទាល់ ជាមេបញ្ជាការរបស់កងពលធំនេះឡើយ ហើយម្យ៉ាងវិញទៀត គាត់បានគ្រប់គ្រងក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ដូច្នេះ **មាស មុត** មិនទទួលខុសត្រូវ ក្នុងឋានៈជាថ្នាក់លើ

ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងការបោសសម្អាតកងពល ១១៧ ឡើយ។

## ៨.២ ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ

### ៨.២.១ សហចារី

576. **មាស មុត** ទទួលខុសត្រូវក្នុងនាមជាសហចារីចំពោះឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតគិតទុកជាមុន ទាក់ទងនឹងការសម្លាប់ដែលបានប្រព្រឹត្តដោយកងទ័ពជើងទឹក ក្នុងការសម្លាប់ជនជាតិវៀតណាម និងជនជាតិថៃ ការសម្លាប់នានា ដែលបានប្រព្រឹត្តពាក់ព័ន្ធនឹងការបោសសម្អាតនៃកងពល ធំ ១៦៤, ៥០២, ៣១០ និង ១១៧ និងក្នុងការពាក់ព័ន្ធនឹងការសម្លាប់នានា ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សចម្ការទុរេន ការដ្ឋានស្ទឹងហាវ មន្ទីរសន្តិសុខទឹកសាប និងមន្ទីរសន្តិសុខវត្តឥន្ទញាណ។ **មាស មុត** រួមជាមួយអ្នកផ្សេងទៀត បានចូលរួមដោយផ្ទាល់ និងដោយចេតនា ក្នុងការប្រព្រឹត្តការធ្វើមនុស្សឃាតគិតទុកជាមុន ក្នុងករណីនៃការសម្លាប់ដោយចេតនា ដូចបានរៀបរាប់នៅតាមទីតាំងទាំងនោះ។

### ៨.២.២ ការរៀបចំផែនការ និងការបញ្ជា

577. យោងតាមហេតុផលដូចបានលើកឡើងនៅក្នុងផ្នែក ៨.១.២ និង ៨.១.៣ **មាស មុត** ក៏ទទួលខុសត្រូវផងដែរចំពោះការរៀបចំផែនការ និងបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតគិតទុកជាមុន ដូចបានលើកឡើងក្នុងកថាខណ្ឌខាងដើម លើកលែងតែការបោសសម្អាតកងពលធំ ៥០២ និង ៣១០៖ ដូច្នេះ **មាស មុត** មិនទទួលខុសត្រូវចំពោះការរៀបចំផែនការឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតគិតទុកជាមុន ទាក់ទងនឹងការបោសសម្អាតកងពលធំ ៥០២ និង៣១០ ឡើយ។

## *៩. សេចក្តីសម្រេចលើការឃុំខ្លួន មុនការជំនុំជម្រះ*

578. ទោះបីយើង Michael Bohlander បានសន្និដ្ឋានថា មានបទចោទគ្រប់គ្រាន់ដើម្បីនាំខ្លួន **មាស មុត** ទៅជំនុំជម្រះក្តី តែយើង Michael Bohlander យល់ឃើញថា ការឃុំខ្លួនគាត់រង់ចាំការជំនុំជម្រះពុំមែនជាការចាំបាច់ ដើម្បីបញ្ចៀសនូវកត្តាហានិភ័យនានាអនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ គាត់បានដឹងជាច្រើនឆ្នាំមកហើយថា គាត់ស្ថិតក្រោមការស៊ើបអង្កេត និងបានចូលរួមជាមួយ ស.ច.ស ក្នុងអំឡុងនៃកិច្ចស៊ើបសួរទាំងមូល។ ពុំមានសញ្ញាណបង្ហាញថា គាត់អាច

គេចខ្លួនចេញពីយុត្តាធិការ ដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ ឬជ្រៀតជ្រែកទៅក្នុងដំណើរការតុលាការតាមវិធីណាមួយឡើយ។ ពុំមានការព្រួយបារម្ភអំពីសន្តិសុខរបស់គាត់ ឬការថែរក្សាសណ្តាប់ធ្នាប់ដែលតម្រូវឱ្យចេញដីកាបង្គាប់ឱ្យឃុំខ្លួនគាត់ទេ។

579. សំអាងហេតុមួយទៀតដែលជំទាស់ទៅនឹងការបង្គាប់ឱ្យឃុំខ្លួននៅពេលនេះ គឺភាពមិនច្បាស់លាស់ផ្នែកនីតិវិធី ដោយសារមានដីកាដំណោះស្រាយផ្ទុយគ្នា ហេតុនេះវាពុំមានភាពច្បាស់លាស់អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ថាតើដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងនៅតែដំណើរការទៅមុខ ឬយ៉ាងណា ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រលើសលប់ដើម្បីសម្រេចទៅបណ្តឹងឧទ្ធរណ៍ទេនោះ។

## ១០. ដីកាបញ្ចប់អនុលោមតាមវិធាន ៦៦*ស្ទួន*

580. **យើង Michael Bohlander សម្រេចបញ្ចប់**កិច្ចស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុនានា ដែលមិនបានបញ្ចូលនៅក្នុងសេចក្តីសម្រេច អនុលោមតាមវិធាន ៦៦*ស្ទួន* ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ១២។

## ១១. ដីកាលើកលែងការចោទប្រកាន់ដោយផ្នែក

581. បទចោទនានាដូចខាងក្រោមត្រូវបាន**លើកលែងពីការប្រកាន់៖**

### ១. ការសម្លាប់ជនជាតិវៀតណាមដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

### ២. ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

### ៣. ទីតាំងសម្លាប់មនុស្សចម្ការទុរេន

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

**៤. ការដ្ឋានកងកេង និងការដ្ឋានបិតត្រាំង (តំបន់រាម)**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍ តាមរយៈការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត*

**៥. មន្ទីរសន្តិសុខទឹកសាប**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត*

- *អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម*

**៦. មន្ទីរសន្តិសុខវត្តឥន្ទញាណ**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត*

- *អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម*

**១២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

**មាស មុត**

កើតថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៣៨

នៅភូមិពោធិ៍ ឃុំស្រែក្នុង

ស្រុកកំពង់ឈូក ខេត្តកំពត

អាសយដ្ឋានបច្ចុប្បន្ន៖

[redacted]

**ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ**

**ចំពោះឧក្រិដ្ឋកម្មនានាដូចខាងក្រោម÷**

**បទចោទទី១÷**

**អំពើប្រល័យពូជសាសន៍**

ទៅលើជនជាតិវៀតណាម ដោយសារការសម្លាប់សមាជិកក្រុម

តាមរយៈការប្រព្រឹត្តិសហឧក្រិដ្ឋកម្មរួម ("JCE") ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥ និង ២១៧-២៥៧

ដែលអាចផ្តន្ទាទោសតាមមាត្រា ៤ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

## បទចោទទី២÷

## ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ១. ការសម្លាប់ជនជាតិវៀតណាម ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃក្រោមទម្រង់ជាការធ្វើទារុណកម្ម*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ជាជម្រើសម្យ៉ាងទៀត តាមរយៈការរៀបចំផែនការ ឬការចេញបញ្ជា និងជាជម្រើសបន្ថែមទៀត តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥ និង ២១៧-២៥៧

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**២. ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ**

<u>នៅក្នុងដែនទឹក និងនៅលើកោះនានាដែលកម្ពុជាប្រជាធិបតេយ្យបានអះអាង និងនៅតំបន់កំពង់សោម</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ជាជម្រើសម្យ៉ាងទៀត តាមរយៈការរៀបចំផែនការ ឬការចេញបញ្ជា និងជាជម្រើសបន្ថែមទៀត តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៥៩-២០៥ និង ២១៧-២៥៧

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**៣. ទីតាំងសម្លាប់មនុស្សចម្ការទុរេន**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការបាត់ខ្លួនដោយបង្ខំ)*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងទៀត*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៩៩-២០៥ និង ២៥៨-២៦៩

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**៤.ការបោសសម្អាតកងពលធំ ១៦៤, ៥០២ ៣១០ និង ១១៧**

<u>នៅទីតាំងផ្សេងទៀតក្រៅពីមន្ទីរសន្តិសុខ ស-២១</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត*

<u>នៅមន្ទីរសន្តិសុខ ស-២១</u>

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្ម*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត*

ត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹង៖

- កងពលធំ ១៦៤ តាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

- កងពលធំ ៥០២ និងកងពលធំ ៣១០ តាមរយៈសហឧក្រិដ្ឋកម្មរួម និង

- កងពលធំ ១១៧ តាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥ និង ២៧០-៣២៩

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**៥. ការដ្ឋានកងកេង និងការដ្ឋានបិតត្រាំង (តំបន់រាម)**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង និងការងារដោយបង្ខំ)*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ*
  *តាមរយៈការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥ និង ៣៣០-៣៥៤

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

### ៦. ការដ្ឋានស្ទឹងហាវ

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការងារដោយបង្ខំ)*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈអំពើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥ និង ៣៥៥-៤០២

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

## ៨. មន្ទីរសន្តិសុខទឹកសាប

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង និងការងារដោយបង្ខំ)*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ តាមរយៈការសម្លាប់រង្គាល អំពើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៩៩-២០៥ និង ៤០៣-៤២៥

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

## ៩. មន្ទីរសន្តិសុខវត្តឥន្ទញាណ

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត*
- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង*

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សដោយសារស្ថានភាពនៃការឃុំឃាំង)*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៩៩-២០៥ និង ៤២៦-៤៤៣

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**៩. អាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម**

- *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ)*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៩៩-២០៥ និង ៤៤៤-៤៥៥

ដែលអាចផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**បទចោទទី៣÷**

**ឧក្រិដ្ឋកម្មសង្គ្រាម**

**១. ការសម្លាប់ជនជាតិវៀតណាមដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ**

- *អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព និង ការធ្វើទារុណកម្មបន្ថែមនៅមន្ទីរសន្តិសុខ ស-២១*

## ២. ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

- *អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ - ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា និងការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព*

បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការរៀបចំផែនការឬការចេញបញ្ជា ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២៥៧

ដែលអាចផ្តន្ទាទោសតាមមាត្រា ៦ មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក។

**បទចោទទី៤÷**

**ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦**

**អំពើមនុស្សឃាតដោយចេតនាគិតទុកជាមុន៖**

- ការសម្លាប់ជនជាតិវៀតណាមដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ
- ការសម្លាប់ជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ
- ទីតាំងសម្លាប់មនុស្សចម្ការទុរេន
- មន្ទីរសន្តិសុខ ស-២១
- ការបោសសម្អាតនៅក្នុងកងពលធំ ១៦៤ កងពលធំ ៥០២ កងពលធំ ៣១០ និង កងពលធំ ១១៧
- ការដ្ឋានស្ទឹងហាវ
- មន្ទីរសន្តិសុខទឹកសាប
- មន្ទីរសន្តិសុខវត្តឥន្ទញាណ

តាមរយៈការប្រព្រឹត្ត (ការប្រព្រឹត្តិរួមគ្នា) និង (លើកលែងតែឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងកងពលធំ ៥០២ និងកងពលធំ ៣១០) ឬការរៀបចំផែនការ ឬការចេញបញ្ជា

ផ្អែកលើអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤៩-២០៥, ២១៧-៣២៩, និង ៣៥៥-៤៤៣

ដែលអាចផ្ដន្ទាទោសតាមមាត្រា ៣(ថ្មី) មាត្រា ២៩ និងមាត្រា ៣៩ នៃច្បាប់ អ.វ.ត.ក និងមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

## ១៣. ការបញ្ចប់ការស៊ើបអង្កេតដែលនៅសេសសល់

ក្រៅពីការស៊ើបអង្កេតដែលបានលើកឡើងនៅក្នុងចំណុច ១០-១២ ខាងលើ ការស៊ើបអង្កេតដែលនៅសេសសល់ក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ចប់។

ដីកាដំណោះស្រាយនេះចេញជាភាសាអង់គ្លេស ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងចេញតាមក្រោយ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**